ការបោះពុម្ពផ្សាយរបស់ កម្មវិធីអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាព នូវជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ

# ការវិភាគស្ថានភាព

## ខេត្តស្ទឹងត្រែង ប្រទេសកម្ពុជា



ដោយលោក ធួន ទ្រី និង ម៉ាគីស ឆេមប៊ើរ (Marcus Chambers)

កម្មវិធី ដែលចូលរួមផ្តល់ថវិកាដោយ UNDP-IUCN-MRC GEF

UNDP

IUCN The World Conservation Union

MEKONG RIVER COMMISSION MRC FOR SUSTAINABLE DEVELOPMENT

ការកំណត់ អត្តសញ្ញាណភូមិសាស្ត្រនៅក្នុងសៀវភៅនេះ និងការបង្ហាញនូវឯកសារផ្សេងៗ គឺមិនបានបញ្ជាក់នូវទស្សនៈរបស់បុគ្គលណាមួយ ដែលជាផ្នែករបស់កម្មវិធីអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាព នូវជីវចម្រុះតំបន់ដីសើមទន្លេមេគង្គ (ឬអង្គការដែលបានចូលរួមផ្សេងៗ ដូចជា រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតឡាវ ថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយមវៀតណាម កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) អង្គការសហភាពអភិរក្សពិភពលោក (IUCN) គណៈកម្មការទន្លេមេគង្គ (MRC) ទាក់ទងនឹងស្ថានភាពច្បាប់របស់ប្រទេស ទឹកដី ឬតំបន់ណាមួយ ឬអជ្ញាធររបស់ប្រទេស ឬទាក់ទងនឹងការកំណត់ព្រំព្រទល់ ឬដែនដី របស់ប្រទេសណាមួយ។

ទស្សនៈដែលបានបង្ហាញនៅក្នុងការបោះពុម្ពផ្សាយនេះ គឺពុំមានសារៈសំខាន់ក្នុងការឆ្លុះបញ្ចាំងនូវទស្សនៈរបស់កម្មវិធីអភិរក្ស និងប្រើ ប្រាស់ដោយនិរនត្តរភាព នូវជីវៈចម្រុះតំបន់ដីសើម (ឬអង្គការចូលរួមផ្សេងៗទៀត ដូចជាប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ សហភាពអភិរក្សពិភពលោក និងគណៈកម្មការទន្លេមេគង្គ។

បោះពុម្ពដោយ : កម្មវិធីអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាព នូវជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ (MWBP)

រក្សាសិទ្ធិ : © ២០០៦ កម្មវិធីអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាព នូវជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ (MWBP) តាងនាមឱ្យកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ។

ការផលិតឡើងវិញ នៃឯកសារនេះសំរាប់គោលបំណងអប់រំ និងមិនធ្វើពាណិជ្ជកម្ម គឺត្រូវបានអនុញ្ញាតដោយពុំចាំបាច់សរសេរសុំការអនុញ្ញាតិជាមុនពីម្ចាស់កម្មសិទ្ធ ប្រសិនបើប្រភពត្រូវបានទទួលស្គាល់ពេញលេញ។

ការផលិតឡើងវិញ នៃឯកសារក្នុងគោលបំណងដើម្បីលក់ ឬធ្វើអាជីវកម្ម ត្រូវបានហាមឃាត់ដោយពុំមានការអនុញ្ញាតិពីម្ចាស់កម្មសិទ្ធិ។

មាតិកានៅក្នុងឯកសារនេះ មានលក្ខណៈត្រឹមត្រូវ ស្របពេលដែលកំពុងសរសេរនៅខែមេសា ឆ្នាំ ២០០៥

ការដកស្រង់ប្រភព : Try.T. and Chambers. M. (2006). *Situation Analysis: Stung Treng Province, Cambodia*. Mekong Wetlands Biodiversity Conservation and Sustainable Programme, Vientiane, Lao PDR. 93 pp.

ISBN:

| | |
|---|---|
| វចនាក្រមដោយ : | Studio Terra Co., Ltd. |
| រូបភាពក្របដោយ: | កម្មវិធីអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាព នូវជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ |
| រៀបចំរចនាដោយ : | Studio Terra Co., Ltd |
| ផលិតដោយ : | កម្មវិធីអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាព នូវជីវៈចម្រុះតំបន់ដីសើម |
| បោះពុម្ពផ្សាយដោយ : | Ink On Paper Co., Ltd. |

ឯកសារនេះមាននៅ : កម្មវិធីអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាព នូវជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ
Program Management Unit
082/02 Fa Ngum Roads, Vientiane, Lao PDR
Tel: +856 (0) 21 240 904, Fax: +856(0) 21 216 127
Email: info@mekongwetlands.org
Web: www.mekongwetlands.org

# ការវិភាគស្ថានភាព នៅខេត្តស្ទឹងត្រែង ប្រទេសកម្ពុជា

ដោយធូនទ្រី និង ម៉ាគីសឆេមប៊ឺរ

បកប្រែដោយ : លោក ធូន ទ្រី

កែសម្រួលដោយ: លោក ពេជ្រ ដារ៉ុង និង សួស ស៊ីវុត្ថា

# តារាងមាតិកា


បញ្ជីតារាង ........ iv

បញ្ជីផែនទី ........ iv

ពាក្យជាអក្សរកាត់ និងបំព្រួញ ........ v

ពាក្យតាមមូលដ្ឋាន និងសទ្ទានុក្រម ........ vii

ឯកតា នៃរង្វាស់រង្វាល់ ........ viii

**ជំពូក ១ : ស្ថានភាពទូទៅ** ........ ១

សេចក្តីផ្តើមចំពោះតំបន់ដីសើម និងវិធីសាស្រ្ត ........ ១

តំបន់រ៉ាមសារខេត្តស្ទឹងត្រែង ........ ៤

បញ្ហាសំខាន់ៗ : និន្នាការអភិវឌ្ឍន៍ និងបរិស្ថាន ........ ៦

សង្ខេប ........ ៩

**ជំពូក២ : ប្រវត្តិសាស្រ្ត** ........ ១១

ប្រវត្តិដើម ........ ១១

និន្នាការនយោបាយ : ការកកើត នៃរដ្ឋទំនើប ........ ១៤

សង្ខេប ........ ១៧

**ជំពូក៣ : ប្រជាជន និង ជីវភាពរស់នៅ** ........ ១៩

ចំនួនប្រជាជន និងការធ្វើបំលាស់ទី ........ ១៩

បញ្ហាសុខភាព ........ ២១

ជនជាតិនៅខេត្តស្ទឹងត្រែង ........ ២៣

ការតាំងលំនៅរបស់ប្រជាជន ........ ២៥

សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធ ........ ២៥

យុទ្ធសាស្រ្តចិញ្ចឹមជីវិត ........ ២៦

បច្ចេកទេសនេសាទ ការគ្រប់គ្រង និងកម្មសិទ្ធិ ........ ៣៣

ឥទ្ធិពលរបស់ទីផ្សារ និងរដ្ឋ ........ ៣៥

លក្ខណៈ បុព្វហេតុ និងកត្តា នៃភាពក្រីក្រ និងភាពងាយរងគ្រោះ ........ ៣៧

យុទ្ធសាស្រ្តអនុវត្ត ដើម្បីកាត់បន្ថយភាពងាយរងគ្រោះ........ ៤១

សង្ខេប ........ ៤១

**ជំពូក៤ : បរិស្ថាន និងជីវៈចម្រុះ** ..... ៤៣
សេចក្តីផ្តើម ..... ៤៣
អាកាសធាតុ ..... ៤៣
ធារទឹក ..... ៤៤
ការផ្លាស់ប្តូរអាកាសធាតុ ..... ៤៩
ភូគព្ភសាស្រ្ត និងធនធានរ៉ែ ..... ៥១
ប្រភេទធនធានដី ..... ៥១
ប្រភេទរុក្ខជាតិ ..... ៥៤
ថនិកសត្វ ..... ៥៦
ពពួកបក្សី ..... ៥៩
ឧរង្គសត្វ និងមណ្ឌុកសត្វ ..... ៦១
បច្ចាជាតិ ..... ៦២
ប្រភេទសត្វគ្មានឆ្អឹងកង ..... ៦៧
សង្ខេប ..... ៦៧

**ជំពូក៥ : និន្នាការអភិវឌ្ឍន៍** ..... ៧០
សេចក្តីផ្តើម ..... ៧០
យុទ្ធសាស្រ្តអភិវឌ្ឍន៍សំខាន់ៗ ..... ៧០
ផលប្រយោជន៍ ជាអាទិភាពរបស់ប្រទេសកម្ពុជា ..... ៧២
គោលនយោបាយរដ្ឋ សំរាប់កំណើនសេដ្ឋកិច្ច ..... ៧៥
សកម្មភាពអភិវឌ្ឍន៍របស់សង្គមស៊ីវិល ..... ៧៨
គោលនយោបាយតំបន់ដីសើម និងធនធានទឹក ..... ៨១
អនុសញ្ញាអន្តរជាតិនានា ..... ៨៣
សង្ខេប ..... ៨៤

**ជំពូក ៦ : នយោបាយ និងស្ថាប័ន** ..... ៨៥
សេចក្តីផ្តើម ..... ៨៥
អភិបាលកិច្ច និងវិមជ្ឈការ ..... ៨៥
តួនាទី និងសមត្ថភាព នៃប្រព័ន្ធរដ្ឋបាល និងស្ថាប័នរបស់រដ្ឋ ..... ៨៦
ការចូលរួមពីសាធារណៈ ..... ៨៨

អ្នកពាក់ព័ន្ធសំខាន់ៗ ........ ៨៩
សង្ខេប ........ ៩២

**ជំពូក ៧ : ការវិភាគ** ........ ៩៣
សេចក្តីផ្តើម ........ ៩៣
ភាពងាយរងគ្រោះ ........ ៩៣
ហានិភ័យ និងការគំរាមកំហែង ........ ៩៥
ឱកាសផ្សេងៗ ........ ៩៧
ភាពចន្លោះប្រហោង នៃការស្រាវជ្រាវ ........ ៩៨
អន្តរាគមន៍របស់កម្មវិធី អភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាព នូវជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ ........ ៩៩
ការគ្រប់គ្រង របស់តំបន់រ៉ាមសារ ........ ១០២

**ឯកសារយោង** ........ ១០៣

## បញ្ជីតារាង


តារាង ៣.១ របាយប្រជាជននៅតាមស្រុកនីមួយៗ នៃខេត្តស្ទឹងត្រែង ........ ១៩
តារាង ៣.២ ចំនួន ឃុំ ភូមិ ប្រជាជន និងអន្តរជន នៅក្នុងតំបន់រ៉ាមសារ ........ ២០
តារាង ៣.៣ ការកើតឡើង នៃជំងឺ ស៊ីស្តូសូមីញ៉ាស៊ីស នៅតំបន់រ៉ាមសារ តាំងពីឆ្នាំ ១៩៩៧-២០០៤ ........ ២២
តារាង ៣.៤ ប្រភពប្រាក់ចំណូលតាមរយៈសកម្មភាព សំរាប់ភូមិផ្សេងៗនៅស្រុកសៀមបូក ........ ២៦
តារាង ៣.៥ ភាពខុសគ្នាផ្នែកសេដ្ឋកិច្ចសង្គម របស់គ្រួសារនៅភូមិកោះស្នែង ........ ២៨
តារាង ៣.៦ ការប្រើប្រាស់ដីធ្លី របស់ឃុំទាំង៤នៅតំបន់រ៉ាមសារ ........ ៣០
តារាង ៣.៧ សង្ខេប នៃការបំលាស់ទីរបស់មច្ឆានៅខេត្តស្ទឹងត្រែង ........ ៣២
តារាង ៣.៨ បុព្វហេតុ នៃភាពក្រីក្រនៅភូមិចំនួន៣ ........ ៣៩
តារាង ៣.៩ ការខូចខាត ដោយទឹកជំនន់នៅខេត្តស្ទឹងត្រែង ចាប់ពីឆ្នាំ២០០០-២០០២ ........ ៤០
តារាង ៤.១ កំពស់ទឹកភ្លៀងជាមធ្យមប្រចាំខែនៅខេត្តស្ទឹងត្រែង ពីឆ្នាំ ១៩៩៤-២០០០ ........ ៤៤
តារាង ៤.២ សង្ខេបទិន្នន័យអាកាសធាតុ ពីទីរួមខេត្តស្ទឹងត្រែង ឆ្នាំ២០០៣-២០០៤ ........ ៤៤
តារាង ៤.៣ កម្រិតទឹកប្រចាំខែជាមធ្យម (ម៉ែត្រ) របស់ទន្លេមេគង្គនៅទីរួមខេត្តស្ទឹងត្រែង ឆ្នាំ ១៩៩៩-២០០៤ ........ ៤៧
តារាង ៤.៤ លំហូរ ជាមធ្យម អប្បរមា និងអតិបរមា របស់ទន្លេមេគង្គ នៅខេត្តស្ទឹងត្រែង ឆ្នាំ ១៩៦២-១៩៨៨ ........ ៤៨
តារាង ៤.៥ ទិន្នន័យគុណភាពទឹកប្រចាំខែ ដោយចាប់ពីចេត្តក្រចេះ (កម្ពុជា) ប៉ាកសេ (ប្រទេសឡាវ) និងកម្រិតមធ្យមរបស់ទន្លេនៅទ្វីបអាស៊ី ........ ៤៨
តារាង ៤.៦ ការកើតឡើង នៃថនិកសត្វ ដែលបានរាយការណ៍ឃើញនៅក្បែរ ឬនៅក្នុងតំបន់រ៉ាមសារ ........ ៥៧
តារាង ៤.៧ ការគំរាមកំហែងសំខាន់ចំពោះប្រភេទថនិកសត្វកម្ពុជា ដែលបានចុះបញ្ជីរអង្គការសហភាពអភិរក្សពិភព លោក ដែលមាន ឬធ្លាប់កើតមាននៅក្នុង ឬនៅក្បែរតំបន់រ៉ាមសារ ........ ៥៨
តារាង ៤.៨ ប្រភេទបក្សីកម្ពុជាសំខាន់ៗ ដែលរកឃើញនៅក្នុង ឬនៅក្បែរតំបន់រ៉ាមសារ ........ ៦០
តារាង ៤.៩ ប្រភេទឧរង្គសត្វ ដែលបានកើតឡើងនៅក្នុង ឬនៅក្បែរតំបន់រ៉ាមសារ ........ ៦២
តារាង ៤.១០ ប្រភេទមច្ឆាសំខាន់ៗ នៅតំបន់រ៉ាមសារ ........ ៦៥
តារាង ៤.១១ ឈ្មោះ អន្លង់ នៅតំបន់រ៉ាមសារ ........ ៦៦


## បញ្ជី ផែនទី


ផែនទី ១.១ ផែនទីរដ្ឋបាលខេត្តស្ទឹងត្រែង ........ ២
ផែនទី ១.២ ផែនទីតំបន់រ៉ាមសារ ក្នុងខេត្តស្ទឹងត្រែង ........ ៣
ផែនទី ៤.១ ផែនទីធារទឹក នៅខេត្តស្ទឹងត្រែង ........ ៤៦
ផែនទី ៤.២ ផែនទីភូគព្ភសាស្ត្រ នៅខេត្តស្ទឹងត្រែង ........ ៥២
ផែនទី ៤.៣ ផែនទីស្ថានភាពដី ខេត្តស្ទឹងត្រែង ........ ៥៣

## ពាក្យជាអក្សរកាត់ ឬពាក្យបំព្រួញ

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ASEAN | សមាគម នៃប្រជាជាតិអាស៊ីអាគ្នេយ៍ |
| BDP | ផែនការអភិវឌ្ឍន៍អាងទន្លេ |
| CAA | អង្គការផ្តល់ជំនួយសហគមន៍បរទេស (អុកស្វាម អូស្ត្រាលី) |
| CARERE | គំរោងស្តារ និងបង្កើតឡើងវិញតាមតំបន់កម្ពុជា |
| CBNRM | ការគ្រប់គ្រងធនធានធម្មជាតិ ដោយផ្អែកលើសហគមន៍ |
| CEPA | សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ |
| CFM | ការគ្រប់គ្រងសហគមន៍នេសាទ |
| CITES | អនុសញ្ញា ស្តីពីការហាមធ្វើពាណិជ្ជកម្មអន្តរជាតិទៅលើប្រភេទសត្វជិតផុតពូជ |
| CNMC | គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា |
| CPP | គណៈបក្សប្រជាជនកម្ពុជា |
| CPRs | ធនធានរួម |
| CRDC | គណៈកម្មការអភិវឌ្ឍន៍ជនបទឃុំ |
| CTIA | សមាគមឧស្សាហកម្ម ព្រៃឈើកម្ពុជា |
| DANIDA | ទីភ្នាក់ងារ អភិវឌ្ឍន៍អន្តរជាតិ ប្រទេសដាណឺម៉ាក |
| DoE | មន្ទីរបរិស្ថានខេត្ត |
| DoF | នាយកដ្ឋានជលផល |
| EIA | ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន |
| ESIA | ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម |
| FAO | អង្គការ កសិកម្ម និង ស្បៀងអាហារពិភពលោក |
| FUNCINPEC | គណៈបក្សហ្វ៊ុនស៊ិនប៉ិច |
| GAP | ផែនការសកម្មភាពអភិបាលកិច្ច |
| GEF | មូលនិធិបរិស្ថានពិភពលោក |
| GMS | មហាអនុតំបន់អាងទន្លេមេគង្គ |
| ICLARM | មជ្ឈមណ្ឌលអន្តរជាតិ សំរាប់គ្រប់គ្រងធនធានវារីជាតិ |
| IDRC | មជ្ឈមណ្ឌលស្រាវជ្រាវ អភិវឌ្ឍន៍អន្តរជាតិ |
| IOs | អង្គការអន្តរជាតិ |
| IUCN | សហភាពអភិរក្សពិភពលោក |
| Lao PDR | សាធារណរដ្ឋប្រជាមានិតឡាវ |
| LMB | អាងទន្លេមេគង្គក្រោម |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| | |
|---|---|
| MDCP | គំរោងអភិរក្សសត្វផ្សោតទន្លេមេគង្គ |
| MoE | ក្រសួងបរិស្ថាន |
| MOWRAM | ក្រសួងធនធានទឹក និងឧត្តុនិយម |
| MRC | គណៈកម្មការទន្លេមេគង្គ |
| DRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| MW | មេហ្គាវ៉ាត់ |
| MWBP | កម្មវិធីអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាព នូវជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ |
| NGOs | អង្គការមិនមែនរដ្ឋាភិបាល |
| NRM | ការគ្រប់គ្រងធនធានធម្មជាតិ |
| NTFP | អនុផលព្រៃឈើ |
| NVDP | កម្មវិធីអភិវឌ្ឍន៍ភូមិ ភូមិភាគឦសាន្ត |
| PDWRAM | មន្ទីរធនធានទឹក និងឧត្តុនិយម |
| PFD | អង្គការដៃគូ ដើម្បីអភិវឌ្ឍន៍ |
| PIPs | កម្មវិធីវិនិយោគសាធារណៈ |
| PLG | ដៃគូ សំរាប់អភិបាលកិច្ចមូលដ្ឋាន |
| PoE | មន្ទីរបរិស្ថានខេត្ត |
| PPA | ការវាយតំលៃភាពក្រីក្របែបចូលរួម |
| PRDC | គណៈកម្មាធិការ អភិវឌ្ឍន៍ជនបទខេត្ត |
| RGC | រាជរដ្ឋាភិបាល |
| SAWG | ក្រុមការងារអនុតំបន់ |
| SEDP I | ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរយៈពេល៥ឆ្នាំលើកទី១ |
| SEDP II | ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរយៈពេល៥ឆ្នាំលើកទី២ |
| SRP | គណៈបក្សសមរង្ស៊ី |
| *sp* | ប្រភេទ |
| *spp* | ប្រភេទផ្សេងៗ |
| UN | អង្គការសហប្រជាជាតិ |
| UNDP | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ |
| UNICEF | មូលនិធិកុមារ របស់អង្គការសហប្រជាជាតិ |
| UNTAC | អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិ ប្រចាំកម្ពុជា |
| USAID | ទីភ្នាក់ងារផ្តល់ជំនួយសហរដ្ឋអាមេរិក សំរាប់អភិវឌ្ឍន៍អន្តរជាតិ |
| VDC | គណៈកម្មការអភិវឌ្ឍន៍ភូមិ |

| | |
|---|---|
| VFC | គណៈកម្មការសហគមន៍នេសាទភូមិ |
| YWAM | អង្គការ យុវជនបំពេញបេសកកម្ម |
| WB | ធនាគារពិភពលោក |
| WCS | អង្គការសមាគមអភិរក្សសត្វព្រៃ |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក |
| WWF | អង្គការផ្តល់ជំនួយពិភពលោក ដើម្បីធម្មជាតិ |

## ពាក្យតាមមូលដ្ឋាន និងសទ្ទានុក្រម

| ពាក្យតាមមូលដ្ឋាន | ពាក្យជាភាសាអង់គ្លេស ឬ វិទ្យាសាស្ត្រ |
|---|---|
| អន្លង់ | Deep pool |
| បឹង | Lake |
| កម្ពុជាប្រជាធិបតេយ្យ | Democratic Kampuchea |
| ចំការ | Farming |
| ឧបករណ៍នេសាទ ចាន់ | A droop-door trap |
| ឧបករណ៍នេសាទ ចូន | A V-shape net |
| ឆ្លុះត្រី | Torch fishing |
| រង្វាស់ទំងន់ ហាប | Unit of weight ( 1 harb = 60kg) |
| ខេត្ត | Province |
| ខ្មែរអ៊ិស្លាម | Chams |
| ខ្មែរលើ | Hill tribes |
| ឃុំ | Commune |
| កោះ | Island |
| គោព្រៃ | Wild ox |
| ក្រុម | Group |
| ឧបករណ៍នេសាទ លប | Cylindrical drum trap |
| មង | Gill nets |
| អ្នកស្រុកក្រោម | Lowland people |
| អ្នកស្រុកលើ | Upland people |
| អ្នកតស៊ូ | The fighters |
| អូរ | Stream |
| ឧបករណ៍នេសាទ អួន | Seine net |
| ភូមិ | Village |

| | |
|---|---|
| ឧបករណ៍នេសាទ សំណាញ់ | Cast net |
| ឧបករណ៍នេសាទ សន្ទូច | Hook and Line |
| សាធារណរដ្ឋខ្មែរ | Khmer republic |
| ស្រុក | District |
| រៀល | Cambodian currency |
| ឧបករណ៍នេសាទ ឈើប | Cylindrical current trap or funnel trap |
| ថ្មកំបោរ | Marble |
| ឧបករណ៍នេសាទ ថ្នង | Scoop-net |
| ឧបករណ៍នេសាទ តុម | Vertical vase trap |
| ត្រី | Fish |
| ត្រីកែស | Glass catfish |
| ត្រី គុលរាំង | Giant barb or *catlocarpio siamensis* |
| ត្រី ក្រាញ់ | Anabantidae |
| ត្រី ប៉ាស៊ីអ៊ី | Mekongina erythrospila |
| ត្រី ប្រា | Pangasid catfish |
| ត្រី រាជ | Giant catfish |
| ត្រី រៀល | Henicorhynchus caudinaculatus |
| ត្រី ត្រសក់ | Seven-line barb |
| ឧបករណ៍នេសាទ ទ្រូ | Oblong trap |

## ឯកតា នៃរង្វាស់រង្វាល់

### ប្រវែង (ម៉ែត្រ និងគីឡូម៉ែត្រ)

១ ម៉ែត្រ (ម)= ១00 សង់ទីម៉ែត្រ (សម)

១ គីឡូម៉ែត្រ (គម) = ១000 ម៉ែត្រ

### ទំហំ ( ហិកតា និងម៉ែត្រការ៉េ-ម$^{២}$ )

១ ហិកតា (ហត) =១0.000 ម$^{២}$

**ទំងន់ (គីឡូក្រាម)**

១ គីឡូក្រាម (គក្រ) = ២,២០៥ផោន (lb)

១ ហាប = ៦០ គ.ក្រ

១ តោន = ១.០០០ គក្រ

**រូបិយវត្ថុ (រៀល)**

៤,២០០ រៀល =១ ដុល្លា

**សីតុណ្ហភាព (អង្សា សេ)**

$^{0}$C =អង្សា សេ

**ចំណុះ**

ម៣/វិនាទី = ម៉ែត្រគីប ក្នុង ១ វិនាទី

**កំហាប់**

mg/l=មីលីក្រាម ក្នុង១លីត្រ

# ជំពូក១:　　ស្ថានភាពទូទៅ

## ការណែនាំ អំពីតំបន់ដីសើម និងវិធីសាស្ត្រ

ស្ទឹងត្រែង គឺជាខេត្តមួយ ក្នុងចំនោមខេត្តដាច់ស្រយ៉ាលជាច្រើនរបស់ប្រទេសកម្ពុជា ស្ថិតនៅភាគ ឥសាន មានចំងាយ៤៨១គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ។ ខេត្តនេះ មានព្រំប្រទល់ខាងជើង ជាប់នឹងសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ខាងកើតជាប់នឹងខេត្តរតនៈគីរី ខាងត្បូងជាប់នឹងខេត្តមណ្ឌលគីរី ខាងលិចជាប់នឹងខេត្តក្រចេះ និងព្រះវិហារ (ផែនទី ១.១)។ ទីរួមខេត្ត មានឈ្មោះជាផ្លូវការ ស្ទឹងត្រែង។

មន្ទីរផែនការខេត្ត (២០០៣)បានរាយការណ៍ថា ខេត្តស្ទឹងត្រែងមានផ្ទៃដី ១១,០៩២គ.ម² ហើយត្រូវបានបែងចែកជាដីសំរាប់ប្រើប្រាស់ ចំនួនប្រាំបួនប្រភេទ (ផ្នែកខ្លះហាក់ដូចជាជាន់គ្នា) ដូចតទៅ:

ដីព្រៃ (៩២៨,000 ហត)

ដីស្រែ (១៩,000 ហត)

ដីកសិដ្ឋាន (២,១៩៣ ហត)

ដីលំនៅដ្ឋាន (១០៣,២១៧ ហត)

ក្រុមហ៊ុនឧស្សាហកម្មបៃតង (១០០, ៨៥២ ហត)

ក្រុមហ៊ុនដីសម្បទាន ឧស្សាហកម្មដំឡូងមី (៧,៤០០ ហត)

ផ្លូវថ្នល់ (២,៤០០ ហត)

ទន្លេ ស្ទឹង និង ព្រែក (៤១,០៩៤ តហ)

ដីទំនេរ (១៣,២០០ ហត)

អ្នកភូមិតំបន់រ៉ាមសារ (ផែនទី១.២) បានពឹងអាស្រ័យខ្លាំងទៅលើធនធានតំបន់ដីសើមទន្លេមេគង្គ សំរាប់តម្រូវការម្ហូបអាហារ និងប្រាក់ចំណូល។ ពួកគេភាគច្រើន ជាកសិករធ្វើស្រែ និងនេសាទ។ ទន្លេ និងតំបន់ដីសើមនៅជាប់តំបន់ រ៉ាមសារ (រួមទាំង វាលស្រែ) បានផ្តល់នូវរបរចិញ្ចឹមជីវិតរួមផ្សំជាច្រើន។ តែធនធានទាំងនេះ កំពុងស្ថិតនៅក្រោមកំណើន សំពាធពីការអភិវឌ្ឍន៍ជាច្រើន ដែលអាចគ្រោះថ្នាក់ដល់សមត្ថភាពធនធានតំបន់ដីសើម ក្នុងការបន្តផ្តល់នូវតម្រូវការចាំបាច់របស់អ្នកភូមិ។

ចំពោះការគ្រប់គ្រងផ្នែករដ្ឋបាល ខេត្តស្ទឹងត្រែង ចែកជាប្រាំស្រុក គឺស្រុកស្ទឹងត្រែង ថាឡាបរិវ៉ាត់ សៀមបូក សេ សាន និងសៀមប៉ាង និងបែងចែកជាឃុំចំនួន៣៤ និងភូមិចំនួន១២៨ (ភូមិខ្លះត្រូវបានបញ្ចូលគ្នាតាមគោលការណ៍រដ្ឋបាល)។ ការសិក្សាថ្មីៗដោយមន្ទីរផែនការខេត្តបង្ហាញថា ខេត្តនេះមានគ្រួសារ ចំនួន១៧,៦០៨ និងចំនួនប្រជាជនសរុប ៩១,៧៩៥ នាក់ ក្នុងនោះមាន ស្ត្រី៤៧,២៣៦ នាក់ (៥១.៥%)។ ចំនួនសមាជិកជាមធ្យមក្នុងមួយគ្រួសារមាន ៥.២ នាក់។

ចំនួនប្រជាជនទាំងអស់របស់ខេត្ត គឺមានចំនួនតិចជាង១% (0.៧%) នៃចំនួនប្រជាជនទូទាំងប្រទេស។ អត្រា កំណើនប្រជាជនប្រចាំឆ្នាំ គឺ២.៤៩%។ ហើយដង់ស៊ីតេប្រជាជន គឺប្រហែល៨នាក់/១គម² ដែលចំនួននេះទាបជាង ចំនួនដង់ស៊ីតេមធ្យមថ្នាក់ជាតិ ៦៤នាក់/១គ.ម² (មន្ទីរផែនការខេត្ត, ២០០៣)។

**ផែនទី ១.១: ផែនទីរដ្ឋបាលខេត្តស្ទឹងត្រែង**



## ផែនទី ១.២: ផែនទី តំបន់រ៉ាមសារនៅខេត្តស្ទឹងត្រែង



ទន្លេមេគង្គ បានហូរកាត់ខេត្តស្ទឹងត្រែង ពីជើងទៅត្បូង។ នៅទីរួមខេត្ត ទន្លេមេគង្គបានជួបប្រសព្វជាមួយទន្លេសេកុង ដែលបានភ្ជាប់ដៃទន្លេចំនួនពីរទៀត គឺទន្លេសេសាន និងស្រែពក។ ទន្លេទាំងអស់ ស្ថិតនៅភាគខាងលើដែលមានអន្លង់ជ្រៅៗ តំបន់ទឹកជូរ និងព្រៃលិចទឹកជាច្រើន។ ការជួបប្រសព្វនេះ មិនត្រឹមផ្តល់នូវផ្លូវនាវាចរទេ គឺថែមទាំងផ្តល់នូវសារសំខាន់នូវជម្រកត្រីពង-កូន និងផ្លូវធ្វើបំលាស់ទីរបស់វា។ ធនធានទាំងអស់នេះ ត្រូវការ ការពារព្រោះវាជាជម្រកសំរាប់ប្រភេទត្រីពិសេសមួយចំនួនដូចជា ត្រីត្រសក់ ត្រីរាជ ត្រីគល់រាំង និងត្រីបាស៊ីអ៊ី ជាដើម (Danida, ២០០០)។ មានប្រជាជនប្រមាណ៩០% បានរស់នៅតាមបណ្តោយទន្លេទាំងបួន ហើយបាន ពឹងអាស្រ័យលើការនេសាទសំរាប់បរិភោគប្រចាំថ្ងៃ និងបង្កើតប្រាក់ចំណូល ( Vannaren, ២០០២ )។

## តំបន់រ៉ាមសារនៅខេត្តស្ទឹងត្រែង

ប្រព័ន្ធអេកូឡូស៊ីដ៏សាំញ៉ាំរបស់តំបន់រ៉ាមសារខេត្តស្ទឹងត្រែង គឺមិនត្រឹមមានការទទួលស្គាល់នាពេលថ្មីៗនេះទេ។ ការពិពណ៌នាតំបន់នេះលើកដំបូង ត្រូវបានបង្ហាញតាំងពីសម័យអាណានិគមបារាំងនៅសតវត្សទី១៩។ ក្នុងអំឡុងពេលនៃការរុករករបស់ក្រុមស្រាវជ្រាវបារាំង នាឆ្នាំ១៨៦៦-១៨៦៨ នៅតាមដងទន្លេមេគង្គ លោក deCarné ដែលជាសមាជិកស្រាវជ្រាវម្នាក់បានធ្វើការពិពណ៌នាលក្ខណៈទន្លេពីខេត្តក្រចេះមកខេត្តស្ទឹងត្រែងថា:

> ដងទន្លេ បានបង្ហាញនូវកោះនានា ដែលបានបែងចែកជាដៃធំៗជាច្រើន។ ត្រើយម្ខាងនៃដងទន្លេ គឺមិន-អាចមើលឃើញពីចំងាយបានទេ ដោយសារមានចុះអ័ព្យច្រើន។ ទឹកទន្លេ បានហូរបោកនឹងផ្ទាំងថ្មបង្កើតបានជាទឹកជូរជាហូរហែរ ដោយពុំមានការរំខាន និងបង្កើតឱ្យមានសូរសំលេង កងរំពងទៅលើអា-កាស។ នៅតាមចន្លោះកោះនានា ទឹកជូរ ទាំង នេះ (ទឹកហូរគួចលើផ្ទាំងថ្ម) បានផ្តល់នូវសោភ័ណ្ឌភាពមួយ ដោយរួមទាំងរុក្ខជាតិមិនគួរឱ្យជឿជាច្រើន បានដោត ឫសនៅលើផ្ទាំងថ្ម និងហ្វូងត្រីជាច្រើនបណ្តែតខ្លួននៅលើផ្ទៃទឹក។ មែកឈើទាំងឡាយ មានរាងទ្រេតទៅតាមលំហូរ ទឹក ដែលអាចបញ្ជាក់ថាដើមឈើទាំងនេះបានលិចក្នុងទឹកទន្លេ។ ដើមឈើខ្ពស់ៗមួយចំនួន បានតោងលើដី ដោយសារប្រភេទរុក្ខជាតិវល្លិ៍ធ្វើខ្លួនមួយចំនួនទៀត បានភ្ជាប់ទៅនឹងច្រាំង ដែលមានឫសរាងដូចសក់មនុស្សស្រី ទំលាក់ដើរបញ្ច្រាសខ្យល់។ ជ្រលងទន្លេ មានលក្ខណៈបត់បែនខ្វូលខ្វាញ់ ដែលកន្លែងខ្លះទឹកទន្លេផុសឡើងនៅពេលដែលហូរឆ្លងកាត់យ៉ាងលឿន។
>
> **(លោក de Carné ឆ្នាំ ១៨៧២)**

ចាប់ផ្តើមពីទីរួមខេត្តស្ទឹងត្រែង រហូតដល់ព្រំដែនប្រទេសឡាវ លក្ខណៈនៃដងទន្លេនៅតែបន្តការទាក់ទាញអារម្មណ៍យ៉ាងខ្លាំង។ នៅទីនេះហើយ ដែលលោក de Carné (១៨៧២) បានពិពណ៌នាថា នៅកន្លែងមួយចំនួនទឹកទន្លេ ហូរយ៉ាងគំហុកតាមជ្រលងទន្លេ ដែលមានលក្ខណៈបត់បែន និងតាមចន្លោះព្រៃលិចទឹកនៅ-តាមបាតទន្លេ។ ទន្លេ និងព្រៃលិចទឹកបានភ្ជាប់គ្នាពីកន្លែងមួយទៅមួយ ហើយគ្មានឮសូរសំលេងអ្វីក្រៅពីសូរខ្យល់បក់បោកមែកឈើ និងសូរទឹកហូរច្រាលលើឫសឈើទាំងនោះទេ។ យោងតាមកំណត់ហេតុរបស់គាត់ បានឱ្យដឹងផងដែរថា នៅពេលល្ងាច គឺមានអ្នកនេសាទមួយចំនួន បង្ហាញខ្លួនជាមួយនឹងពន្លឺភ្លើងក្រហម ដែលបំភ្លឺពួកគេមើលទៅ ដូចសត្វនាគបញ្ចាំងភ្លើងចូលទៅក្នុងទឹក និងភាពស្ងាត់ជ្រងំ នៃរាត្រីកាលមកដល់។

នៅកន្លែងផ្សេងៗ ទឹកទន្លេបានហូរសាច លិចពាក់កណ្តាលដើមឈើដ៏មានមន្តស្នេហ៍ ដែលបានទ្រេតពីលើផ្ទៃទឹក ហើយនឹងស្លឹកឈើស្រស់ៗដែលទើបលិចទឹក ដោយរួមទាំងផ្កាពណ៌ស និងក្រហមនៅក្នុងបរិស្ថានមួយ ដ៏ត្រជាក់រហឹម។

**ពីលោក de Carné មកតំបន់រ៉ាមសារ**

ការពណ៌នារបស់លោក de Carné គឺស្ថិតនៅជាការពិត និងប្រាកដនិយមជាច្រើន សំរាប់ពេលបច្ចុប្បន្ន និងអនាគត។ ដោយការទទួលស្គាល់នូវសារៈសំខាន់របស់តំបន់ទាំងនេះ នៅឆ្នាំ១៩៨៧ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានប្រកាសខេត្តទាំងនេះ (តំបន់មេគង្គលើនៃប្រទេសកម្ពុជា) ជាតំបន់ការពារសំរាប់ត្រីពង-កូន និងហាមឃាត់មិនឱ្យមាន ឡូត៍នេសាទ និងការធ្វើនេសាទពាណិជ្ជកម្មខ្នាតធំ។

នៅឆ្នាំ១៩៩៩ ទន្លេមេគង្គដែលមានផ្ទៃដីលាតសន្ធឹង ៣៧ គ.ម ដោយចាប់ផ្តើមពីទីរួមខេត្តស្ទឹងត្រែង ភាគខាងជើង ប្រមាណ៥គ.ម និងភាគខាងត្បូងព្រំដែនឡាវប្រមាណ៣ គ.ម និងផ្ទៃដីអមច្រាំងទន្លេសងខាងចំនួន៥០០ម ត្រូវបានចាត់ទុក ជា តំបន់រ៉ាមសារ (តំបន់ដីសើម នៃសារៈសំខាន់ជាអន្តរជាតិ ដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយអនុសញ្ញារ៉ាមសារ)។ តំបន់នេះ មានផ្ទៃដីចំនួន១៤.៦០០ ហត។ បច្ចុប្បន្នមានប្រជាជនប្រមាណ១៣.០០០នាក់ កំពុងរស់នៅក្នុងតំបន់នេះ។ តំបន់រ៉ាមសារ ស្ថិតនៅក្នុងស្រុកពីរ : ថាឡាបរិវ៉ាត់ និងស្ទឹងត្រែង មានឃុំចំនួនបួន ភូមិចំនួន២១ និងមានកោះចំនួន៤០ (DoE, 2002)។

នៅរដូវប្រាំង (ខែវិច្ឆិកា ដល់ខែឧសភា) កោះដែលមានដើមឈើដុះច្រើន បានបង្ហាញខ្លួនឡើងវិញ បន្ទាប់ពីទឹកស្រក ហើយបង្កើតបានជាកន្លែងតាំងលំនៅបណ្តោះអាសន្ន សំរាប់អ្នកនេសាទបំលាស់ទីពីកន្លែងផ្សេងៗ ហើយក៏ជាទីកន្លែងមួយយ៉ាងល្អសំរាប់ទេសចរធម្មជាតិផងដែរ។ ព្រៃឈើភាគច្រើន ដែលដុះនៅលើកោះមានលក្ខណៈខុសគ្នាពីព្រៃឈើដែលដុះ តាមច្រាំងទន្លេ និងនៅលើគោកជិតនោះ (Rundell, 1999)។ នៅពេលរដូវទឹកឡើង ស្លឹកឈើទាំងនោះបានផ្តល់នូវជម្រក និងចំណីដល់ពពួកត្រី ជាពិសេសកូនត្រី។ មន្ទីរបរិស្ថានខេត្តនៅឆ្នាំ ២០០២ បានរាយការណ៍ថា មានត្រីប្រមាណ១០០ប្រភេទ រស់នៅក្នុងតំបន់ ក្នុងនោះមាន ចំនួន៥០% ជាប្រភេទត្រីមានតំលៃសេដ្ឋកិច្ចខ្ពស់ សំរាប់ប្រជាជនរស់នៅ។ ប៉ុន្តែ លោក Vong (2004) ក៏បានរាយការណ៍ថា មានត្រីចំនួន១៧០ប្រភេទ ដែលបានរកឃើញនៅតំបន់នោះ។

ដោយមានល័ក្ខខ័ណ្ឌប្រព័ន្ធអេកូឡូស៊ីដ៏ពិសេស និងសំបូរបែបតំបន់រ៉ាមសារ បានផ្តល់នូវប្រភេទសត្វជាច្រើនដូចជា ប្រភេទថនិកសត្វ បក្សី ពពួកល្មូន មច្ឆាជាតិ និងរុក្ខជាតិ ដែលបានបកស្រាយលំអិតនៅជំពូកទី៤។ ប្រភេទត្រីចំនួនបួន ដែលបានចុះក្នុងបញ្ជីការពារ[១] របស់កម្មវិធីអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាពនូវជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ (MWBP) ត្រូវបានរកឃើញនៅក្នុង ឬនៅក្បែរតំបន់រ៉ាមសារ គឺសត្វផ្សោតសត្វក្រៀល ត្រីរាជ និងក្រពើភ្នំ។ សត្វទាំងនេះ ផ្តល់នូវតំបន់សារៈសំខាន់បន្ថែម សំរាប់កម្មវិធីភិរក្ស។

[១] ប្រភេទសត្វការពារ របស់កម្មវិធី ត្រូវបានជ្រើសរើសដោយយោងតាមលក្ខណៈពិសេស និងដោយសារវាបានបំពេញទៅនឹងលក្ខណៈវិនិច្ឆ័យ មួយ ឬច្រើនយ៉ាង :

- ស្ថិតនៅក្នុងភាពសំបូរបែប នៃតំបន់ដីសើម និងតំណាងឱ្យដែនជម្រកស្ថិតក្នុងការគំរាមកំហែង និងជាប្រភេទសត្វពាក់ព័ន្ធរបស់វា ។
- មានរបាយជាលក្ខណៈតំបន់ ឬលក្ខណៈឆ្លងដែន

តំបន់រ៉ាមសារ ប្រមូលផ្តុំទៅដោយព្រែក និងស្ទឹងប្រហែលចំនួន៤០។ ស្ទឹងដែលមានសារៈប្រយោជន៍បំផុត គឺអូរតាឡាស់ មានប្រភពមកពីភ្នំដងរែក ចំងាយប្រមាណ៥០គីឡូម៉ែត្រ ភាគខាងជើងនៃតំបន់រ៉ាមសារ។ អូរនេះ មានប្រវែង៦០គ.ម ហើយផ្តល់សារៈសំខាន់ជាជំរកត្រី ជាតំបន់ត្រីពងកូន និងជាកន្លែងសំរាប់រីកធំធាត់របស់ត្រីនៅក្នុងរដូវវស្សា។ វាក៏មានសារៈសំខាន់សំរាប់សត្វរស់នៅក្នុងទឹកមួយចំនួនទៀត ដូចជា ក្រពើ អណ្តើកកន្ធាយ និងសត្វព្រៃដ៏ទៃទៀតដែលរស់នៅ ក្នុងព្រៃបៃតងជានិច្ច។

លោកទ្រី (២០០៤) បានរៀបរាប់ថា ចាប់ពីខែកញ្ញា ដល់ខែធ្នូ រៀងរាល់ឆ្នាំមានអ្នកនេសាទជាច្រើន បានមកតាំងទីលំនៅដើម្បីនេសាទត្រីនៅអូរតាឡាស់ ជាពិសេសអ្នកនេសាទដែលមានដើមកំណើតជាជនជាតិឡាវ។ អូរនេះ ត្រូវបានចាត់ទុកថា ជាកន្លែងដែលសំបូរត្រីជាងគេបំផុតក្នុងខេត្ត ដែលអ្នកនេសាទអាចដកហូតធនធានតាមបែបបុរាណ។ ប៉ុន្តែនៅទសវត្សរ៍ទី៩០ គឺក្នុងអំឡុងពេលសកម្មភាពនេសាទអនាធិបតេយ្យ អូរនេះត្រូវបានលក់ឱ្យក្រុមហ៊ុនឯកជន ដើម្បីដកហូតធនធានផ្តាច់មុខ ហើយប្រជាជនមូលដ្ឋានត្រូវបានច្រានចោលមិនឱ្យ នេ-សាទ។ តែក្រោយមក ដោយមានអន្តរាគមន៍ ពីអង្គការមិនមែនរដ្ឋាភិបាល និងការតវ៉ាប្រឆាំងពីប្រជាជន អូរនេះត្រូវប្រគល់ឱ្យប្រជាជនមូលដ្ឋានវិញ។ តែទោះជាយ៉ាងណា ការនេសាទខុសច្បាប់បានកើតឡើងតាមដងអូរ និងគ្រប់រដូវ ដែលទង្វើនេះ គឺជាបញ្ហារួមមួយនៃតំបន់រ៉ាមសារផងដែរ។

យោងតាមច្បាប់ជលផលឆ្នាំ ១៩៨៧ ការនេសាទបែបឧស្សាហកម្ម គឺមិនអនុញ្ញាតនៅតំបន់រ៉ាមសារ។ ការនេសាទ លក្ខណៈសិប្បកម្ម និងគ្រួសារ គឺអនុញ្ញាត។ លើសពីនេះទៅទៀត តំបន់ភាគច្រើន ត្រូវបានចងក្រងជាសហគមន៍នេសាទ គ្រប់គ្រងដោយប្រជាជនមូលដ្ឋាន។ ដោយសារច្បាប់ និងបទប្បញ្ញត្តិមិនត្រូវបានអនុវត្តពេញលេញដោយប្រជាជនមូលដ្ឋាន និង អ្នកមកពីខាងក្រៅ តំបន់នេសាទទាំងនេះ គឺស្ថិតនៅស្ថានភាពបើកចំហ។ ហេតុដូច្នេះ ជារៀងរាល់ឆ្នាំ ចាប់ពីខែមករា ដល់ខែឧសភា យើងឃើញមានអ្នកនេសាទមានជាតិសាសន៍ និងមកពីកន្លែងផ្សេងៗ មកធ្វើនេសាទនៅតំបន់រ៉ាមសារ ជាពិសេសនៅពេលដែលការនេសាទនៅទន្លេសេកុង សេសាន និងស្រែពក (មើលផែនទី ៤.១) មិនសូវសំបូរត្រី ឬនៅពេល ដែលទឹកទន្លេរាក់ នេសាទលែងបាន។

មានកន្លែងមួយចំនួន ដូចជាកោះទន្លេមួយ ក្នុងឃុំកោះស្នែង គឺមានវាលខ្សាច់ធំទូលាយ អន្លង់ជ្រៅៗ និងព្រៃលិច ទឹកអមសង្ខាងជាច្រើន ដែលបង្កនូវលក្ខណៈល្អសំរាប់ការនេសាទដោយប្រើឧបករណ៍អួន។ ហេតុដូច្នេះ ការិយាល័យជលផលខេត្ត បានសំរេចចិត្តលក់ដែននេសាទនេះ ឱ្យឯកជនធ្វើអាជីវកម្មអួន ដើម្បីចាប់ត្រីរៀល ប៉ុន្តែតាមពិតឧបករណ៍អួន បានចាប់ត្រីគ្រប់ប្រភេទដែលធ្វើបំលាស់ទីឆ្លងកាត់តំបន់នេះ។ ជាថ្មីម្តងទៀត ការអនុវត្តបែបនេះ បានបណ្តាលឱ្យមានការប្រឆាំងតវ៉ាពីប្រជាជនមូលដ្ឋានឱ្យដកអួនចេញពីតំបន់នេះ។

ករណីសិក្សាមួយចំនួនខាងលើ បង្ហាញនូវសារៈសំខាន់នៃជលផល និងការនេសាទនៅក្នុងតំបន់រ៉ាមសារ។ ចំពោះប្រជាជនដែលរស់នៅក្នុងតំបន់នេះ ការនេសាទ គឺពិតជាមានសារៈប្រយោជន៍ខ្លាំងចំពោះពួកគេ។

## បញ្ហាសំខាន់ៗ : និន្នាការអភិវឌ្ឍន៍ និងបរិស្ថាន

ការប្រើប្រាស់ធនធានតំបន់ដីសើមក្នុងតំបន់រ៉ាមសារ ត្រូវមានការថ្លឹងថ្លែង ជាមួយនឹងសមត្ថភាពបរិស្ថាន

- ផ្តល់នូវឱកាសក្នុងការជំរុញនូវកិច្ចសហប្រតិបត្តការសំរាប់ការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ី និងជីវចម្រុះ។



និងសមត្ថភាពក្នុងការផ្តល់នូវការប្រើប្រាស់ដោយឈ្លាសវៃ និងនិរន្តរភាពនៃធនធានធម្មជាតិតំបន់ដីសើម និងសំរាប់ផលប្រយោជន៍ប្រជាជននាពេលបច្ចុប្បន្ន និងអនាគត។

ប្រជាជនដែលរស់នៅក្នុង ឬក្បែរតំបន់រ៉ាមសារ ទទួលនូវប្រយោជន៍ជាច្រើន ដូចជា អុសសំរាប់ថាមពល ដាំស្ល និងកំដៅ រុក្ខជាតិ និងសត្វព្រៃសំរាប់អាហារ និងឱសថបុរាណ ឈើសំរាប់សង់ផ្ទះ គ្រឿងសង្ហារឹម និងតុបតែង និងអាហារមូលដ្ឋាន ដូចជាស្រូវ ត្រី សាច់ ផ្លែឈើ និងបន្លែជាដើម។ ធនធានទាំងនេះ ក៏ជាប្រភពផ្តល់នូវប្រាក់ចំណូលដល់ប្រជាជនមូលដ្ឋានផងដែរ។ ជាទូទៅ ធនធានតំបន់ដីសើម ផ្តល់នូវប្រយោជន៍យ៉ាង ច្រើនដល់ សហគមន៍មូលដ្ឋាន។ ប្រសិនបើធនធានតំបន់ ដីសើមត្រូវបាត់បង់ ពេលនោះវត្ថុទាំងនេះ នឹងត្រូវបាត់បង់ផងដែរ។

ទោះជាយ៉ាងណា មកដល់ពេលនេះ ពុំទាន់មានគោលនយោបាយ ឬផែនការច្បាស់លាស់ពីរដ្ឋាភិបាល ដើម្បីការពារធនធានទាំងនេះទេ។ គោលនយោបាយទាំងនេះ គឺជាកាតព្វកិច្ច ស្ថិតនៅក្រោមអនុសញ្ញារ៉ាមសារ ដែលតម្រូវឱ្យប្រទេសចុះហត្ថលេខី អនុវត្តនូវជំហ៊ានសមស្របទាំងឡាយណា ដើម្បីគ្រប់គ្រង និងអភិរក្សតំបន់ដីសើមរបស់ពួកគេ (Nga, 2004)។

យោងតាមរបាយការណ៍ ដែលបានបោះពុម្ពផ្សាយនៅឆ្នាំ២០០០ ដោយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ និងមូលនិធិបរិស្ថានពិភពលោកបានឱ្យដឹងថា ទោះបីតំបន់ភូមិភាគឥសាន្តប្រទេសកម្ពុជា សំបូរទៅដោយព្រៃឈើ និងមានចំនួនប្រជាជនតិច ក៏ការកាប់ឈើទាំងស្រប និងខុសច្បាប់ ជាប្រភពនៃការបាត់បង់ព្រៃឈើ និងថយចុះ។ សូម្បីតែថ្មីៗនេះ មានបរិស្ថាននុរក្ស[២] ត្រូវបានជ្រើសរើស ដើម្បីទប់ស្កាត់នូវសកម្មភាពខុសច្បាប់មួយចំនួន តែការរានព្រៃធ្វើចំការ និងការរានដីថ្មី ដើម្បីកសិកម្មពនេចរ និងដាំបន្លែ មិនត្រូវបានទប់ស្កាត់ឡើយ។ ប្រជាជនភាគច្រើន មិនយល់ពីសារៈសំខាន់នៃព្រៃឈើទេ។

របាយការណ៍ដដែលបានឱ្យដឹងទៀតថា ការបាត់បង់ដែនជម្រក គឺមិនអាចជៀសវាងបាន ដោយសារកំណើនសំពាធលើដីធ្លី ដោយសារអវត្តមានកម្មវិធីអភិវឌ្ឍន៍ចម្រុះរបស់រដ្ឋាភិបាល។ សញ្ញាណបច្ចុប្បន្ន បង្ហាញថាប្រជាជននឹងបន្តប្រែក្លាយតំបន់ដីព្រៃ ឱ្យទៅជាតំបន់តាំងលំនៅថ្មី និងកន្លែងដាំដំណាំ (UNDP និង GEF, 2000)។

របាយការណ៍សង្ខេបរបស់លោក **ង៉ា** ក្នុងឆ្នាំ ២០០៤ ស្តីពីការគំរាមកំហែងដល់តំបន់រ៉ាមសារ បានលើកឡើងនូវបញ្ហាជាច្រើន។ បញ្ហាទាំងនេះ រួមមានកង្វះខាតការសម្របសម្រួលតាមវិស័យ ក្នុងការធ្វើផែនការចំនោម

[២] បរិស្ថាននុរក្ស ជាភ្នាក់ងាររដ្ឋ មានតួនាទីការពារ និងទប់ស្កាត់ការបំផ្លាញបរិស្ថាននៅក្នុងតំបន់ពួកគេ ជាពិសេសតំបន់រ៉ាមសារ។ ភ្នាក់ងារទាំងនេះ ត្រូវរាយការណ៍រាល់បញ្ហា និងសកម្មភាព ទាក់ទងនឹងការបំផ្លាញបរិស្ថានឱ្យមន្ទីរបរិស្ថានខេត្ត។ បច្ចុប្បន្ន មានបរិស្ថាននុរក្ស ចំនួន ១៥ នាក់ នៅក្នុងតំបន់រ៉ាមសារ។

ស្ថាប័នពាក់ព័ន្ធ ក្របខ័ណ្ឌ គោលនយោបាយនៅខ្សោយ ការចែករំលែកព័ត៌មាន និងការយល់ដឹងមិនគ្រប់គ្រាន់ កង្វះខាតធនធានបច្ចេកទេស និងមនុស្ស និងកង្វះខាតជម្រើសទៅលើការប្រើប្រាស់ធនធានធម្មជាតិ។ អ្នកស្រី ជុង (២០០៥) បានរកឃើញនូវបញ្ហាស្រដៀងគ្នាដែរ ហើយបានបន្ថែមថាកង្វះខាតការយល់ដឹងនៃតំលៃសេដ្ឋកិច្ច ធនធានតំបន់ដីសើមពីសំណាក់ប្រជាជនមូលដ្ឋាន និងប្រទេសទាំងមូល។ មានធនធានតំបន់ដីសើមជាច្រើនមិន បានឱ្យតំលៃឬមិនយកចិត្តទុកដាក់ពិចារណាតំលៃសេដ្ឋកិច្ចរបស់វា។

បញ្ហាផ្សេងទៀត ដែលគំរាមកំហែងដល់តំបន់រ៉ាមសារ គឺមិនស្ថិតនៅក្នុងប្រទេសកម្ពុជទេ។ បញ្ហាទាំងនេះ គឺបណ្តាលមកពីគំរោងអភិវឌ្ឍន៍ឆ្លងដែន ដូចជាឥទ្ធិពលគំរោងស្តារប្រព័ន្ធនាវាចរ ពីប្រទេសចិនមកកាន់ប្រទេសឡាវ និងគំរោងសង់វារីអគ្គិសនីខ្នាតធំតាមដងទន្លេមេគង្គមួយចំនួនទៀត ដែលតម្រូវឱ្យមានការកែប្រែប្រព័ន្ធលំហូរទន្លេទាំងស្រុង។ គំរោងខ្នាតធំតាមដងទន្លេមេគង្គភាគខាងលើ អាចប៉ះពាល់ដល់ជីវភាពប្រជាជនមូលដ្ឋាន និងនិរន្តរភាពធនធានជលផល ប៉ុន្តែប្រជាជនមូលដ្ឋានមានសំលេងតិចតួចណាស់ក្នុងការប្រឆាំង និងកាត់បន្ថយផលប៉ះពាល់ទាំងនេះ (Try និង Vannara, 2004)។

លោក Ojendal និង Torell (2000) ក៏បានបង្ហាញថាគំរោងអភិវឌ្ឍន៍ខ្នាតធំ ដូចជាការកាប់ឈើ និងសង់វារីអគ្គិសនីបានដាក់សំពាធទៅលើធនធានព្រៃឈើ និងទឹក។ ប្រទេសកម្ពុជា ធ្លាប់មានបទពិសោធន៍ និង-អត្រា នៃការធ្វើសម្បទានព្រៃឈើគួរឱ្យភ្ញាក់ផ្អើល។ នៅដើមឆ្នាំទសវត្សរ៍ទី៩០ ការប្រតិបត្តិការកាប់ឈើខុសច្បាប់ បានបណ្តាលឱ្យព្រៃឈើបានកាប់លើសអត្រាដកហូតបែបនិរន្តរភាពប្រមាណ៣-៥ដង។ ការដកហូតព្រៃឈើ គឺជាឧទាហរណ៍មួយនៃការដកហូតធនធានបែបប្រយោជន៍បុគ្គល ជំនួសឱ្យផែនការអភិវឌ្ឍន៍ដោយ និរន្តរ-ភាព ក្នុងការគាំទ្រប្រយោជន៍យូរអង្វែងរបស់ប្រព័ន្ធអេកូឡូស៊ី និងប្រជាជនទាំងមូល។ ការបន្តបាត់បង់ព្រៃឈើនៅជុំវិញតំបន់រ៉ាមសារ នឹងនាំឱ្យមានការបាត់បង់ជីវៈចម្រុះ និងបង្កើនភាពងាយរងគ្រោះដល់ប្រជាជនមូលដ្ឋានទៅ នឹងភាពក្រីក្រ និងកង្វះអាហារូបត្ថម្ភ។

ការអភិវឌ្ឍន៍វារីអគ្គិសនី នឹងបណ្តាលឱ្យមានការផ្លាស់ប្តូរបរិស្ថាន និងការប្រកួតប្រជែងជាមួយនឹងវិស័យសេដ្ឋកិច្ចផ្សេងៗទៀតដូចជា ជលផល កសិកម្ម ទេសចរណ៍ សំរាប់ធនធានដែលមានស្រាប់។ នៅក្នុងន័យនេះ តំលៃសង្គម និងបរិស្ថានពេញលេញ ទាក់ទងនឹងការអភិវឌ្ឍន៍វារីអគ្គិសនី ត្រូវតែដាក់បញ្ចូលទៅក្នុងផែនការគំរោង (Ojendal និង Torell, 2000)។

លោក Baird ឆ្នាំ ២០០១ និង Ratner ឆ្នាំ២០០៣ បានធ្វើការរិះគន់ ទំនប់ខ្នាតធំដែលបានបំផ្លាញធនធានជលផលនៅតាមដងទន្លេមេគង្គ និងដៃនានារបស់វា។ ទំនប់វារីអគ្គិសនីបានបំផ្លាញ ជាពិសេសប្រភេទត្រីធ្វើការបំលាស់ទី តាមខ្សែទឹកភាគខាងលើ និងក្រោមនៃដងទន្លេ។ ប្រភេទត្រីទាំងនេះ មានសារៈសំខាន់ដល់ផលនេសាទនៅតំបន់រ៉ាមសារ។ ក្រៅពីការរារាំងដល់ចរាចរត្រី ទំនប់អគ្គិសនី បានផ្លាស់ប្តូរលំហូរទន្លេបង្កឱ្យមានកំណក សីតុណ្ហភាព និងគុណ ភាពទឹក បំផ្លាញធនធានវារីជាច្រើនថែមទៀត។

នៅប្រទេសកម្ពុជា ជាតិប្រូតេអ៊ីនភាគច្រើនបរិភោគប្រចាំថ្ងៃ ច្រើនជាង៨០% បានមកពីត្រី ដែលក្នុងនោះមានចំនួន ៦០% ចាប់ពីបឹងទន្លេសាប។ សេណារីយ៉ូនេះ បង្ហាញថា ការបាត់បង់ធនធានព្រៃឈើ និងជលផលនឹងបណ្តាលឱ្យមានបញ្ហាធ្ងន់ធ្ងរដល់ជីវភាពរស់នៅ និងសន្តិសុខស្បៀង ហើយនឹងជះឥទ្ធិពលអាក្រក់នៅទូទាំងប្រទេស។

ឧទាហរណ៍ ការប្រតិបត្តិទំនប់វារីអគ្គិសនីយ៉ាលីនៅប្រទេសវៀតណាមតាមដងទន្លេសេសាន គឺជាការពិតមួយនាពេលបច្ចុប្បន្ន ទាក់ទងផលប៉ះពាល់ឆ្លងដែននៃការអភិវឌ្ឍន៍ធនធាន នៅក្នុងប្រព័ន្ធទន្លេមេគង្គទាំងមូល។ ផលប៉ះពាល់ភាគច្រើន ធ្លាក់ទៅលើសហគមន៍ជនជាតិភាគតិច (ប្រហែលចំនួន៥០.០០០នាក់)។ នៅខេត្តរតនគិរីមានក្រុមជនជាតិចំនួន៩ បានទទួលនូវផលប៉ះពាល់រួមមាន ជនជាតិឡាវ ចារ៉ាយ (ច្រាយ) ការចក់ ទំពួន ព្រៅ គ្រឹង ខ្មែរ កាវ៉ែត និងចិន។ នៅខេត្តស្ទឹងត្រែង មានក្រុមជនជាតិចំនួន៧ បានទទួលរងប៉ះពាល់ ដូចជាឡាវ ឡាវដើម ខ្មែរ ខ្មែរខិះ ខ្មែរផារនើម ពួង និងជនជាតិ គ្រឹង Biard et al, 2002; Hirsh និង Wyatt, 2004).

លោក Learner ឆ្នាំ២០០៣បង្ហាញថា យ៉ាងហោចណាស់មានប្រជាជនចំនួន៣២នាក់បានលង់ទឹងស្លាប់ដោយសារទឹកហូរគំហុកពេក។ លើសពីនេះទៅទៀត ដំណាំកសិកម្មជាច្រើនត្រូវបានបំផ្លាញដោយទឹកជំនន់ផលនេសាទធ្លាក់ចុះ គុណភាពទឹកថយចុះ និងជំងឺកើនឡើង។ លោក McKenny ឆ្នាំ ២០០១ ក៏បានបង្ហាញផងដែរថា ទំនាប់វារីអគ្គិសនីយ៉ាលីរបស់វៀតណាម នៅតាមដងទន្លេសេសាន បានបំផ្លាញប្រាក់ចំណូលប្រចាំឆ្នាំប្រមាណ ២,៥ លានដុល្លារអាមេរិក សំរាប់គ្រួសារចំនួន ៣.៤៣៤។ ប្រាក់ចំណូលប្រចាំខែរបស់គ្រួសារបានធ្លាក់ចុះពី១០៩ដុល្លារ មកត្រឹម៤៦ដុល្លារក្នុងមួយខែ គឺស្មើនឹង ៥៧% នៃប្រាក់ចំណូលធ្លាក់ចុះ។ ការបាត់បង់ធនធានរូបិយមួយចំនួនទៀតក្នុងអំឡុងឆ្នាំ ១៩៩៦-១៩៩៩ គឺមានចំនួន ៨០០.០០០ ដុល្លារ ដោយរាប់ទាំងការបាត់បង់ឧបករណ៍នេសាទ ទូក សត្វពាហនៈ ផ្ទះសម្បែង និងជង្រុកស្រូវ។

គំរោងអភិវឌ្ឍន៍ខ្នាតធំ តែងតែមើលរំលង នូវធនធានមិនត្រូវចំណាយថវិកា ដូចជា អុសដុត និងប្រភេទត្រីផ្សេងៗ ពស់ ពពួកល្មូន ជាដើម ដែលបានចាត់ទុកជាផលិតផលទីពីរបន្ទាប់ពីស្រូវ។ ភាគច្រើននៃផលិតផលទាំងនេះ គឺមិនដែលលក់នៅទីផ្សារទេ ហើយសារៈសំខាន់របស់ពួកវា តែងតែមើលរំលងនៅពេលដែលគេធ្វើការវិភាគប្រយោជន៍ និងតំលៃនៃការប្រតិបត្តិទំនប់ខ្នាតធំ។ តែទោះជាយ៉ាងណា ការធ្វើកសិកម្មនេសាទ និងបរបាញ់ត្រឹមតែរស់បានទ្រទ្រង់ជីវិតមនុស្សជាច្រើននាក់ (Ojendal និង Torell, 2000)។

## សង្ខេប

តំបន់រ៉ាមសារខេត្តស្ទឹងត្រែង ប្រទេសកម្ពុជា គឺមានសារៈសំខាន់សំរាប់ជីវភាពរបស់នៅប្រជាជន និងអភិរក្សជីវៈចម្រុះ។ ប្រជាជនដែលរស់នៅ ឬនៅក្បែរតំបន់ដីសើមទាំងនេះ បានទទួលផលប្រយោជន៍ជាច្រើនដូចជា អូសដុតសំរាប់ដាំស្ល និងកំដៅ រុក្ខជាតិ និងសត្វព្រៃសំរាប់ធ្វើឱសថបុរាណ ឈើសំរាប់សង់ផ្ទះ សង្ហារឹមតុបតែងលំអរ អាហារមូលដ្ឋាន ដូចជា ស្រូវ ត្រី សាច់ ផ្លែឈើហូបផ្លែ និងបន្លែបង្កា ទឹកសំរាប់ដាំស្ល និងបោកគក់ ដុះលាង ខ្សាច់ និងថ្មសំរាប់សង់អាគារធំៗ និងផ្លូវទឹកសំរាប់នាវាចរ។ ធនធានដីសើមតំបន់រ៉ាមសារផ្តល់នូវផលប្រយោជន៍មហាសាល ដល់សហគមន៍មូលដ្ឋាន សំរាប់បច្ចុប្បន្ន និងអនាគត។ ប្រសិនបើធនធានតំបន់ដីសើមត្រូវបាត់បង់ វត្ថុទាំងនេះក៏ត្រូវបាត់បង់ដែរ។

តែទោះជាយ៉ាងណាមកដល់ពេលនេះ មានភាពរាំងស្ទះមួយចំនួនដល់ប្រសិទ្ធភាពគ្រប់គ្រងនៃតំបន់រ៉ាមសារ។ ការរាំងស្ទះទាំងនេះ រួមមានកង្វះខាតការសម្របសម្រួលរវាងវិស័យផ្សេងៗ ក្របខ័ណ្ឌគោលនយោបាយនៅខ្សោយ និងការមិនគាំទ្រតំលៃសេដ្ឋកិច្ចបរិស្ថាន ព័ត៌មានគោលមិនគ្រប់គ្រាន់សំរាប់បង្កើត

គោលនយោបាយដីសើម ការសម្រេចចិត្តគ្រប់គ្រង និងផែនការ ធនធានបច្ចេកទេស និងធនធានមនុស្សមិនគ្រប់គ្រាន់ និងកង្វះខាតជម្រើសសំរាប់ប្រើប្រាស់ធនធានដោយសហគមន៍មូលដ្ឋាន។ កត្តាទាំងនេះ ជាលទ្ធផលនៃការប្រើប្រាស់ធនធានដោយពុំមាននិរន្តរភាព។

# ជំពូក២: ប្រវត្តិសាស្ត្រ

## ប្រវត្តិដើម

ប្រវត្តិសាស្ត្រនៃឧបទ្វីបអាស៊ីអាគ្នេយ៍ ដោយរួមទាំងអាងទន្លេមេគង្គ គឺមានការវិវត្តន៍ ជាហូរហែរតាមរយៈសង្គ្រាម ការឈ្លានពាន វាតទីនិយម និងការធ្វើចំណាកស្រុក ពីក្រុមកុលសម្ព័ន្ធផ្សេងៗ ដោយរួមមានជនជាតិ ឡាវ វៀតណាម ខ្មែរ មន ចិន និងថៃ។ ជាលទ្ធផល ឧបទ្វីបអាស៊ីអាគ្នេយ៍ បានក្លាយជាទឹកដីមួយដែលសំបូរទៅដោយ ពូជសាសន៍ ភាសា និងក្រុម កុលសម្ព័ន្ធចំរុះផ្សេងៗគ្នាបំផុតមួយ នៅលើសកលលោក។

នៅខេត្តស្ទឹងត្រែងប្រទេសកម្ពុជា ការជួបគ្នាវាងទន្លេមេគង្គ និងដៃនានារបស់វានៅទីរួមខេត្ត គឺមិនត្រឹមតែបានផ្តល់នូវធនធានធម្មជាតិដ៏មហាសាលនោះទេ វាថែមទាំងបានបង្កើតនូវចំនុចយុទ្ធសាស្ត្រចម្បងមួយសំរាប់ការតាំងលំនៅរបស់ ប្រជាជន និងការធ្វើពាណិជ្ជកម្ម។ យោងតាមកំណត់ត្រារបស់លោក ប៉ាវី ឆ្នាំ១៨៧៩ ដល់ឆ្នាំ ១៨៩៥ បានបង្ហាញឱ្យដឹងថា ខេត្តនេះគឺជាមជ្ឈមណ្ឌលមួយដ៏ធំ ព្រោះវាមានទីតាំងល្អដែលមានចំនុចប្រសព្វទន្លេមេគង្គ ជាមួយនឹងទន្លេចំនួន៣ផ្សេងទៀត គឺទន្លេសេកុង សេសាន និងស្រែពក។ ផ្លូវទឹកទាំងនេះ ហើយដែលបានផ្តល់នូវយុទ្ធសាស្ត្រកម្រិតទី១ ហើយបានប្រែក្លាយខេត្តនេះទៅជាមជ្ឈមណ្ឌលពាណិជ្ជកម្មដ៏សំខាន់ ( Cupet, 1898)។

ក្នុងអំឡុងពេលចុងសតវត្សរ៍ទី៦ អាណាចក្រនគហ្វូណន ដែលបច្ចុប្បន្នជាប្រទេសកម្ពុជាត្រូវបានវាយប្រហារដោយជនជាតិស៊ុនដា (Sunda) នៅតាមសមុទ្រ និងការគាបសង្កត់ដោយជនជាតិខ្មែរនៅឯឧបទ្វីប។ ខ្មែរនៅពេលនោះ មានមូលដ្ឋានយ៉ាងធំនៅតាមដងទន្លេមេគង្គភាគខាងក្រោមបំផុត។ ដោយសារវត្តមានរបស់ខ្មែរពេលនោះគេឃើញមានការផ្លាស់ប្តូរអំណាចនយោបាយ ដោយផ្អែកលើពាណិជ្ជកម្មទៅកាន់អំណាចនយោបាយដោយផ្អែកលើការដាំស្រូវ ដោយរួមទាំងការផ្លាស់ ប្តូរទីតាំងពីតំបន់ឆ្នេរ មកកាន់តំបន់ជុំវិញបឹងទន្លេសាប វិញ។ យុគសម័យអង្គរដ៏រុងរឿង (ប្រហែលចាប់ផ្តើមសតវត្សរ៍ទី៩ ដល់ទី១៥) គឺផ្អែកលើការគ្រប់គ្រងធនធានទឹកដ៏ប៉ិនប្រសព្វ តាមរយៈការកសាងនូវទំនប់ទឹកតូចៗជាច្រើន (Ojendal, 2000)។ កត្តានេះបង្ហាញថា អាណាចក្រខ្មែរប្រហែលជាមានលក្ខណៈគ្រាន់បើជាងអាណាចក្រដំបូងដ៏ទៃទៀត នៅអាស៊ីអាគ្នេយ៍ទាក់ទងនឹងការប្រើប្រាស់ទឹក ប្រកបដោយប្រសិទ្ធភាព ពីអាងទន្លេមេគង្គ។

ការវិភាគប្រវត្តិសាស្ត្រដោយលោក Ironside and Baird (2003) ក៏បានបង្ហាញថាខេត្តស្ទឹងត្រែងបានរងនូវឥទ្ធិពលពីប្រទេសជិតខាងជាច្រើន។ អ្នកនិពន្ធទាំងពីរបានពន្យល់ថា ជាដំបូងជនជាតិឡាវបានមកដល់ខេត្តស្ទឹងត្រែង ហើយបន្ទាប់មកឆ្ពោះទៅកាន់តំបន់រតនគីរី កាលពី៣០០ឆ្នាំមុន។ ដោយសារខ្មែរបាត់បង់ទឹកដីភាគខាងជើងទៅឱ្យថៃនៅសតវត្សរ៍ ទី១៣ និងដោយរួមទាំងការបោះបង់ទីក្រុងអង្គរធំក្នុងឆ្នាំ១៤៣២ ជនជាតិឡាវបានព្យាយាមដណ្តើមយកបណ្តាខេត្តភាគខាងជើងពីខ្មែរក្នុងឆ្នាំ១៥៧១។ នៅពេលនោះ ខ្មែរបានដករួចជាស្រេចពីភាគខាងត្បូងអាងទន្លេសេកុង ប៉ុន្តែនៅគ្រប់គ្រងទីក្រុងស្ទឹងត្រែងនៅឡើយ (គឺបាចុង[៣])។

[៣] បាចុងបច្ចុប្បន្ន គឺឈ្មោះភូមិមួយដែលស្ថិតនៅចំនុចប្រសព្វវាងទន្លេសេកុង និងមេគង្គ នៃទីរួមខេត្តស្ទឹងត្រែង។ ឈ្មោះនេះ មានប្រវត្តិមក ពីវិហារចាស់មួយ បានបាក់ចូលទៅក្នុងទឹកទន្លេមេគង្គ នៅសល់តែគ្រឹះតាំងពីយូរលង់ណាស់មកហើយ។

ដោយមានការឈ្លានពានពីជនជាតិឡាវ ខេត្តស្ទឹងត្រែងត្រូវបានបោះបង់ចោល ហើយជនជាតខ្មែរ ដែល-បានគ្រប់គ្រងដំបូងនៅតាមអាងទន្លេសេកុង និងសេសាន ត្រូវបានបែកចាក់ជាបណ្តោះអាសន្ន។ បន្ទាប់ពីការបាក់បែកនូវទីក្រុងលង្វែក (ទីក្រុងថ្មីរបស់ ខ្មែរ) ក្នុងឆ្នាំ១៥៨៧ទៅឱ្យថៃ ស្តេចស្រុកខ្មែរបានរត់មកជ្រកកោននៅខេត្តស្ទឹងត្រែង ក្រោមការការពាររបស់ស្តេចឡាវ។ នៅអំឡុងឆ្នាំ ១៦២១ ស្តេចខ្មែរឈ្មោះ ជ័យជេដ្ឋាទី១១ ចង់ធ្វើការគ្រប់គ្រងឡើងវិញទៅលើអាងទន្លេសេកុង ហើយបានរៀបចំក្រុមរុករកដែលមានទាហ៊ានខ្មែរចំនួន៣០០នាក់ និងទាហានបរទេសមួយចំនួនទៀត ហើយទីបំផុតក៏បានវាយយកតំបន់អាងទន្លេមួយផ្នែកធំ។ ការឈ្លានពាននេះអាចជាប្រភពនៃវត្តមានជនជាតិខ្មែរខិះ ដែលគេដឹងថាមានសូរសំនៀងស្រដៀងគ្នានឹងអ្នកស្រុកដើមនៅខេត្តសៀមរាប ហើយបានបន្តតាំងលំនៅតាមផ្នែកមួយចំនួន នៃដងទន្លេសេសាន ស្រែពក និងសេកុង ដែលបច្ចុប្បន្នគឺស្រុកសៀមប៉ាង និងសេសាន នៃខេត្តស្ទឹងត្រែង។ នៅឆ្នាំ១៦៤១ តំបន់ទឹកធ្លាក់ល្បាក់ខោននៃទន្លេមេគង្គ បានកំណត់ព្រំដែនរវាងអាណាចក្រទាំងពីរ។ ហើយជនជាតិភាគតិចមួយ (moi) ស្ថិតក្រោមការគ្រប់គ្រងរបស់ឡាវដែលជាម្ចាស់ថ្មី (Ironside and Baird, 2003)។

ក្នុងអំឡុងសតវត្សរ៍ទី១៥-១៦ ដោយមានការពង្រីកទឹកដីពីប្រទេសវៀណាមពីភាគខាងកើត និងប្រទេសឡាវ ពីទិសខាងជើង ទង្វើនេះបានរុញច្រានអ្នកតាំងលំនៅចាម និងខ្មែរពីខេត្តស្ទឹងត្រែងទៅកាន់តំបន់ភូមិភាគកណ្តាលនៃប្រទេសកម្ពុជា។ នៅចុងសតវត្សរ៍ទី១៨ និងដើមសតវត្សរ៍ទី១៩ សៀមបានគ្រប់គ្រងផ្នែកជាច្រើននៃប្រទេសកម្ពុជាភាគខាងជើង និងភាគខាងត្បូងប្រទេសឡាវ ពេលនោះសហគមន៍កុលសម្ព័ន្ធជនជាតិភាគតិចត្រូវបានទារពន្ធជាមាសយ៉ាងធ្ងន់ធ្ងរ ដោយអ្នកគ្រប់គ្រងថ្មី និងការធ្វើពាណិជ្ជកម្មទៅលើទាសករ។

នៅឆ្នាំ១៨១៤ សៀមបានគ្រប់គ្រងក្រុងស្ទឹងត្រែង។ ហើយបន្ទាប់មក ពួកគេបានគ្រប់គ្រងតំបន់ជាច្រើននៃខេត្តស្ទឹងត្រែង និងស្រែពកខាងក្រោម។ នៅពេលនោះ ជនចំណូលស្រុកឡាវដំបូងមកកាន់តំបន់ ដែលបច្ចុប្បន្ន គឺជាខេត្តស្ទឹងត្រែង និងរតនគីរី មានតួនាទីជាអ្នកជំនួញ ឬអ្នកជួយដូរទាសករ។ តែចំពោះជនចំណូលស្រុក ក្រោយៗមកគឺជាអ្នកនេសាទ និងកសិករ ដែលភាគច្រើនបានធ្វើបំលាស់ទីមកពីតំបន់ប្រជាជនរស់នៅកុះករ **ស៊ីផាន់ដន** (បួនពាន់កោះ) ដែលស្ថិតនៅតាមដងទន្លេមេគង្គ ប្រទេសឡាវភាគខាងត្បូង (បច្ចុប្បន្ន គឺស្រុកខុង ខេត្តចំប៉ាសាក់)។

នៅអំឡុងឆ្នាំប្រមាណ ១៨៨២-៨៣ មានជនជាតិឡាវចំនួន៤០០០នាក់ ត្រូវបានចុះបញ្ជីបង់ពន្ធឱ្យចៅហ្វាយស្រុកស្ទឹងត្រែង ដែលលាតសន្ធឹងពីតំបន់សំបូរតាមដងទន្លេមេគង្គ (បច្ចុប្បន្ន គឺជាស្រុកសំបូរ ខេត្តក្រចេះ) ភាគខាងត្បូង និងស្រុកសៀមប៉ាងនៅភាគខាងជើង និងក្រុមកុលសម្ព័ន្ធភ្នំទាំងអស់នៅភាគខាងកើត (Aymonier ដែលបានដកស្រង់ដោយ Ironside and Baird, 2003)។ យោងតាមកំណត់ហេតុបង់ពន្ធដា នៅឆ្នាំ១៩០៥ នៅតំបន់ទន្លេសេកុង សេសាន ស្រែពក និងស្ទឹងត្រែង បានបង្ហាញនូវបុរសជនជាតិខ្មែរ និងឡាវចំនួន ២០១៨នាក់ ដែលមានអាយុចាប់ពី២០ ដល់៥៩ឆ្នាំ រស់នៅភូមិ ចំនួន៦៤។ យោងតាមស្ថិតិនេះ លោក Guérin កាលពីឆ្នាំ២០០១ បានប៉ាន់ប្រមាណថា ចំនួននៃជនជាតិខ្មែរ និងឡាវនៅតំបន់នេះ គឺមិនច្រើនជាង១២០០០ ឡើយ។

យោងតាមការវិភាគប្រវត្តិសាស្ត្រឡើងវិញដោយលោក Ironside and Baird (2003) ក៏បានសន្និដ្ឋានផងដែរថា ទោះបីស្ថិតនៅក្រោមការត្រួតត្រារបស់ថៃ និងឡាវក៏ដោយ ក៏ប្រជាជនដែលរស់នៅលើទឹកដី នៃ-អាងទន្លេសេកុង ទន្លេសេសាន និងស្រែពក ដោយរួមទាំងតំបន់នៅខាងក្រោយខេត្តក្រចេះ (ក្នុងនោះរួមមានខេត្ត រតនគិរី និងមណ្ឌលគិរីបច្ចុប្បន្ន) បានបន្តនូវទំនាក់ទំនងពាណិជ្ជកម្មរបស់ខ្លួនជាមួយនិងអាណាចក្រខ្មែរ។

ជនជតិខ្មែរ និងជាពិសេសជនជាតិចិនបានធ្វើដំណើរឆ្លងកាត់តំបន់ដាឡាក់ (បច្ចុប្បន្នខ្ពង់រាបកណ្តាលនៃប្រទេសវៀតណាម) ហើយបានលក់នូវទំនិញដូចជា អំបិល កុម្ភការភ័ណ្ឌ ដែក និងទំនិញមិនសូវមានតំលៃមួយចំនួន (ក្រាស ក្រណាត់/សំពត់ក្រគុង ពាងស្រាជាដើម) សំរាប់ពួកទាសករ កុយរមាស មាស និងធ្មេញដំរី ជាដើម។

នៅឆ្នាំ១៨៤៩ បារាំងបានបង្កើតបេសកកម្មសាមនទូតតំបន់កន្ទុមដោយឆ្លងកាត់អាងទន្លេសេសាន និងស្រែពក ហើយបានរុញច្រានពួកសៀមឱ្យដកថយក្រោយ ឆ្ពោះទៅទិសខាងលិចនៃដងទន្លេមេគង្គ។ នៅឆ្នាំ១៨៦៣ ស្តេចនរោត្តម (ដែលជាជីលួតរបស់ស្តេចបច្ចុប្បន្ន) ត្រូវបានបង្ខំឱ្យដាក់ប្រទេសកម្ពុជា ស្ថិតនៅក្រោមអណា-ព្យាបាលរបស់ប្រទេសបារាំង។ ហើយក្នុងឆ្នាំ១៨៦៤ ប្រទេសនេះបានក្លាយទៅជាអាណានិគម ប្រទេសបារាំង (Sovathana, 2005)។ ស្របពេលនោះ ធនធានធម្មជាតិ ដោយរួមទាំងផលិតផលដើមឈើ ដីធ្លី និងធនធានរ៉ែត្រូវបានដកហូត និងធ្វើអាជីវកម្មដោយជនជាតិបារាំង (Chandler, 1995)។ ដោយសារអំណាចអាណានិគមពីប្រទេសបារាំង ពេលនោះការតស៊ូដើម្បីគ្រប់គ្រង និងមានឥទ្ធិពលទៅលើតំបន់ ត្រូវបានបញ្ឈប់បណ្តោះអាសន្ន ហើយពេលនោះ ត្រូវបានគេអះអាងថា ប្រទេសបារាំងបានជួយសង្គ្រោះអាណាចក្រខ្មែរពីការលេបត្របាក់ពីប្រទេសថៃ និងវៀតណាម បន្ទាប់ពីការត្រលប់មកដល់របស់ខ្លួន។

មានហេតុផលមួយសំរាប់ការយកចិត្តទុកដាក់របស់បារាំងមកលើប្រទេសកម្ពុជា គឺជាការប៉ុនប៉ងដើម្បីត្រួតត្រាទន្លេមេគង្គដែលបានគិតថាជាផ្លូវមួយខ្លី និងជិតបំផុត ឆ្ពោះទៅកាន់ខេត្តយូណាន ភាគត្បូងប្រទេសចិន។ ដោយសារហេតុផល សេដ្ឋកិច្ច និងយុទ្ធសាស្ត្រ ដោយគួបផ្សំនឹងមោទនភាពប្រទេសជាតិផងនោះ បានជំរុញឱ្យជនជាតិបារាំងនៅទឹកដីកូសាំងស៊ីន (ឧបទ្វីបអាស៊ីអាគ្នេយ៍) ឱ្យបង្កើននូវភាពប្រឹងប្រែងរបស់ខ្លួនក្នុងការត្រួតត្រាមកលើប្រទេសកម្ពុជា (Reddy, 1970)។

ប៉ុន្តែ បារាំងមិនបានដឹងនូវភូមិសាស្ត្រសាំញ៉ាំ និងតំបន់ទឹកជ្រោះហូរខ្លួលខ្លាញ់របស់ទន្លេមេគង្គ ដោយចាប់ពីខេត្តក្រចេះ ឆ្លងកាត់ខេត្តស្ទឹងត្រែង មកដល់តំបន់ល្បាក់ខោន ប្រទេសឡាវ ដែលទាំងនេះបង្កើននូវឧបសគ្គយ៉ាងខ្លាំងក្នុងការធ្វើដំណើរដោយនាវា តាមដងទន្លេទាំងមូល (Ojendal, 2000) ។ ក្រុមស្រាវជ្រាវទន្លេមេគង្គបារាំងដែលបានចាប់ផ្តើមនៅឆ្នាំ១៨៦៦ ហើយត្រូវបញ្ចប់ពីរឆ្នាំក្រោយមក ត្រូវបានចាត់ទុកជាកិច្ចប្រឹងប្រែងមួយអស្ចារ្យនៃសម័យកាលរុករកប្រកបដោយវីរភាព។ ទោះបីមកដល់ពេលនេះ ការពិតនៃទន្លេមេគង្គដែលបាន រុករកដោយក្រុមជនជាតិបារាំង គឺសាកសមនឹងទទួលនូវកិត្តិយស នៃការស្រាវជ្រាវរបស់ពួកគេណាស់។

ផ្លូវទឹកដ៏សំខាន់មួយទៀត គឺជាច្រករវាងទន្លេសេកុង និងមេគង្គ។ ផ្លូវទឹកនេះ អាចធ្វើនាវាចរបានរវាងប្រទេសឡាវ និងកម្ពុជាដោយផ្តល់នូវជម្រើសឆ្លងកាត់ជាលក្ខណៈអន្តរជាតិ បើប្រៀបធៀបនឹងទន្លេមេគង្គ (Osborne, 2000)។

នៅឆ្នាំ ១៨៩៥ កម្ពុជាបានបាត់បង់តំបន់ អាតាពឺ សៀមប៉ាង ស្ទឹងត្រែង ជាដំបូងទៅឱ្យកូសាំងស៊ីន ហើយបន្ទាប់មកប្រទេសឡាវ (Colm,1999) ។ នៅឆ្នាំ១៩៥៣ ស្របពេលការត្រួតត្រាពីអាណានិគមបារាំងត្រូវបានបញ្ចប់ ខេត្តស្ទឹងត្រែង និងរតនគិរី ត្រូវបានប្រគល់ឱ្យប្រទេសកម្ពុជាវិញ។

## និន្នាការនយោបាយ : ការកើតឡើង នៃរដ្ឋទំនើប

បន្ទាប់ពីការទទួលឯករាជ្យពីប្រទេសបារាំងនៅឆ្នាំ១៩៥៣ ប្រទេសកម្ពុជាបានស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្តេចនរោត្តមសីហនុ។ ក្នុងអំឡុងពេលនេះ ភូមិភាគឥសាន្តប្រទេសកម្ពុជា ត្រូវបានចាត់ទុកថាមានចំនួនប្រជាជនតិចរស់នៅរកេតរកូត ហើយតម្រូវការធនធានធម្មជាតិក៏មានកម្រិតទាបផងដែរ(Sovathana, 2004)។ ស្របពេលនោះ មានប្រព័ន្ធគ្រប់គ្រងឃុំ និងខេត្តរបស់រដ្ឋជាច្រើនត្រូវបានបង្កើតឡើង។ នៅឆ្នាំ១៩៥៩ ខេត្តរតនគិរី ត្រូវបានបង្កើតឡើងដែលធ្លាប់ជាតំបន់មួយភាគខាងកើតនៃខេត្តស្ទឹងត្រែង ហើយនៅឆ្នាំ១៩៦០ខេត្តមណ្ឌលគិរី ក៏ត្រូវបានបង្កើតឡើង ដែលធ្លាប់ជាតំបន់មួយស្ថិតនៅភាគខាងកើតនៃខេត្តក្រចេះ។ នៅតាមភូមិការអនុវត្តបែបប្រពៃណី បានដឹកនាំនូវការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយភាពរិតត្បិត។ ពេលនោះធនធានធម្មជាតិមានច្រើនសន្ធឹកសន្ធាប់ ប៉ុន្តែរាជរដ្ឋាភិបាលបានបង្ខំសហគមន៍ជនជាតិភាគតិចឱ្យតាំងលំនៅថ្មី និងលើកទឹកចិត្តអ្នកស្រុកក្រោម ឱ្យមករស់នៅតំបន់ខ្ពង់រាបភាគឥសាន្តប្រទេសកម្ពុជា។ ស្របពេលនោះ គោលនយោបាយរបស់រាជរដ្ឋាភិបាល គឺផ្តោតជាចម្បងទៅលើការប្រែក្លាយក្រុមកុលសម្ព័ន្ធ ឱ្យមករស់នៅក្នុងសង្គមទំនើប ដោយស្ថិតនៅក្រោមការត្រួតត្រាដែនដីជាតិតែមួយ។ ការធ្វើសមាហរណកម្មបែបនេះ ត្រូវបានអនុវត្តឡើងតាមរយៈប្រព័ន្ធអប់រំរដ្ឋ ដោយបង្រៀនក្រុមកុលសម្ព័ន្ធឱ្យស្លៀកពាក់ ដូចជនជាតិភាគច្រើន(ខ្មែរ) ដាំដំណាំយុទ្ធសាស្ត្រ និងការចូលរួមទីផ្សារសេដ្ឋកិច្ច។

ជាទូទៅ ប្រជាជនមានជីវិតរស់នៅដោយសន្តិភាព និងមានជីវភាពរុងរឿង នៅក្នុងរបបសង្គមរាស្ត្រនិយម ដែលប្រការទាំងនេះ បានស្ថិតនៅក្នុងការចងចាំរបស់ជនជាតិខ្មែរភាគច្រើន។ ស្របពេលនោះ ការពង្រីក និងការលើកកំពស់ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ គឺមានគោលដៅធំក្នុងការការពារព្រំដែនជាតិ ពីការឈ្លានពានរបស់ប្រទេសជិតខាង ជាជាងការដកហូតយកធនធានធម្មជាតិ។

ជាក់ស្តែង នៅភូមិអូរស្វាយ ក្នុងតំបន់រ៉ាមសារ ត្រូវបានបង្កើតឡើងនៅថ្ងៃទី១ មករា ឆ្នាំ១៩៦០។ ពេលនោះមានប្រជាជនប្រមាណ៣០០គ្រួសារ ដែលភាគច្រើនជាយោធាមករស់នៅការពារព្រំដែនប្រទេស។ ប្រជាជនរស់នៅក្នុងភូមិអូរស្វាយ អាចហៅថាអ្នកស្រុកក្រោម ភាគច្រើនជាជនជាតិខ្មែរ ជាពិសេសជាគ្រួសារទាហានចូលនិវត្តន៍ មកពីខេត្តតាកែវ កំពត ស្វាយរៀង ព្រៃវែង កំពង់ស្ពឺ កំពង់ចាម កណ្តាល និងក្រចេះ ដោយរួមទាំងខ្មែរនៅកម្ពុជាក្រោមផងដែរ (Try and Vannara, 2004)។ បច្ចុប្បន្ន អូរស្វាយ[៤] គឺជាឃុំមួយក្នុងចំនោម

[៤] ឃុំនេះ ត្រូវបានបង្កើតឡើងដំបូងគេបន្ទាប់ពីប្រទេសកម្ពុជាទទួលឯករាជ្យពីបារាំង។ មានអ្នកមកតាំងលំនៅថ្មីផងដែរ នៅឃុំសាមគ្គី បន្ទាប់ពីកងទ័ពវៀតណាមត្រួតត្រាប្រទេសកម្ពុជា។ ភូមិមួយចំនួនទៀតក្នុងតំបន់រ៉ាមសារ មានការរស់នៅតាំងពីយូលង់ណាស់មក ហើយពីសហគមន៍មូលដ្ឋាន ដូចជា កោះស្នែង និងព្រះរំកិល (ដែលគេជឿថា បានមករស់នៅជាងពាសតវត្សរ៍មកហើយ)។ ចម្រុះភាព នៃជនជាតិ ក្នុងតំបន់រ៉ាមសារ គឺមិនសូវជាធំដុំទេ ភាគច្រើនជាជនជាតិខ្មែរ និងឡាវ ដែលរស់នៅលាយលំគ្នា ហើយភាសារជនជាតិទាំងពីរត្រូវបាន ប្រើប្រាស់ប្រចាំថ្ងៃ។ ក្រុមកុលសម្ព័ន្ធគួយត្រូវបានគេជឿថា រស់នៅក្នុងស្រុកថាឡាបរិវ៉ាត់ ប៉ុន្តែមិនទៅជិត តំបន់រ៉ាមសារទេ។

ឃុំទាំង៤ ក្នុងតំបន់វ៉ាមសារ ដែលមានភូមិចំនួន៥ : កោះព្នៅ អូរស្វាយ អូររុន វ៉ិនសៀន និងភូមិកោះហិប ដែលមានគ្រួសារសរុបចំនួន៤៩០ និងប្រជាជនចំនួន២៥៥៤។ ពួកគេភាគច្រើន បានតាំង លំនៅតាមដងទន្លេមេគង្គ។

តែទោះជាយ៉ាងណា នយោបាយប្រទេសកម្ពុជាពុំមានស្ថេរភាព ដោយសារជម្លោះកើតឡើងរវាងសហរដ្ឋអាមេរិក និងតំបន់គ្រប់គ្រងរបស់រុស្សីក្នុងអំឡុងពេលសង្គ្រាមត្រជាក់។ កត្តានេះ បានជះឥទ្ធពលទៅលើសេចក្តីសម្រេចចិត្តរបស់ស្តេចក្នុងទសវត្សរ៍ទី៦០ ក្នុងការឆ្លើយតបនិងតម្រូវការនយោបាយមួយខ្ចីដោយរក្សានូវអព្យាក្រឹតភាពរបស់កម្ពុជា (Sovathana, 2004)។ តែក្រោយមក ប្រទេសកម្ពុជា បានជួបប្រទះនូវសង្គ្រាមស៊ីវិលជាច្រើនរបប។

របប លុន នុល បានចាប់ផ្តើមពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥។ របបនេះ បានចាប់ផ្តើមឡើងដោយរដ្ឋប្រហារនៅខែមីនា ឆ្នាំ១៩៧០ ដែលដឹកនាំដោយលោកសេនាប្រមុខ លុន នុល ហើយបានដណ្តើមរាជ ពីស្តេចនរោត្តមសីហនុ ក្នុងខណៈពេលដែលព្រះអង្គគង្គនៅក្រៅប្រទេស។ ឧត្តមសេនី លុន នុល បានបង្កើតរបបមួយឈ្មោះថាសាធារណៈរដ្ឋខ្មែរ។ ប៉ុន្តែ អំឡុងពេលនេះមានការបះបោរពីប្រជាជនប្រឆាំងនឹងឧត្តមសេនី លុន នុល ដោយចង់ទាមទារនូវការត្រឡប់មកវិញនូវរបប សង្គមរាស្ត្រនិយម (Kiernan et al, 1982)។ ការបះបោរនេះ ត្រូវបានដឹកនាំដោយក្រុមឧទ្ទាមខ្មែរក្រហម ដែលមាន មូលដ្ឋាន នៅបណ្តាខេត្តភូមិភាគឥសាន្តប្រទេស ដោយរួមទាំងខេត្តផ្សេងៗទៀត ដូចជា តាកែវ កំពត កំពង់ចាម និងកំពង់ធំ ជាដើម។ ពួកឧទ្ទាមខ្មែរក្រហម បានគ្រប់គ្រងតំបន់ខេត្តរតនគីរី និងស្រុកសៀមប៉ាង នៃខេត្តស្ទឹងត្រែង ស្របពេលដែល រដ្ឋាភិបាល លុន នុល កំពុងស្ទុះស្ទារកសាងផ្លូវនៅតំបន់ទាំងនេះ ដើម្បីពង្រឹកអំណាចពួកគេ(Sovathana, 2004)។

ឆ្លងកាត់អំឡុងពេលនេះ របបលុន នុល បានទទួលនូវកេរ្តិ៍ឈ្មោះអាក្រក់ពីប្រជាជន។ មន្ត្រីជាន់ខ្ពស់មួយចំនួនបានក្លាយជាឈ្មួញកាប់ឈើ ហើយបានរំលោភលើច្បាប់សហគមន៍មូលដ្ឋាន ដោយដកហូតយកប្រភេទឈើប្រណិតៗពីក្នុងព្រៃ។ សត្វព្រៃជាច្រើនប្រភេទ ដូចជា ក្តាន់ និងគោព្រៃ ត្រូវបានសំលាប់ដោយពួកទាហានធ្វើជាចំណីអាហារ។ សហគមន៍ជនជាតិមួយចំនួនត្រូវបានរើលំនៅដ្ឋាន ទ្រព្យសម្បត្តិមួយចំនួនត្រូវបានរិបអូស និងអំពើព្រៃផ្សៃក៏ត្រូវបានអនុវត្តប្រឆាំងនឹងប្រជាជនមូលដ្ឋានផងដែរ (Zweers et al, 2003)។

នៅឆ្នាំ ១៩៧៣ ទាហានសហរដ្ឋអាមេរិក បានចាប់ផ្តើមទម្លាក់គ្រាប់បែកដ៏សន្ធឹកសន្ធាប់មកលើតំបន់ភូមិភាគឥសាន្តតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម និងតាមដងទន្លេមេគង្គដោយរួមទាំងដែនានារបស់វាក្នុងខេត្តស្ទឹងត្រែង។ ទង្វើនេះបានបំផ្លាញដល់សហគមន៍មូលដ្ឋាន និងធនធានធម្មជាតិ។ រដ្ឋាភិបាលលុន នុល បានបាត់បង់អំណាចរបស់ខ្លួនបន្តិចម្តងៗ ក្នុងការគ្រប់គ្រងតំបន់ខ្ពង់រាបភូមិភាគឥសាន្ត។ ស្របពេលនោះក្រុមអ្នកតស៊ូបានគ្រប់គ្រងទឹកដីមួយចំនួន ហើយបានជ្រើសរើសជនជាតិភាគតិចឱ្យចូលបំរើនៅក្នុងជួរកងទ័ពរបស់ខ្លួន ដែលជាទង្វើមួយមានការគាំទ្រយ៉ាងខ្លាំងក្នុងចំនោមប្រជាជនមូលដ្ឋាន។

រដ្ឋាភិបាលខ្មែរក្រហម ដែលចាប់ផ្តើមឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩ ត្រូវបានគេស្គាល់ថាជារបបមួយហាមឃាត់នូវការអនុវត្តវប្បធម៌ ប្រពៃណី។ ប៉ុល ពត (Politic Potential Patriot) គឺជាឈ្មោះដែលបានផ្តល់ឱ្យមេដឹកនាំខ្មែរក្រហម សាឡុតស បានផ្តួលរំលំរបបយោធា ឧត្តមសេនី លុន នុល នៅខែមេសា ឆ្នាំ១៩៧៥ ហើយ

បានបង្កើតនូវរដ្ឋាភិបាលថ្មីមួយដែលមានឈ្មោះថា កម្ពុជាប្រជាធិបតេយ្យ។ នៅពេលនោះ រដ្ឋាភិបាលថ្មីនេះបានលុបចោលនូវស្ថាប័ន និងរហដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់។ លទ្ធិបែបថ្មីរបស់របបកម្ពុជាប្រជាធិបតេយ្យ បានណែនាំនូវកំណែទម្រង់កសិកម្មនៅតាមជនបទដោយបង្ខំប្រជាជនភាគច្រើនឱ្យជម្លៀសពីទីក្រុង ហើយដាក់ឱ្យធ្វើការនៅក្នុងវិស័យកសិកម្ម។ ជារួម គោលនយោបាយទូទៅក្នុងរបបខ្មែរក្រហម គឺឆ្ពោះទៅរកការអភិវឌ្ឍន៍កសិកម្ម ជាពិសេសផលិតផលស្រូវដែលមានប្រព័ន្ធស្រោចស្រព។ ការអនុវត្តន៍កសិកម្មពរនេចរ និងវប្បធម៌អន្តោគ្រាម មិនត្រូវបានយកចិត្តទុកដាក់។ ដោយការប្រកាន់យករបបឃោរឃៅ និងការរំលោភប្រឆាំងនឹងជនជាតិវៀណាម របបនេះត្រូវបានបញ្ចប់ទៅវិញយ៉ាងខ្លី។

របប ហេង សំរិន ដែលចាប់ផ្តើមនៅទសវត្សរ៍ទី៨០ ត្រូវបានគេស្គាល់ថាជាការចាប់ផ្តើមនូវការបាត់បង់ធនធានធម្មជាតិ។ នៅឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានឈ្លានពានប្រទេសកម្ពុជា ហើយបានលើកបន្តុករដ្ឋាភិបាលថ្មីបែបសង្គមនិយមដែលមានឈ្មោះថា សាធារណៈរដ្ឋប្រជាមានិតកម្ពុជា។ កងទ័ពវៀតណាមបានគ្រប់គ្រងប្រទេសនេះ រហូតដល់ឆ្នាំ១៩៨៧។ រដ្ឋាភិបាលថ្មីនេះ ត្រូវបានដឹកនាំដោយលោក ហេងសំរិន។ តែទោះជាយ៉ាងណា តំបន់ភូមិភាគឥសាន្ត ជាពិសេស រតនគីរី ស្ទឹងត្រែង និងមណ្ឌលគីរីគឺបានកាត់ផ្តាច់ស្ទើរតែទាំងស្រុងពីការគ្រប់គ្រងរបស់រដ្ឋាភិបាលមជ្ឈឹម។ តំបន់ទាំងនេះ ត្រូវបានទុកឱ្យនៅឯកោរដោយសារបញ្ហាអសន្តិសុខ និងផ្លូវលំបាក។ លើសពីនេះទៅទៀត ព្រឹត្តិការណ៍នៅក្នុងអំឡុងពេលនេះបានបង្ហាញឱ្យដឹងថា អន្តរាគមន៍របស់រដ្ឋាភិបាលទៅលើជីវិតអ្នកស្រុកភ្នំ បានធ្វើឱ្យចុះអត់ថយនូវប្រព័ន្ធគ្រប់គ្រងធនធានធម្មជាតិ និងផលប៉ះពាល់យ៉ាងខ្លាំងទៅលើវប្បធម៌-ប្រពៃណីរបស់ពួកគេថែមទៀត។

ចំពោះរដ្ឋាភិបាលបច្ចុប្បន្ន មានឈ្មោះថា រាជរដ្ឋាភិបាលកម្ពុជា ដែលមានគោលបំណងធំប្រឆាំងនឹងភាពក្រីក្រនៅតាមតំបន់ដាច់ស្រយ៉ាល។ បន្ទាប់ពីសង្គ្រាមស៊ីវិលត្រូវបានបញ្ចប់ប្រទេសកម្ពុជាបានក្លាយជាប្រទេសដែលក្រជាងគេបំផុតនៅលើពិភពលោក ហើយក៏ជាប្រទេសដែលមានអត្រាភាពក្រីក្រជាងគេបំផុតនៅទ្វីបអាស៊ីដែរ។ កត្តានេះបានឆ្លុះឱ្យឃើញនូវការទើបងើបចេញពីសង្គ្រាមរ៉ាំរ៉ៃ និងការបាត់បង់លំនៅដ្ឋានអស់រយៈពេល៣០ឆ្នាំ។ គេបានប៉ាន់ប្រមាណថាប្រជាជនចំនួន៨៥% ពឹងផ្អែកលើកសិកម្មដើម្បីចិញ្ចឹមជីវិតនោះ គឺជាអ្នកទទួលរងនូវឧប្បត្តិហេតុ នៃភាពក្រីក្រដ៏ធំបំផុត។

បន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ តុលា ឆ្នាំ១៩៩១ ប្រទេសកម្ពុជាបានបោះជំហានយ៉ាងធំដោយបានប្រែក្លាយប្រព័ន្ធគ្រប់គ្រងរដ្ឋបែបសង្គមនិយម មកជារបបទីផ្សាសេដ្ឋកិច្ច និងការផ្លាស់ប្តូរប្រព័ន្ធនយោបាយគណបក្សតែ១ មកប្រព័ន្ធនយោបាយគណបក្សចំរុះ (Peou, 2000) ។ ប្រទេសកម្ពុជា បានចូលរួមជាមួយអង្គការពាណិជ្ជកម្ម អន្តរជាតិ និងបានអនុវត្តគោលនយោបាយគាំទ្រសេដ្ឋកិច្ចទីផ្សារនៅទូទាំងប្រទេស។ ជាលទ្ធផល រដ្ឋាភិបាលកម្ពុជាបានជួបប្រទះនឹងការផ្លាស់ប្តូរដ៏គំហុក ដោយចាប់ផ្តើមពីភាពក្រីក្រឆ្ពោះទៅកាន់ភាពរីកចំរើន នៅក្នុងវិស័យមួយចំនួនតាមរយៈកំណើនសេដ្ឋកិច្ចដ៏គំហុក។

នៅក្នុងខេត្តស្ទឹងត្រែង ការផ្លាស់ប្តូរថ្នាក់ជាតិទាំងនេះ បាននាំមកនូវឱកាសដើម្បីអភិវឌ្ឍជាច្រើន។ ការទាក់ទាញនៃទេសភាពនៅតាមដងទន្លេមេគង្គនៅក្នុងខេត្ត ដោយរួមមាន បណ្តាកោះ អន្លង់ជ្រៅ សត្វផ្សោតទន្លេមេគង្គ សកម្មភាពនេសាទ និងព្រៃលិចទឹក និងភាពសំបូរបែបនៃបក្សីទឹករបស់ទន្លេជាច្រើន។ ទាំងនេះ

គឺជាចំនុចទាក់ទាញនូវវិស័យទេសចរណ៍ប្រកដដោយសក្តានុពល។

ជាទូទៅអ្នកទេសចរណ៍ បានមកទស្សនាខេត្តស្ទឹងត្រែងតាមរយៈការរៀបចំផ្ទាល់ខ្លួន ដោយសារពុំទាន់មានការរៀបចំនូវវិស័យទេសចរណ៍បែបឧស្សាហ៍កម្ម ប៉ុន្តែវាជាសញ្ញាណនៃការកើនឡើងនូវសមាហរណកម្មតំបន់នេះឱ្យចូលទៅនឹងទីផ្សារទេសចរថ្នាក់តំបន់។ អ្នកទេសចរណ៍ភាគច្រើនជាជនបរទេស បានឆ្លងកាត់ ប្រទេ-សឡាវ និងទីក្រុងភ្នំពេញដែលជាផ្នែកមួយនៃការធ្វើដំណើរជុំវិញទន្លេមេគង្គ ឬប្រចាំឧបទ្វីបអាស៊ីអាគ្នេយ៍របស់ពួកគេ។ ដោយគួបផ្សំនូវចំនុចនេះ និងកត្តាផ្សេងៗដែលបានលើកឡើងខាងលើ អាចសន្និដ្ឋានបានថា ប្រជាជនដែលរស់នៅតាមដងទន្លេ និងដៃនានារបស់ទន្លេ គឺកំពុងតែមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយនឹងប្រព័ន្ធទីផ្សារសេដ្ឋកិច្ច ទាំងនៅក្នុងប្រទេស និងទូទាំងតំបន់។

សារៈសំខាន់ នៃសេដ្ឋកិច្ចបែបគ្រប់គ្រាន់នៅទីរួមខេត្តស្ទឹងត្រែង បានតម្រូវឱ្យសហគមន៍មូលដ្ឋានចូលរួមក្នុងប្រព័ន្ធដោះដូរបែបទីផ្សារមួយចំនួន ដើម្បីទទួលបាននូវគ្រឿងបរិភោគចាំបាច់មួយចំនួនជាពិសេស អង្ករ បន្លែ រូបិយប័ណ្ណ និងផលិត ផលដ៏ទៃទៀត ដែលពួកគេមិនអាចផលិតដោយខ្លួនឯង។ បើយោងទៅតាមនិន្នាការទីផ្សារបច្ចុប្បន្ន អ្នកនេសាទបានភ្ជាប់សហគមន៍ដាច់ស្រយាលជាច្រើនទៅនឹងទីផ្សារខាងក្រៅ ហើយដែលទង្វើនេះមានសារៈសំខាន់ក្នុងការអភិវឌ្ឍន៍ទំនាក់ទំនងទីផ្សារ។

ដូចបានបកស្រាយខាងដើម ទន្លេទាំងឡាយ និងប្រជាជនដែលរស់នៅខេត្តស្ទឹងត្រែង គឺពុំបានស្ថិតនៅភាពឯកោរទៅនឹងពិភពខាងក្រៅទេ។ និន្នាការនៃការអភិវឌ្ឍន៍ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធនៅក្នុងខេត្ត បានក្លាយទៅជាអាទិភាពខ្ពស់បំផុត នៃការពង្រីក និងកំណើនសេដ្ឋកិច្ច។ ដោយបានទទួលកម្ចីគ្មានការប្រាក់ពីរដ្ឋាភិបាលនៃសារធារណៈរដ្ឋប្រជាមានិតចិន គំរោងស្ថារឡើងវិញនូវផ្លូវជាតិលេខ៧ ដោយចាប់ពីពីខេត្តក្រចេះមកកាន់ខេត្តស្ទឹងត្រែង ឆ្ពោះទៅកាន់ព្រំប្រទល់ឡាវ (១៨៧គ.ម) គឺកំពុងតែដំណើរការសាងសង់។ គំរោងនេះត្រូវបានគេយល់ថា មានសារៈសំខាន់សំរាប់បណ្តាខេត្តនៅភាគឥសាន្តប្រទេសកម្ពុជា។ ម្យ៉ាងទៀត ការកសាងផ្លូវនេះក៏ជាផ្នែកមួយនៃផ្លូវជាតិអាស៊ាន(A.11) និងជាផ្លូវជាតិនៃបណ្តាប្រជាជាជាតិអាស៊ី អាគ្នេយ៏(AH.11) ដោយភ្ជាប់ពីទីក្រុងយុនមីង (ប្រទេសចិនភាគខាងត្បូង) ឆ្ពោះទៅកាន់កំពង់ផែរអន្តរជាតិក្រុងព្រះសីហនុ ដោយឆ្លងកាត់ប្រទេសវៀតណាម និងឡាវ។

ផ្លូវថ្មល់នេះ នឹងបំរើផលប្រយោជន៍សេដ្ឋកិច្ចមិនត្រឹមតែប្រចាំថ្នាក់តំបន់ទន្លេមេគង្គនោះទេ គឺថែមទាំងប្រចាំតំបន់ អាស៊ីអាគ្នេយ៏ ទាំងមូលផងដែរ។ ការស្តារ និងការកែលំអ នៃផ្លូវជាតិផ្នែកនេះ នឹងជួយសម្រួលនូវមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ សំរាប់ទំនិញ និងមនុស្ស ដែលជាវិភាគទានក្នុងការលើកកំពស់នូវសេដ្ឋកិច្ចប្រចាំតំបន់ តាយរយៈការសន្សំពេលវេលា និងតំលៃធ្វើដំណើរ។ នេះគឺជាកត្តចម្បង ក្នុងការបន្តអភិវឌ្ឍន៍ខេត្តស្ទឹងត្រែង។

## សន្ទេប

ដោយមានចំនុចប្រសព្វ រវាងទន្លេមេគង្គ ជាមួយនឹងដៃនានារបស់វា ក្នុងខេត្តស្ទឹងត្រែង វាមិនត្រឹមបង្កើត

ឱ្យមាននូវ ធនធានធម្មជាតិដ៏មហាសាលសំរាប់មនុស្ស និងប្រព័ន្ធអេកូឡូស៊ីរបស់បច្ចានោះទេ គឺថែមទាំងបានបង្កើតបានជាទីតាំង យុទ្ធសាស្រ្តចម្បងមួយសំរាប់ការតាំងលំនៅ និងទំនាក់ទំនងពាណិជ្ជកម្មរបស់មនុស្សជាតិ។ តាំងពីដើមមក ទន្លេមេគង្គបានក្លាយជាកន្លែងជួបជុំដ៏សំខាន់ នៅពេលដែលយើងនិយាយអំពីការធ្វើបំលាស់របស់មនុស្ស ពីជើងមកត្បូងនៃឧបទ្វីអាស៊ីអាគ្នេយ៏។ វាជាតំបន់មួយ ដែលពោរពេញទៅដោយជាតិសាសន៍ចំរុះ ព្រោះតំបន់នេះធ្លាប់ទទួលរងនូវការធ្វើបំលាស់ទីពីជនជាតិផ្សេងៗ ដែលពេលនោះជនជាតិណាខ្លាំងជាង ជាអ្នកគ្រប់គ្រងតំបន់ដែលមានតំលៃ និងសំបូរទៅដោយធនធានធម្មជាតិ ហើយបណ្តេញអ្នកស្រុកដើម ឱ្យទៅរស់នៅតំបន់ដែលមិនសូវមានធនធាន ឬទៅរស់នៅតំបន់ភ្នំ។

ចាប់តាំងពីឆ្នាំ១៩៧០កន្លងមក ខេត្តស្ទឹងត្រែងបានឆ្លងកាត់នូវភ្លើងសង្គ្រាម និងនយោបាយ នៃថ្នាក់តំបន់។ អំពើបង្កសង្គ្រាមទាំងនេះបានធានាថា ផែនការអភិវឌ្ឍន៍ដែលបានគ្រោងក្នុងទសវត្សរ៍ទី ៥០ និង៦០ គឺមិនអាចបង្កើតឱ្យមានផ្លែផ្កាបានទេ។ ប្រទេសមហាអំណាចដែលមានលទ្ធិផ្ទុយគ្នា បានលុកលុយប្រទេសកម្ពុជា ហើយបានបង្កើតឱ្យមានសង្គ្រាមស៊ីវិល តាំងពីទសវត្សរ៍ទី៧០ ដល់ទសវត្សរ៍ទី៩០។ ក្នុងករណីនេះ តំបន់ភូមិភាគឥសាន្តប្រទេសកម្ពុជា និងប្រជាជនរបស់ខ្លួន ត្រូវបាន កាត់ផ្តាច់ពីប្រទេសទាំងមូល។

តែទោះជាយ៉ាងណា បន្ទាប់ពីមានកិច្ចចារសន្តិភាពក្រុងប៉ារីស ថ្ងៃទី២៣ តុលា ឆ្នាំ១៩៩១មក ប្រទេសកម្ពុជា បានធ្វើការបោះជំហានឆ្ពោះទៅមុខ ដោយធ្វើការកែប្រែពីការគ្រប់គ្រងរដ្ឋបែបសង្គមនិយម មកកាន់របបទីផ្សារសេដ្ឋកិច្ច និងការ កែប្រែរបបនយោបាយដែលមានគណបក្សតែមួយ មកកាន់គណបក្សចំរុះ។ នៅឆ្នាំ១៩៩៣ អាជ្ញាធរបណ្តោះអាសន្ន របស់អង្គ ការសហប្រជាជាតិ ប្រចាំកម្ពុជា (UNTAC) បានគាំទ្រការបោះឆ្នោតថ្នាក់ជាតិប្រកបដោយលទ្ធិប្រជាធិបតេយ្យ។ ចាប់ពី ពេលនោះមក ប្រទេសកម្ពុជាបានបង្កើននូវស្ថេរភាពសង្គម និងការតភ្ជាប់តំបន់ជាច្រើននៅក្នុងប្រទេស។ ប្រទេសកម្ពុជាបាន ចូលរួមពាណិជ្ជកម្មអន្តរជាតិ និងអនុវត្តការគាំទ្រគោលនយោបាយសេដ្ឋកិច្ចទីផ្សារនៅទូទាំងប្រទេស។ ជាលទ្ធផលរដ្ឋាភិបាល កម្ពុជា បានជួបប្រទះនូវការផ្លាស់ប្តូរដ៏គំហុក ដោយចាប់ផ្តើមធ្វើដំណើរចេញពីភាពក្រីក្រ មកកាន់ភាពរីកចំរើន នៅក្នុងវិស័យ មួយចំនួនក្នុងស្ថានភាពតក់ក្រហល់ នៃកំណើនសេដ្ឋកិច្ច។ ស្របពេលនោះ គំរោងអភិវឌ្ឍន៍ខ្នាតធំ ដូចជាការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានផ្តល់អាទិភាពខ្ពស់នៅតាមបណ្តាខេត្តភាគឥសាន្តប្រទេសកម្ពុជា ដែលបានដាក់គំនាបយ៉ាងខ្លាំងទៅលើធនធានធម្មជាតិ ដូចជាមច្ឆាជាតិ ព្រៃឈើ ដែលជាប្រភពចម្បងនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចនោះ។

បច្ចុប្បន្ន ខេត្តស្ទឹងត្រែង បានចាប់ផ្តើមនូវយុគសម័យថ្មី នៃការធ្វើសមាហរណកម្ម ទៅក្នុងសង្គម និងសេដ្ឋកិច្ចរបស់ ប្រទេសជាតិទាំងមូល។ នេះ គឺជាអនាគតដែលនឹងនាំមកនូវការផ្លាស់ប្តូរ និងឱកាសដ៏ធំធេងមួយ ប៉ុន្តែវាក៏ជាហានិភ័យមួយ ទាក់ទងនឹងការផ្លាស់ប្តូរផ្នែកបរិស្ថាននៅក្នុងតំបន់រ៉ាមសារ និងតំបន់ផ្សេងៗទៀតនៅក្នុងខេត្តផងដែរ។

# ជំពូក៣ៈ ប្រជាជន និងជីវភាពរស់នៅ

## ចំនួនប្រជាជន និងការធ្វើចំណាស់ទី

នៅឆ្នាំ១៩៩៩ វិទ្យាស្ថានស្ថិតិជាតិបានបង្ហាញឱ្យដឹងថា ខេត្តស្ទឹងត្រែងមានគ្រួសារចំនួន១៤.១២៦ មានប្រជាជនសរុបចំនួន៨១.០៧៤នាក់ (សមាជិកចំនួន៥,៦នាក់/គ្រួសារ) ដែលមានស្ត្រីស្មើនឹងចំនួន៥០.៥% នៃចំនួនប្រជាជនសរុប។ ដង់ស៊ីតេប្រជាជនក្នុងខេត្ត គឺស្មើនឹង៧នាក់/គ.ម២ ដែលចំនួននេះទាបជាងខ្លាំង បើធៀបទៅនឹងដង់ស៊ីតេថ្នាក់ជាតិចំនួន ៦៤នាក់/គ.ម២។

ដោយសារខេត្តនេះមានចំនួនប្រជាជនតិច និងសំបូរទៅដោយធនធានធម្មជាតិ ហេតុដូច្នេះអត្រាអ្នកចំណូលស្រុកមានកម្រិតខ្ពស់។ ដូចបានបង្ហាញនៅក្នុងតារាងស្រង់ចំនួនប្រជាជនក្នុងឆ្នាំ១៩៩៨ គឺមានអត្រាប្រជាជនចំនួន១៩.៤% ជាអ្នកចំណូលស្រុកមកពីខេត្តផ្សេងៗ។ នៅឆ្នាំ២០០៣ ចំនួនប្រជាជននៅក្នុងខេត្តបានកើនឡើងដល់ចំនួន៩១៧៩៥នាក់ ដែលក្នុងស្រុកស្ទឹងត្រែង និងស្រុកថាឡាបរិវ៉ាត់ មានប្រជាជនស្មើនឹង ៥៧.៣% នៃប្រជាជនទូទាំងខេត្ត។ របាយប្រជាជនតាមស្រុកនីមួយៗ គឺត្រូវបានបកស្រាយនៅក្នុងតារាង ៣.១ ខាងក្រោម។

**តារាង ៣.១ របាយប្រជាជនតាមស្រុកនីមួយក្នុងខេត្តស្ទឹងត្រែង**

| ស្រុក | ចំនួនគ្រួសារ | ចំនួនប្រជាជន | | | អត្រាភេទ (ចំនួន បុរស/ ១០០ស្ត្រី ) | អត្រាភាគរយ |
|---|---|---|---|---|---|---|
| | | ស្ត្រី | បុរស | ចំនួនសរុប | | |
| សេ សាន | ២.៧៥៦ | ៦.៣៤២ | ៦.១៣១ | ១២.៤៧៣ | ៩៦.៧ | ១៣.៦ |
| សៀម បូក | ២.២៣១ | ៥.៨០៨ | ៥.៤៤១ | ១១.២៤៩ | ៩៣.៧ | ១២.៣ |
| សៀម ប៉ាង | ២.៨១៨ | ៨.០៩៦ | ៧.៤០៦ | ១៥.៥០២ | ៩១.៥ | ១៦.៩ |
| ស្ទឹងត្រែង | ៤.៩៣០ | ១៤.១២៥ | ១៣.៨២១ | ២៧.៩៤៦ | ៩៧.៨ | ៣០.៤ |
| ថាឡាបរិវ៉ាត់ | ៤.៨៧៨ | ១២.៨៦៥ | ១១.៧៦០ | ២៤.៦២៥ | ៩១.៤ | ២៦.៨ |
| សរុប | ១៧.៦១៣ | ៤៧.២៣៦ | ៤៤.៥៥៩ | ៩១.៧៩៥ | ៩៤.៣ | ១០០% |

**ប្រភព :** មន្ទីរផែនការខេត្ត ឆ្នាំ២០០៣

ប្រជាជនភាគច្រើនក្នុងខេត្តស្ទឹងត្រែងគឺពុំបានទទួលការអប់រំជ្រៅជ្រះ ព្រោះជាខេត្តនៅតំបន់ជនបទដាច់ស្រយ៉ាល។ ចំនួនភាគរយនៃអក្ខរជន ដែលមានអាយុចាប់ពី៧ឆ្នាំឡើងទៅ គឺមានចំនួន៤៨.៤%។ យោងតាមការ

វិភាគកម្រិតអប់រំ នៃចំនួនអក្ខរជនទូទាំងខេត្តបានឱ្យដឹងថា មានប្រជាជនចំនួន៦៦.២% មិនបានរៀនចប់ថ្នាក់បឋមសិក្សា។ គឺមានតែចំនួន០.៣% ទេ ដែលបានបញ្ចប់ថ្នាក់មធ្យមសិក្សាកម្រិត២ (NIS, 1999)។

ចំពោះប្រជាជនរស់នៅក្នុងតំបន់រ៉ាមសារ (តារាង៣.២) បើយោងតាមទិន្នន័យភូមិដែលបានអនុវត្តឡើងដោយក្រុមការងារដឹកនាំដោយកម្មវិធីសិលាឆ្នាំ២០០៣ បានបង្ហាញឱ្យដឹងថា ចំនួនអ្នកដែលមិនចេះអក្សរ គឺមានកម្រិតខ្ពស់។ មានស្រុកចំនួនពីរ ដែលស្ថិត នៅក្នុងតំបន់រ៉ាមសារ គឺស្រុកស្ទឹងត្រែង និងថាឡាបរិវ៉ាត់។ នៅស្រុកស្ទឹងត្រែងមានឃុំចំនួន១ (សាមគ្គី) ដែលមាន ភូមិចំនួន៤ មានគ្រួសារចំនួន៦១១ ស្មើនឹងប្រជាជនសរុបចំនួន៣៧៦៩ ក្នុងនោះស្ត្រីចំនួន១៩៧៣ និងប្រុសចំនួន១៧៩៦។ ក្នុងនោះ មានប្រជាជនចំនួន២៧៩នាក់ មិនចេះអក្សរ មានស្ត្រីចំនួន១៥០ ដែលមានអាយុចាប់ពី១៥ ឆ្នាំឡើងទៅ។

ស្រុកថាឡាបរិវ៉ាត់ មានឃុំចំនួន៣: អូរស្វាយ កោះស្នែង និងព្រះរំកិល ដែលស្ថិតនៅក្នុងតំបន់រ៉ាមសារ។ ក្នុងនោះ មានភូមិចំនួន១៧ មានគ្រួសារចំនួន១៧៦៤ ស្មើនឹងប្រជាជនចំនួន៩៤១៧ នាក់ ស្រីចំនួន ៤៩៤៤នាក់។ ចំនួនអ្នកមិនចេះអក្សរ ចំនួន២៦២៣នាក់ ស្រីចំនួន១២៥៥ ដែលមានអាយុចាប់ពី១៥ឡើងទៅ។

**តារាង ៣.២ ឈ្មោះ ឃុំ ភូមិ ចំនួនប្រជាជន និងអ្នកមិនចេះអក្សរ នៅក្នុងតំបន់រ៉ាមសារ**

| ល.រ | ឈ្មោះឃុំ | ឈ្មោះភូមិ | ចំនួនគ្រួសារ | ស្ត្រី | បុរស | សរុប | អនក្ខរជន (អាយុ១៥ ឡើងទៅ) | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | ស្ត្រី | បុរស | សរុប |
| ១ | សាមគ្គី[៥] | ថ្មី | ១៤៦ | ៤៣៨ | ៤០១ | ៨៣៩ | ៣០ | ២៧ | ៥៧ |
| | | ហាងខូ សួន | ២២៧ | ៧៨៩ | ៦៧២ | ១៤៦១ | ៦១ | ៣០ | ៩១ |
| | | កោះ ខនឌិន | ១២០ | ៤១៦ | ៣៩៦ | ៨១២ | ១៨ | ៤៥ | ៦៣ |
| | | ខាំ ផាន់ | ៧៧ | ២០៣ | ២០៥ | ៤០៨ | ៣០ | ២១ | ៥១ |
| | | គីឡូ៨[៦] | ៤១ | ១២៧ | ១២២ | ២៤៩ | ១១ | ៦ | ១៧ |
| **សរុប** | | **៤ ភូមិ** | **៦១១** | **១៩៧៣** | **១៧៩៦** | **៣៧៦៩** | **១៥០** | **១២៩** | **២៧៩** |
| ២ | កោះ ស្នែង | កោះ ស្នែង | ១៧៥ | ៤៩៣ | ៤៦៥ | ៩៥៨ | ១៩៦ | ១៧០ | ៣៦៦ |
| | | កោះ ស្រឡៅ | ៨៥ | ២៣៥ | ២១៥ | ៤៥០ | ៩០ | ៥០ | ១៤០ |
| | | កោះ កី | ៥៨ | ១៦២ | ១៣៩ | ៣០១ | ៣១ | ២២ | ៥៣ |
| | | ជាំ ធំ | ៥៥ | ១៨៥ | ១៩៥ | ៣៨០ | ២៧ | ២៧ | ៥៤ |
| សរុប | | ៤ ភូមិ | ៣៧៣ | ១០៧៥ | ១០១៤ | ២០៨៩ | ៣៤៤ | ២៦៩ | ៦១៣ |

[៥] ឃុំនេះ ស្ថិតនៅក្នុងស្រុកស្ទឹងត្រែង ក្រៅពីនេះ គឺស្ថិតនៅក្នុងស្រុកថាឡាបរិវ៉ាត់។

[៦] ភូមិនេះ មិនស្ថិតនៅក្នុងតំបន់រ៉ាមសារទេ។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៣ | អូរ ស្វាយ | កោះ ឈ្មោ | ៩២ | ២៨៤ | ២៤០ | ៥២៤ | ១៩ | ១០ | ២៩ |
| | | អូរស្វាយ | ១៥៧ | ៤០៤ | ៤០០ | ៨០៤ | ២១ | ១៤ | ៣៥ |
| | | អូរ រុន | ១៣៦ | ៣៦១ | ៣៥៧ | ៧១៨ | ២៥ | ១៨ | ៤៣ |
| | | វ៉ុន សឿន | ៣២ | ៨៦ | ៧៧ | ១៦៣ | ៣៧ | ៣០ | ៦៧ |
| | | កោះ ហិម | ៧៣ | ១៧៤ | ១៧១ | ៣៤៥ | ៣៣ | ៦៣ | ៩៦ |
| **សរុប** | | **៥ ភូមិ** | **៤៩០** | **១៣០៩** | **១២៤៥** | **២៥៥៤** | **១៣៥** | **១៣៥** | **២៧០** |
| ៤ | ព្រះរំកិល | ស្មើ | ១០០ | ២៧០ | ២៨២ | ៥៥២ | ១០៤ | ៨៨ | ១៩២ |
| | | កណ្តាល | ១៧៦ | ៤៤០ | ៣៦៥ | ៨០៥ | ១១០ | ១១៨ | ២២៨ |
| | | កោះ ឈើទាលតូច | ៩៧ | ២៣៥ | ២៣០ | ៤៦៥ | ១០៥ | ៩៨ | ២០៣ |
| | | កោះ ឈើទាលធំ | ៩៦ | ២៩៩ | ២៣០ | ៥២៩ | ១៣១ | ១១៣ | ២៤៤ |
| | | កោះ ល្ហ | ៦៥ | ១៧៩ | ១៦១ | ៣៣០ | ៧៦ | ៨០ | ១៥៦ |
| | | ក្រឡាពាស | ១១៦ | ៤៧១ | ៣៣០ | ៨០១ | ១៤០ | ១២០ | ២៦០ |
| | | ក្រោម | ១៤៨ | ៤០០ | ៣៦៨ | ៧៦៨ | ១១០ | ១១៦ | ២២៦ |
| | | អន្លង់ ស្វាយ | ១០៣ | ២៦៦ | ២៤៨ | ៥១៤ | ១១៣ | ១១៨ | ២៣១ |
| **សរុបរួម** | | **៨ភូមិ** | **៩០១** | **២៥៦០** | **២២១៤** | **៤៧៧៤** | **៨៨៩** | **៨៥១** | **១៧៤០** |

**ប្រភព :** ក្រុមការងារ សីលា (២០០៣)

## បញ្ហាសុខភាព

ព័ត៌មានលំអិត ស្តីពីសុខភាពប្រជាជន រស់នៅក្នុងតំបន់រ៉ាមសារ គឺពុំសូវមានច្រើនទេ។ ហេតុដូច្នេះហើយ ព័ត៌មានត្រូវបានដកស្រង់ពីរបាយការណ៍របស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា(CNMC, 2005a) ដែលបានពិចារណាសុខភាពប្រជាជនរស់នៅតាមដងទន្លេមេគង្គ ចាប់ខេត្តក្រចេះ រហូតដល់ព្រំដែនឡាវ។

ទោះបីជាការផ្គត់ផ្គង់ទឹកមានសារៈសំខាន់បំផុត និងសំបូរហូរហៀរនៅក្នុងតំបន់រ៉ាមសារ ក៏ប្រជាជនរស់នៅតាមដងទន្លេមេគង្គមានឱកាសតិចតួចបំផុតក្នុងការប្រើប្រាស់ទឹកស្អាត។ ប្រជាជនចំនួនតិចជាង២០% មានឱកាសក្នុងការប្រើប្រាស់ និងបរិភោគទឹកស្អាត ហើយដែលគេជឿថា មានគ្រោះថ្នាក់ខ្ពស់នៃការកើតជំងឺដង្កូវពោះវៀន។ ភូមិមួយចំនួនមានអណ្តូងទឹក ហើយភូមិមួយចំនួនទៀតត្រូវការកែលំអនូវស្ថានភាពទាំងនេះ។

ស្រដៀងគ្នានេះដែរ គឺតំបន់ទាំងនេះ មានគ្រោះថ្នាក់ខ្ពស់ទាក់ទងនឹងជំងឺគ្រុនចាញ់ នៅក្នុងប្រទេសកម្ពុជា។ ជំងឺគ្រុនចាញ់ តែងតែកើតឡើងនៅតំបន់ខ្ពង់រាប ដែលនៅឆ្ងាយពីទន្លេមេគង្គ។ នេះគឺជាទំនាក់ទំនងដ៏ខ្លាំងមួយទាក់ទងនឹងការកើតឡើង រវាងជំងឺគ្រុនចាញ់ និងភាពក្រីក្រ។ អ្នកក្រ ពុំមានលទ្ធភាពទប់ស្កាត់នូវការរីករាលដាលនៃជំងឺ ឬពុំមានលទ្ធភាពព្យាបាល នៅពេលឆ្លងជំងឺនេះ។ ការរីកសាយនៃជំងឺ ជះឥទ្ធិពលទៅលើការអភិវឌ្ឍន៍សេដ្ឋកិច្ច ដោយបណ្តាលឱ្យស្លាប់ ឬចុះខ្សោយនូវផ្នែកមួយដ៏ធំនៅក្នុងភូមិ។

យោងតាមរបាយការណ៍មន្ទីរសុខាភិបាលខេត្តឆ្នាំ២០០៤ បានឱ្យដឹងថា នៅទូទាំងខេត្តមានមជ្ឈមណ្ឌល

សុខភាពចំនួន៩។ មានអ្នកជំងឺចំនួន ៣៦ ៧៨៦នាក់ បានទៅពិគ្រោះយោបល់ ឬពិនិត្យសុខភាពជាមួយពេទ្យឆ្មប និងវេជ្ជបណ្ឌិត នៅមន្ទីរពេទ្យទាំងនេះ។ ក្នុងចំនោមតួរលេខទាំងនេះ មានអ្នកជំងឺចំនួន៥០០៣នាក់ បានធ្វើតេស្តរកមេរោគគ្រុនចាញ់ ហើយអ្នកជំងឺចំនួន២៦៩៦ មានជំងឺគ្រុនចាញ់។ នៅតំបន់រ៉ាមសារ គឺមានមណ្ឌលសុខភាពមួយ ស្ថិតនៅក្នុងឃុំព្រះរំកិល។ ក្នុងឆ្នាំ ២០០៤ មានប្រជាជនចំនួន១៤៦នាក់ បានឆ្លងនូវជំងឺគ្រុនចាញ់។ ចំនួនអ្នកជំងឺនេះ បានបែងចែកតាមក្រុមអាយុចំនួនប្រាំ : អាយុពី០ ដល់៤ឆ្នាំ មាន១៣នាក់ អាយុពី ៥ ដល់១៤ឆ្នាំ មាន២៨នាក់ អាយុពី១៥ ដល់៤៥ មាន៩៨ករណី និងអាយុ ចាប់ពី៥០ ឡើង ទៅ មាន៧ករណី។ ដោយសារជំងឺគ្រុនចាញ់ ប្រជាជនដែលរស់នៅតាមដងទន្លេមេគង្គ មានអត្រាកុមារខ្វះទំងន់ច្រើនជាងតំបន់ផ្សេងៗក្នុងប្រទេស និងនៅតាមដងទន្លេមេគង្គភាគខាងក្រោមទាំងមូល។ នៅតំបន់មួយចំនួន មានកុមារចំនួន ៥០% បានខ្វះនូវជីវជាតិ ជាពិសេសកង្វះអាហាររូបបត្ថម្ភ ដែលករណីនេះ មានទំនាក់ទំនងយ៉ាងជិតស្និតជាមួយនឹងអត្រាភាពក្រីក្រខ្ពស់។

យោងតាមការធ្វើអង្កេតដោយមន្ទីរអភិវឌ្ឍន៍ជនបទឆ្នាំ២០០៣ (PDRD, 2003) បានផ្តល់នូវព័ត៌មានលំអិតស្តីពី ស្ថានភាពសុខភាពកុមារ និងមាតា នៅក្នុងភូមិដែលបានជ្រើសរើស (៥៨ភូមិ ១៧ឃុំ ក្នុងស្រុកចំនួន៣) ក្នុងខេត្តស្ទឹងត្រែង។ លទ្ធផលអង្កេតតាមភូមិក្នុងស្រុកថាឡាបរិវ៉ាត ដោយរួមទាំងភូមិមួយចំនួនក្នុងតំបន់រ៉ាមសារ បានបង្ហាញថា មានកុមារអាយុក្រោម៥ឆ្នាំចំនួន៤៤.៨% គឺខ្វះទំងន់ ចំនួន២៥.៦% មានជំងឺរាគចំនួន ៥៧.២% មានជំងឺគ្រុនផ្តាសសាយ និង៤៣.៦% មានជំងឺគ្រុនក្តៅ។ មានស្ត្រីចំនួនជាង២០% បានទទួលនូវជំងឺទាក់ទងនឹងសរីរាង្គទាបជាង១៨.៥ ដែលអត្រានេះបង្ហាញឱ្យដឹងថា កង្វះអាហារ និងអាហាររូបត្ថម្ភ។ តួលេខទាំងនេះ បញ្ជាក់នូវកម្រិតសុខភាពខ្សោយអាចចាត់ទុកជាស្ថានភាពទូទៅរបស់ភូមិ ដែលស្ថិតនៅតំបន់រ៉ាមសារទាំងមូល។

ជំងឺស៊ីស្តូសូមីញ៉ាស៊ីស (ស៊ីស្តូ) ក៏មានកើតឡើងនៅតំបន់រ៉ាមសារដែរ។ យោងតាមការអង្កេតលក្ខណៈវិនិច្ឆ័យដែលបាន អនុវត្តដោយមន្ទីរសុខាភិបាលខេត្តស្ទឹងត្រែងបានឱ្យដឹងថាជំងឺនេះបានកើតឡើងនៅតាមដងទន្លេ ចំនួន៣: មេគង្គ សេកុង និងសេសាន។

ការចុះធ្វើការអង្កេត និងស្រាវជ្រាវជំងឺស៊ីស្តូ ត្រូវបានអនុវត្តជាប្រចាំទៅលើសាលាបឋមសិក្សាគោលដៅចំនួន២៥ ដោយចាប់ផ្តើមតាំងពីឆ្នាំ១៩៩៧ នៅតាមដងទន្លេទាំងបី។ ក្នុងចំណោមសាលាទាំងនេះ គឺមានភូមិ និងសាលាបឋមសិក្សាចំនួន៦ ស្ថិតនៅក្នុងតំបន់រ៉ាមសារ។ តារាង៣.៣ បង្ហាញនូវអត្រាអ្នកមានជំងឺស៊ីស្តូនៅតំបន់រ៉ាមសារ ចាប់តាំងពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០០៤។

**តារាង ៣.៣ អត្រាជំងឺស៊ីស្តូ នៅក្នុងតំបន់រ៉ាមសារ**

| ភូមិ / សាលារៀន | ប្រជាជនសរុប | ១៩៩៧ % | ១៩៩៨ % | ១៩៩៩ % | ២០០០ % | ២០០១ % | ២០០២ % | ២០០៣ % | ២០០៤ % |
|---|---|---|---|---|---|---|---|---|---|
| វាល ខ្សាច់ | ៥២៥ | ៩.៣ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| កោះ ស្នែង | ៨៣៤ | ១៧.០ | | | ៦.៦ | ៧.២ | ០ | ០ | ០ |
| អូរ ស្វាយ | ៧១២ | ១១.៧ | ៨.៩ | ០ | ០ | ០ | ០ | ០ | ០ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ក្រឡាពាស | ៤៩១ | ៤៣.៧ | ៣១.0 | 0 | 0 | 0 | 0 | 0 | 0 |
| ក្រោម | ៧៥៦ | | | | ៨.៨ | ១.៤ | 0 | 0 | 0 |
| អន្លង់ស្វាយ | ៥២១ | | ៥.៧ | | 0 | 0 | 0 | 0 | 0 |

**ប្រភព :** ដកស្រង់ពីលោកព្រលឹង ឆ្នាំ ២០០៥ (សំគាល់លេខ0 នៅក្នុងតារាងខាងលើ គឺបញ្ជាក់ថា ជំងឺមិនអាចរកឃើញ

ទិន្នន័យបង្ហាញថា ចំនួនប្រជាជនដែលមានជំងឺ កំពុងតែថយចុះ។ មានអង្គការមួយចំនួន ដូចជាគ្រូពេទ្យគ្មានព្រំដែន អង្គការយុវជនបំពេញបេសកកម្ម និងអង្គការដៃគូដើម្បីអភិវឌ្ឍន៍ បានផ្តល់នូវមធ្យោបាយធ្វើដំណើរ និងកម្មវិធីអនាម័យដូចជា អណ្តូងទឹក និងបង្គន់អនាម័យជាដើម។ មានអង្គការផ្សេងៗទៀត ដូចជាអង្គការ សុខ-ភាពពិភពលោក មូលនិធិសាសាហ្គាវ៉ា (Sasagawa Foundation) ដែលបានផ្តល់នូវការគាំទ្រហិរញ្ញវត្ថុ និងការបណ្តុះបណ្តាលដល់ប្រជាជន។ តែទោះជាយ៉ាងណា ជំងឺស៊ីស្តូ ត្រូវបានរាយការណ៍ កើតមាននៅស្រុកសេ-សាន និងសៀមប៉ាង ជាកន្លែងដែលទន្លេសេកុង និងសេសាន ផ្តល់នូវប្រភព ទឹកតែមួយគត់។

## ជាតិពន្ធុនៅខេត្តស្ទឹងត្រែង

យោងតាមរបាយការណ៍ របស់គណៈកម្មាធិការអភិវឌ្ឍន៍ខេត្តស្ទឹងត្រែងឆ្នាំ១៩៩៧ គឺមានជនជាតិចំនួន ១៤ក្រុម ដែលកំពុងតែរស់នៅក្នុងខេត្តស្ទឹងត្រែង។ ក្រុមជនជាតិទាំងនេះរួមមាន : ខ្មែរ (៦៤ ២៧១) ឡាវ (៤៩២៨) កាវ៉ែត (២០៦៤) គួយ (១៥៨៨) វៀតណាម (៦៧៤) ចិន (៤៥៨) ព្នង (២៨៤) លុន (៣៥៩) ព្រៅ (៣៨៥) គ្រឹង (២១០) ចាម (៨៥) ទំពួន (១៨) កាចក (១៤) និងប្រាយ/ចារាយ (៥)។ ទាក់ទងនឹងទំនាក់ទំនងជនជាតិ ប្រជាជនដែលរស់នៅក្នុងខេត្តស្ទឹងត្រែងតែងតែសំគាល់ខ្លួនគេថា ជាអ្នកស្រុកលើដែលសំដៅទៅលើអ្នករស់នៅតំបន់កសិកម្ម ដាំស្រូវ និងដំណាំកសិកម្ម សំរាប់យកមកបរិភោគ ឬលក់។

ចំពោះក្រុមកុលសម្ព័ន្ធ ឬខ្មែរលើ គឺភាគច្រើនរស់នៅតំបន់ភ្នំ ភាគឥសាន្តប្រទេស។ នៅទីនោះ ក៏មានជនជាតិឡាវ ចិន និងវៀតណាម មកពីតំបន់ទំនាបមករស់នៅផងដែរ ដែលភាគច្រើនបានរស់នៅទីប្រជុំជន ឬតំបន់ដែលមានផ្លូវគមនា គមន៍។

ប្រជាជនខ្មែរលើ នៅរក្សាអត្តសញ្ញាណ របៀបរស់នៅដាច់ដោយឡែក ព្រោះគេយល់ថា ពួកគេជាកសិករជាអ្នក បំផ្លាញព្រៃឈើ និងបរិស្ថាន និង ជាអ្នកតាំងលំនៅខុសច្បាប់ (តាមទស្សនៈរបស់មន្ត្រីរដ្ឋាភិបាល)។ លើសពីនេះទៅទៀត ក្រុមជនជាតិទាំងនេះ ត្រូវបានចាត់ទុកថា ជាក្រុមមនុស្សមានភាពទន់ខ្សោយជាងបើយោងតាមប្រវត្តិទំនាក់ទំនងនយោបាយ សេដ្ឋកិច្ច និងសង្គមជាមួយនិងអ្នកស្រុកក្រោម។ តែទោះជាយ៉ាងណា ដោយសារការអភិវឌ្ឍន៍បានចូលមកដល់ភូមិភាគឥសាន្តនៃប្រទេសកម្ពុជា សិទ្ធិ និងឱកាសក្នុងការដកហូត ឬទាញផលបែបបុរាណទៅលើដីធ្លី ព្រៃឈើ និងធនធានធម្មជាតិ នៅក្នុងសហគមន៍ បានធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពជនជាតិភាគតិច ដើម្បីធានានូវសុវត្ថិភាពជីវភាពរស់នៅ និងការរក្សានូវអត្តសញ្ញាណ និងវប្បធម៌របស់ពួកគេ។

ទន្លេមេគង្គនៅខេត្តស្ទឹងត្រែង ត្រូវបានគេស្គាល់ថាជាមេគង្គលើ ហេតុដូច្នេះហើយទើបប្រជាជនដែលរស់

នៅក្នុងខេត្តនេះបានសំគាល់ខ្លួនឯងថាជាអ្នកស្រុកលើ ចំពោះអ្នកដែលរស់នៅតាមបណ្តោយខ្សែទឹកទន្លេនេះត្រូវបានសំគាល់ថា ជាអ្នកស្រុកក្រោមទៅវិញ។ ជាទូទៅ អ្នកស្រុកក្រោមតែងតែមានឥទ្ធិពលខ្លាំងជាង បើនិ-យាយពីផ្នែកសេដ្ឋកិច្ច និងនយោបាយ តែចំពោះអ្នកស្រុកលើវិញបានទទួលការអប់រំទាបជាង មិនសូវស៊ីវិល័យ និងមានឥទ្ធិពលតិចជាង ដោយសារពួក គេរស់នៅតំបន់ ដាច់ស្រយ៉ាល។

ក្រុមជាតិពន្ធមួយទៀត គឺជនជាតិចាម ឬខ្មែរ អ៊ីស្លាម។ ពួកគេ ភាគច្រើនជាអ្នកនេសាទពេញម៉ោង។ ពួកគេរស់នៅទីរួមខេត្ត ដែលមានគ្រួសារមិនលើសពី៥០។ ពួកគេ បានពឹងអាស្រ័យទាំងស្រុងទៅលើការនេសាទជាច្រើនជំនាន់ដើម្បីចិញ្ចឹមជីវិត ហេតុនេះទើបពួកគេបានមានចំណេះដឹង បទពិសោធន៍ និងជំនាញច្រើនជាងអ្នកនេសាទខ្មែរ។ ជាធម្មតា ពួកចាមរស់នៅដាច់ដោយឡែកពីខ្មែរ ទាំងការរស់នៅលើគោក ឬនៅលើទូក ព្រោះពួក នេះពុំមានដីធ្លីទេក្នុងការប្រកបរបរកសិកម្ម។ ពួកគេមកពីខេត្តកំពង់ចាម (តំបន់ទំនាបកណ្តាលកម្ពុជា) និងមកពីភ្នំពេញ។ ចាប់ពីខែឧសភា ដល់ខែកញ្ញា មានជនជាតិ ចាមជាច្រើន បានមកដល់ខេត្តស្ទឹងត្រែង។ ពួកគេទាំងនេះ អាចចាត់ថាជាជនពនេចរ ដោយសារពួកគេរស់នៅលើទូក ហើយធ្វើដំណើរពីកន្លែងមួយ ទៅកន្លែងមួយយ៉ាងឆ្ងាយពេញមួយឆ្នាំ ដើម្បីធ្វើការនេសាទ។

ចំណែកឯជនជាតិវៀតណាម គឺជាក្រុមជាតិពន្ធមួយចុងក្រោយ ពាក់ព័ន្ធនឹងការនេសាទនៅក្នុងខេត្ត។ ពួកគេជាអ្នកចំណូលស្រុក ភាគច្រើនបានមករស់នៅទឹកដីនេះបន្ទាប់ពីមានអន្តរាគមន៍ប្រទេសវៀតណាមមកលើកម្ពុជាឆ្នាំ១៩៧៩។

ជនជាតិវៀតណាម[៧] ភាគច្រើនបានរស់នៅតាមបណ្តោយច្រាំងទន្លេ នៅត្រង់ចំនុចប្រសព្វរវាងទន្លេមេគង្គ និងសេកុង ក្បែរកំពង់ផែពាណិជ្ជកម្ម។ នៅដើមឆ្នាំ ២០០៣ សហគមន៍ជនជាតិវៀតណាម មានចំនួន១៧៥គ្រួសារ ក្នុងនោះមានគ្រួសារចំនួន៤៥ ជាអ្នកចិញ្ចឹមត្រីឆ្តោ និងត្រីកែសតាមបែរ ស្ថិតនៅក្បែរទីប្រសព្វរវាងទន្លេមេគង្គ និងសេកុង។

ក្រៅពីការចិញ្ចឹមត្រី គ្រួសារទាំងនេះក៏មានចិញ្ចឹមជ្រូក ដោយដាក់ក្នុងទ្រុងក្រោមផ្ទះ និងមានលក់ទំនិញកំប៉ិកកំប៉ុកផងដែរ។ ពួកគេ បានធ្វើនេសាទពេញរដូវ ដោយធ្វើដំណើរពីកន្លែងមួយទៅមួយយ៉ាង ទៀងទាត់។ កន្លែងទាំងនោះរួមមាន កោះកី កោះហិប និងអូរតាឡាស ក្នុងតំបន់រ៉ាមសារជាដើម។ ពួកគេ ក៏បានទៅនេសាទកន្លែងផ្សេងៗផងដែរ ដូចជាទន្លេ សេសាន ស្រែពក និងសេកុង។

សរុបមកវិញ ជនជាតិភាគតិចដែលអនុវត្ត នូវរបៀបរស់នៅបែបប្រពៃណី ក្នុងតំបន់រ៉ាមសារ គឺស្ទើរតែពុំឃើញមាន។ ជនជាតិគួយ (ភាគច្រើនមានរស់នៅក្នុងឃុំអន្លុងជ្រៃ ស្រុកថាឡាបរិវ៉ាត់) គឺមានទំនាក់ទំនងខ្លាំងជាមួយនឹងទន្លេ ប៉ុន្តែមិនស្ថិតនៅក្នុងតំបន់រ៉ាមសារទេ។ ជនជាតិគួយមួយចំនួនទៀត បានរស់នៅក្នុងភូមិជាំធំ ឃុំកោះស្នែង តំបន់រ៉ាមសារ។ ប៉ុន្តែ របៀបរស់នៅប្រចាំថ្ងៃរបស់ពួកគេបានលាយលំជាមួយជនជាតិខ្មែរ និងឡាវ ហើយសកម្មភាពចិញ្ចឹមជីវិតរបស់ពួកគេ ស្រដៀងគ្នានឹង ស្រុកក្រោមដែរ។ បច្ចុប្បន្នពួកគេកំពុងតែត្រូវបានធ្វើសមាហរណកម្មតាមរយៈប្រព័ន្ធសេដ្ឋកិច្ច សង្គម វប្បធម៌ និងនយោបាយជាមួយនឹងអ្នកស្រុកក្រោម។

[៧] គ្រួសារទាំងនេះ គឺមិនត្រូវបានផ្តល់កម្មសិទ្ធកាន់កាប់ដី នៅក្នុងច្បាប់ប្រទេសកម្ពុជា ដោយសារសញ្ជាតិរបស់ពួកគេ។

## ការតាំងលំនៅរបស់ប្រជាជន

ចំពោះភូមិទាំង២១ក្នុងតំបន់រ៉ាមសារ គឺបានកើតរាយបាយតាមដងទន្លេ និងកោះនានា។ កន្លែងដែលមានមនុស្សរស់នៅកុះករជាងគេ គឺឃុំព្រះរំកិល ដែលស្ថិតនៅត្រើយខាងលិចទន្លេមេគង្គ ទល់មុខឃុំអូរស្វាយ។ ប្រជាជនដែលរស់នៅក្នុងឃុំនេះ គឺមានដើមកំណើតចំរុះខ្មែរ-ឡាវ។ ជាធម្មតា ពួកគេពុំឃើញមានការហាមឃាត់ ឬត្រួតពិនិត្យក្នុងការឆ្លងកាត់ព្រំដែន (ដោយរួមទាំងប្រជាជននៅឃុំកោះស្នែង និងអូរស្វាយ ) ក្នុងគោលបំណងសួរសុខទុកញាតិសន្តាន និងធ្វើពាណិជ្ជកម្ម។

មានគ្រួសារមួយចំនួន បានតាំងលំនៅបណ្តោះអាសន្នតាមរដូវនៅលើកោះ ហើយដាំដំណាំកសិកម្មនៅទីនោះ។ ផ្ទះអចិន្ត្រៃនៅក្នុងភូមិ ភាគច្រើនមានទំហំធំ ធ្វើពីឈើ ប្រក់ស័ង្កសី ឬដំបូលប្រក់ស្បូវ។ ចំពោះអាគារដែលធ្វើពីបេតុងប្រក់ក្បឿង ភាគច្រើនសង់ក្នុងភូមិដែលមានប្រជាជនរស់នៅកុះករ ក្នុងគោលបំណងបំរើសាសនា។ កន្លែងដែលមានការសាងសង់ច្រើន គឺមាននៅមជ្ឈមណ្ឌលពាណិជ្ជកម្មទីរួមខេត្ត និងតំបន់ទីផ្សារពាណិជ្ជកម្ម ស្រុកថាឡាបរិវ៉ាត់ តាមបណ្តោយព្រំដែន កម្ពុជា-ឡាវ។

ភូមិភាគច្រើននៅតំបន់រ៉ាមសារ គឺមានលក្ខណៈរកេតរកូត និងព័ទ្ធជុំវិញដោយដើមឈើហូបផ្លែ។ តាមច្រាំងទន្លេភាគច្រើនដាំដំណាំកសិកម្ម ជាពិសេសសួនបន្លែនៅរដូវប្រាំង។ ចំពោះកោះដែលមានប្រជាជនរស់នៅកុះករ គឺតែងតែមានព្រៃឈើមួយចំនួនតូចដែលបានរក្សាទុកក្នុងគោលបំណងសាសនា និងសង្គម។

## ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម

ភូមិភាគច្រើនក្នុងតំបន់រ៉ាមសារ ត្រូវបានចាត់ទុកជាទីជនបទ ដែលមានប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធតិចតួច។ មកដល់ពេលថ្មីៗនេះ មានគ្រួសារមួយចំនួនតូចមានភ្លើងអគ្គិសនីប្រើ។ អ្នកដែលមានអគ្គិសនីទាំងនោះ គឺបានមកពីម៉ាស៊ីនភ្លើងផ្ទាល់ខ្លួន ឬដោយប្រើអាគុយ។ ម្យ៉ាងទៀត ប្រជាជនស្ទើរតែគ្រប់គ្នាបានប្រើអុស ដើម្បីចំអិតអាហារ។ ហើយភូមិភាគច្រើន ពុំមានមណ្ឌលសុខភាពទេ លើកលែងតែឃុំព្រះរំកិលមួយចេញ។ នៅតាមព្រំដែនកម្ពុជា-ឡាវ មានផ្សារចំនួនពីរៈ វ៉ឺនខាម ក្នុង ទឹកដីឡាវ និងវ៉ឺនខាវ (ដែលបានបង្កើតឡើងក្នុងឆ្នាំ២០០៤) ស្ថិតនៅឃុំអូរស្វាយ ប្រទេសកម្ពុជា។ ឃុំអូរស្វាយតភ្ជាប់ នឹងផ្លូវ ជាតិលេខ៧ រវាងខេត្តស្ទឹងត្រែង និងព្រំដែនឡាវ។

ផលិតផលក្នុងមូលដ្ឋានភាគច្រើន ដូចជាផលិតផលកសិកម្មត្រី និងធនធានធម្មជាតិផ្សេងៗទៀត បានមកពីតំបន់រ៉ាមសារ។ តែចំពោះទំនិញផ្សេងៗវិញដូចជាសំលៀកបំពាក់ សំភារៈ និងឧបករណ៍ផ្ទះសម្បែង គឺត្រូវយកពីទីរួមខេត្តស្ទឹងត្រែង និងប្រទេសឡាវ។ មធ្យោបាយដឹកទំនិញ និងប្រជាជន តែងតែប្រើដោយទូក។ ដោយមានការស្តារ និងកែលំអរផ្លូវជាតិថ្មី មធ្យោបាយដឹកជញ្ជូន និងធ្វើដំណើរដោយឡាន និងម៉ូតូនឹងមានការកើនឡើង។

មានសេវាកម្មទូកដ ពីទីរួមខេត្តស្ទឹងត្រែង មកព្រំដែនឡាវផ្ទាល់ និងទៀតទាត់។ តែការធ្វើដំណើរដោយទូកនេះ មានការលំបាកខ្លាំងនៅរដូវប្រាំង ពេលកម្រិតទឹករាក់។ មធ្យោបាយធ្វើដំណើរប្រភេទនេះ ត្រូវបានប្រើប្រាស់ច្រើនពីប្រជាជនមូលដ្ឋាន ក្នុងគោលបំណងពាណិជ្ជកម្ម ហើយក៏ពេញនិយមផងដែរសំរាប់អ្នកទេសចរណ៍ ព្រោះពួកគេសប្បាយនឹងទេសភាពតាមដងទន្លេ ក្នុងតំបន់រ៉ាមសារ។ ចាប់តាំងពីវត្តមានទូកលឿននៅឆ្នាំ២០០១

ចំនួនរបស់វាបានកើនឡើង ដើម្បីដឹកអ្នកដំណើរ ទំនិញ និងអ្នកទេសចរណ៍ ឆ្លងកាត់តំបន់រ៉ាមសារ។ តែទោះជាយ៉ាងណា មានការព្រួយបារម្ភមួយចំនួនទាក់ទងនឹងសំលេង និង ល្បឿនរបស់វា។ ទូកទាំងនេះ អាចជាការរំខានដល់ជម្រក សត្វព្រៃ និងសុវត្ថិភាពមនុស្សផងដែរ។

## យុទ្ធសាស្ត្រចិញ្ចឹមជីវិត



ភូមិភាគច្រើនក្នុងតំបន់រ៉ាមសារ គឺស្ថិតនៅតាមដងទន្លេមេគង្គ និងនៅលើកោះសំខាន់ៗរបស់វា។ តំបន់ទាំងនេះ គឺសំបូរទៅដោយធនធានធម្មជាតិ ជីវៈចម្រុះ ដូចជាព្រៃលិចទឹក បក្សីទឹក ប្រភេទសត្វមាន និងគ្មានឆ្អឹងកង និងមច្ឆាជាតិ។ ធនធានធម្មជាតិទាំងនេះ គឺជាប្រភពដ៏សំខាន់នៃជីវភាពរស់នៅ របស់ប្រជាជនមូលដ្ឋាន។ សកម្មភាពចិញ្ចឹមជីវិតផ្សេងៗ រួមមាន ការធ្វើស្រែ ការនេសាទ ធ្វើចំការ ការប្រមូលអនុផលព្រៃឈើ ការចិញ្ចឹមសត្វ និងការធ្វើជំនួញខ្នាតតូច (Try, 2004).

លោក វណ្ណារ៉េន ឆ្នាំ២០០២ បានបកស្រាយថា មានប្រជាជននៅទូទាំងខេត្តចំនួន៩៥% ជាកសិករ ក្រៅពីនេះ ជាពាណិជ្ជករ មន្ត្រីរដ្ឋាភិបាល និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល។ កសិករភាគច្រើនបានអនុវត្តកសិកម្ម បែបបុរាណ។ ពួកគេ ចិញ្ចឹមមគោ ក្របី សំរាប់ភ្ជួរ-រាស់ និងប្រើសំភារៈកសិកម្មសាមញ្ញ និងពូជស្រូវមូលដ្ឋាន។ ជាក់ស្តែងនៅស្រុកសៀមបូក ដែលស្ថិតដងទន្លេមេគង្គនៅខ្សែទឹកខាងក្រោមទីរួមខេត្តស្ទឹងត្រែង បានបង្ហាញថា ប្រាក់ចំណូល ប្រចាំឆ្នាំរបស់ប្រជាជន មានកម្រិតទាប បើប្រៀបធៀបនឹងខេត្តផ្សេងៗ។ អ្នកភូមិនៅទីនោះបានពឹងផ្អែកលើការធ្វើស្រែ-ចំការ នេសាទ និងដាំបន្លែ សំរាប់បរិភោគប្រចាំថ្ងៃ។ ប្រាក់ចំណូល ត្រូវបានប្រើសំរាប់តម្រូវការចាំបាច់ក្នុងគ្រួសារ ដូចជា អំបិល ស្ករ សំលៀកបំពាក់ និងឧបករណ៍នេសាទជាដើម។

យោងតាមការចុះអង្កេត ស្រាវជ្រាវតាមផ្ទះនៅក្នុងភូមិចំនួន៣ (កោះសំពាយ កោះព្រះ និងត្បូងខ្លា) បានឱ្យដឹងថាប្រាក់ចំណូលរបស់ពួកគេ គឺបានមកពីផលិតផលត្រី ស្រូវ បន្លែ ដំណាំកសិកម្ម ការចិញ្ចឹមសត្វ ផលិតផលអនុផលព្រៃឈើ សត្វព្រៃ និងប្រាក់ខែ (សូមមើលតារាង ៣.៤)។

**តារាង ៣.៤ ប្រភពប្រាក់ចំណូលតាមសកម្មភាព សំរាប់ភូមិនៅស្រុកសៀមបូក**

| ប្រភព | ប្រាក់ចំនូល (រៀល)/១ដុល្លារ ប្រហែល ៤០០០ រៀល | | |
|---|---|---|---|
| | អប្បរមា | អតិបរិមា | ជាមធ្យម |
| ផលិតផលត្រី | ៣០០០០ | ៦០០០០០ | ១៥០៦២០ |
| ផលិតផលស្រូវ | ៣០០០០ | ១៥០០០០ | ៧០៨៣០ |

| | | | |
|---|---|---|---|
| **បន្លែ និងដំណាំកសិកម្ម** | **៥០០០** | **៤០០០០០** | **៧១៧៧០** |
| **សត្វពាហនៈ** | **២០០០០** | **៣៥០០០០** | **៩៦៨៧០** |
| **អនុផលព្រៃឈើ** | **៣០០០០** | **៣០០០០០** | **១៣២៥០០** |
| **ប្រាក់ខែ** | **៧២០០០** | **២៣៨៨០០០** | **៨៤២២០០** |
| **សរុប** | **១៨៧០០០** | **៤១៨៨០០០** | **១៣៦៤៧៥០** |

ប្រភព : ដងស្រង់ចេញពីលោក វណ្ណារ៉េន ២០០២

ប្រភពជីវភាពរបស់ប្រជាជនដែលរស់នៅតាមដងទន្លេក្នុងខេត្តស្ទឹងត្រែង គឺមិនសូវខុសគ្នាទេ។ លទ្ធផលសិក្សាថ្មីៗ ស្តីពីការវាយតំលៃភាពក្រីក្រ (PPA, 2003) ក្នុងខេត្តស្ទឹងត្រែងបានបង្ហាញថា ជីវភាពរបស់ប្រជាជនរស់នៅតាមដងទន្លេមេគង្គ និងតាមដៃរបស់វា គឺមិនផ្តោតលើសកម្មភាពតែមួយទេ។ សកម្មភាពចិញ្ចឹមជីវិត ទាំងនោះរួមមាន ការធ្វើស្រែ-ចំការ នេសាទ ចិញ្ចឹមសត្វ ប្រមូលអនុផលព្រៃឈើ បរបាញ់សត្វ ដាំបន្លែតាមច្រាំងទន្លេ ដាំដំណាំចម្រុះ បើកទូកដ និងធ្វើពាណិជ្ជកម្មខ្នាតតូចជាដើម។

លោក ទ្រី នៅឆ្នាំ២០០៤ (Try, 2004) ក៏បានកត់សំគាល់ថា ភូមិភាគច្រើននៅតំបន់រ៉ាមសារ មានសេដ្ឋកិច្ច ដោយផ្អែកលើស្រែ។ សិទ្ធិក្នុងការប្រើប្រាស់ដី និងដកហូតនូវធនធានធម្មជាតិព័ទ្ធជុំវិញ គឺជាកត្តាសំខាន់បំផុតសំរាប់សេដ្ឋកិច្ចរបស់ពួកគេ។ កាលពីដើមឡើយ ប្រជាជនដែលរស់នៅទីនេះភាគច្រើនអនុវត្តកសិកម្មពនេចរ ដែលមានការកាប់ព្រៃរិល ជុំចាប់ពី៨ ទៅ១៣ឆ្នាំ តែនៅពេលថ្មីៗនេះ ការទុកដីឱ្យទំនេរចោលបាន ថយចុះពីមួយឆ្នាំ ទៅមួយឆ្នាំ។ នៅឃុំកោះស្នែង នៅពេលដែល ប្រជាជនរានដីព្រៃដើម្បីធ្វើស្រែ ឬចំការពួកគេអាចចុះបញ្ជីដីនៅសាលាឃុំ ដោយគ្រាន់តែបង់៥០.០០០រៀល (ប្រហែល ១២,៥០ ដុល្លារ)ក្នុង១ឆ្នាំក្នុងហិកតា។

ប្រព័ន្ធកសិកម្មរបស់ភូមិភាគច្រើនក្នុងតំបន់រ៉ាមសារគេសង្កេតឃើញមានពីរប្រភេទ: ទីមួយសំដៅទៅលើស្រែវស្សា និងទីពីរសំដៅទៅលើចំការ។ ការដាំស្រូវវស្សាត្រូវបានគិតថាជាផលិតផលសំខាន់សំរាប់ប្រជាជនតាមភូមិ និងកោះ ដោយពឹងផ្អែកលើទឹកភ្លៀង។ ការកាន់កាប់ដីធ្លីសំរាប់គ្រួសារនីមួយៗគឺពុំសូវមានសំពាធខ្លាំងទេ ព្រោះចំនួនប្រជាជននៅតាមឃុំនីមួយៗ នៅមានកម្រិតទាបនៅឡើយ។ នៅឃុំកោះស្នែង គ្រួសារនីមួយៗអាចមានដីជាកម្មសិទ្ធ ដោយចាប់ពី០១ ទៅ០៥ហិកតា

សំរាប់ដីស្រែវស្សា ដោយអាស្រ័យទៅនឹងកំលាំងពលកម្មដែលមាននៅក្នុងគ្រួសារ។ តែទោះជាយ៉ាងណាការកាន់កាប់ផ្ទៃដី ជាមធ្យមនៅក្នុងគ្រួសារ គឺប្រមាណ១.៦៧ហត/គ្រួសារ។ ទិន្នផលស្រូវដែលខ្ពស់ជាងគេ គឺនៅក្នុងឆ្នាំ២០០០ និង ២០០២ នៅពេលដែលកសិករបានផលិតបានទិន្នផលចាប់ពី២.០០០ គ.ក ទៅ ២៥.០០០ គ.ក្រ ក្នុងមួយហិកតាសំរាប់ស្រូវ វស្សា។ ទិនផលនេះ គឺមានកម្រិតខ្ពស់ជាងតួរលេខដែលបានផលិតដោយមន្ទីរកសិកម្មខេត្ត ពីមួយតោនទៅពីរតោនក្នុងមួយហិកតា។

យោងតាមការចុះអង្កេតស្រាវជ្រាវស្តីពីជីវភាពរស់នៅដោយលោកសិទ្ធិឆ្នាំ២០០០ (Sithik, 2000) នៅឃុំកោះស្នែងបានឱ្យដឹងថា ការបរិភោគស្រូវប្រចាំឆ្នាំជាមធ្យមសំរាប់គ្រួសារ គឺប្រហែល ៣៦,២ហាប (១ហាប ស្មើ

នឹង៦០ គ.ក្រ) ឬ ស្មើនឹង២.១៧២ គ.ក្រ។ លទ្ធផលចុះអង្កេតនោះបានឱ្យដឹងថា ជាមធ្យមគ្រួសារមួយមានសមាជិក ចំនួន៥នាក់ ហើយគ្រួសារធំ អាចមានចំនួនដល់ទៅ៧នាក់។ ភូមិភាគច្រើន មានទីតាំងជាប់មាត់ទន្លេមេគង្គ ដែលមានព្រៃលិចទឹកតាម វាលទំនាប និងតាម កោះ និងភាគច្រើនព័ទ្ធជុំវិញដោយវាលស្រែវស្សា និងព្រៃនៅកន្ទុយភូមិ។ ហើយនៅរដូវវស្សា (ឧសភា ដល់តុលា) ដីស្រែទាំងអស់ត្រូវគ្រប់គ្រងដោយស្រូវវស្សា ហើយមានកន្លែងតិចតួចសំរាប់ក្របីរកចំណីអាហារ។ ហេតុដូច្នេះ នៅរដូវវស្សា ក្របីជា ច្រើន គឺមើលទៅមានរាងស្គមជាងនៅរដូវប្រាំង។

ចំការ គឺនៅពេលដែលព្រៃឈើត្រូវបានរាន ហើយដុតធ្វើជាជី។ ចំពោះដីដែលមានជីជាតិល្អ ដំណាំអាចដាំរយៈពេល បី-បួនឆ្នាំ ដោយមិនត្រូវការដាក់ជី ឬកំលាំងពលកម្មខ្លាំងទេ ដែលជាតម្រូវការមួយនៃបច្ចេកទេសដាំស្រូវវស្សា។ នៅពេល ដែលដីអស់ជីជាតិ កសិករតាមសហគមន៍បានរើទៅកាន់ចំការថ្មី ដោយទុកឱ្យដីនោះបង្កើតនូវជីជាតិតាមលក្ខណៈធម្មជាតិឡើងវិញ។ ប្រព័ន្ធកសិកម្មបែបនេះ ត្រូវបានអនុវត្តជារួមដោយប្រជាជននៅក្នុងឃុំកោះស្នែង។ គេឃើញមានផលប្រយោជន៍មួយចំនួនផងដែរ ទាក់ទងនឹងប្រព័ន្ធកសិកម្មបែបនេះ។ ព្រោះវាទាមទារកំលាំងពលកម្មតិច នៅពេលដែលដីទើបតែរានថ្មី ហើយទិន្នផលស្រូវ ក៏បានល្អថែមទៀត។

លោកទ្រីក្នុងឆ្នាំ២០០៤ បានបង្ហាញថា បើយោងតាមការប្រែប្រួលរបបសង្គមថ្មីៗ ឱកាសដកហូតធនធានធម្មជាតិ និងប្រព័ន្ធចិញ្ចឹមជីវិតនៅក្នុងភូមិ ក៏មានការប្រែប្រួលដែរ។ អ្នកភូមិនៅកោះស្នែងបានធ្វើការបំលាស់ទីអាស្រ័យទៅនឹងភាពមិនច្បាស់លាស់នៃធនធានធម្មជាតិ និងយុទ្ធសាស្ត្រចិញ្ចឹមជីវិតរបស់គ្រួសារនីមួយៗ។ លក្ខណៈបត់បែននៃយុទ្ធសាស្ត្រចិញ្ចឹមជីវិតបែបនេះត្រូវបានអនុវត្ត និងទទួលយកដោយគ្រួសារផ្សេងៗ ដើម្បីឆ្លើយតបនឹងភាពមិនច្បាស់លាស់ និងការប្រែប្រួលនៃធនធានមច្ឆា។ យោងតាមក្រុមពិភាក្សា និងការធ្វើចំណាត់ថ្នាក់ទ្រព្យសម្បត្តិជាមួយប្រជាជនមូលដ្ឋាន មានគ្រួសារចំនួនបីប្រភេទ ត្រូវបានកំណត់នៅក្នុងភូមិ ជាអ្នកធូរធារ អ្នកកណ្តាល និងអ្នកក្រ (សូមមើលតារាង ៣.៥)។

**តារាង ៣.៥ : ភាពខុសគ្នាផ្នែកសេដ្ឋកិច្ចសង្គមរបស់គ្រួសារក្នុងភូមិកោះស្នែង**

| **ស្ថានភាពសង្គម** | **លក្ខណៈគ្រួសារ** |
|---|---|
| **អ្នកធូធារ (ប្រហែល២០គ្រួសារ)** | • **ជាអ្នកមានអំណាចជាអ្នកទិញត្រីលក់ និងជាឈ្មួញកណ្តាលក្នុងភូមិ ដែលមានទំនាក់ទំនងបង ប្អូន និងសង្គមខ្លាំង ទាំងនៅក្នុងភូមិ និងនៅក្រៅភូមិ។**<br>• **មានផ្ទះធំ ធ្វើពីឈើប្រក់ស័ង្កសី។ មានដីស្រែ-ចំការច្រើនជាងតម្រូវការ (៣-៥ហត)។ ជូនកាល ជួលកំលាំងបន្ថែមក្នុងការធ្វើស្រែ-ចំការ។**<br>• **មានក្របី និងជ្រូក (ច្រើនជាង៦ក្បាល ) ហើយមានមាន់ ទាច្រើនជាង ៤០ក្បាល។**<br>• **ជារួមគ្រួសារទាំងនេះ តែងតែមាននូវទ្រព្យសម្បត្តិដូចជា: កាណូត ម៉ាស៊ីនកិនស្រូវ ម៉ាស៊ីនបូមទឹក មានវីដេអូ ឬទារ៉ាអូខេសំរាប់ជួល ហើយអាចមាន-ចរិកា សំរាប់ឱ្យគេខ្ចីចងការ។** |

| | |
|---|---|
| អ្នកកណ្តាល (ប្រហែល១៤១គ្រួសារ) | • គ្រួសារទាំងនេះមានផ្ទះល្អ។ ពួកគេមានដីស្រែ និងសួនដំណាំគ្រប់គ្រាន់ (ពី១-៣ហត)<br>• ពួកគេមានកំលាំងពលកម្មគ្រប់គ្រាន់ ដែលអាចបង្កើតប្រាក់ចំណូល និងផលិតផលបន្ថែម ដើម្បីលក់ដូរជាមួយអ្នកភូមិជិតខាង។<br>• ជាធម្មតា គ្រួសារទាំងនេះ មានទូកចំនួន២ :ទូកអុំ/ចែវ និងការណូត។<br>• ពួកគេមានសត្វពាហនៈ ជ្រូក មាន់ទាគ្រប់គ្រាន់ សំរាប់ឆ្លើយតបទៅនឹង តម្រូវការចាំបាច់ក្នុងគ្រួសារបាន។<br>• ជារើយៗ គ្រួសារទាំងនេះមានឱកាសស្រួបយកធនធានព្រៃឈើ ដូចជាការប្រមូលអនុផលព្រៃឈើ។ |
| អ្នកក្រ (ប្រហែល៧គ្រួសារ) | • មានផ្ទះតូច ដំបូលប្រកស្បូវ<br>• មានដីស្រែ-ចំការតិច ដោយសារពុំមានកំលាំងពលកម្មគ្រប់គ្រាន់<br>• ទាក់ទងបច្ចេកទេសផលិត គ្រួសារទាំងនេះតែងតែមាន ទូកចែវ និងក្របី ពីរ-បី ឬមាន់ ជ្រូក មាន់ទា ចំនួនពីរ បី។<br>• គ្រួសារទាំងនេះ តែងជួបប្រទះកង្វះខាតស្បៀង និងថវិកា ដែលជូនកាលត្រូវលក់កំលាំងពលកម្ម ដើម្បីរកថវិកា និងស្បៀងបន្ថែម។ ជាទូទៅ គ្រួសារទាំងនេះ ដឹកនាំដោយស្ត្រីមេមាយ ដែលបានលែងលះគ្នា។ |

**ប្រភព :** ដកស្រង់ពី លោកទ្រី ២០០៤

ដោយសារស្ថានភាពរបស់ក្រុមមនុស្សខុសគ្នា ការចែករំលែកនូវឱកាសក៏មិនដូចគ្នាដែរ ទាក់ទងនឹងយុទ្ធសាស្ត្រចិញ្ចឹមជីវិត ការដកហូតធនធានធម្មជាតិ និងការលក់ដូរជាមួយនឹងអ្នកភូមិ និងក្រៅភូមិ។ ប្រការនេះ គ្រួសារអ្នកក្រមានឱកាសតិចតួចក្នុងការគ្រប់គ្រងដីធ្លី កំលាំងពលកម្ម និងមធ្យោបាយធ្វើដំណើរទៅកាន់ទីផ្សារ មណ្ឌលសុខភាព ឬជម្រើសបង្កើតប្រាក់ចំណូល។ ពួកគេ ជាពិសេសពឹងអាស្រ័យទៅលើការនេសាទ ដើម្បីយកថវិកាទិញអង្កប្រចាំថ្ងៃតែប៉ុណ្ណោះ។

ការកាន់កាប់ដី គឺជាទ្រព្យធនរូបិយមួយក្នុងការកំណត់ជីវភាពរស់នៅរបស់មនុស្ស។ ការប្រើប្រាស់ដីធ្លីទៅតាមឃុំ ទាំង៤ ក្នុងតំបន់រ៉ាមសារ បង្ហាញនូវក្នុងតារាង ៣.៦។ តួរលេខនេះ ត្រូវបានដកស្រង់ពីផែនការអភិវឌ្ឍន៍ឃុំរយៈពេល ៥ឆ្នាំ។

**តារាង ៣.៦ : ផែនការប្រើប្រាស់ដីធ្លី របស់ឃុំទាំង៤ក្នុងតំបន់រ៉ាមសារ**

| ឃុំ | ការបែងចែកដីធ្លី | ទំហំ(ហាត) |
|---|---|---|
| សាមគ្គី | ដីលំនៅដ្ឋាន | ៧៥២ |
| | ដីលំនៅដ្ឋានបំរុង | ១,៥០៤ |
| | ដីបំរុងសំរាប់គោលបំណងផ្សេងៗ | ២,៩៥០ |
| | ដីទុកទំនេរ | ១៨,៨៥៤ |
| | ដីទុកបំរុងប្រើប្រាស់បែបប្រពៃណី | ៧,៤២០ |
| | ក្រុមហ៊ុនសម្បទានដីកែវវុទ្ធី | ៧,៤០០ |
| | ដីដាំដំណាំ | ៨,១៦៥ |
| | កោះ និងទន្លេ | ៣,១៤៧ |
| កោះស្នែង | វាលស្រែ | ៣៩០ |
| | ដីចំការ | ៤២០ |
| | ដីលំនៅដ្ឋាន | ៣៨ |
| | ដីព្រៃ | ២០,៧៥២ |
| អូរស្វាយ | ដីស្រែវស្សា | ៣៤៥ |
| | ដីដាំដុះ | ២៨៥ |
| | សំណើដីព្រៃសហគមន៍ព្រៃឈើ (មួយចំនួនស្ថិតក្នុងតំបន់សម្បទាន) | ៥,០០០ |
| ព្រះរំកិល | ស្រែវស្សា | ១២៦ |
| | លំនៅដ្ឋាន | ១៥៣ |
| | ដីដាំដុះ | ២៦៦ |
| | ដីលិចទឹក | ៨៣ |
| | ដីព្រៃ | ១៧៨១ |

ប្រភព : ដកស្រង់ពីផែនការអភិវឌ្ឍន៍ឃុំ ២០០៣

នៅក្នុងឃុំកោះស្នែង ផ្ទៃដីចំការមានទំហំប្រហែល១,១ហត សំរាប់គ្រួសារនីមួយៗ ដើម្បីដាំដំណាំបន្លែរួមផ្សំដូចជា ឪឡឹក ថ្នាំជក់ ត្រសក់ ប៉េងប៉ោះ ម្ទេស ដំឡូង សណ្តែកបាយ ត្រប់ ជាដើម។ ប្រភេទផលិតផលកសិកម្មទាំងនេះ តែងតែដាំនៅតាមច្រាំង/មាត់ទន្លេ និងនៅតាមកោះ។ អ្នកភូមិកោះស្នែងតែងតែពង្រីកចំការរបស់ពួកគេនៅតាមកោះផ្សេងៗ នៅក្នុងឃុំដូចជាកោះហាន, កោះគី, កោះសំបូរ កោះទន្លេមួយ និងកោះកណ្តុរ។ នៅលើកោះទាំងនេះ គឺនៅមានព្រៃឈើធម្មជាតិជាច្រើន ហើយការតាំងលំនៅថ្មីក៏នៅមានលក្ខណៈបណ្តោះអាសន្ននៅឡើយ។ តែទោះជាយ៉ាងណា មានកោះមួយចំនួននៅក្នុងឃុំកោះស្នែង បានទាក់ទាញអ្នកភូមិផ្សេងៗទៀត ជាពិសេសមកពីឃុំសាមគ្គីដើម្បីមករស់នៅ។

លោកស្រីជុង (២០០៥) បានបង្ហាញថា ភូមិរ៉ុនសៀន នៃតំបន់រ៉ាមសារ របស់ទន្លេមេគង្គបានផ្តល់នូវធនធានសេដ្ឋកិច្ច និងសេវាកម្មជាច្រើន។ ធនធានដែលសំខាន់បំផុត គឺត្រីសំរាប់ការបរិភោគប្រចាំគ្រួសារ និងការលក់តាមមូលដ្ឋាន ដែលតំលៃគិតជាមធ្យមក្នុង១គ្រួសារ ស្មើនឹង ១,៧០០,០០០ រៀល ឬ៤២៥ ដុល្លារ។ ទំនិញ និងសេវាកម្មផ្សេងៗរួមមាន ទឹកសំរាប់ងូត បោកគក់ ដាំស្ល ផឹក នាវាចរ សម្ភារៈសាងសង់ ប្រភេទសត្វ និ-ងរុក្ខជាតិក្នុងទឹកសំរាប់បរិភោគ លក់ ថ្នាំពេទ្យ ធារាសាស្ត្រ និងការកំសាន្តជាដើម។

វិធីសាស្ត្រនេសាទ គឺប្រែប្រួលទៅតាមរដូវកាល បំលាស់ទីរបស់ត្រី, អត្តចរិតរបស់ត្រី និងប្រព័ន្ធអេកូឡូស៊ីរបស់ទន្លេ ។ យោងតាមលក្ខណៈរូប និងប្រព័ន្ធអេកូឡូស៊ីទាំងនេះ យើងអាចធ្វើការកំណត់តំបន់ត្រីពងកូនជាបីផ្នែក។ ផ្នែកទី១ គឺចាប់ផ្តើម ពីទីរួមខេត្តស្ទឹងត្រែង ឆ្ពោះទៅកាន់ព្រំដែនឡាវ ដែលរួមមានតំបន់រ៉ាមសារផងដែរ។ ប្រព័ន្ធអេកូឡូស៊ីនៅក្នុងផ្នែកនេះ ត្រូវបាន ពណ៌នាថាមានព្រៃលិចទឹកល្អ ប្រព័ន្ធទន្លេសាំញ៉ាំ ដូចជាតំបន់ទឹកជូរ អន្លង់ជ្រៅៗ ដែលអាចប្រើបានច្រើនយ៉ាងដូចជា ការនេសាទតាមរដូវ តំបន់ពងកូនរបស់ត្រី ជាកន្លែងផ្តល់នូវប្រភេទបក្សីទឹកដ៏សំបូរបែប ដីកសិកម្ម និងធនធានទេសចរណ៍ធម្មជាតិ។

ផ្នែកទី២ គឺចាប់ពីទន្លេរួមខេត្តស្ទឹងត្រែង រហូតដល់ព្រំប្រទល់ខេត្តក្រចេះ។ នៅក្នុងផ្នែកនោះ គឺមានអន្លង់ជ្រៅៗជាច្រើនដែលបានកំណត់ជាទីជម្រករបស់ប្រភេទត្រីសំខាន់ៗ។ អន្លង់មួយចំនួន គឺជាកន្លែងពងកូនរបស់ត្រី ត្រសក់ ត្រីគល់រាំង, ត្រីប្រា និងត្រីប្រម៉ា ជាដើម។

ផ្នែកទី៣ គឺជាដៃរបស់ទន្លេមេគង្គ ជាពិសេសទន្លេសេកុង សេសាន និងទន្លេស្រែពក ដែលមានអន្លង់ ជ្រៅៗជាច្រើនសំរាប់ត្រីពងកូន និងធ្វើការបំលាស់ទីផងដែរ។ នៅតាមដងទន្លេសេសាន មានអន្លង់ជ្រៅមួយ ចំនួនបានរាក់រយៈពេលបីបួនឆ្នាំមុន ដោយសារកំណរដីមកពីការប្រតិបត្តិទំនប់វារីអគ្គិសនីយ៉ាលី នៅខ្សែទឹកខាងលើក្នុងប្រទេសវៀតណាម។ ជាក់ស្តែង មានអន្លង់មួយនៅស្រុកវ៉ឺនសៃ ខេត្តរតនគីរី ត្រូវបានគេរាយការណ៍ថាបានរាក់ដោយចាប់ពីជម្រៅ៧-៨ម៉ែត្រ មកត្រឹមកន្លះម៉ែត្រ ក្នុងរយៈពេល៣ឆ្នាំ ហើយប្រភេទត្រីដ៏ច្រើនសន្ធឹកសន្ធាប់ត្រូវបានបាត់បង់ (Baird et al ២000)។ លើសពីនេះទៅទៀត នៅអូរតាឡាស់ អូកាំផា និងអូរម្រះ ដែលជាដៃទន្លេមេគង្គ និងអូរស្នូងដែលជាដៃទន្លេសេកុងត្រូវបានគេចាត់ទុកថាជាតំបន់ត្រីពងកូន និងធ្វើបំលាស់ទីយ៉ាងសំខាន់បំផុត។

ការធ្វើបំលាស់ទីរបស់ត្រីតាមរដូវ ត្រូវបានរកឃើញថាមាន ២ប្រភេទ នៅក្នុងខេត្ត។ លោក Thuok និង Van Zaling (២000) បានពន្យល់ថានៅរាល់ឆ្នាំ ប្រភេទត្រីដែលធ្វើការបំលាស់ទីមានរយៈចំងាយវែងបានបណ្តែតខ្លួន (ករណីកូនត្រី) ហើយ(ករណីត្រីធំ)ពីតំបន់ពងកូនតាមដងទន្លេមេគង្គភាគខាងជើងប្រទេសកម្ពុជា និងភាគខាងត្បូង ប្រទេសឡាវ ឆ្ពោះទៅកាន់តំបន់ចិញ្ចឹមជីវិតរបស់វានៅបឹងទន្លេសាប និងនៅក្នុងតំបន់ដីសើមផ្សេងៗទៀត ក្នុងប្រទេសកម្ពុជា និងតំបន់ ដីសណ្តរទន្លេមេគង្គ វៀតណាម។ នៅពេលដែលត្រីធំឡើង ពួកវាក៏ធ្វើបំលាស់ទី មកកាន់តំបន់មេគង្គភាគខាងលើវិញ។

Phallavan និង Pheng (២000) បង្ហាញថាការបំលាស់ទីត្រីពងកូនបានចាប់ផ្តើមក្នុងទន្លេមេគង្គនៅដើមរដូវភ្លៀងធ្លាក់ (ខែឧសភា-សីហា)។ ពង និងកូនត្រីបានបណ្តែតខ្លួនតាមកំលាំងទឹកហូរ ហើយបត់ចូលទៅក្នុងតំបន់ព្រៃលិចទឹកជុំវិញបឹងទន្លេសាប និងតំបន់ភាគខាងត្បូងទីក្រុងភ្នំពេញ។ នៅពេលរដូវទឹកស្រកប្រភេទ

ត្រីភាគច្រើន បានធ្វើការបំលាស់ទីទៅកាន់កន្លែងទឹកជ្រៅៗនៅតាមបឹង ទន្លេ និងដៃទន្លេនានា (បំលាស់ទីខ្លី ) ប៉ុន្តែមានប្រភេទត្រីជាច្រើនផងដែរ បានធ្វើការបំលាស់ទីរយៈពេលវែងទៅកាន់ទន្លេមេគង្គ ក្នុងខេត្តស្ទឹងត្រែង និងប្រទេសឡាវ។

ជាក់ស្តែងត្រីប្រា ត្រូវគេយល់ថាបានរស់នៅកន្លែងទឹកជ្រៅ ឬអន្លង់ជ្រៅៗ និងតំបន់ដែលមានទឹកជូរក្នុងទន្លេមេគង្គ ដែលពេលខ្លះនៅតាមដៃទន្លេ ដូចជាទន្លេសេកុង សេសាន និងស្រែពក ដើម្បីធ្វើការពងកូន។ មេត្រីប្រានីមួយៗ អាចមានពងច្រើនសន្ធឹកសន្ធាប់ ដែលចំនួននេះប្រឈមនឹងគ្រោះធម្មជាតិផ្សេងៗ បណ្តាលឱ្យកូនត្រីស្លាប់ច្រើន។ ដោយយោងតាមលំនាំបំលាស់ទីរបស់ត្រី យើងឃើញថា ទន្លេមេគង្គ និងដៃរបស់វាក្នុងខេត្តស្ទឹងត្រែង គឺមិនស្ថិតនៅក្នុងភាពឯកកោទេ ព្រោះវាបានតភ្ជាប់ជាមួយប្រទេសឡាវ បឹងទន្លេសាប ហើយតំបន់សំបុកត្រីភាគខាងត្បូងទីក្រុងភ្នំពេញ ក៏បានតភ្ជាប់ទៅនឹងតំបន់ ដីសណ្តទន្លេមេគង្គផងដែរ (MRC, ២000)។

ប្រភេទត្រីដែលមានសារៈសំខាន់មួយទៀតគឺត្រីរៀល។ ប្រភេទត្រីនេះមានចំនួនច្រើនសន្ធឹកសន្ធាប់ ដោយចាប់ពីខែមករា ដល់ខែឧសភា។ ទន្លេមេគង្គក្នុងខេត្តស្ទឹងត្រែង បានក្លាយជាតំបន់ជ្រកកោន និងពងកូន របស់ប្រភេទត្រីនេះនៅរដូវប្រាំង។ ត្រីពេញវ័យមួយចំនួនតូចក៏បានបំលាស់ទីចុះតាមខ្សែទឹកខាងក្រោម ដោយចាប់ពីខែមិថុនា ដល់ខែសីហា។ តែទោះជាយ៉ាងណា ក្នុងរយៈពេលស្ទើរតែ៦ខែ ដោយចាប់ពីចុងខែកក្កដា ដល់ពាក់កណ្តាលខែមករា គឺពុំសូវឃើញមានត្រីរៀលក្នុងខេត្ត ស្ទឹងត្រែងទេ ( Phallavan និង Pheng,២000)។ ចំពោះលោក Baird et al(២000) វិញ គាត់បានរាយការណ៍ថា ត្រីរៀលឡើងខ្លាំង គឺនៅពេលខែពេញបូរមី (ពេញវង្ស) ក្នុងចន្លោះខែធ្នូ មករា និងកុម្ភៈ ក្នុងខេត្តស្ទឹងត្រែងខាងក្រោមល្បាក់ខោន។

ប្រភេទត្រីដែលតែងជួបប្រទះ គឺត្រីប៉ាស៊ីអ៊ី ដែលប្រទះឃើញនៅតាមតំបន់ទឹកជូរតំបន់រ៉ាមសារ និងនៅតាមដៃទន្លេនានា។ ត្រីនេះភាគច្រើន ឃើញមាននៅភាគខាងជើងនៃប្រទេសកម្ពុជា។ លោក Rainboth (១៩៩៦) បានរាយការណ៍ថា ប្រភេទត្រីនេះអាចមានទំហំរហូតដល់៤៥ ស.ម។ ត្រីនេះ ចិញ្ចឹមជីវិតដោយចំណី ឬង់កុង ....ហើយជាប្រភេទ ត្រីដែលមានតំលៃ និងតម្រូវការខ្លាំងនៅតាមបណ្តាខេត្តភាគខាងជើង និងនៅ ទីក្រុង-ភ្នំពេញ។ ត្រីនេះអាចនេសាទបានតាមរយៈ ការដាក់មងបណ្តែត អួសអួន បង់សំណាញ់ និងដាក់លប។ បច្ចុប្បន្ន ប្រភេទត្រីនេះ បានថយនូវចំនួនរបស់វា។ លក្ខណៈនៃការបំលាស់ទីរបស់ត្រីក្នុងតំបន់រ៉ាមសារ ត្រូវបានសង្ខេប ក្នុង-តារាង ៣.៧ ខាងក្រោម។

**តារាង ៣.៧: ការសង្ខេបនៃការបំលាស់ទីរបស់ត្រីក្នុងខេត្តស្ទឹងត្រែង**

| បរិបទរដូវកាល | ចលនាបំលាស់ទីរបស់ត្រីសំខាន់ៗ |
|---|---|
| រដូវទឹកឡើង (កក្កដា-វិច្ឆិកា) | បំលាស់ទីត្រីពេញវ័យ រយៈចំងាយខ្លី ចូលទៅក្នុងតំបន់ លិចទឹក អូរ និងព្រៃក និង ដៃទន្លេ សំរាប់ពងកូន និងរកចំណី |
| ដំណាក់កាលអន្តរកាល (ធ្នូ-មករា) | បំលាស់ទីរបស់ត្រីពេញវ័យ និងកូនត្រីពីផ្ទៃទឹកតាមរដូវ មកកាន់កន្លែងអចិន្ត្រៃ (ភាគច្រើន បំលាស់ទីពីអូរ ព្រៃក ដៃទន្លេ មកកាន់ទន្លេមេគង្គ និងអន្លង់ជ្រៅៗ) |
| រដូវប្រាំង (កុម្ភៈ-មេសា) | ការធ្វើបំលាស់ទីរយៈចំងាយវែង មកកាន់ដែនជម្រករៀងខ្លួន |

| | |
|---|---|
| *ដំណាក់កាលអន្តរកាល (ឧសភា-មិថុនា)* | *ការធ្វើបំលាស់ទីរយៈពេលខ្លាយ ទៅកាន់តំបន់ពងកូន។ ត្រីចាប់ផ្តើមពង និងធ្វើបំលាស់ទីមកខ្សែទឹកខាងក្រោម។* |
| *ពីរខែ មិថុនា-កក្កដា* | *ពង និងកូនត្រីបានបណ្តែតខ្លួន តាមខ្សែទឹកតាមកំលាំងទឹកហូរ រួចហើយចែកចាយតាម តំបន់ទឹកលិច ដែលជាកន្លែងផ្តល់នូវការរីកធំធាត់ ដល់កូនត្រីទាំងនេះ។* |

**ប្រភព :** ដកស្រង់ពី លោក ទ្រី ២០០៤

## បច្ចេកទេសនេសាទ កម្មសិទ្ធិ និងការគ្រប់គ្រងផលផល

បច្ចេកទេស និងឧបករណ៍នេសាទដែលបានប្រើប្រាស់ក្នុងតំបន់វាំមសារ បានបង្ហាញនូវការអនុវត្តដ៏ល្អមួយ និងការវិវត្តន៍ នៃជីវិតប្រចាំថ្ងៃរបស់អ្នកនេសាទ។ ប្រពៃណីវប្បធម៌ ដោយរួមទាំងភូមិសាស្ត្រ ខុសៗគ្នាដែលកើតមានតាំងពីបុរាណកាល បាននាំមកនូវភាពផ្សេងៗគ្នានៃឧបករណ៍នេសាទ បង្កើតឡើងដោយជាតិពន្ធផ្សេងៗ។ ជាលទ្ធផល ឈ្មោះប្រភេទឧបករណ៍នេសាទថ្មីៗ កំពុងតែមានការវិវត្តន៍ និងទទួលយកមកអនុវត្ត ហើយប្រភេទឧបករណ៍ចាស់ៗ ត្រូវបានបោះបង់ចោល ឬបំលែងវាមកប្រើឱ្យស្របតាមបំរែបំរួលល័ក្ខខ័ណ្ឌសង្គម សេដ្ឋកិច្ច និងបរិស្ថាន។ ឆ្លងកាត់ការចុះ សិក្សាស្រាវជ្រាវ និងការរំលឹកស្នាដៃសិក្សាកន្លងមក បានឱ្យដឹងថា ឧបករណ៍ នេ-សាទដែលកំពុងប្រើប្រាស់ និងប្រតិបត្តិក្នុង តំបន់វាំមសារ គឺអាចចែកជា ៧ប្រភេទផ្សេងៗគ្នា។

ប្រភេទទី១ ដែលមានការប្រើប្រាស់ជាទូទៅ ក្នុងតំបន់វាំមសារទាំងមូលរួមមាន (១)គឺ ឧបករណ៍ចាន់។ ឧបករណ៍នេះ ត្រូវបានប្រើដើម្បីចាប់ត្រីក្នុងទន្លេ អំឡុងពេលទឹកឡើង ហើយមានកំលាំងទឹកហូរខ្លាំងនៅក្នុងព្រៃលិចទឹក។ ចាប់ពីខែឧសភា ដល់ខែកក្កដា ឧបករណ៍នេះត្រូវបានប្រើដើម្បីចាប់ត្រីខ្យា។ (២) ឧបករណ៍នេសាទលប អាចប្រើចាប់ត្រីគ្រប់ប្រភេទ តាមព្រៃលិចទឹក ស្ទឹង ព្រែក ដៃនានារបស់ទន្លេ និងនៅក្នុងទន្លេ។ ត្រីដែលចាប់បានដោយឧបករណ៍នេះ រួមមាន ត្រីព្រួល ត្រីឆ្អែក ត្រីប៉ាវ៉ា ត្រីប៉ាស៊ីអ៊ី និងត្រីខ្យា។ (៣) ឧបករណ៍នេសាទទ្រូ គឺជាឧបករណ៍នេសាទលក្ខណៈគ្រួសារ ប្រើដើម្បីចាប់ត្រីពីព្រែក ប្រឡាយតូច នៅពេលទឹកហូរចេញ នៅរដូវប្រាំង។ ឧបករណ៍នេះ ក៏អាចប្រើដើម្បីចាប់ត្រីពី វាលស្រែ ត្រពាំងតូចៗ និងប្រឡាយក្នុងរដូវវស្សាផងដែរ។ ប្រភេទត្រីដែលតែងតែចាប់បានដោយឧបករណ៍នេសាទនេះរួមមាន ត្រីអណ្តែង ត្រីរស់ ត្រីក្រាញ់ និងត្រីរៀលជាដើម។ (៤) ឧបករណ៍នេសាទតុម ជាប្រភេទឧបករណ៍នេសាទពេញនិយមផងដែរ ប្រើសំរាប់ចាប់ត្រីរៀលយកបរិភោគប្រចាំថ្ងៃ ធ្វើត្រីឆ្អើ និងប្រហុក។ (៥) ឧបករណ៍នេសាទឈីប ជាប្រភេទឧបករណ៍បុរាណ ប្រើដោយប្រជាជនមូលដ្ឋានដើម្បីចាប់ត្រីចេញពីព្រែក អូរ និងដៃទន្លេ ឆ្ពោះទៅកាន់ទន្លេ។ ឧបករណ៍នេះ ត្រូវបានគេប្រើជាច្រើននៅអូតាឡាស់ ជាកន្លែងដែលប្រភេទត្រីមានតំលៃភាគច្រើនត្រូវបានចាប់ ដូចជាត្រីកែស ឆ្អិន ឆ្លាំង ត្រីទនេល ជាដើម។ (៦) ឧបករណ៍នេសាទសន្ទូច ដែលមានច្រើនប្រភេទ ដូចជា សន្ទូចនធង សន្ទូចបង្កៃ និងសន្ទូចបោះ។ ឧបករណ៍ នេសាទទាំងនេះ ត្រូវបានប្រើគ្រប់រដូវនេសាទ។ (៧)ឧបករណ៍នេសាទ សំណាញ់ ដែលរួមមានប្រភេទផ្សេងៗគ្នា អាស្រ័យទៅនឹងប្រភេទ និងទំហំត្រីដែលត្រូវចាប់។ ឧបករណ៍នេះ ត្រូវបានប្រើភាគច្រើននៅតាមអន្លុងជ្រៅៗក្នុងរដូវប្រាំង។

ប្រភេទឧបករណ៍នេសាទទី២ គឺសំដៅទៅលើមង និងមងបណ្តែត។ ឧបករណ៍ទាំងនេះ ត្រូវបានប្រើយ៉ាង

ពេញនិយមនៅតាមប្រភេទផ្ទៃទឹកផ្សេងៗ ដូចជាទន្លេ ព្រែក អូរ និងតាមជ្រលងទន្លេ ឬតាមអន្លង់ជ្រៅៗផងដែរ។ វាអាចប្រើនៅកន្លែងដែលមានទឹករាក់ ទឹកជ្រៅ ទឹកនឹង ឬទឹកហូរ ទាំងរដូវប្រាំង និងវស្សា។ មានមងចំនួនពីរប្រភេទ ដែលបានប្រើ នៅក្នុងតំបន់រ៉ាមសារ គឺមងកាំង ដែលអ្នកនេសាទប្រើនៅកន្លែងកំណត់ និងមងបណ្តែត ដែលអ្នកនេសាទវាយកាត់ទន្លេ បណ្តែតតាមកំលាំងទឹកហូរ ភាគច្រើនឃើញមាននៅកោះទន្លេមួយ ក្នុងឃុំកោះស្នែង និងនៅឃុំសាមគ្គី។

ប្រភេទទី៣ គឺសំដៅលើឧបករណ៍នេសាទអួន ដែលប្រតិបត្តិផ្តាច់មុខដោយអ្នកនេសាទអាជីវកម្មនៅកោះទន្លេមួយក្នុងឃុំកោះស្នែង។ ឧបករណ៍នេះមានពីរប្រភេទដែរ គឺអួនគោលដៅ ដែលអនុញ្ញាតអោយនេសាទកន្លែងដែលកំណត់ឱ្យ ដោយការិយាល័យជលផលខេត្ត និងអួនចល័ត ដែលអាចប្រើនៅគ្រប់ទីកន្លែងបាន។ ឧបករណ៍នេសាទនេះ ទាមទារនូវកំលាំងពលកម្ម និងថវិកាច្រើនដែរ ដើម្បីធ្វើវិនិយោគទុន ហើយថែមទាំងបានបង្កើតនូវជម្លោះជាច្រើនជាមួយអ្នកនេសាទមូលដ្ឋាន ព្រោះឧបករណ៍នេះបានស្ទាក់ចាប់ត្រីដែលធ្វើបំលាស់ទីតាមប្រេក ឬខ្សែទឹកក្នុងទន្លេស្ទើរតែទាំងអស់។

ប្រភេទឧបករណ៍នេសាទទី៤ គឺថ្នង ដែលប្រើនៅតាមដងទន្លេពុំមានលក្ខណៈស្មុគស្មាញ។ ត្រីភាគច្រើនដែលចាប់ដោយឧបករណ៍នេះគឺតូចៗប្រើសំរាប់បរិភោគប្រចាំថ្ងៃ និងទុកធ្វើត្រីហាល។

ប្រភេទឧបករណ៍ទី៥ គឺជួន។ ឧបករណ៍នេះប្រើក្នុងទន្លេត្រង់កន្លែងដែលមានលក្ខណៈសាំញ៉ាំ ឬកន្លែងនៅជុំវិញអន្លង់ជ្រៅដែលមានប្រភេទត្រីជាច្រើនលាក់ខ្លួននៅរដូវប្រាំង។ ប្រភេទឧបករណ៍នេះ មានការងាយស្រួលក្នុងការរក្សាទុក ព្រោះវាស្រួលសំអាតបន្ទាប់ពីប្រើរួច និងស្រួលបត់ទុកដាក់ក្រោមនននផ្ទះថែមទៀត។

ប្រភេទឧបករណ៍ទី៦ គឺការឆ្លុះត្រី។ នេះជាវិធីសាស្ត្រមួយ ដោយប្រើភ្លើងហ្វា ឬភ្លើងពិលឆ្លុះត្រីពេលយប់ ហើយយកសមចាក់ត្រី។ ព្រោះពេលនោះត្រីខ្លះ បានដេកសំងំលខ្លួន នៅក្រោមផ្ទៃទឹកក្បែរមែកឈើ។ លើសពីនេះទៀត ត្រីធំៗ ភាគច្រើនបានចេញពីអន្លង់ជ្រៅៗ ស្វែងរកចំណីនៅពេលយប់។ អ្នកនេសាទឧបករណ៍នេះ តែងតែអនុវត្តជាក្រុម ដោយមនុស្ស ចំនួនបីទៅដប់នាក់ ដើរឆ្លងកាត់អន្លង់រាក់ៗ និងជួរថ្មរដិបរដុប ពីកន្លែងមួយទៅកន្លែងមួយទៀតនៅក្នុងទន្លេ។ ការនេសាទបែបនេះ គឺពេញនិយមខ្លាំងចំពោះយុវវ័យ និងអ្នកនេសាទមកពីឃុំព្រះរំកិល និងឃុំអូរស្វាយ នៅរដូវប្រាំង ដើម្បីចាក់ត្រីរស់ភាគច្រើន។

ប្រភេទឧបករណ៍ចុងក្រោយ គឺការប្រើកាំភ្លើងកៅស៊ូ។ ការនេសាទបែបនេះ អាចទុកជាប្រភេទល្បែងមួយ អនុវត្តភាគច្រើនដោយក្រុមយុវវ័យ នៅឃុំព្រះរំកិល និងឃុំអូរស្វាយ នៅពេលដែលពួកគេចេញទៅឃ្វាលក្របីនៅតាមកោះក្នុងទន្លេ ។ ឧបករណ៍នេះ បានប្រើដើម្បីបាញ់សត្វកង្កែប ដែលរស់នៅតាមគុម្ពព្រៃលិចទឹកភាគច្រើននៅខែមិនា និងមេសា។ ជួនកាល កាំភ្លើងកៅស៊ូនេះបានប្រើសំលាប់សត្វបក្សីទឹកនៅទីនោះ ដែល-ជាទង្វើមួយខុស ច្បាប់ផងដែរ។

សង្ខេបមកវិញ មានប្រភេទឧបករណ៍នេសាទចំនួន៧ ដែលប្រើប្រាស់ក្នុងតំបន់រ៉ាមសារ។ មានការនេសាទចំនួនពីរប្រភេទ បានប្រើប្រាស់ឧបករណ៍ទាំងនេះ គឺការនេសាទលក្ខណៈគ្រួសារ និងការនេសាទសិប្បកម្ម។ ការនេសាទជា លក្ខណៈគ្រួសារ គឺមិនត្រូវបង់ពន្ធ ដែលភាគច្រើនជាអ្នកនេសាទមកពីក្នុងភូមិ ឬអ្នកនេសាទតាមរដូវកាលមកពីកន្លែងផ្សេងៗ មកបោះជំរុំនៅតាមកោះ ឬតាមទួលនៅក្នុងទន្លេ។ ការនេសាទលក្ខណៈសិប្បកម្ម

គឺតម្រូវឱ្យបង់ពន្ធជូនរដ្ឋភាគច្រើនជាឧបករណ៍មងបណ្តែត អួនគោលដៅ និងអួនចល័ត ដែលអ្នកនេសាទទាំងនោះមិនមានទីលំនៅក្នុង តំបន់រ៉ាមសារទេ។ សិទ្ធិក្នុងការនេសាទ ក្នុងតំបន់រ៉ាមសារ មានលក្ខណៈបទបែនច្រើន។ ហេតុដូច្នេះ អ្នកនេសាទ ទាមទារនូវចំណេះដឹងច្រើនទាក់ទងនឹងប្រព័ន្ធអេកូឡូស៊ីទន្លេ និងដែរបស់វាដោយរួមទាំងចំណេះដឹងទៅលើការ បំលាស់ទីរបស់ត្រី និងការប្រែប្រួលរបបទឹកទន្លេ។ ចំណេះដឹងទាំងនេះហើយ ដែលធ្វើឱ្យអ្នកនេសាទអាចជ្រើស រើសឧបករណ៍ និងទីកន្លែងនេសាទបានសមស្របបំផុត។

នៅរដូវវស្សាចាប់ពីខែឧសភាដល់ខែកញ្ញា ឱកាសក្នុងការគ្រប់គ្រងតំបន់នេសាទ គឺទុកចំហ ព្រោះកម្រិតទឹកនៅខ្ពស់។ លើសពីនេះទៀតប្រភេទត្រីធំៗកំពុងតែរស់នៅរប៉ាត់រប៉ាយ។ ប៉ុន្តែចាប់ពីខែតុលាដល់ខែមេសា ឱកាសក្នុងការគ្រប់គ្រងតំបន់នេសាទសំខាន់ៗ គឺត្រូវបានគ្រប់គ្រងដោយអ្នកនេសាទ ដោយប្រើមងបណ្តែតអួនគោលដៅ និងចល័ត ជាពិសេស តំបន់នេសាទនៅក្នុងឃុំកោះស្នែង។

បច្ចុប្បន្ន ដែននេសាទក្នុងតំបន់រ៉ាមសារ បានក្លាយជាសេចក្តីប្រាថ្នា ពីអ្នកខាងក្រៅ ក្នុងការទាញផលប្រយោជន៍ជាអាតិបរិមា។ លើសពីនេះទៅទៀត ស្ថាប័នមូលដ្ឋានសំរាប់ការគ្រប់គ្រងសហគមន៍នេសាទ គឺពុំមានភាពច្បាស់លាស់ ហើយដំណើរការឯកជនភូបនីយកម្មនៅក្នុងខេត្ត បានបង្កើតឱ្យមានការប្រកួតប្រជែងគ្នា ពីអ្នកមកពីខាងក្រៅតំបន់ ដើម្បីគ្រប់គ្រងតំបន់នេសាទសំបូរត្រី ហើយទុកតំបន់ដែលមិនសូវសំបូរត្រីឱ្យអ្នកមូលដ្ឋានជាអ្នកគ្រប់គ្រង និងធ្វើការនេសាទ។

## ឥទ្ធិពលរបស់ទីផ្សារ និងរដ្ឋ

បណ្តាខេត្តភាគឥសាន្ត នៃប្រទេសកម្ពុជា គឺនៅរក្សាលក្ខណៈជនបទពុំសូវមមាញឹក ដោយសារតំបន់នេះត្រូវបានទុកឱ្យឯកោអស់មួយរយៈ ហើយបានបាត់បង់នូវឱកាសអភិវឌ្ឍន៍សេដ្ឋកិច្ច និងការផ្លាស់ប្តូរសង្គមដូចខេត្តដទៃនៅក្នុងប្រទេស។ ការស្រាវជ្រាវក្នុងទឹកដីឡាវ និងខេត្តស្ទឹងត្រែង ដោយ Daconto (២០០១) ជឿជាក់ថា សង្គ្រាមស៊ីវិលអូសបន្លាយ និងអស្ថេរភាព ដែលបានកើតឡើងនៅកម្ពុជា ជាច្រើនទសវត្សរ៍ បានរាំងស្ទះដល់ឱកាសអភិវឌ្ឍន៍ តំបន់តាមច្រកទន្លេមេគង្គក្នុងការធក់ឱកាសជាទីតាំងយុទ្ធសាស្ត្រផ្លូវពាណិជ្ជកម្មរបស់ខ្លួន។

តែទោះជាយ៉ាងណា បរិយាកាសឯកោ និងការពឹងលើខ្លួនឯង ទាំងផ្នែកនយោបាយ និងសេដ្ឋកិច្ច បានផ្លាស់ប្តូរចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ទី៨០ បន្ទាប់ពីមានការកែទំរង់នយោបាយ ដោយចាប់ផ្តើមផ្តោតទៅលើវិនិយោគទុនឯកជន និងទំនាក់ទំនងល្អជាមួយប្រទេសជិតខាង។ កត្តាទាំងនេះ ដោយរួមមានការសម្រេចបាននូវសន្តិភាពនៅកម្ពុជា និងការរីកចំរើនខ្លាំងនៅប្រទេសថៃ បានធ្វើឱ្យតំបន់ភាគឥសាន្តនៃខេត្តស្ទឹងត្រែងជា តំបន់មួយស្ថិតក្នុងបរិបទថ្មីស្រឡាង។ ទង្វើនេះ បានផ្តល់នូវឱកាសជាច្រើន សំរាប់ប្រជាជនតំបន់រ៉ាមសារ ដែលមានលក្ខណៈជាយុទ្ធសាស្ត្រ។

លោកទ្រី (២០០៤) បានបង្ហាញថា ការដកហូតធនធានធម្មជាតិ និងពាណិជ្ជកម្មនៅកម្ពុជាបានចាប់ផ្តើមក្នុងឆ្នាំ ១៩៨៩ នៅពេលដែលគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរបស់រដ្ឋាភិបាល បានចាប់ផ្តើមផ្លាស់ប្តូរពីរបបសង្គមនិយមមកកាន់របបទីផ្សារសេរីវិញ។ ដំណាក់កាលនេះ ត្រូវបានជំរុញដោយកំណើនឧបត្ថម្ភពីអន្តរជាតិ និង

ការធ្វើសមាហរណកម្ម ជាមួយកំលាំងទីផ្សារអន្តរជាតិ ក្នុងអំឡុងពេលគ្រប់គ្រងបណ្តោះអាសន្នរបស់អ៊ុនតាក់ ចាប់ពីឆ្នាំ ១៩៩១-១៩៩៣។

ទាក់ទងនឹងធនធានជលផល ការនាំត្រីចេញពីខេត្តទៅកាន់បរទេស និងទីក្រុងភ្នំពេញ បានចាប់ផ្តើមតាំងពីឆ្នាំ ១៩៩១។ ពេលនោះមានក្រុមហ៊ុនទិញត្រីមួយមកពីភ្នំពេញ ត្រូវបានផ្តល់សិទ្ធិទិញត្រីលក់ទៅប្រទេសឡាវ និង-ទីក្រុងភ្នំពេញ។ នៅពាក់កណ្តាលទសវត្សរ៍ទី៩០ មានក្រុមហ៊ុនទិញត្រីច្រើនបានប្រតិបត្តិនៅក្នុងខេត្ត។ សិទ្ធិត្រូវបានផ្តល់ផ្តាច់មុខចំពោះក្រុមហ៊ុនណា ឈ្នះការដេញថ្លៃ។ ប៉ុន្តែនៅរាល់ដំណាក់កាលដេញថ្លៃ មានមនុស្សជាច្រើនប្រភេទបានប្រកួតប្រជែងគ្នា ទាំងស្របនិងខុសច្បាប់ ដើម្បីទទួលយកសិទ្ធិនេះ។ មានប្រព័ន្ធនៃការផ្តល់សិទ្ធិមួយ គឺតាមរយៈការលក់អូរ ដែលភាគច្រើនអនុវត្តឡើង ដោយមន្ត្រីប៉ូលីស ឬយោធាក្នុងខេត្ត។ ជាក់ស្តែងនៅអូរតាឡាស ក្នុងឃុំព្រះរំកិល និងអូឈើទាលក្នុងឃុំកោះស្នែង ត្រូវបានលក់ ឱ្យមន្ត្រីយោធា ដោយការិយាល័យជលផលខេត្ត ហើយអូរទាំងនេះត្រូវបានបិទតាំងពីឆ្នាំ១៩៩៥ ដល់ឆ្នាំ ១៩៩៩។ សកម្មភាពនេះ ត្រូវបានតវ៉ាយ៉ាងខ្លាំងពីប្រជាជនមូលដ្ឋាន ហើយហេតុការណ៍នេះក៏បានចុះផ្សាយនៅក្នុងសារព័ត៌មានផងដែរ។ ហេតុដូច្នេះការតវ៉ាក៏ទទួលបានជោគជ័យផងដែរ។ វិធីសាស្ត្រ នៃការផ្តល់អជ្ញាប័ណ្ណស្របច្បាប់មួយផ្សេងទៀត គឺតាមរយៈក្រុមហ៊ុនលក់ និងទិញត្រី ដែលទទួលសិទ្ធិស្របច្បាប់ផ្ទាល់ពីក្រសួងពាក់ព័ន្ធ។ ឱកាសនៅក្នុងដំណើរការដេញថ្លៃបែបនេះ តែងតែទាក់ទងនឹងនយោបាយ ឬទំនាក់ទំនងញាតិសន្តាន។ វិធីសាស្ត្រនេះ បានធ្វើឱ្យប្រជាជនមូលដ្ឋានដែលពុំមានសិទ្ធិស្របច្បាប់បានក្លាយទៅជាអ្នកនេសាទខុសច្បាប់ ហើយមិនត្រូវបានអនុញ្ញាតិឱ្យនេសាទ ឬទិញជួរតាមរយៈដំណើរការស្របច្បាប់នេះ។ តែទោះជាយ៉ាងណា ការបន្តនេសាទរបស់ពួកគេ គឺមិនអាចចាត់ទុកថាខុសច្បាប់ទេ ព្រោះពួកគេមានសិទ្ធិនេសាទបែបប្រពៃណី។

ចំពោះធនធានព្រៃឈើក៏ដូចជលផលដែរ ព្រោះវាបានក្លាយជាគោលដៅដកហូតបែបសេដ្ឋកិច្ចដោយក្រុមហ៊ុនឯកជន ដែលទទួលសិទ្ធិពីរដ្ឋាភិបាល។ នៅឆ្នាំ១៩៩៩ រដ្ឋាភិបាលបានផ្តល់ដីសម្បទានសេដ្ឋកិច្ចដល់ក្រុមហ៊ុនម្យៅ ដំឡូងមី ចំនួនជាង៧៤០០ ហត ដែលភាគច្រើនជាដីព្រៃរបោះ និងព្រៃស្រោង។ ចាប់ពីពេលនោះមក សិទ្ធិប្រើប្រាស់ធនធាន ព្រៃឈើ របស់សហគមន៍ត្រូវបាន រិតត្បិត ព្រោះក្រុមហ៊ុនបានអះអាងថា រដ្ឋាភិបាលផ្តល់នូវសិទ្ធិផ្តាច់មុខឱ្យពួកគេ។

លោកទ្រី និងវណ្ណារ៉ា (២០០៤) បានពន្យល់ថា មុនក្រុមហ៊ុនសម្បទានមកដល់ ប្រជាជនមូលដ្ឋានអាច-ចូលព្រៃ ប្រមូលអនុផលព្រៃឈើ ដូចជាផ្សិត និងឱសថបុរាណ។ ឥឡូវ ពួកគេត្រូវសុំការអនុញ្ញាតពីអ្នកការពារព្រៃដែលពួក គេធ្លាប់ចូលដោយសេរីនោះ។ លើសពីនេះទៀត ប្រជាជនដែលមានដីស្រែរបស់ខ្លួន ស្ថិតនៅក្នុង-ដីក្រុមហ៊ុនសម្បទាន គឺមិនអាចចូលទៅធ្វើស្រែថែមទៀត។ ម្ចាស់ក្រុមហ៊ុនសម្បទាន បានអះអាងនូវសិទ្ធិស្របច្បាប់ថា ដីទាំងអស់ដោយរួមទាំងដីស្រែ និងព្រៃឈើ គឺជាកម្មសិទ្ធិរបស់ពួកគេ។ ហេតុដូចនេះ ក្រុមហ៊ុនសម្បទានបានបណ្តេញ កសិករមូលដ្ឋាន ដ៏មានប្រសិទ្ធភាពដែលពួកគេទាំងនោះត្រូវតែរកវិធីដោះស្រាយដើម្បីរករបរ និងប្រាក់ចំណូលថ្មី។ នៅក្នុងន័យនេះ ការពឹងផ្អែកទាំងស្រុងទៅលើការនេសាទ បានក្លាយជាយុទ្ធសាស្ត្រចំបងសំរាប់ប្រជាជនភាគច្រើន។ ស្របពេលនោះ សំពាធទៅលើតម្រូវការនេសាទដោយរួមទាំង ការនេសាទខុសច្បាប់ផង បានបណ្តាលឱ្យធនធានជលផលកាន់តែថយទៅៗ។

## លក្ខណៈ បុព្វហេតុ នៃភាពក្រីក្រ និងភាពងាយរងគ្រោះ

ការវាយតំលៃភាពងាយរងគ្រោះ កំណត់នូវអ្វីដែលចាត់ទុកថា ជាហានិភ័យនៅក្នុងសហគមន៍ ហើយសាកសួរពីហេតុផលហានិភ័យរបស់ពួកគេ។ ល័ក្ខខ័ណ្ឌអសុវត្ថិភាព អាចបណ្តាលមកពីភាពទន់ខ្សោយរចនាសម្ព័ន្ធនៃកម្មសិទ្ធិ ដូចជាសំភារៈសំណង់មិនមាំ ឬបណ្តាលមកពីស្ថានភាពសេដ្ឋកិច្ចសង្គម។ ការវាយតំលៃភាពងាយរងគ្រោះ បង្ហាញពីកម្រិតនៃការបំផ្លាញដែលអាគារមនុស្ស ឬវត្ថុផ្សេងៗទៀត ដូចជាធនធានធម្មជាតិ អាចទទួលរងគ្រោះ នៅក្នុងព្រឹត្តិ-ការ គ្រោះថ្នាក់ពីការបំពុលជាក់លាក់ណាមួយ។

យោងតាមការសិក្សាថ្មីៗដោយអង្គការសហភាពអភិរក្សពិភពលោក (IUCN) និងអង្គការ Action Aid (2003) បានបែងចែកភាពងាយរងគ្រោះជាបីកម្រិតនៅខេត្តស្ទឹងត្រែង គឺកម្រិតភូមិ គ្រួសារ និងសមត្ថភាពបុគ្គល។ ការវិភាគផលប៉ះពាល់កម្រិតគ្រួសារ និងភូមិបានផ្តោតទៅលើបញ្ហាសំខាន់ៗ៤យ៉ាង : ភាពសិករិចរិលព្រៃឈើ ធនធានជលផលថយចុះ ទឹកជំនន់ និងគ្រោះរាំងស្ងួត។ ការសិក្សាបានរកឃើញថា ប្រជាជនធ្លាប់រកបានប្រាក់ចំណូលច្រើន តែឥឡូវប្រាក់ចំណូលធ្លាក់ចុះពីរបររកស៊ី។ មានគ្រួសារមួយចំនួន រកប្រាក់ចំណូលតិច ហើយគ្រួសារមួយចំនួនខ្វះស្បៀងអាហារ ដែលនៅទីបំផុតបានធ្លាក់ខ្លួនស៊ីឈ្នួល ឬជំពាក់បំណុលគេ។ ដោយសារធនធានធម្មជាតិថយចុះ ប្រជាជនត្រូវបង្ខំចិត្តស្វះស្វែងរកមុខរបរចិញ្ចឹមជីវិតថ្មី ខុសពីអ្វី ដែលពួកគេធ្លាប់មានពីមុន។ ពួកគេភាគច្រើនពុំមានសមត្ថភាព ចំណេះដឹង ឬជំនាញផ្ទាល់ខ្លួនដើម្បីបង្កើននូវការផ្លាស់ប្តូរទាំងនេះ។ ជាផលវិបាក តម្រូវការ-មូលដ្ឋាន សំរាប់គ្រួសារបានកើនឡើង ហើយគ្រួសារអ្នកក្រស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះ និងការគំរាមកំហែងដើម្បីសង្គ្រោះជីវិត។

### *កម្រិតភូមិ*

ការសិក្សា បានកំណត់នូវភាពងាយរងគ្រោះជាច្រើននៅកម្រិតភូមិ។ ទី១ គឺភាពរាំងស្ងួត និងទឹកជំនន់ ដែលតែងតែបំផ្លាញផលដំណាំ។ ដោយសារវាជាផ្នែកមួយនៃភាពងាយរងគ្រោះ ប្រជាជនបានធ្វើការកត់ត្រា ពេលវេលានៃរដូវកាលប្រែប្រួល ដោយរួមទាំងស្ថានភាពភ្លៀងធ្លាក់នៅរដូវវស្សាថែមទៀត។ ការយល់ឃើញរបស់ប្រជាជនមូលដ្ឋាន ទាក់ទងនឹងអាកាសធាតុ គឺពិតជាមានសារៈសំខាន់ ព្រោះខេត្តស្ទឹងត្រែងមានស្ថានីយឧតុនិយមតែមួយកន្លែង។ យោងតាមការវាយតំលៃថ្មីៗ នៅភូមិចំនួនពីរ (ក្រឡាពាស និងកោះជ្រើម) ដោយ Docelmascolo (២០០៤) បង្ហាញថា នៅកោះជ្រើមរដូវភ្លៀងធ្លាក់បានចាប់ផ្តើមយឺតជាង២ខែ បើប្រៀបធៀបនឹងភូមិក្រឡាពាស ព្រោះភ្លៀងធ្លាក់បានចាប់ផ្តើមយឺតជាង៥សប្តាហ៍ ហើយបញ្ចប់ទៅវិញមុន៣សប្តាហ៍។ សហគមន៍ទាំងពីរ ក៏បានកត់ត្រាផងដែរនូវប្រវត្តិភាពរាំងស្ងួតនៅក្នុងតំបន់ពួកគេ។ នៅភូមិក្រឡាពាស ក្នុងឆ្នាំ១៩៩៩ ប្រជាជនបានចាំថាជាឆ្នាំដែលមានភាពរាំងស្ងួតខ្លាំង តែចំពោះភូមិកោះជ្រើម គឺក្នុងឆ្នាំ២០០០ និង២០០៣ ចាត់ទុកថាជាឆ្នាំអាក្រក់បំផុត។ យោងតាមលទ្ធផល នៃការសិក្សាបង្ហាញថា អ្នកភូមិទទួលស្គាល់នូវភាពរាំងស្ងួតខុសៗគ្នា។

បុព្វហេតុទី២នៃភាពងាយរងគ្រោះ គឺបណ្តាលមកពីការដកហូតធនធានព្រៃឈើ និងធនធានតំបន់ដីសើម ធនធានអនុផលព្រៃឈើ ការបរបាញ់សត្វ និងជួញដូរសត្វព្រៃ ការកាប់ព្រៃឈើខ្នាតធំហួសកំរិត និងការធ្វើកសិកម្មដោយកាប់ និងដុតព្រៃ។ កំណើនសំពាធពីអ្នកមកពីខាងក្រៅ និងភាពអសមត្ថភាពរបស់ប្រជាជនក្នុងការ

ប្រកួតប្រជែងក្នុងការនេសាទ និងកង្វះខាតនៃការការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នរដ្ឋ គឺជាផ្នែកមួយនៃភាពងាយរងគ្រោះផងដែរ។ វាជាការពិតណាស់ ដែលអ្នកភូមិមួយចំនួនបានជ្រើសយកការកាប់ឈើខុសច្បាប់ ដើម្បីបង្គ្រប់ប្រាក់ចំណូលរបស់ពួកគេ។ បញ្ហានេះ ត្រូវដោះស្រាយដោយប្រុងប្រយ័ត្ន ដោយសារសិទ្ធិប្រើប្រាស់នៅក្នុងតំបន់នេះ ពុំមានភាពច្បាស់លាស់។ ចំពោះអនុផលព្រៃឈើដូចជាដើមជ័រទឹក និងផ្តៅ ត្រូវការសិក្សាបន្ថែមដើម្បីផ្ទៀងផ្ទាត់ជាមួយផលប៉ះពាល់ ដែលបណ្តាលមក ពីបម្រែបម្រួលអាកាសធាតុ។

ការធ្វើអង្កេតស្រាវជ្រាវ ដោយអ្នកភូមិទៅលើផលិតផលទាំងនេះអាចមានសារសំខាន់ ប៉ុន្តែបញ្ហាគ្រប់គ្រង ជាពិសេសទាក់ទងនឹងសិទ្ធិ និងឱកាស គឺត្រូវចាត់ចែងដោយប្រុងប្រយ័ត្ន។ ភូមិទាំងពីរ គឺមានការពឹងអាស្រ័យខ្លាំងទៅលើធនធានវារី ជាពិសេសកង្កែប និងត្រកួត។ សត្វកង្កែប មានការប្រែប្រួលខ្លាំងទៅតាមលំនាំអាកាសធាតុ។ ហេតុដូច្នេះ ការសិក្សា បន្ថែមទៅលើតំបន់នេះ អាចបង្កើតនូវការចាប់អារម្មណ៍ពីប្រជាជនដែលពឹងផ្អែកលើសត្វកង្កែប ដើម្បីធ្វើជាអាហារតាមមូលដ្ឋាន។

## *កម្រិតគ្រួសារ*

បុព្វហេតុសំខាន់ នៃភាពងាយរងគ្រោះនៅកម្រិតគ្រួសារ គឺការបាត់បង់ធនធានតំបន់ដីសើម (ព្រៃឈើ សត្វព្រៃ និងអនុផលព្រៃឈើ) ដោយសារការដកហូតធនធានហួសកម្រិត និងបាតុភូតធម្មជាតិដូចជា ទឹកជំនន់ និងគ្រោះរាំងស្ងួតដែលបំផ្លាញដំណាំស្រូវ និងមធ្យោបាយចិញ្ចឹមជីវិតផ្សេងៗទៀត ដោយរួមទាំងកង្វះខាតនូវធនធានដើម្បីប្រកួតប្រជែងជាមួយអ្នកដែលមានកាណូត និងមធ្យោបាយទំនើបៗក្នុងការធ្វើនេសាទ។ ការអនុវត្តច្បាប់ដោយស្ថាប័នពាក់ព័ន្ធ និងសហគមន៍ មូលដ្ឋាន នៅមានកម្រិត ហើយបានប៉ះពាល់ខ្លាំងដល់អ្នកក្រ ដោយពុំមានសមត្ថភាពប្រជែងជាមួយអ្នកមានធនធាន។ អ្នកក្រ អ្នកក្រទ័ល និងស្ត្រីមេម៉ាយ ជាអ្នកងាយរងគ្រោះបំផុតនៅកម្រិតភូមិ។ ស្ថានភាពពួកគេ កាន់តែលំបាកចាប់តាំងពី ទសវត្សរ៍ ទី៩០ ហើយគ្រួសារងាយរងគ្រោះទៅនឹងសន្តិសុខស្បៀង។

អ្នកក្រ បានពឹងអាស្រ័យខ្លាំងទៅលើធនធានធម្មជាតិដើម្បីចិញ្ចឹមជីវិត និងសន្តិសុខស្បៀង ហើយភាពងាយរងគ្រោះ នឹងកើនឡើងនៅពេលដែលធនធានត្រូវបានបាត់បង់ ឬស្រុតចុះ។ នៅក្នុងការប្រជែងទៅលើធនធានបាត់បង់ គ្រួសារអ្នកក្រពុំមានសំភារៈគ្រប់គ្រាន់ ដូចជាកាណូត ក្របី និងគោ និងការធ្វើជំនួញទាំងខាងក្នុង និងខាងក្រៅភូមិ ដូចអ្នកមានធនធានទេ។ បន្ទាប់ពីឆ្លងកាត់គ្រោះទឹកជំនន់ និងរាំងស្ងួត គ្រួសារអ្នកក្រតែងតែបង្កើនការដកហូតធនធានធម្មជាតិ ដើម្បីបំពេញនឹងការបំផ្លាញ។

## *បុព្វហេតុនៃភាពក្រីក្រ*

យោងតាមរបាយការណ៍របស់អង្គការសហភាពអភិរក្សពិភពលោក (IUCN) និង អង្គការ Action Aid ឆ្នាំ ២០០៣ បានចុះបញ្ជី នៃកត្តាដែលភាពក្រីក្រនៅតំបន់រ៉ាមសារ និងភូមិផ្សេងៗ អាចត្រូវបានវាយតំលៃ (តារាង ៣.៨)។

**តារាង ៣.៨ បុព្វហេតុ នៃភាពក្រីក្រនៅភូមិចំនួនបី**

| **កោះជ្រឹម** | **ក្រឡាពាស (រ៉ាមសារ)** | **បានហួយ** |
| --- | --- | --- |
| • ធនធានតំបន់ដីសើមថយចុះ<br>• ភាពមិនស្មើគ្នា នៃការផលហូត ធនធានតំបន់ដីសើម។ អ្នកធូធារមានឱកាសច្រើន ជាងអ្នកក្រ<br>• ចំនួនសមាជិកគ្រួសារច្រើនពេក។ អ្នកក្រ មានសមាជិកច្រើន ពិបាករស់ទំហំ ដីដូចគ្នា<br>• តំលៃចំណាយច្រើនជាងប្រាក់ចំណូល<br>• ការឧបត្ថម្ភអភិវឌ្ឍន៍ ពីផ្នែកផ្សេងៗ មានកម្រិត និងយឺតយ៉ាវ | • ខ្វះកំលាំងអូសទាញសត្វពាហន<br>• ដីស្រែតូច និងបានផលទាប<br>• ដីស្រែលិចទឹក<br>• ដីស្រែមិនសូវមានជីជាតិ<br>• ភាពរាំងស្ងួត<br>• បញ្ហាសត្វល្អិតចង្រៃបំផ្លាញ ស្រូវ<br>• កង្វះខាតជំនាញ និងចំណេះ ដឹង<br>• បញ្ហាជំងឺរ៉ាំរ៉ៃមានស្រាប់<br>• បាត់បង់ព្រៃឈើ<br>• គ្មានទីផ្សារសំរាប់អនុផលព្រៃឈើ និងដំណាំអនុផល។ | • ខ្វះធនធានមនុស្ស<br>• មេគ្រួសារជាស្ត្រី ឬមានស្រីមេម៉ាយច្រើនពេក<br>• កង្វះខាតសត្វពាហន<br>• គ្មានទូក ឬកាណូតសំរាប់ដឹកអនុផលព្រៃឈើ និងត្រី<br>• គ្មានសំភារៈសមស្រប សំរាប់ផលហូតផលិតផលព្រៃឈើ<br>• គ្មានសំភារៈ នេសាទទំនើប<br>• គ្មានជំនាញក្នុងការផលហូតធនធានព្រៃឈើ និងអនុផលព្រៃឈើ<br>• តែងតែរងគ្រោះដោយគ្រោះធម្មជាតិ ដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត និងសត្វល្អិត បំផ្លាញដំណាំ។<br>• ខ្វះមជ្ឈមណ្ឌលសុខភាព ហើយ ប្រជាជន រងគ្រោះដោយជំងឺឆ្លង<br>• ចំណាយចវិកាច្រើន ទិញថ្នាំព្យាបាល |

**ប្រភព:** ដកស្រង់ពីរបាយការណ៍ អង្គការ IUNC និង Action Aid ឆ្នាំ២០០៣

សង្ខេបមកវិញ ធម្មជាតិនៃភាពក្រីក្រ និងភាពងាយរងគ្រោះ ដោយរួមទាំងបុព្វហេតុ និងសុចនាករ គឺមានភាពខុសគ្នាពីតំបន់នីមួយៗ។ ប្រជាជនអាចធ្លាក់ខ្លួន និងងាយរងគ្រោះទៅតាមពេលវេលា ទីកន្លែង និងវិធីផ្សេងៗគ្នា។

## *គ្រោះធម្មជាតិ*

ខេត្តស្ទឹងត្រែង មានសក្តានុពលធនធានទឹកខ្ពស់ ដូចជាទន្លេ ស្ទឹង ព្រែក ប៉ុន្តែគ្មានអាងស្តុកទឹក ឬប្រព័ន្ធធារាសាស្ត្រ។ តារាង ៣.៩ បង្ហាញពីតំលៃសេដ្ឋកិច្ច បណ្តាលមកពីគ្រោះទឹកជំនន់នៅខេត្តស្ទឹងត្រែង ចាប់ពីឆ្នាំ ២០០០ ដល់ ២០០២។ ទោះបី គ្រោះទឹកជំនន់នៅខេត្តស្ទឹងត្រែងមានកម្រិតទាប បើប្រៀបធៀបនឹងតំបន់ផ្សេងៗ

នៃប្រទេសកម្ពុជា ក៏ការបាត់បង់ នៅតែមានសារៈសំខាន់ និងគ្រោះថ្នាក់ដល់បុគ្គលផងដែរ។

**តារាង ៣.៩ គ្រោះទឹកជំនន់នៅខេត្តស្ទឹងត្រែង ចាប់ពីឆ្នាំ ២០០០-២០០២**

| បញ្ជី នៃការខូចខាត | ២០០០ | | ២០០១ | | ២០០២ | |
|---|---|---|---|---|---|---|
| | បរិមាណ | តំលៃប៉ាន់ស្មាន (ដុល្លារ) | បរិ-មាណ | តំលៃប៉ាន់ស្មាន (ដុល្លារ) | បរិមាណ | តំលៃប៉ាន់ស្មាន (ដុល្លារ) |
| ផ្ទះ | ៧ | ១០.៥០០ | ៣ | ១.៥០០ | ៣ | ២៥០០ |
| ចំនួនគ្រួសាររងគ្រោះ | ៤.៩៦៨ | | ៧.៥៤៣ | | ៤៤០ | |
| ចំនួន សត្វពាហនៈ-ស្លាប់ (ក្បាល) | | | ១២៥ | ២.០០០ | | |
| ស្រូវវស្សា (ហត) | ២.៨៥៤ | ៣៨៦.៨១៥ | ២.៧២២ | ៤០៨.៣០០ | ១.១៤៩ | ១៧២.៣៥០ |
| ដំណាំកសិកម្ម (ហត) | ២៣៨ | ១១៩.០០០ | ២២០ | ៣២.៩៩០ | ២៩១ | ៣៥.២០០ |
| ផ្លូវក្រាលគ្រួស (ម$^2$) | ១៨.០០០ | ១០៦.៦៣២ | ២.០២០ | ៥០.៥០០ | ១.២០០ | ៣០.០០០ |
| ផ្លូវក្រាលក្រហម (ម$^2$) | ៥៧.០០០ | ២៨.១៣៩ | ៤៩.៨៤៤ | ១១១.១១០ | ៨.៧៧២ | ១៩.២៩០ |
| លូ | ១ | ៥.៨០០ | ៤៦ | ៥.០០០ | ២៤ | ២.៦០០ |
| ស្ពាន | ១៩ | ៨៦.៣៨០ | ៧៩៤ | ១៩៦.០០០ | ៣០៥ | ៧៥.៣០០ |
| សាលារៀន | ២ | ១.២១៨ | ៣ | ១០.០០០ | | |
| សរុប | | ៧០៤.៤៨៤ | | ៨១៧.៤០០ | | ៣៣៧.២៤០ |

**ប្រភព:** មន្ទីរផែនការខេត្ត ឆ្នាំ ២០០៣

ចំពោះតំបន់រ៉ាមសារ ការសិក្សារបស់អង្គការ IUCN និង Action Aid ឆ្នាំ២០០៣ នៅភូមិក្រឡាពាស បានបង្ហាញថា នៅឆ្នាំ១៩៩៩ គ្រោះទឹកជំនន់មានលក្ខណៈធ្ងន់ធ្ងរ ហើយត្រូវបានធ្វើការសិក្សាបន្ថែមដោយ Docenmascolo ឆ្នាំ២០០៤ សំរាប់ធ្វើការស៊ើបអង្កេតពីភាពងាយរងគ្រោះ។ ករណីសិក្សា បានរកឃើញថាការបំផ្លាញដំណាំស្រូវមានសារៈសំខាន់ ហើយមានប្រហែល៣០% នៃទិន្នផលត្រូវបានបាត់បង់រាល់ព្រឹត្តិការបែបនេះ។ ដោយសារទិន្នផលស្រូវទទួលបាន១តោនក្នុង១ហត ហើយគ្រួសារដែលមានសមាជិក៥នាក់ ត្រូវការស្រូវចំនួន៦០ហាបសំរាប់ការបរិភោគប្រចាំឆ្នាំ ហេតុដូច្នេះ ការបាត់បង់ទិន្នផលផ្ទួនៗពិតជាមានផលវិបាកច្រើន។ នៅភូមិក្រឡាពាស អ្នកឆ្លើយនឹងសំនួរចំនួន១០នាក់បានរាយការណ៍ ទិន្នផលបាត់បង់ ៤នាក់បានឆ្លើយថាត្រូវខូចខាតចាប់ពី៤០-៦០% បីនាក់បានឆ្លើយថា ៨០-៩០% ខូចខាត ហើយចំនួនបីនាក់ទៀត បានឆ្លើយថាទិន្នផលស្រូវ ត្រូវបំផ្លាញទាំងស្រុង។

ភូមិក្រឡាពាស បានបាត់បង់នូវដំណាំមានតំលៃ ដូចជាអំពៅ និងចេកជាដើម។ ការបាត់បង់ដំណាំ ដូចជា ម្ទេស ត្រប់ ល្ពៅ និងសូនដំណាំផ្សេងៗ ក៏ត្រូវរាយការណ៍ផងដែរ។ កង្វះខាតដំណាំហូបផ្លែ និងបន្លែផ្សេងៗ បាន ប៉ះពាល់ដល់ផ្នែកអាហារូបត្ថម្ភ។ គេអាចសន្និដ្ឋានផងដែរ ការបាត់បង់ប្រហាក់ប្រហែលគ្នាអាចកើតឡើងនៅ ទូទាំងតំបន់វ៉ាមសារ ក្នុងអំឡុងពេលដែលមានទឹកជំនន់។

## យុទ្ធសាស្ត្រប្រើដើម្បីកាត់បន្ថយភាពងាយរងគ្រោះ

យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ត្រូវតែមានលក្ខណៈឆ្លើយតប និងបត់បែនតាមកាលៈទេសៈនៅតាម មូលដ្ឋាន។ យុទ្ធសាស្ត្របង្ហាញនៅទីនេះ គឺតំណាងឱ្យវិធីសាស្ត្រទូទៅ ដែលនឹងអាចអនុវត្តបានទៅលើតម្រូវការ ជាក់លាក់នៅតាមតំបន់បង្ហាញនីមួយៗ។

យុទ្ធសាស្ត្រដែលប្រជាជននៅតាមភូមិប្រើ ដើម្បីប្រឈមនឹងភាពងាយរងគ្រោះ រួមមានការរៀបចំដក ហូតធនធានតំបន់ដីសើម តាមរយៈការបង្កើតសហគមន៍ព្រៃឈើ បង្កើតធនាគារស្រូវ សំរាប់ផ្តល់កម្ចីយកការ ទាប គំរោងឥណទាន និងធនាគារសត្វពាហនៈ។ ដើម្បីប្រឈមនឹងភាពងាយរងគ្រោះ អ្នកភូមិបានសំនូមពរឱ្យ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័ន ពាក់ព័ន្ធផ្សេងៗជួយ ។ បច្ចុប្បន្ន យុទ្ធសាស្ត្រទាំងនេះ ពុំទាន់មានការ អភិវឌ្ឍន៍ល្អទេនៅក្នុងតំបន់វ៉ាមសារ។

ចំពោះយុទ្ធសាស្ត្រដែលប្រើនៅកម្រិតគ្រួសារ ក្នុងការប្រឈមនឹងភាពងាយរងគ្រោះ គឺការបង្កើនកំលាំង ពលកម្ម។ នៅកម្រិតនេះ ប្រជាជនបានព្យាយាមពង្រីកផ្ទៃដីស្រែ-ចំការ ចិញ្ចឹមសត្វ ដកហូតធនធានតំបន់ដី សើម ដូចជាត្រី និងអនុផល ព្រៃឈើ ទៅតាមសមត្ថភាពដែលពួកគេមាន។ គ្រួសារជាច្រើន បានព្យាយាមបង្វែ ប្រភពចិញ្ចឹមជីវិត។ ចំពោះគ្រួសារ ដែលពុំមានធនធានមនុស្ស ឬគ្រួសារដែលដឹកនាំដោយស្ត្រី គឺមានការលំបាក ក្នុងការទទួលធនធានមនុស្ស និងហិរញ្ញវត្ថុ ដើម្បីជំនះនូវ ភាពងាយរងគ្រោះបណ្តាលមកពីភាពសិករិចរិលធន- ធានធម្មជាតិ និងធនធានតំបន់ដីសើម។ ទាំងនេះ ត្រូវការការគាំទ្ររួម ដើម្បីបង្វែជីភាពរស់នៅ និងកាត់បន្ថយ ភាពងាយរងគ្រោះរបស់ពួកគេ។

តម្រូវការមួយដែលចាំបាច់ គឺការសហការ និងសម្រសម្រួលស្ថាប័ន។ ដើម្បីរក្សា និងបង្កើតកម្រិតជីវ ភាពរស់នៅរបស់ពួកគេ អ្នកភូមិមានជំនឿថា អង្គការមិនមែនរដ្ឋាភិបាល អាចសហការជាមួយរដ្ឋាភិបាល ជួយ- ពួកគេគ្រប់គ្រង និង រក្សាធនធានធម្មជាតិ ដែលជាប្រយោជន៍ជីវភាពរបស់ខ្លួន និងមនុស្សជំនាន់ក្រោយ។ វិធាន ការទាំងនេះ រួមមានកម្មវិធី សហគមន៍ព្រៃឈើ និងជលផលជាដើម។

## សង្ខេប

របទនាសម្ព័ន្ធភូមិ ភាគច្រើននៅតំបន់វ៉ាមសារ មានការរៀបចំល្អតាំងពីយូរលង់ណាស់មកហើយ ទាក់ទង នឹងបទដ្ឋាន សមភាព និងការចែករំលែកនូវធនធាន។ ការធ្វើស្រែ (ស្រែស្រូវ និងស្រែចំការ) បានចាត់ទុកថាជា របរសំខាន់សំរាប់គ្រួសារទាំងអស់។គ្រប់គ្រួសារទាំងអស់ មានឱកាសគ្រប់គ្រងដីធ្លី ទោះបីតិច ឬច្រើនក្តី។ សកម្ម ភាពចិញ្ចឹមជីវិតសំខាន់ៗនៅ តំបន់វ៉ាមសារ ឬតាមដងទន្លេ អាចសង្ខេបដូចខាងក្រោម។

ការធ្វើស្រែ និងនេសាទ គឺជាមុខរបរសំខាន់បំផុត សំរាប់គ្រួសារស្ទើរតែទាំងអស់។ ការនេសាទ ធ្វើឡើងសំរាប់ បរិភោគក្នុងគ្រួសារ និងលក់ផងដែរ។ ការចិញ្ចឹមសត្វ (ជ្រូក មាន់ គោ និងក្របី) គឺជាមុខរបរ និងប្រភពប្រាក់ចំណូលបន្ថែមសំរាប់ គ្រួសារជាច្រើន។ សត្វមាន់ អាចប្រើសំរាប់បរិភោគក្នុងគ្រួសារ តែសត្វពាហន អាចប្រើសំរាប់លក់នៅផ្សារ ដើម្បីយកមកប្រើតាមតម្រូវការចាំបាច់ផ្សេងៗ ដូចជា ថ្នាំពេទ្យ បង់ថ្លៃសាលារៀន ជាដើម ។

គ្រួសារភាគច្រើន ពាក់ព័ន្ធក្នុងការប្រមូលអនុផលព្រៃឈើ ដែលជាប្រភពប្រាក់ចំណូលបន្ថែម ដូចជាផ្តៅ និងដងជ័រ លក់យកថវិកាសំរាប់តម្រូវការគ្រួសារ។ ការបរបាញ់សត្វ ក៏ជាមុខរបរបន្ទាប់បន្សំផងដែរ។ ទង្វើនេះបានធ្វើឡើងសំរាប់ការ បរិភោគប្រចាំគ្រួសារ លក់តាមមូលដ្ឋាន និងទីផ្សារខេត្តស្ទឹងត្រែង និងប្រទេសឡាវ។

អ្នកភូមិភាគច្រើនរស់នៅតាមដងទន្លេ ប្រហែល៣០%នៃគ្រួសារសរុប បានដាំដំណាំតាមច្រាំង និងបាតទន្លេ។ គ្រួសារមួយចំនួន មានសួនដំណាំនៅជុំវិញផ្ទះ។ ប្រជាជន ក៏បានបេះបន្លែព្រៃនៅរដូវវស្សា យកមកបរិភោគប្រចាំថ្ងៃ និងលក់នៅទីផ្សារ។ ឬស្សី ត្រូវបានកាប់ពីព្រៃផងដែរ ដើម្បីលក់ក្នុងភូមិ និងក្រៅភូមិ។ លើសពីនេះទៅទៀត ការដាំដំណាំចម្រុះ ដូចជា ចេក សណ្តែក ពោត ដំឡូង និងឥឡឹក គឺជាមុខរបររួមផ្សំមួយដែរ។ តែដោយមានសំពាធទីផ្សារ និងកំណើនពាណិជ្ជកម្ម ឯកជន សហគមន៍ទាំងនេះមិនអាចគេចផុតពីផលប៉ះពាល់ទាក់ទង នឹងវិសមភាព ក្នុងការដកហូតធនធាន ព្រៃឈើ និងជលផល។ ស្ថានភាពសេដ្ឋកិច្ច និងសង្គម នៃភាពឯកកោ និងពឹងលើខ្លួនឯង បានផ្លាស់ប្តូរតាំងពីទសវត្សរ៍ទី៨០ បន្ទាប់ពីមានកំណែទំរង់នយោបាយ លើកកំពស់វិស័យវិនិយោគទុនឯកជន និងមានទំនាក់ទំនងល្អជាមួយប្រទេសជិតខាង។ កត្តាទាំងនេះ ដោយរួមមានការសំរេចបាននូវសន្តិភាពក្នុងប្រទេស និងការអភិវឌ្ឍន៍ច្រើននៅប្រទេសថៃ ឥឡូវបានចាត់ទុកតំបន់ភូមិភាគ ឥសាន្តប្រទេសកម្ពុជា ជាបរិបទមួយថ្មីស្រឡាងក្នុងការផ្តល់ នូវឱកាសជាច្រើនសំរាប់ប្រជាជនមូលដ្ឋាន ជាយុទ្ធសាស្រ្តក្នុងខេត្តស្ទឹងត្រែង គឺតំបន់រ៉ាមសារ។

គ្រួសារមួយចំនួន អាចរកបានប្រាក់ចំណូលតិចតួច ស្របពេលដែលគ្រួសារមួយចំនួនទៀត ពុំមានស្រូវហូបគ្រប់គ្រាន់ ដែលទីបំផុតបង្ខំលក់កំលាំងពលកម្ម ឬជំពាក់បំណុលគេ។ ដោយសារធនធានធម្មជាតិថយចុះ ប្រជាជនមួយចំនួនបានស្វែងរកមុខរបរថ្មី ខុសពីមុន។ ជាផលវិបាក តម្រូវការមូលដ្ឋានសំរាប់គ្រួសារបានកើនឡើង ហើយគ្រួសារក្រីក្រស្ថិតនៅក្នុងស្ថានភាព ងាយរងគ្រោះដើម្បីចិញ្ចឹមជីវិត។ យុទ្ធសាស្រ្តដែលបានបកស្រាយនៅក្នុងជំពូកនេះ គឺមានលក្ខណៈទូទៅ ដែលអាចអនុវត្តបានទៅតាមតម្រូវការជាក់លាក់មួយចំនួននៅតាមភូមិ។

ការគំរាមកំហែងមួយទៀតចំពោះតំបន់រ៉ាមសារ គឺគ្រោះធម្មជាតិ។ ចាប់ពីឆ្នាំ ២០០០ ដល់២០០៣ គ្រោះទឹកជំនន់ បានកើតឡើងនៅក្នុងខេត្ត។ កត្តានេះ បណ្តាលមកពីភ្លៀងខ្លាំងផង និងការបើកទឹកពីទំនប់វារីអគ្គិសនីពីទន្លេសេសាន ប្រទេសវៀតណាម។ ម្យ៉ាងទៀតគ្រោះរាំងស្ងួត បានកើតឡើងជាប្រចាំ ហើយបានបំផ្លាញដំណាំស្រូវវស្សាភាគច្រើននៅក្នុងតំបន់រ៉ាមសារ។ ដោយសារទិន្នផលស្រូវបានបំផ្លាញ និងថយចុះ ប្រជាជនត្រូវស្វែងរកនូវជម្រើសសំរាប់ចិញ្ចឹមជីវិត ដូចជាបរបាញ់ សត្វ និងនេសាទត្រីខុសច្បាប់ជាដើម។ ទង្វើនេះ បានដាក់សំពាធខ្លាំងទៅលើធនធានតំបន់ដីសើមនៃតំបន់រ៉ាមសារ ដែលពុំទាន់មានក្របខ័ណ្ឌច្បាប់ និងការគ្រប់គ្រងធនធានធម្មជាតិច្បាស់លាស់នៅឡើយ។

# ជំពូក៤: បរិស្ថាន និង ជីវៈចម្រុះ

## សេចក្តីផ្តើម

ជំពូកនេះ បង្ហាញព័ត៌មានពីលក្ខណៈបរិស្ថានតំបន់រ៉ាមសារ និងតំបន់នៅជុំវិញរបស់វា ។ មានក-រណីជាច្រើន ដែលព័ត៌មានមិនសូវសំបូរ ទាក់ទងនឹងផ្នែកនេះ ។

## អាកាសធាតុ



អាកាសធាតុនៅខេត្តស្ទឹងត្រែង ក៏ដូចជានៅទូទាំងប្រទេសដែរដែលទទួលរងសំពាធខ្យល់មូសុងបក់ទៅមក រវាងទិសនិរតី និងទិសឦសាន ។ រដូវវស្សាមានខ្យល់បក់ពីទិសនិរតីចាប់ផ្តើមពីខែឧសភា ដល់ខែកញ្ញា ។ រដូវរងាមានខ្យល់បក់ពីទិសឦសាន ចាប់ពីខែវិច្ឆិកា ដល់ខែមិនា ហើយពីខែមេសាដល់តុលាជារដូវឆ្លងកាត់ បណ្តោះ អាសន្ន។ ភ្នំខ្ពស់ៗតាមឆ្នេរសមុទ្រនៅប្រទេសវៀតណាម បានធ្វើជារនាំង ខេត្តស្ទឹងត្រែង នៅពេលមានខ្យល់មូសុងត្រជាក់ស្ងួតខ្លាំងបក់ពីទិសឦសាន ។ នៅពេលនេះ ជាពិសេសនៅខែធ្នូ និងមករាខ្យល់ត្រជាក់បំផុតបក់ពីអាស៊ីកណ្តាល មកកាន់ភាគឦសាននៃកម្ពុជា ។ ចាប់ពីខែកុម្ភៈទៅ ខ្យល់ខាងត្បូងនាំយកខ្យល់ក្តៅមកជាមួយដែលធ្វើឱ្យអាកាសធាតុក្តៅបំផុតរហូតដល់ខែឧសភា ។

ទិន្នន័យទឹកភ្លៀងមធ្យមប្រចាំឆ្នាំសំរាប់ខេត្តស្ទឹងត្រែងពីឆ្នាំ ១៩៩៤-២០០០ បង្ហាញជូននៅតារាង ៤.១ ( CTIA, ២០០២) ។ ទិន្នន័យនេះ បង្ហាញថាមានភ្លៀងខ្លាំងតាមរដូវដែលភ្លៀង ៨៤ ភាគរយមាននៅខែឧសភា និងតុលា ។ តែខែខ្លះ ដូចជាចាប់ពីវិច្ឆិកាដល់ខែកុម្ភៈមិនមានភ្លៀងសោះ ។ ខែមិថុនា ឆ្នាំ ២០០០ មានភ្លៀងធ្លាក់ខ្ពស់ជាងគេបំផុតគឺ ៥១៩.៣ មម ។ កំរិតទឹកភ្លៀងប្រចាំឆ្នាំខ្ពស់ គឺចាប់ពី ១៤៤១.៣ មម(ឆ្នាំ ១៩៩៦) ដល់ ២៦០០.២ មម (ឆ្នាំ ២០០០) ។

មានស្ថានីយ៏កត់ត្រាអាកាសធាតុ៦នៅក្នុងខេត្តស្ទឹងត្រែង។ ទិន្នន័យពីអាកាសធាតុអាចមានតែសំរាប់ឆ្នាំ២០០៣ និង២០០៤ ដែលទិន្នន័យនោះ គឺជាមធ្យមភាគសំរាប់ស្ថានីយ៏២ក្នុងទីរួមខេត្តដែលបានបង្ហាញជូននៅតារាង៤.២។ ទឹកភ្លៀងប្រែប្រួលខ្លាំងនាពេល២ឆ្នាំ (១៣៧៣ មម ដល់ ១៨០៧ មម) ដែលដូចគ្នាទៅនឹងសី-តុណ្ហភាពប្រចាំឆ្នាំដែរគឺ ៣៣អង្សា ទៅ៣៦.៥ អង្សា។

ដូចនេះ សីតុណ្ហភាពប្រែប្រួលខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំនៅខេត្តស្ទឹងត្រែង ។ ការប្រែប្រួលនេះគឺជាលក្ខណៈពិសេសរបស់បរិស្ថាន ដែលអ្នកភូមិនៅតំបន់រ៉ាមសារត្រូវប្រឈមមុខ។ ទឹកភ្លៀងនៅរដូវដាំស្រូវ មាន-សារៈសំខាន់ណាស់សំរាប់ ដំណាំស្រូវ ។

**តារាង ៤.១ មធ្យមភាគទឹកភ្លៀងប្រចាំខែសំរាប់ខេត្តស្ទឹងត្រែង នាឆ្នាំ ១៩៩៤_២០០០**

| ខែ | មធ្យមភាគទឹកភ្លៀង ១៩៩៤_២០០០ (មម) | % នៃមធ្យមភាគប្រចាំឆ្នាំ | គំរិតប្រចាំឆ្នាំ ១៩៩៤_២០០០ (មម) |
|---|---|---|---|
| មករា | ០.៩ | ០.១ | ០_៥.១ |
| កុម្ភៈ | ១.២ | ០.២ | ០_៥.៧ |
| មិនា | ៤៣.៩ | ២.២ | ៤.០_១២១.២ |
| មេសា | ១៦៧.៨ | ៨.៥ | ២២_៤០៣.៨ |
| ឧសភា | ២៤៩.២ | ១២.៧ | ១១៦.៦_៤៤៣.៤ |
| មិថុនា | ២៤៥.០ | ១២.៥ | ៦៥.៤_៥១៩.៣ |
| កក្កដា | ២៨៩.៤ | ១៤.៧ | ១០៦.៨_៤២៤.៦ |
| សីហា | ៣៣៣.៤ | ១៧.០ | ២៤៥.៧_៤០៤.៣ |
| កញ្ញា | ៣០៨.៤ | ១៥.៧ | ១៧៦.៤_៤៥៨.១ |
| តុលា | ២២៨.៨ | ១១.៦ | ១០៦.៧_៣៨៩.៨ |
| វិច្ឆិកា | ៨២.០ | ៤.២ | ០_២៤២.០ |
| ធ្នូ | ១៦.២ | ០.៨ | ០_៦១.១ |
| **ប្រចាំឆ្នាំ** | **១៩៦៦.២** | | **១៤៤១.៣_២៦០០.២** |

**ព្រភព:** ដកស្រង់ពី CTIA, 2000

**តារាង ៤.២ សង្ខេបទិន្នន័យអាកាសធាតុពីខេត្តស្ទឹងត្រែង ២០០៣ និង ២០០៤**

| ប៉ារ៉ាម៉ែត្រ | ២០០៣ | ២០០៤ |
|---|---|---|
| **ទឹកភ្លៀងប្រចាំឆ្នាំសរុប (មម)** | ១៣៧៣ | ១៨០៧ |
| មធ្យមភាគសីតុណ្ហភាពខ្ពស់បំផុតប្រចាំឆ្នាំ (oC) | ៣៣.០ | ៣៦.៥ |
| មធ្យមភាគសីតុណ្ហភាពទាបបំផុតប្រចាំឆ្នាំ (°C) | ២៤.០ | ២៣.០ |
| មធ្យមភាគសីតុណ្ហភាពប្រចាំឆ្នាំ (°C) | ៣០.៥ | ៣៤.០ |
| សីតុណ្ហភាពខ្ពស់បំផុត (°C) | ៣៨.៥ | ៤០.០ |
| សីតុណ្ហភាពទាប (°C) | ១១.៥ | ១៨.៦ |

**ប្រភព:** ដកស្រង់ពី មន្ទីរធនធានទឹក និងឧតុនិយមខេត្តស្ទឹងត្រែង ខែមករា ២០០៥

## ផ្នែកជលធារទឹក

មេគង្គជាទន្លេមួយក្នុងចំណោមទន្លេធំៗនៅលើពិភពលោក ដែលអាងរបស់ទន្លេនេះមានប្រវែង២៦០០គម

លាតសន្ធឹងពីខ្ពង់រាបទីបេ ទៅសមុទ្រចិនខាងត្បូង ហើយមានក្រឡាផ្ទៃ ៧៩៥០០០គម$^{២}$ ។ ទន្លេនេះ មានប្រវែង ៤៨០០ គម ដែលមានចំណុះទឹកប្រចាំឆ្នាំ ៤៧៥០០០ លានម៉ែត្រគីប ដែលនេះជាទន្លេវែងបំផុតទី១២ និងធំបំផុតទី១០ ។

ទន្លេមេគង្គបានបង្ហាញនូវការប្រែប្រួលនៃលំហូរប្រចាំឆ្នាំ នឹងមានការប្រែប្រួលផងដែរនូវរបបទឹកភ្លៀងប្រចាំរដូវនៅតាមអាងទន្លេនេះ ។ កំពស់ទឹកទន្លេ បានវាស់នៅខាងត្បូងទីប្រសព្វនៃទន្លេមេគង្គ និងទន្លេសេសានក្នុងខេត្តស្ទឹងត្រែង (តារាង ៤.៣)។ នៅចន្លោះឆ្នាំ ១៩៩៩ និង ២០០៤ មធ្យមភាគកំពស់ទឹកភ្លៀងខ្ពស់ជាងគេបំផុតនៅខែសីហា ឬខែកញ្ញា ដែលប្រែប្រួលពី ១០.២២ ម ទៅ ១១.៩២ ម ។ ដូចគ្នានេះ មធ្យមភាគកំពស់ទឹកទាបនៅខែ មិនា មេសា ឬឧសភា និងប្រែប្រួលពី ១.១៦ ម ទៅ ២.៣៤ ម ។ ការប្រែប្រួលប្រចាំឆ្នាំ ដែលទាបបំផុត និងខ្ពស់បំផុតពី ៧.៨៩ ម (ឆ្នាំ ២០០៣ ) ទៅ ៩.២០ ម (ឆ្នាំ ២០០០)។

អត្រាបរិមាណទឹកសំរាប់ទន្លេមេគង្គនៅខេត្តស្ទឹងត្រែងបានផ្តល់ដោយគំរោងដានីដា ឆ្នាំ ២០០០ មាននៅតារាង ៤.៤។ អត្រាបរិមាណទឹកប្រែប្រួលខ្លាំងក្នុងរយៈពេល២៦ឆ្នាំនេះ។ ដូចនេះ មធ្យមភាគបរិមាណទឹកច្រើនបំផុតនៅខែកញ្ញា (៣៧៤៨៤ម$^{៣}$ ក្នុង១វិនាទី) ដែលលើសបរិមាណសំរាប់ខែមេសា (១៩៦៦ ម$^{៣}$ ក្នុង១វិនាទី) ដល់ទៅ១៩ដង ។ លំហូរធំ សំរាប់ខែកញ្ញា (៦៧០៨៣ ម$^{៣}$ ក្នុង១វិនាទី) ដែលលើសលំហូរទាបបំផុតសំរាប់ខែឧសភា (១១៩៨ ម$^{៣}$ ក្នុង១វិនាទី) ដល់ ទៅ ៥៦ដង ។

ទោះជាមានការប្រែប្រួលរវាងលំហូររបស់ទន្លេប្រចាំឆ្នាំ និងប្រចាំរដូវ ក៏អត្រាបរិមាណទឹកពី ទន្លេមេគង្គក្រោម គឺនៅនឹង (MRC, 2003)។ ការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំនៅទាប បើធៀបនឹងស្តង់ដាអាស៊ាន និងពិភពលោក ។ ទឹកជំនន់ខ្លាំងដែលកើតមាន គឺមិនធំជាងទឹកជំនន់ធម្មតានោះទេ ។ ការជន់លិចនៅតំបន់រ៉ាមសារកើតមាន តែមិនមានការកត់ត្រាលំអិតទេ ។ ការខូចខាតភាគច្រើន កើតមានចំពោះដំណាំស្រូវដែលធ្វើឱ្យកសិករខាតបង់ច្រើន ។

តំបន់រ៉ាមសារមានដៃទន្លេតូចៗមួយចំនួន (ប្រហែល៤០)ដែលត្រូវហូរចូល (ផែនទី ៤.១) ។ ដៃទាំងនេះហូរចូល តាមរដូវ ឯដៃតូចៗជាងគេរីងស្ងួតរយៈពេលច្រើនអាទិត្យ ឬច្រើនខែនៅរដូវប្រាំង ។ នៅរដូវវស្សា (ខែវិច្ឆិកា - ឧសភា) ដៃទន្លេទាំងនេះទទួលទឹកពីតំបន់រងទឹកភ្លៀងរបស់វា និងពីទឹកទន្លេមេគង្គផង ។ ដៃធំៗជាងគេដូចជា អូរតាឡាស់មានសារៈសំខាន់ណាស់សំរាប់ត្រីពង-កូន និងរីកធំធាត់។ ការពិតណាស់ដែលថាដៃទន្លេទាំងនេះមានតួនាទីសំខាន់ដូចគ្នា ។

តំបន់រងទឹកភ្លៀងរបស់តំបន់រ៉ាមសារមានទំហំផ្សេងៗគ្នារវាងច្រាំងខាងកើត និងច្រាំងខាងលិច។ នៅច្រាំងខាងកើត វាលាតសន្ធឹងប្រវែង ១០ គម ដែលមានផ្ទៃដីចូលដល់ទន្លេសេកុង ។ នៅផ្នែកខាងលិច ដែលជាដៃទន្លេឈ្មោះ អូរតាឡាស់ មានបណ្តោយប្រវែង៦០គម និងតំបន់រងទឹកភ្លៀងមានក្រឡាផ្ទៃប្រហែល ៥០០០ គម$^{២}$ ។ ក្រឡាផ្ទៃរងទឹកភ្លៀងសរុប នៅច្រាំងខាងលិចមានច្រើនជាង៦០០០ គម$^{២}$ ។ គេឃើញមាននៅតំបន់រងទឹកភ្លៀង (ផែនទី ខ្នាត ១:៥០០០០) នូវផ្ទៃដី ដែលត្រូវលិចទឹកច្រើន និងស្រះទឹកជាច្រើនទៀត ។ តួនាទី និងតំលៃនៃតំបន់ទាំងនេះសំរាប់ត្រី និងសត្វព្រៃ មិនទាន់បានសិក្សាទេ ។

នៅភាគខាងត្បូងនៃតំបន់រ៉ាមសារប្រហែល ៥គម ទន្លេមេគង្គត្រូវភ្ជាប់ដោយទន្លេមួយឈ្មោះថា សេកុង ។

នៅខាង កើតទីរួមខេត្តស្ទឹងត្រែង ទន្លេសេកុងបានតភ្ជាប់ដោយទន្លេធំ២ទៀត គឺ ទន្លេសេសាន និងទន្លេស្រែពក។ ទន្លេទាំងបីនេះ ហូរចាក់ដោយតំបន់ភ្នំធំៗរបស់ប្រទេសឡាវភាគត្បូង និងតំបន់កណ្តាលខាងលិចរបស់ប្រទេសវៀតណាម (ភ្នំអាណាមីត) ។ ជាសរុប ទន្លេសេកុងមានលំហូរប្រហែល១៦.៧% នៃលំហូរសរុបរបស់ទន្លេមេគង្គ ។ គុណភាព និងបរិមាណលំហូររបស់ទន្លេទាំងនេះមានសារៈសំខាន់សំរាប់រក្សាលក្ខខ័ណ្ឌធារទឹកល្អនៅតំបន់រ៉ាមសារ។ ការប្រែប្រួលអាក្រក់ ចំពោះធារទឹកទន្លេមេគង្គ នៅខាងក្រោមខេត្តស្ទឹងត្រែងនឹងបំផ្លាញតំបន់រ៉ាមសារ និងជាពិសេសប៉ះពាល់ដល់ការបំលាស់ទីរបស់ត្រីតាមដងទន្លេផ្នែកខាងលើ ។



មិនមានទិន្នន័យពីការអង្កេតគុណភាពទឹកទេ សំរាប់ទន្លេមេគង្គនៅខេត្តស្ទឹងត្រែង។ ទីតាំងជិតបំផុតបាន សិក្សាដោយគណៈកម្មការទន្លេមេគង្គ នៅក្នុងកម្មវិធីអង្កេតគុណភាពទឹកពីខេត្តក្រចេះទៅភាគខាងត្បូង និង ខេត្តប៉ាក់សេ ប្រទេសឡាវ ទៅភាគខាងជើង ។ ទីតាំងទាំងពីរ គឺប្រហែលជា ២០០ គម ពីខេត្តស្ទឹងត្រែង ។

ព័ត៌មានពីទន្លេទាំងពីរនេះមាននៅក្នុងតារាង ៤.៥ ។ គុណភាពទឹករបស់ទន្លេមេគង្គ ក៏ដូចនៅក្នុងទន្លេ អាស៊ីផ្សេងៗទៀតដែរ។ កំរិតខ្ពស់ជាងគេសំរាប់កាល់ស្យូម បញ្ជាក់ថាមានជាតិថ្មកំបោរនៅតំបន់រងទឹកភ្លៀង ទន្លេមេគង្គខាងលើ។ កំរិតនេះ ត្រូវថយចុះវិញនៅទន្លេមេគង្គផ្នែកខាងក្រោម ជាពិសេសវាថយចុះដោយសារ ទន្លេសេកុង សេសាន និងទន្លេស្រែពក ដែលហូរកាត់ថ្មមានជាតិកាល់ស្យូមតិចនៅប្រទេសឡាវ និងតំបន់ខ្ពង់រាប ប្រទេសវៀតណាម ។ កំរិតអាសូតទាប ឯកំរិតផូស្វ័រសរុប គឺខ្ពស់ ដែលនេះអាចបណ្តាលមកពីសារធាតុកករ ក្នុងទឹក ។

គណៈកម្មការទន្លេមេគង្គបានធ្វើការអង្កេតទៀងទាត់សំរាប់សារធាតុកករសរុប ភាពចំលងអគ្គីសនី ផូស្វ័រសរុប និងអាសូតសរុប នៅតំបន់ប៉ាក់សេ ប្រទេសឡាវ ចាប់តាំងពីឆ្នាំ ១៩៨២ និងនៅខេត្តក្រចេះតាំងពីឆ្នាំ ១៩៩២ (MRC, 2003)។ នៅពេលនេះ កំរិតសារធាតុកករបានថយចុះនៅស្ទើរគ្រប់កន្លែង ហើយដែលគេជឿថា (MRC, 2003) ដោយសារតែសារធាតុ នេះត្រូវកាត់បន្ថយដោយទំនប់វារីអគ្គិសនី ម៉ានវ៉ាន នៅប្រទេសចិន ។ ភាព ចំលងអគ្គីសនី បានថយចុះដែរនៅគ្រប់កន្លែង ។ កំរិតអាសូត និងផូស្វ័រប្រែប្រួលតិចតួចនៅពេលនេះ នៅគ្រប់ កន្លែងនៅទន្លេមេគង្គ។ គុណភាពទឹកនៅតំបន់វ៉ាមសារ មានជាមធ្យមរវាងកំរិតសំរាប់ខេត្តប៉ាក់សេ និងខេត្ត ក្រចេះ ដែលបង្ហាញនូវការប្រែប្រួលដូចគ្នា ។

**តារាង ៤.៣ កំរិតកំពស់ទឹកប្រចាំខែជាមធ្យមរបស់ទន្លេមេគង្គនៅទីរួមខេត្តស្ទឹងត្រែង កម្ពុជា ១៩៩៩- ២០០៤**

| **កំរិតកំពស់ទឹក (ជាម៉ែត្រ)** | | | | | | |
|---|---|---|---|---|---|---|
| **ខែ** | **១៩៩៩** | **២០០០** | **២០០១** | **២០០២** | **២០០៣** | **២០០៤** |
| **មករា** | **២.៨** | **២.៧៨** | **១.៩៩** | **២.៩១** | **៣.០៥** | **២.៤៦** |
| **កុម្ភៈ** | **២.៥២** | **២.៤៨** | **១.៥៥** | **២.៥៩** | **២.៦៤** | **២.២៩** |
| **មិនា** | **២.៣៤** | **២.៤២*** | **១.៥៥** | **២.៤០** | **២.៤៦** | **២.០៧** |
| **មេសា** | **២.៤១*** | **២.៤៣** | **១.៤៧** | **២.៣២*** | **២.៤២*** | **២.១៧*** |
| **ឧសភា** | **៣.៩៦** | **២.៨៥** | **១.៦៣8** | **២.៨៣** | **២.៦៨** | **២.៦៦** |
| **មិថុនា** | **៦.១៤** | **៥.៥** | **២.៧៣** | **៥.១៦** | **៤.០៦** | **៤.៦៦** |
| **កក្កដា** | **៩.២២** | **៧.៩២** | **៥.៣២** | **៨.១៣** | **៥.១៦** | **៥.៧៩** |
| **សីហា** | **៨.៣៧** | **១០.០១*** | **៧.៩៨*** | **៩.៩៦*** | **៧.៣៥** | **៩.០៦** |
| **កញ្ញា** | **១០.៣២*** | **៩.៤៩** | **៨.២៦** | **៩.៧៦** | **៨.៨០*** | **៩.២៥*** |
| **តុលា** | **៦.៧១** | **៦.៥៣** | **៤.៦៣** | **៦.៤៧** | **៥.៥៧** | **៥.៤០** |
| **វិច្ឆិកា** | **៤.៥២** | **៥.១៦** | **៣.៣៣** | **៤.៥០** | **៣.៥៨** | **៣.៥១** |

| | | | | | | |
|---|---|---|---|---|---|---|
| **ធ្នូ** | **៣.៣៨** | **៣.៥៥** | **២.៤៩** | **៣.៥៦** | **២.៨៤** | **២.៩៤** |
| **ខ្ពស់បំផុត** | **១១.៤៩** | **១១.៩៧** | **១០.៧៤** | **១១.៥៣** | **១០.២៣** | **១០.២២** |
| **ទាបបំផុត** | **២.១០** | **២.២៧** | **១.១៦** | **២.២៤** | **២.៣៤** | **១.៩៧** |

**ប្រភព:** ដកស្រង់ពីទិន្នន័យផ្តល់ដោយមន្ទីរធនធានទឹក និងឧតុនិយមខេត្តស្ទឹងត្រែង ។

មធ្យមភាគប្រចាំខែត្រូវបានគណនាកំរិត ទឹកដែលវាស់ពីរដងក្នុងមួយថ្ងៃនៅទីរួមខេត្តស្ទឹងត្រែង ។

[8] ខែប្រចាំឆ្នាំនៃកំរិតទឹក ខ្ពស់បំផុតដាច់ខាត និងទាបបំផុតដាច់ខាត ។ កំរិតទាំង២នេះមាននៅគ្រប់ខែ ។ ឧទាហរណ៍នៅ ឆ្នាំ ១៩៩៩ កំរិតកំពស់ទឹកទាបដាច់ខាត មាននៅខែមេសា (២.១០ ម) ឯខែដែលកំរិតកំពស់ទឹកទាបបំផុត (២.៤១ ម) នៅខែ-មិនា ។

## តារាង ៤.៤ លំហូរទាប ខ្ពស់ និងមធ្យម សំរាប់ទន្លេមេគង្គនៅខេត្តស្ទឹងត្រែង, ១៩៦២-១៩៨៨

| **ខែ** | **លំហូរទាប (ម$^3$,នាទី)** | **លំហូរខ្ពស់(ម$^3$,នាទី)** | **លំហូរមធ្យម(ម$^3$,នាទី)** |
|---|---|---|---|
| មករា | ១៩៨៦ | ៦០៥០ | ៣៥២៨ |
| កុម្ភៈ | ១៧៧៧ | ៣៦៤០ | ២៥៧២ |
| មិនា | ១៤៣៦ | ២៨៤០ | ២០៥១ |
| មេសា | ១២៥០ | ៣១៧៧ | ១៩៦៥ |
| ឧសភា | ១១៩៨ | ១០៤០០ | ៣៣៤៨ |
| មិថុនា | ២៤១០ | ៣៧៤០០ | ១០៦០៥ |
| កក្កដា | ៥០៣២ | ៤៦៦៣៨ | ២១១០៤ |
| សីហា | ១២៤៩១ | ៦១៣០០ | ៣៣៧៦៥ |
| កញ្ញា | ២០៧០០ | ៦៧០៨៣ | ៣៧៤៨៤ |
| តុលា | ៩៦២១ | ៥៩៣២០ | ២២៩៣៣ |
| វិច្ឆិកា | ៤៤០០ | ៣០២៩២ | ១១១៩៣ |
| ធ្នូ | ២៣៨០ | ១១២៨៦ | ៥៤៨៨ |

**ប្រភព:** ចំលងពី ដានីដា ២០០០

## តារាង ៤.៥ ទិន្នន័យគុណភាពទឹកប្រចាំខែពីខេត្តក្រចេះ និងខេត្តប៉ាក់សេ ប្រទេសឡាវ និងមធ្យមភាគទន្លេនៅ-អាស៊ី (មធ្យមភាគសំណាកប្រចាំខែ ម.គ្រ ,លីត្រ)

| **ប៉ារ៉ាម៉ែត្រ** | **ខេត្តក្រចេះ** | **ខេត្តប៉ាក់សេ** | **មធ្យមភាគនៅអាស៊ី** |
|---|---|---|---|
| កាល់ស្យូម | ១៥.៥ | ២៣.១ | ១៨.៤ |
| ម៉ាញ៉េស្យូម | ៤.១ | ៤.៦ | ៥.៦ |
| សូដ្យូម | ៦.៩ | ៦.៧ | ៥.៥ |
| ប៉ូតាស្យូម | ១.៤ | ១.៦ | ៣.៨ |

| | | | |
|---|---|---|---|
| **ដែក** | **១.២១** | **០.១៨** | **០.០១** |
| **ស៊ុលផាត** | **៩.៣** | **១៧.១** | **៨.៤** |
| **ក្លរ** | **៥.០** | **៨.០** | **៨.៧** |
| **ស៊ីលីកាត** | **១១.៤** | **១២.២** | **១១.៧** |
| **នីត្រាត** | **០.១** | **០.១** | **០.៧** |
| **ប៊ីកាបូណាត** | **៦២** | **៨៣** | **៧៩** |
| **ធាតុកករសរុប** | **១២២** | **២១៥** | - |
| **ផូស្វ័រសរុប** | **០.០២** | **០.០៤** | - |

**ប្រភព:** ដកស្រង់ពី MRC, 2003

## ការប្រែប្រួលអាកាសធាតុ

ការវាយតំលៃហ្មត់ចត់បំផុតសំរាប់ការប្រែប្រួលអាកាសធាតុ និងឥទ្ធិពលរបស់វាទៅលើអាងទន្លេ មេគង្គ បានផ្តល់ដោយ Chu *et al* (2003)។ ក្នុងការសិក្សានោះ គេបានព្យាករណ៍នូវការប្រែប្រួលផ្សេងៗ និងវាយតំលៃការប៉ះពាល់ដែលអាច មានទៅលើលក្ខខ័ណ្ឌសេដ្ឋកិច្ចសង្គមរបស់អាងទន្លេនេះ ។ ការប៉ះពាល់របស់ អាកាសធាតុ អាស្រ័យទៅលើអន្តរអំពើរវាង ការប្រែប្រួលអាកាសធាតុ(ទឹកភ្លៀង សីតុណ្ហភាព។ល។) និងកត្តាសេដ្ឋកិច្ចសង្គម (កំណើនប្រជាជន, សកម្មភាពកសិកម្ម, ដំណាំឧស្សាហកម្ម ភាពក្រីក្រ និងកំរិតចំណូល ។ល។) ។ ឥទ្ធិពលទៅលើជីវចំរុះ នឹងអាស្រ័យលើកត្តាដូចគ្នានេះដែរ ដោយថែមកត្តាផ្សេងៗទៀត ដូចជា អត្តចរិតរបស់មនុស្សចំពោះការបរបាញ់សត្វ និងសត្វព្រៃជាទូទៅ ។ ភាពស្មុគស្មាញនេះ ដោយរួមផ្សំជាមួយការខ្វះចំណេះដឹងពីអេកូឡូស៊ីសត្វនៅតំបន់រ៉ាមសារ បាននាំឱ្យមានការលំបាកក្នុងការព្យាករណ៍ ឥទ្ធិពលរបស់ការប្រែប្រួលអាកាសធាតុទៅលើជីវចំរុះ ។

នៅក្នុងការសិក្សាមួយចំនួនដែលបានជ្រើសរើសដោយ Chu *et al* (2003)សំរាប់អាងទន្លេមេគង្គទាំងមូល ពួកគេ ព្យាករណ៍ថា សីតុណ្ហភាពប្រចាំឆ្នាំជាមធ្យមនឹងកើនឡើងពី ២៤.៣ អង្សា (មធ្យមភាគឆ្នាំ ១៩៦១-១៩៩០) ទៅប្រហែល ជា ២៩អង្សា នៅត្រឹមចុងសតវត្សរ៍នេះ ។ នៅក្នុងខែជាច្រើននៅចុងសតវត្សរ៍នេះ សីតុណ្ហ ភាពខ្ពស់បំផុត នឹងមាន លើស៤០អង្សា (បច្ចុប្បន្នសីតុណ្ហភាពខ្ពស់ ដែលមិនធ្លាប់មាន គឺមាននៅខេត្តស្ទឹងត្រែងហើយ)។ នៅតំបន់រ៉ាមសារ សីតុណ្ហភាព ប្រចាំឆ្នាំជាមធ្យម ត្រូវបានព្យាករណ៍ថានឹងកើនពី២៥.៨អង្សា (១៩៦១-១៩៩០) ទៅ ២៩.៨អង្សា នៅឆ្នាំ២០៩៩។

ទាក់ទងជាមួយទឹកភ្លៀង មធ្យមភាគសំរាប់អាងទន្លេមេគង្គទាំងមូលត្រូវបានព្យារកណ៍ថានឹងឡើង ៩.៨% នៅឆ្នាំ២០៩៩ គិតពីមធ្យមភាគឆ្នាំ ១៩៦១-១៩៩០។ នៅជុំវិញតំបន់រ៉ាមសារ ទឹកភ្លៀងត្រូវបានព្យាករណ៍ថា មានការប្រែប្រួលពី២.៣ % ទៅ ៣.៨ % ក្នុងឆ្នាំ ២០១០-២០៣៩ និងកើនពី១.៦% ហើយថយចុះ ១.៥ % ក្នុងកំឡុងឆ្នាំ ២០៧០-២០៩៩ ។ ការប្រែប្រួលរបស់ជីវៈចម្រុះ នៅតំបន់រ៉ាមសារ នឹងអាស្រ័យលើ

បន្ទុំនៃទឹកភ្លៀង និងការប្រែប្រួលទឹកភ្លៀងនៅតំបន់អាងទន្លេទាំងមូល។ ឧទាហរណ៍ កំរិតកំពស់ទឹកទន្លេមេគង្គ នៅតំបន់រ៉ាមសារអាស្រ័យលើទឹកភ្លៀងនៅតំបន់ខាងលើទន្លេ ជាជាងទឹកភ្លៀង នៅលើតំបន់ខាងក្រោមទន្លេ ។

លក្ខខ័ណ្ឌអាកាសធាតុផ្សេងទៀត ត្រូវបានព្យាករណ៍ពីការប្រែប្រួលនៅចុងសតវត្សរ៍នេះ ដោយប្រៀបធៀបកំរិត ដែលធ្វើនៅ ឆ្នាំ ១៩៦១-១៩៩០ ។ ដូច្នេះកំរិតកាំរស្មីព្រះអាទិត្យ នឹងកើនឡើងបន្តិចម្តងៗ ឯល្បឿនខ្យល់នឹងកើនឡើង រីឯសំណើមវិញ នឹងថយចុះ ។

ការប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុនេះ មានការលំបាកនឹងព្យាករណ៍ដោយសារកត្តាជាច្រើនទៀតមានពាក់ព័ន្ធ ក្នុងការប្រែប្រួលនេះ។ កត្តាសំខាន់ក្នុងចំនោមកត្តាទាំងនោះគឺ ចំនួនប្រជាជនកើនឡើងទ្វេររាល់៣៥ឆ្នាំម្តង ដោយមានផលវិបាក បង្កើតជាសំពាធលើបរិស្ថាន ក្នុងនោះមានការកើនឡើងតំរូវការដូចជាចំណីអាហារ កំរិតឧស្សាហកម្ម ប្រព័ន្ធស្រោចស្រព តំរូវការទឹក ការកាប់ព្រៃ (ការហូរច្រោះ តំរូវការទឹក) ។

ចំពោះលក្ខខ័ណ្ឌទាំងនេះមួយចំនួន Chu *et al* (2003) បានព្យាករណ៍ ការប្រែប្រួលសំរាប់លំហូរនៅទន្លេមេគង្គផ្នែក ខាងក្រោមសំរាប់ចុងសតវត្សរ៍នេះ :

- លំហូរតិចប្រចាំខែ ដែលនឹងប្រែប្រួលពី -9.3% to -100%
- លំហូរខ្ពស់ប្រចាំខែ ដែលនឹងប្រែប្រួលពី +30% to +41%;
- លំហូរជាមធ្យមប្រចាំខែ ដែលនឹងប្រែប្រួលពី -10% to +8%;
- លំហូរខ្ពស់ប្រចាំថ្ងៃ ដែលនឹងប្រែប្រួលពី +13% to +35%.

រាល់ការអភិវឌ្ឍន៍ដែលមាន វានឹងធ្វើឱ្យមានការប្រែប្រួលដល់លំហូររបស់ទន្លេមេគង្គ តំបន់រ៉ាមសារ និង-ទឹកន្លែងផ្សេងទៀត។ ការប្រែប្រួលនេះ អាចព្យាករណ៍ពីការប៉ះពាល់ទៅលើអេកូឡូស៊ីត្រី និងជលផលនៅតំបន់នោះ ។ ការបំលាស់ទី និងលក្ខណៈពងកូនរបស់ត្រី បានប្រែប្រួលទៅតាមលក្ខខ័ណ្ឌបច្ចុប្បន្ននៃទន្លេ។ ពោលគឺ ការប្រែប្រួលខ្លាំង មានការប្រែប្រួលអាកាសធាតុ និងកំណើនតំរូវការទឹកនឹងប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។ ការព្យាករណ៍ការប៉ះពាល់ទៅ លើប្រភេទសត្វនីមួយៗ មិនអាចធ្វើបាន ដោយសារមិនមានព័ត៌មានគ្រប់គ្រាន់អំពីតំរូវការអេកូឡូស៊ីរបស់សត្វទាំងនេះទេ ។

កំណើនទ្វេរនៃចំនួនប្រជាជននៅតំបន់រ៉ាមសារនឹងបង្កើនតំរូវការដីកសិកម្ម និងធនធានព្រៃផ្សេងៗទៀត។ ដូចនេះ ដីព្រៃអាចថយចុះ ក្រៅពីនេះមានការប្រែប្រួលផ្សេងទៀតដែលកើតឡើងពីការប្រែប្រួលអាកាសធាតុ។ បើមិនមានការ កែប្រែអត្តចរិកចំពោះការប្រមាញ់សត្វព្រៃទេ នោះការបរបាញ់ នឹងកើនឡើងកាន់តែខ្លាំង ។ ការបាត់បង់ព្រៃ និងកំណើនការបរបាញ់ នឹងបណ្តាលឱ្យជីវចម្រុះថយចុះយ៉ាងខ្លាំង ។ បញ្ហានេះ នឹងបន្តហើយអាចនឹងកើនឡើងនៅពេលបច្ចុប្បន្ននេះ ។

ដើម្បីយល់កាន់តែច្បាស់ពីឥទ្ធិពលការប្រែប្រួលអាកាសធាតុទៅលើតំបន់រ៉ាមសារ ការសិក្សាមួយដែលស្រដៀងនឹង Chu *et al* (2003) ត្រូវតែធ្វើដែលត្រូវផ្តោតអារម្មណ៍លើតំបន់នេះ ។ ការសិក្សានេះអាចផ្តល់

យុទ្ធសាស្ត្រដោះស្រាយសំរាប់ តំបន់រ៉ាមសារ ដែលដូចការសិក្សា Chu *et al* (2003) បានធ្វើសំរាប់អាងទន្លេមេគង្គជាទូទៅ។

## ភូគព្ភសាស្ត្រ និងធនធានរ៉ែ

ភូមិសាស្ត្រខេត្តស្ទឹងត្រែង បង្ហាញនៅផែនទី ៤.២ ។ ប្រព័ន្ធទន្លេមេគង្គ ហូរកាត់តំបន់រ៉ាមសារភាគច្រើនមានល្បាប់ ឥដ្ឋ និងខ្សាច់ ដែលហូរនាំពីផ្នែកខាងលើទន្លេ និងកើតពីការសឹករិចរិល ។ ល្បាប់ទាំងនេះនៅលើថ្មដែលនៅជុំវិញតំបន់រ៉ាមសារ ភាគច្រើនមានថ្មភក់ជាតិកាបូន ។ មានផ្ទាំងថ្មម៉ាបជាច្រើន នៅតាមបណ្តោយច្រាំងខាងកើតទន្លេមេគង្គ។

មានធនធានរ៉ែជាច្រើនទៀត(ការសំភាសន៍ជាបុគ្គលជាមួយមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តស្ទឹងត្រែង ឆ្នាំ២០០៥)នៅខេត្តស្ទឹងត្រែង តែមានរ៉ែមាសច្រើននៅទន្លេសេកុង (នៅតាមព្រំដែនរវាងខេត្តស្ទឹងត្រែង និងរតនៈគីរី) ដែលមិនទាន់មានការទាញយកផលទេ ។ រ៉ែត្បូងថ្មមាននៅទន្លេសេកុង និង សេសាន ដែលកាលពីមានការធ្វើអាជីវកម្មពីឆ្នាំ ១៩៦០-១៩៧០ និងក្រោយមកពីឆ្នាំ ១៩៧០-១៩៧៩ ។ ធនធានរ៉ែទាំងនេះបច្ចុប្បន្ន កំពុងត្រូវបានវាយតំលៃសំរាប់ លទ្ធភាព ធ្វើអាជីវកម្មឡើងវិញ ។ ធនធានរ៉ែដែក និងស្ពាន់ មាននៅខេត្តស្ទឹងត្រែង តែមិនមានព័ត៌មានពីទីតាំង ឬសក្តានុពលសេដ្ឋកិច្ចទេ។ ម្នាងសិលា ថ្មម៉ាប និងត្បូង មាននៅខេត្តនេះដែរ។ ការសិក្សាលទ្ធភាពរុករករ៉ែ ត្រូវបានលើកឡើងសំរាប់ម្នាងសិលា ហើយត្រូវបានបញ្ចប់ហើយសំរាប់ថ្មម៉ាប ។ ប៉ុន្តែ មិនមានការអភិវឌ្ឍន៍អ្វីត្រូវបានស្នើឡើងនៅឡើយ ។

ការចាប់អារម្មណ៍ ត្រូវបានបង្ហាញនៅក្នុងវិស័យធនធានរ៉ែនៅខេត្តស្ទឹងត្រែង ដែលការជីករ៉ែអាចដំណើរការបាន។

## ប្រភេទធនធានដី

ដីនៅតំបន់រ៉ាមសារ (ផែនទី ៤.៣)ស្ថិតក្នុង៤ក្រុមសំខាន់ៗ ដែលពិពណ៌នាដូចខាងក្រោម :

ភាគច្រើននៅច្រាំងខាងលិច និង ក្រោម៤០% នៅច្រាំងខាងកើត ជាដីលីតូសូលអាស៊ីតដែលកើតពីថ្មភក់ដើម ។ វាមានកំរិតអាស៊ីតពី ៤.៥-៦.៥ ហើយជំរៅដល់១៥សង់ទីម៉ែត្រ ។ វាមិនមែនជាដីល្អទេ តែអាចប្រើសំរាប់ដីព្រៃ និងការចិញ្ចឹមសត្វនៅក្នុងព្រៃជ្រុះស្លឹកនៅរដូវក្តៅ។ នៅជិតទន្លេ ដីអាចប្រែប្រួល និងមានជីជាតិជាងដោយសារតែការជន់លិច និង មានទឹកច្រើន ។

នៅតាមបណ្តោយដងទន្លេខាងលិចដូចជាទន្លេអូរតាឡាស់ និងអូរត្រេល និងទីដែលទន្លេនេះតជាមួយទន្លេមេគង្គ ដីភាគច្រើនដីល្បាប់ទន្លេ ដីទាំងនេះមានកំរិតអាស៊ីតទាប (៤.៥-៦.៥) ប៉ុន្តែជាដីល្អដែលអាចបង្កើនជីជាតិដោយថែមជីលាមកសត្វ ជីផូស្វាត និងជីប៉ូតាស ។ ដំណាំ និងដើមឈើភាគច្រើន អាចដុះលូតលាស់លើដីទាំងនេះ ។

កោះរបស់ទន្លេមេគង្គ និងផ្នែកកណ្តាលមួយចំនួននៃច្រាំងខាងកើតរបស់តំបន់រ៉ាមសារ មានដីល្បាប់ពណ៌ត្នោត ។ ដីទាំងនេះ ដោយមានកំរិតអាស៊ីតពី ៥-៦.៨ គឺជាដីមានជីជាតិល្អសំរាប់ដំណាំគ្រប់ប្រភេទ ។

ចាប់ពីអូរស្វាយ ទៅព្រំដែនប្រទេសឡាវ ដីភាគច្រើនជាដីប៉តសូល (ដីច្រោះ)ក្រហមលាយលឿង។ ដីនេះមាន កំរិតអាស៊ីត ៤.២_៦.៨ ដែលមានទំរង់អន់ និងងាយបែក ។ ដីនេះងាយខូចទ្រង់ទ្រាយដោយសារភ្លៀងខ្លាំង និងមានសារធាតុចិញ្ចឹមតិច ។ វាត្រូវការជីគីមី និងជីសរីរាង្គសំរាប់ឱ្យគ្រាប់ដំណាំមានការដុះដាលល្អ ។

នៅតំបន់រ៉ាមសារ មានដីខ្លះល្អ និងខ្លះមិនល្អ។ ដីមានជីជាតិរបស់តំបន់នេះ មាននៅតាមបណ្តោយដៃទន្លេសំខាន់ៗ និងនៅតាមកោះ ។ ដីខ្សត់ជីជាតិ មានច្រើននៅតំបន់រ៉ាមសារ ហើយដែលកំណត់សក្តានុពលកសិកម្ម ។ ដីនៅតំបន់រ៉ាមសារ មិនទាន់មានការសិក្សាច្បាស់លាស់ទេ ដែលមិនមានព័ត៌មានសំរាប់កសិករ ដើម្បីទាញយកផលពីដីទាំងនេះទេ។

**ផែនទី ៤.២ ផែនទីភូគព្ភសាស្ត្រខេត្តស្ទឹងត្រែង**



**ផែនទី ៤.៣ ផែនទីលក្ខណៈដីនៅខេត្តស្ទឹងត្រែង, ១៩៩៦**



## ប្រភេទរុក្ខជាតិ

តំបន់រ៉ាមសារ និងតំបន់ដីដែលនៅជាប់នោះ មានប្រភេទរុក្ខជាតិផ្សេងៗ ។ រុក្ខជាតិទាំងនេះ កើតមានដោយសារតែល័ក្ខខ័ណ្ឌអេកូឡូស៊ីខុសគ្នាដែលបង្កើតដោយប្រព័ន្ធទន្លេមេគង្គ ដែលកោះមានដីខ្សាច់ថ្មលិចទឹកតាមរដូវ ។ រីឯវាលរាបខាងជើង និងខាងកើតមានទន្លេហូរកាត់ ។ ភាគច្រើននៃរុក្ខជាតិទាំងនេះ ដែលនៅក្នុង និងនៅឆ្ងាយពីទន្លេមានការបំផ្លាញតិចតួច និងមានទេសភាពទាក់ទាញបំផុត។ រុក្ខជាតិគ្រប់ប្រភេទនេះ ជាមូលដ្ឋានគ្រឹះសំរាប់ការកកើត និងជាជំរកសត្វគ្រប់ប្រភេទនៅក្នុង និងជាប់តំបន់រ៉ាមសារ ។

តំបន់រ៉ាមសារ និងតំបន់ដែលនៅជាប់នោះមានប្រភេទរុក្ខជាតិដូចតទៅ (Rundell, 1999):

- ព្រៃនៅតាមកោះខ្សាច់ និងថ្មដែលលិចតាមរដូវ នៅទន្លេមេគង្គ
- ព្រៃមាត់ច្រាំងទន្លេ នៅតាមបណ្តោយច្រាំងទន្លេមេគង្គ និងកោះធំៗ
- ព្រៃរបោះឈើទាលភាគច្រើននៅខាងក្រៅ តែជាប់តំបន់រ៉ាមសារ។
- ព្រៃពាក់កណ្តាលស្រោង ភាគច្រើននៅខាងក្រៅ តែជាប់តំបន់រ៉ាមសារ។

ព្រៃនៅលើកោះថ្ម និងខ្សាច់របស់ទន្លេមេគង្គដែលលិចទឹកតាមរដូវ បានធ្វើឱ្យតំបន់រ៉ាមសារមានទេសភាពស្រស់ត្រកាល។ ប្រភេទព្រៃទាំងនេះ មិនសូវមាននៅកន្លែងផ្សេងទៀតទេនៅក្នុងពិភពលោក តែទោះជាយ៉ាងណា វាមាននៅទន្លេមេគង្គភាគខាងត្បូងបំផុតនៃខេត្តក្រចេះ ដែលវាដុះបានល្អនៅតំបន់រ៉ាមសារ។ កោះទាំងឡាយបានលិចដល់ជំរៅ ១០ម៉ែត្រ ដោយសារទន្លេមេគង្គ ឬអាចលិចជ្រៅជាងនេះនៅរដូវវស្សា ហើយលិចរយៈពេលកន្លះឆ្នាំពេញ។ មិនមានការវិវត្តន៍ដីទេ មានតែគ្រួសខ្សាច់ និងថ្មបាតទន្លេ ។ ហើយបន្តពីនោះ គឺភាពរាំងស្ងួត និងខ្វះទឹកកើតមានឡើងម្តងម្កាល ។

ល័ក្ខខ័ណ្ឌអេកូឡូស៊ីបែបនេះ នាំឱ្យមានរុក្ខជាតិពិសេស និងមិនច្រើនប្រភេទដែលអាចរស់នៅបាន ។ ប្រភេទរុក្ខជាតិភាគច្រើនមានដូចជា *Barringtonia, Eugenia, Acacia, Ficus and Anogeissus rivularis*។ រុក្ខជាតិនិមួយៗដុះនៅរាយប៉ាយឃ្លាតពីគ្នាខ្លាំង និងខ្លះទៀតបង្ហាញពីការបន្សាំទៅនឹងភាពរាំងស្ងួត (មានស្លឹកតូចៗ) និងមានឫសលយចេញពីដីប្រវែងប្រហែល៤ម៉ែត្រ ដើម្បីបង្កើនការស្រូបអុកស៊ីសែន ក៏ដូចជាការផ្តល់លំនឹងទប់ទល់នឹងចរន្តទឹកទន្លេខ្លាំង។ រុក្ខជាតិភាគច្រើនមានលក្ខណៈស្រូបទឹកដែលមែកខាងលើកោង និងឫសអាកាសដុះផ្នែកខាងក្រោមនៃដើមឈើ។ ប្រភេទព្រៃបែបនេះមាន ឬមិនមានស្រទាប់ព្រៃ ឬរុក្ខជាតិផ្សេងទៀតនៅខាងក្រោមទេ ។ ប្រភេទមួយគឺ *Morindopsis* អាចកើតជាស្រទាប់ព្រៃគុម្ពោត ។ ប្រភេទនេះដែរអាចកើតមានជាប្រភេទតែមួយគត់ដោយទៅ ជាព្រៃគុម្ពោតក្រាស នៅលើទួលខ្សាច់ ខ្លះ ឬនៅលើកោះនៅក្នុងទន្លេមេគង្គ ។

រុក្ខជាតិនៃតំបន់នេះនៅល្អនៅឡើយ ។ ព្រៃរនាមទាំងនេះមានសារៈសំខាន់សំរាប់ជាជំរក និងទីរកចំណីសំរាប់ត្រី និងជាកន្លែងត្រីពងនៅរដូវទឹកជំនន់ ។ វត្តមានរបស់វាទាំងនេះពិតជាមានសារៈសំខាន់ណាស់សំរាប់តំបន់រ៉ាមសារ ដែលមានតំលៃទាំងផ្នែកវិទ្យាសាស្ត្រ និងទេសភាព ក៏ដូចជាសំរាប់ជលផលដែរ ។

ព្រៃមាត់ទន្លេ មានជាផ្នែកៗនៅតាមបណ្តោយមាត់ច្រាំងទាំងសង្ខាងនៃតំបន់រ៉ាមសារ និងនៅតាមកោះធំៗ។ វាមានការប្រែប្រួលខ្លាំងទាំងទំរង់ និងភាពចំរុះ (Rundell, 1999)។ ល្អបំផុតគឺ ដើមឈើដុះដល់កំពស់ ៣០ម

នៅលើដីល្បប់ ដែលលិច ទឹកតាមរដូវ និងក្រោយមកវិវឌ្ឍន៍ទៅជាព្រៃពាក់កណ្តាលស្រោង។ ប្រភេទដើមឈើ-ភាគច្រើន គឺព្រៃឈើទាល ពាក់កណ្តាលស្រោង ដូចជា *Dipterocarpus alatus, D. dyeri and Hopea odorata* ។ រុក្ខជាតិនៅព្រៃនេះមានទំនាក់ទំនងជាមួយ ព្រៃសើមរបស់ព្រៃជួរភ្នំក្រវាញ និងភ្នំដំរី (ភាគអាគ្នេយ៍របស់កម្ពុជា) ដែលដើរតួនាទីជាផ្លូវដំណររវាងតំបន់ទាំងនេះ និងតំបន់អាណាមីត(វៀតណាម)ទៅភាគខាងកើត ។ ព្រៃនៅមាត់ទន្លេនឹងមានការកាប់សំរាប់ការតាំងទីលំនៅ និងធ្វើកសិកម្ម ។ ទោះជាយ៉ាងណាក៏ដោយ នៅមានតំបន់ខ្លះល្អ និងដើរតួនាទីជាទីសក្ការសាសនានៅលើកោះមួយចំនួនរបស់តំបន់រ៉ាមសារ ដែលកោះទាំងនោះត្រូវបានការពារដោយទំលាប់របស់ប្រជាជននៅតំបន់នោះ (Vong, 2004) ។

ព្រៃរបោះឈើទាល ឬព្រៃឈើទាលស្ងួត គឺជាព្រៃដែលមានច្រើនជាងគេនៅទំនាបភាគខាងជើង និងខាង កើតរបស់ប្រទេសកម្ពុជា។ ទន្លេមេគង្គនៅតំបន់រ៉ាមសារ គឺជាបន្ទាត់បែងចែករវាងតំបន់ទាំងពីរនេះ។ ព្រៃបែបនេះ ដុះនៅលើដីសោះកក្រោះទៅដល់រយៈកំពស់ប្រហែល៦០០ម។ ព្រៃទាំងនេះ គ្រប់ដណ្តប់ដោយប្រភេទ ឈើទាមួយចំនួន (*Shorea siamensis, S. obtusa, Dipterocarpus tuberculatus, D. obtusifolia, D. intricatus*) ដែលជ្រុះស្លឹកនៅរដូវក្តៅ ។ ជាទូទៅ ទំរង់របស់វាមានតែមួយស្រទាប់ដែលដើមឈើមានកំពស់ពី៥-១២ម នៅរាយប៉ាយ ហើយអាចលូតឡើងដល់កំពស់២០ម។ ព្រៃទាំងនេះ ជាទូទៅមានលក្ខណៈជាដីព្រៃ ដែលមានគំរបម្លប់ពី៥០%-៧០% ។ គំរបព្រៃគ្របដណ្តប់ដោយស្មៅ ដែលជាទូទៅជាប្រភេទ *Imperata cylindrica* ។ មានដើមបញ្ញើក្អែក តែពីរបីប្រភេទទេនៅក្នុងតំបន់រ៉ាមសារ ។

បញ្ហារួមរបស់ព្រៃរបោះឈើទាលនេះ គឺភ្លើងឆេះ ហើយដែលព្រៃទាំងនេះតំណាងឱ្យរុក្ខជាតិភ្លើងឆេះចុងក្រោយបំផុត។ ព្រៃប្រភេទនេះ ដែលមាននៅជាប់តំបន់រ៉ាមសារជារឿយៗត្រូវបានគេដុត និងរានព្រៃយកដីដាំស្រូវ និងបរបាញ់ ។ សត្វស្លាប និងថនិកសត្វជាច្រើន បានបន្សាំទៅនឹងការរស់នៅក្នុងប្រភេទព្រៃទាំងនេះ ប៉ុន្តែសត្វទាំងនេះឥឡូវខ្សត់ណាស់ ឬក៏ផុតពូជ ដោយសារការបរបាញ់ ។

ព្រៃពាក់កណ្តាលស្រោងក៏មាននៅតំបន់ទំនាបល្បាប់ទៅកាន់ភាគខាងកើត និងខាងលិចនៃទន្លេមេគង្គ ជាពិសេស កន្លែងដែលនៅជ្រៅ និងមានដីជាតិជាង និងមានសំណើមជាងដីរបស់ព្រៃរបោះឈើទាល ។ នៅពេលដែលគ្មានការបំផ្លាញព្រៃពាក់កណ្តាលស្រោង អាចកើតមានដើមឈើទាលដែលមានកំពស់៥០ម ដែលគ្របពីលើព្រៃគំរបក្រាស់ មានកំពស់តែ ៣០ម។ ព្រៃប្រភេទនេះ មានទំរង់ស្មុកស្មាញ ដែលមានច្រើនទៅដោយវល្លិ៍លីយាណា និងបញ្ញើក្អែក និងប្រភេទរុក្ខជាតិប្រទាល។ ការកើតមាន និងរបាយព្រៃប្រភេទនេះ មិនទាន់បានសិក្សាច្បាស់ទេនៅតំបន់រ៉ាមសារ ប៉ុន្តែព្រៃនេះមិនកើតមានទេ នៅតំបន់តាមដងផ្លូវទៅកាន់អូរស្វាយ និងព្រំដែនឡាវ។ វា អាចកើតមាននៅលើកោះធំៗមួយចំនួនរបស់ទន្លេមេគង្គ ។

ព្រៃរបោះចំរុះ ដូចគ្នានឹងព្រៃពាក់កណ្តាលស្រោង ប៉ុន្តែមានប្រភេទព្រៃរបោះខ្ពស់ជាង ។ អាជ្ញាធរមួយចំនួនមិនគិត ថាវាជាប្រភេទព្រៃខុសគ្នាទេ ដោយគ្រាន់តែការផ្លាស់ប្តូររបស់ព្រៃពាក់កណ្តាលស្រោងតែប៉ុណ្ណោះ (Rundell, 1999)។ ដោយសារមូលហេតុនេះ វត្តមានព្រៃនេះនៅតំបន់រ៉ាមសារ បាននាំឱ្យមានការពិភាក្សា និងមិនមានការចងក្រងត្រឹមត្រូវទេ ។

ប្រភេទរុក្ខជាតិមួយទៀតដែលមានជាទូទៅនៅតំបន់រ៉ាមសារ គឺព្រៃឬស្សី។ ព្រៃនេះកើតមាននៅកន្លែង

ដែលរុក្ខជាតិ ដើមត្រូវបានគេកាប់។ វាមានជាទូទៅ នៅតាមបណ្តោយមាត់ទន្លេ និងនៅពេញភូមិ ។

រុក្ខជាតិនៅតំបន់រ៉ាមសារ និងតំបន់នៅជាប់នោះ មិនទាន់បានសិក្សាច្បាស់ទេ។ ការសិក្សា គួរតែមានជា-ពិសេស សំរាប់ព្រៃនៅតាមកោះខ្សាច់របស់ទន្លេមេគង្គ ដែលលិចទឹកតាមរដូវ ហើយដែលស្ថិតនៅក្នុងព្រំដែនឃុំរបស់តំបន់រ៉ាមសារ។ រុក្ខជាតិ របស់ដៃទន្លេសំខាន់ៗ ដូចជាអូរតាឡាស់ត្រូវបានស្គាល់តិចតួចណាស់ និងនៅ-តាមជួរភ្នំដងរ៉ែក ដែលជាតំបន់រងទឹក ភ្លៀងរបស់វា ក៏មានការចាប់អារម្មណ៍ពិសេសដែរ ។

## ថនិកសត្វ

បច្ចុប្បន្ននេះ ថនិកសត្វប្រហែលជា១០០ប្រភេទ ត្រូវបានកត់ត្រាសំរាប់ប្រទេសកម្ពុជា (Smith, 2001)។ តាមជីវភូមិសាស្ត្រ ប្រទេសកម្ពុជាស្ថិតនៅក្នុងអនុតំបន់ឥណ្ឌូចិន និង ចំពោះថនិកសត្វ អាចបែងចែកជា៤តំបន់ ។ តំបន់២ក្នុងចំណោមតំបន់នេះគឺ តំបន់ព្រៃរបោះឈើទាល និងព្រៃរបោះចម្រុះ ដែលស្ថិតនៅទំនាបខាងជើង និងខាងកើតរបស់ប្រទេសកម្ពុជា។ ព្រៃរបោះឈើទាល ស្ថិតនៅភាគខាងលិចនៃទន្លេមេគង្គ និងមួយទៀតនៅចន្លោះទន្លេមេគង្គ និងព្រំដែនវៀតណាម។ ទន្លេមេគង្គនៅខេត្តស្ទឹងត្រែងដែលមានតំបន់រ៉ាមសារ គឺជាផ្នែកសំខាន់ ដែលដូចនេះវាបង្កើតជាព្រំដែនភូមិសាស្ត្រសត្វ។ នៅទំនាបខាងកើត និងខាងជើង គឺជាទីជំរកសំខាន់សំរាប់ប្រភេទថនិកសត្វដែលរងគ្រោះ វីសត្វដែលគេស្គាល់តិចតួច ជាពិសេសពួកកន្ទឹក ស្វា ឆ្កែ ឆ្មារ ក្ដាន់ និងសត្វពាហនៈ ។

លោក Vong (2004) បានផ្តល់ទិន្នន័យជាច្រើនពីថនិកសត្វដែលមាននៅក្នុង វីនៅជិតតំបន់រ៉ាមសារ។ សរុបមាន២៦ ប្រភេទ ដែលមាននៅតំបន់រ៉ាមសារ (តារាង ៤.៦)។ ថនិកសត្វតូចៗនៅតំបន់រ៉ាមសារ ដូចជា ប្រចៀវ កណ្តុរ កន្ធឹក ភេ សំពោច។ល។ មិនរាប់បញ្ចូលក្នុងការសិក្សានេះទេ។ ចំនួនថនិកសត្វសរុបនៅក្នុងតំបន់រ៉ាមសារ នឹងមានលើសពី២៦។ ថនិកសត្វនៅតំបន់រ៉ាមសារ ភាគច្រើនត្រូវបានគេបរបាញ់ និងមានការបាត់បង់ ឬថយចុះទីជំរក ដែលកត្តាទាំងនេះ បានរួមចំណែកដល់ការថយចុះ និងការផុតពូជប្រភេទជាច្រើនក្នុងមូលដ្ឋាន។ ការបរបាញ់ បានរាលដាលច្រើន ហើយទង្វើនេះត្រូវបានអនុវត្តឡើងសំរាប់បរិភោគ លក់ដូរ ធ្វើជាវត្ថុអនុស្សាវរីយ៍ និងធ្វើថ្នាំជាដើម។

Smith (2001) បានកត់បញ្ចូលការគំរាមកំហែងធំៗ ទៅក្នុងបញ្ជីក្រហម IUCN សំរាប់ប្រទេសកម្ពុជា ដែលសត្វទាំងនោះកំពុងប្រឈម នឹងគ្រោះថ្នាក់ ។ ការគំរាមកំហែងចំពោះប្រភេទទាំងនោះ ដែលកត់ត្រាដោយលោក Vong (2004) មាននៅក្នុងតារាង៤.៧ ។ ដូចនេះ ការគំរាមកំហែងមានចំពោះ១៨ប្រភេទក្នុងចំណោម ២៦ប្រភេទ ដែលបច្ចុប្បន្នមាននៅក្នុង និងជុំវិញតំបន់រ៉ាមសារ។ ជាបន្ថែម លោក Smith (2001) បានកត់ត្រា ៥ប្រភេទទៀត (រញ្ជីប្រជេះ ឆ្មាព្រៃ ឆ្មាដាវ ខ្លារខិន ប្រើស) ដែលធ្វើឱ្យមានការព្រួយបារម្មណ៍ក្នុងការអភិរក្ស។ ស្ថានការណ៍ដែលរៀបរាប់ដោយ Vong (2004) បង្ហាញថា ប្រភេទទាំងចំនួន២៣កំពុងប្រឈមនឹងការបរបាញ់ ការបាត់បង់ និងថយចុះទីជំរកនៅក្នុងតំបន់រ៉ាមសារ។ ដូចនេះ ស្ថានការណ៍ក្នុងតំបន់ ឆ្លុះបញ្ចាំងរូបភាពសង្គម។

Van Song (2003) បានរាយការណ៍ថាកម្ពុជា ជាប្រទេសមួយក្នុងចំណោមប្រទេស២ដែលមានការកើត

ការជួញដូរនេះ គឺនៅតាមបណ្តោយផ្លូវជាតិលេខ៧៨នៅប្រទេសកម្ពុជាកាត់តាមខេត្តរតនៈគីរីទៅកាន់ខេត្តដូកកូ ប្រទេសវៀតណាម។ នេះជាការត្រឹមត្រូវដែលសន្និដ្ឋានថា ការជួញដូរខុសច្បាប់ចំពោះសត្វ (សត្វថនិសត្វ បក្សី ល្មូន) ដែលគេចាប់នៅក្នុង និងនៅជុំវិញតំបន់រ៉ាមសារ ហើយត្រូវបានដឹកជញ្ជូនតាមផ្លូវនោះ ។

មានសត្វផ្សោតមួយហ្វូង (*Orcaella brevirostris*) នៅក្នុងអន្លង់ឈើទាលដែលស្ថិតនៅចុងខាងជើង នៃតំបន់ រ៉ាមសា និងព្រំដែនប្រទេសឡាវ (MDCP, 2004)។ ចំនួននេះមិនច្រើនទេ គឺមាន៨ ទៅ ១០ក្បាល ដែលជាចំនួនសល់ពីហ្វូង ដ៏ធំកាលពីមុន។ សត្វផ្សោតមួយហ្វូងទៀតនៅក្នុងទន្លេមេគង្គ គេប្រទះឃើញនៅភាគខាងជើងខេត្តក្រចេះ ដែលមានចំនួន ប្រហែល៧០ក្បាល។ គេឃើញមាន ការខិតខំប្រឹងប្រែងក្នុងការអភិរក្សសត្វផ្សោតទាំងនេះផងដែរ (MDCP, 2004)។ អនាគត ហ្វូងសត្វផ្សោត តូចមួយនៅតាមបណ្តោយព្រំដែន ពុំមានភាពច្បាស់លាស់ទេ។ ការគំរាមកំហែងកើតពីការប្រើមងធំៗ ដែលមានក្រឡាតូចៗ(ទំហំក្រឡា២៥ស.ម) ដែលធ្វើឱ្យទាក់ជាប់សត្វផ្សោតរហូតស្លាប់ និងមានការប្រើប្រាស់ទូកទេសចរណ៍ដែលលឿន និងមានសំលេងខ្លាំង។ ការរំខានចំពោះសត្វផ្សោត កើតឡើងដោយការប្រើប្រាស់ទូកទេសចរណ៍ និងការនេសាទ ហួសហេតុដែលនាំឱ្យខ្សត់ចំណីសំរាប់សត្វផ្សោត។ សត្វផ្សោតកាលពីមុន មានច្រើននៅទន្លេសេសាន ទន្លេស្រែពក និងទន្លេសេកុង។ បច្ចុប្បន្ននេះ គេកម្រឃើញសត្វផ្សោតនៅទីនោះណាស់ តែមានការរកឃើញសំណាកផ្សោតស្លាប់ នៅខែមករា ឆ្នាំ២០០៥ នៅទន្លេស្រែពកភាគខាងកើតនៃប្រទេសកម្ពុជា និងនៅក្នុងខេត្តស្ទឹងត្រែង រតនៈគីរី និងមណ្ឌលគីរី។

**តារាង ៤.៦ ថនិកសត្វនៅក្នុង និងនៅជិតតំបន់រ៉ាមសារ**

| ឈ្មោះសត្វ | ឈ្មោះវិទ្យាសាស្ត្រ | ពិពណ៌នា |
|---|---|---|
| ពង្រូល | *Manis javanica* | នៅខាងក្រៅតំបន់រ៉ាមសារ ខ្សត់ និងកំពុងថយចុះដោយការបរបាញ់ |
| ស្វាក្តាម | *Macaca fascicu-laris* | មាននៅតំបន់ រ៉ាមសារ បរបាញ់មិនច្រើន |
| ស្វាត្រោស | *Macaca nemes-trina* | មាននៅលើកោះខ្លះនៅតំបន់រ៉ាមសារ និងទន្លេអូរតាឡាស់ |
| ឆ្កែព្រៃអាស៊ី | *Cuon alpinus* | មាននៅតំបន់រ៉ាមសារ តែមិនច្រើន |
| ឆ្កែចចក | *Canis aureus* | មាននៅជុំវិញតំបន់រ៉ាមសារ តែមិនច្រើន |
| ខ្លាឃ្មុំតូច | *Ursus malayanus* | ពីមុនមាននៅជំវិញតំបន់រ៉ាមសារ តែមិនច្រើន និងថយ ចុះនៅ-ផ្នែកខាង ក្រៅ ដោយការបរបាញ់ |
| ខ្លាឃ្មុំអាស៊ីពណ៌ខ្មៅ | *Ursus thibetanus* | ពីមុនមាន តែពេលនេះជឿថាមិនមាននៅតំបន់រ៉ាមសារ ទេ |
| ឆ្មាព្រៃ | *Felis chaus* | នៅតំបន់ជាប់តំបន់រ៉ាមសារដូចជាអូរតាឡាស់ តែមិនច្រើន និងកំពុងទទួល រងការបរបាញ់ |
| ខ្លារខិន | *Panthera pardus* | ជួនកាលមាននៅតំបន់រ៉ាមសារ |
| ខ្លាធំ | *Panthers tigris* | មានរបាយការណ៍ថាមកពីឃុំព្រះរំកិល |

| | | |
|---|---|---|
| **ខ្លាលឿងមាស** | *Catopuma temminkii* | **មិនមានកត់ត្រាទេ និងជឿថាបាត់បង់ពីតំបន់រ៉ាមសារ** |
| **ឆ្មាផាវ** | *Prionailurus bengalensis* | **មាននៅតំបន់រ៉ាមសារ និងប្រឈមការបរបាញ់** |
| **ខ្លាត្រី** | *Prionailurus viverrinus* | **ពីមុនមានគ្រប់កន្លែង តែឥឡូវមាននៅអូរតាឡាស់ និងប្រឈមការ បរបាញ់** |
| **ខ្លារខិនពពាល** | *Neofelis nebulosa* | **មាននៅអូរតាឡាស់ តែមិនច្រើន និងប្រឈមការ បរបាញ់** |
| **កែះ** | *Naemorhedus sumatrensis* | **មាននៅអូរស្វាយនៅឆ្នាំ១៩៩៣ និងប្រឈម ការ បរបាញ់** |
| **ទន្សោង** | *Bos javanicus* | **តែមិនច្រើន និងប្រឈមការ បរបាញ់** |
| **ខ្ទីង** | *Bos gaurus* | **មាននៅព្រៃខាងក្នុងនិងក្រៅតំបន់រ៉ាមសារ និងប្រឈម ការ បរបាញ់** |
| **ក្របីព្រៃ** | *Bubalus arnee* | **មិនមានទៀតទេ** |
| **ប្រើស** | *Cervus unicolor* | **មិនមាននៅតំបន់រ៉ាមសារទេ តែមាននៅព្រៃជិតនោះ និងប្រឈមការ បរបាញ់** |
| **រមាំង** | *Cervus eldii* | **មិនមាននៅតំបន់រ៉ាមសារ និងតំបន់ជិតនោះទេ** |
| **ឈ្លូស** | *Muntiacus muntjac* | **មាននៅលើកោះតំបន់រ៉ាមសារ និងអូរតាឡាស់** |
| **កាំប្រម៉ា** | *Hystrix brachyura* | **មានគ្រប់កន្លែង និងប្រឈមការ បរបាញ់ធ្វើថ្នាំ និងអាហារ** |
| **ជ្រូកព្រៃ** | *Sus scrofa* | **មានគ្រប់កន្លែង និងប្រឈមការ បរបាញ់** |
| **ដំរី** | *Elephas maximus* | **មាននៅខាងក្នុង រី ជិតឃុំព្រះរំកិល** |
| **ស្វាប្រផេះ** | *Nycticebus coucang* | **មាននៅតំបន់រ៉ាមសារ និងថយចុះដោយប្រឈមការ បរបាញ់** |
| **ស្វាភ្លើង** | *Nycticebus pygmaeus* | **មិនមានទៀតទេ** |

**ប្រភព:** ដកស្រង់ពី Smith (2001) and Vong (2004)

**តារាង ៤.៧ ការគំរាមកំហែងចំពោះថនិកសត្វរបស់តំបន់រ៉ាមសារដែលមាននៅក្នុងបញ្ជីក្រហម IUCNកម្ពុជា**

| **លក្ខណៈ IUCN** | **ប្រភេទ** | **គោលដៅល្មើស** | **បរបាញ់** | **បាត់បង់ទីជំរក** | **បាត់បង់ចំណី** |
|---|---|---|---|---|---|
| **កំពុងរងគ្រោះ** | **ទន្សោង** | x | x | | |
| " | **ដំរី** | x | x | | |
| " | **ខ្លាធំ** | x | x | | x |
| " | **ក្របីព្រៃ** | x | x | | |
| **ងាយរងគ្រោះ** | **ខ្ទីង (សត្វពាហនៈព្រៃ)** | x | x | x | |

| | | | | | |
|---|---|---|---|---|---|
| " | កែះ (សត្វពាហនៈព្រៃ) | | x | | |
| " | ឆ្កែព្រៃ | | | | x |
| " | រញ្ជើភ្លើង (ដូចកំប្រុក) | x | x | | |
| " | ស្វាក្តាម | | x | x | |
| " | ខ្លារខិនពពក | x | x | x | x |
| " | ខ្លាឃ្មុំអាស៊ីខ្មៅ | x | x | x | |
| ជិតរងការគំរាមកំហែង | ខ្លាមាសលឿង | | x | | |
| " | ខ្លាត្រី | | x | x | |
| " | ស្វាក្តាម | | x | | |
| " | ពង្រូល | x | x | | |
| ដឹងមិនគ្រប់គ្រាន់ | រមាំង | x | x | | |
| " | ខ្លាឃ្មុំ | x | x | x | |
| " | រញ្ជើប្រផេះ (ដូចកំប្រុក) | x | x | | |

**ប្រភព:** ដកស្រង់ពី Smith (2001)

## ពពួកបក្សី

បច្ចុប្បន្ន មានបក្សីជាង៥០០ប្រភេទ ដែលត្រូវបានកត់ត្រាទុកសំរាប់ប្រទេសកម្ពុជា ប៉ុន្តែសព្វថ្ងៃនេះ ដោយមានការសិក្សានៅតំបន់តូចៗ គេសង្ឃឹមថា វានឹងកើនឡើងប្រហែលជា៦០០ប្រភេទ (Smith, 2001). ប្រទេសកម្ពុជា ត្រូវបានបែងចែកជាតំបន់ភូមិសាស្ត្រផ្សេងគ្នាចំនួន៦ ដោយទាក់ទងទៅនឹងបក្សី។ តំបន់២ ក្នុងចំណោមតំបន់ទាំងនេះ គឺទន្លេមេគង្គ និងព្រៃឈើទាលស្ងួតនៃទំនាបភាគខាងជើង ទៅដល់ខាងកើត និងខាងលិចនៃទន្លេមេគង្គ ដែលមានយ៉ាងច្បាស់នៅតំបនរ៉ាមសារ និងតំបន់ជាប់គ្នានេះ។ ជាសរុប បក្សីចំនួន៣៩ប្រភេទរបស់ប្រទេសកម្ពុជា ត្រូវបានកត់ត្រាដោយ BirdLife International (2003) ដែលចាត់ទុកជាប្រភេទកំពុងរងគ្រោះ រឺ ជិតរងការគំរាមកំហែង។ មាន៦ ប្រភេទមាននៅ តាមបណ្តោយទន្លេមេគង្គ ដែលបញ្ជាក់ថាតំបន់រ៉ាមសារ និងតំបន់នៅជាប់គ្នានេះ ជាតំបន់អភិរក្សបក្សីសំខាន់ៗ ។

BirdLife International (2003) បានកំណត់អត្តសញ្ញាណតំបន់សត្វស្លាបចំនួន៤០ សំរាប់ប្រទេសកម្ពុជា។ តំបន់មួយ គឺបណ្តាញទន្លេមេគង្គពីខេត្តក្រចេះទៅដល់ព្រំដែនប្រទេសឡាវ ដែលត្រូវរាប់ជាតំបន់រ៉ាមសារ ។ តំបន់សត្វស្លាប នេះមានប្រភេទរងគ្រោះ និងជិតរងការគំរាមកំហែងចំនួន៧ ដូចជា ត្មាតផេះ (*Gyps bengalensis*)និងចំពីកស (*Pseudibis davisoni*) និងប្រភេទដែលជិតរងការគំរាមកំហែង រំពេពោះខ្មៅ (*Sterna acuticauda*) អកត្រីក្បាលប្រផេះ (*Ichthyophaga ichthyaetus*) / ត្មាតភ្លើង (*Sarcogyps calvus*), ស្មោញ

(*Anhinga melanogaster*) និង ប្រភេទពិសេសរបស់ទន្លេមេគង្គគឺ Mekong wagtail (*Motacilla samveasnae*) ។ Vong (2004) បានកត់ត្រាថា ប្រភេទទាំងមាននៅតំបន់រ៉ាមសារ។

សព្វថ្ងៃមានការសិក្សាពីបក្សីនៅក្នុងតំបន់រ៉ាមសារ និងតំបន់នៅជាប់គ្នានោះ ដែលVong (2004) បានកត់ត្រាថាមាន២៣១ប្រភេទ ។ នេះគឺជាចំនួនដែលស្ទើតែស្មើនឹងពាក់កណ្ដាលនៃចំនួនបក្សីទូទាំងប្រទេសកម្ពុជា ។ កំណត់ត្រានេះរាប់ទាំងបក្សីដែលមកពីបណ្ដាញទន្លេមេគង្គ និងទំនាបខាងជើងទៅដល់ទិសខាងកើត និងខាងលិចនៃទន្លេនេះ។ លោក Smith (2001) បានកំណត់អត្តសញ្ញាណបក្សីកម្ពុជាចំនួន៣៩ប្រភេទ និងលោក Vong (2004) បានកត់ត្រា១៧ប្រភេទ ពីតំបន់រ៉ាមសារ (តារាង ៤.៨)។ នេះជាការពិតណាស់ដែលថាតំបន់រ៉ាមសារ និងតំបន់ព្រៃជាប់នោះមានសារៈសំខាន់សំរាប់អភិរក្សសត្វស្លាបរបស់ប្រទេសកម្ពុជា។

**តារាង ៤.៨ ប្រភេទបក្សីសំខាន់ៗរបស់កម្ពុជាដែលនៅក្នុង និងជិតតំបន់រ៉ាមសារ**

| ឈ្មោះបក្សី | ឈ្មោះវិទ្យាសាស្ត្រ | ពិពណ៌នា |
|---|---|---|
| ទុងប្រផេះ | *Pelecanus philippensis* | មានពីខែសីហា ដល់វិច្ឆិកា<br>កំពុងរងគ្រោះ - ងាយរងគ្រោះ |
| ស្នោញ | *Anhinga melanogaster* |ជិតរងការគំរាមកំហែង |
| រនាលពណ៌ | *Mycteria leucocephala* | ជិតរងការគំរាមកំហែង |
| ត្រដក់តូច | *Leptoptilos javanicus* | រងការគំរាមកំហែង-ងាយរងគ្រោះ |
| ត្រដក់ធំ | *Leptoptilos dubius* | រងការគំរាមកំហែង- កំពុងរងគ្រោះ |
| ចំកំ ក ស | *Pseudibis davisoni* | កំពុងរងគំរាមកំហែងធ្ងន់ធ្ងរ |
| ទាកាប៉ាព្រៃ | *Carina scutulata* | រងការគំរាមកំហែង-កំពុងរងគ្រោះធ្ងន់ធ្ងរ |
| អកត្រីតូច | *Ichthyophaga humilis* | ជិតរងការគំរាមកំហែង |
| អកត្រីក្បាលប្រផេះ | *Ichthyophaga ichthya* | ជិតរងការគំរាមកំហែង |
| ត្មាតផេះ | *Gyps bengalensis* | ជិតរងការគំរាមកំហែងធ្ងន់ធ្ងរ |
| ត្មាតខ្មៅ | *Aegypius monachus* | ជិតរងការគំរាមកំហែង |
| ត្មាតភ្លើង | *Sarcogyps calvus* | ជិតរងការគំរាមកំហែង |
| ស្ទាំងស្លាបស្រួចចុងខ្នងស | *Aquilla clanga* | ជិតរងការគំរាមកំហែង |
| ក្ងោកបៃតង | *Pavo muticus* | ជិតរងការគំរាមកំហែង-ងាយរងគ្រោះ |
| រំពេពោះខ្មៅ | *Sterna acuticauda* | ជិតរងការគំរាមកំហែង |
| រំពេចំពុះខ្ទីវែង | *Rhyncops albicollis* | ត្រូវការបញ្ជាក់ឡើងវិញ |
| កេងកងធំ | *Buceros bicornis* | ជិតរងការគំរាមកំហែង |

**ប្រភព:** ដកស្រង់ពី Smith (2001) and Vong (2004)

Bird Life International (2003), Smith (2001) និង Vong (2004) បានកំណត់ពីការគំរាមកំហែងស្រដៀងគ្នា ចំពោះបក្សីប្រទេសកម្ពុជា ។ ការគំរាមកំហែងធំបំផុតគឺ ការបរបាញ់ ការប្រមូលយកពងកូនរួមទាំងការសំលាប់ និង ការចាប់សត្វពេញវ័យ។ សកម្មភាពទាំងនេះ ធ្វើឡើងនៅវេជ្ជផ្សេងៗ សំរាប់យកទៅធ្វើអាហារ សំរាប់ជំនួញ សំរាប់ធ្វើថ្នាំ សំរាប់អ្នកបន់ស្រន់លែងនៅតាមទីអារាម និងសំរាប់ជាសត្វចិញ្ចឹមតាមផ្ទះនិងឧទ្យាន ។ ការបាត់បង់ និងថយចុះទីជំរកក៏ជាបញ្ហាធំដែរ។ ការបាត់បង់ទាំងនេះមានដោយសារសកម្មភាពដូចជា ការស្រោចស្រពតំបន់ដីសើមសំរាប់ធ្វើកសិកម្ម ការកាប់ ដើមឈើដែលជាទីជំរក ការកាប់ឈើ ការសង់ទំនប់វារីអគ្គិសនីកាត់ទន្លេ។ ការសង់ទំនប់ទឹកនេះ នាំឱ្យមានការបាត់បង់កោះ ខ្សាច់ដែលជាជំរកសត្វស្លាបនៅទន្លេសេសាន (Claassen, 2004)។

Danida (2000) បានរាយការណ៍ថា សត្វក្រៀលមាននៅអូរស្វាយ និងឃុំព្រះរំកិល និងឃុំផ្សេងៗទៀតជិតតំបន់រ៉ាមសារ។ Vong (2004) មិនបានកត់ត្រាប្រភេទនេះទេ។ នេះជាប្រភេទសត្វស្លាប ដែលរងការគំរាមកំហែងទូទាំងពិភពលោក ហើយដែលវាធ្វើការបន្តពូជនៅដីវាលស្មៅ និងទីវាលនៅក្នុងព្រៃឈើទាលស្ងួតរបស់វាលទំនាបខាងជើង និងខាង កើតប្រទេសកម្ពុជា។ បក្សីនេះ ជាប្រភេទមួយក្នុងចំណោម៨ប្រភេទ ដែលមានសារៈសំខាន់សំរាប់កម្មវិធីអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាព នូវជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ (MWBP)។ ដូចនេះហើយរបាយការណ៍ពីវត្តមានសត្វក្រៀល នៅតំបន់រ៉ាមសារ និងតំបន់ជិតនោះ មានសារៈប្រយោជន៍ណាស់ ។

## ពពួកល្មូន និងមណ្ឌូកសត្វ

វត្តមាន និងរបាយល្មូន និងមណ្ឌូកសត្វរបស់កម្ពុជាមិនត្រូវបានគេស្គាល់ច្បាស់ដូចក្រុមថនិកសត្វ និងបក្សីទេ។ Vong (2004) បានកត់ត្រាថា មានល្មូន៤៣ប្រភេទនៅក្នុង និងជុំវិញតំបន់រ៉ាមសារ ឯ Smith (2001) ពិពណ៌នាថា ៤១ប្រភេទ ចំណែក Stuart *et al* (2001) បានកត់ត្រាថាមានអណ្តើក១៨ប្រភេទ។ កំណត់ត្រានេះ ក៏រាប់បញ្ចូលអណ្តើក សមុទ្រ៥ ប្រភេទផងដែរ។

មាន៤៣ប្រភេទទៀត ដែលកត់ត្រាដោយលោក Vong (2004) មាននៅក្នុងតារាង៤.៩។ ចំនួន២៣ប្រភេទដែលរកឃើញដោយ Smith (2001) មានសារៈសំខាន់សំរាប់ការអភិរក្ស ។ ពិតណាស់ដែលតំបន់រ៉ាមសារ និងទន្លេរបស់វាព្រមទាំងព្រៃនៅជាប់នោះ មានល្មូនចម្រុះសំខាន់ៗ។ បច្ចុប្បន្ន ជាងពាក់កណ្តាលនៃប្រភេទដែលបានកត់ត្រា មានសារៈសំខាន់ជាអន្តរជាតិ សំរាប់ការអភិរក្ស ដែលរាប់បញ្ចូលក្នុងក្រុម IUCN ឬក្រុម CITES ឬជាក្រុមសត្វដែលរកឃើញ ដោយ Smith (2001)។

ដោយមានភស្តុតាង ដែលប្រមូលដោយ Vong (2004) យើងអាចឃើញថា ល្មូនជាច្រើនត្រូវបានប្រមាញ់។ ពួកវាត្រូវបានលក់នៅតាមផ្សារក្នុងតំបន់ ឬសំរាប់ធ្វើម្ហូប និងនាំចេញទៅប្រទេសឡាវ វៀតណាមសំរាប់ធ្វើម្ហូប យកស្បែក និងធ្វើថ្នាំ។ ការប្រមាញ់ និងការចាប់នៅក្នុងតំបន់ គឺជាការគំរាមកំហែងធំបំផុតចំពោះការរស់នៅរបស់ល្មូនជាច្រើនប្រភេទ។ Vong (2004) បានរាយការណ៍ថា ប្រភេទល្មូនទឹកជាច្រើនត្រូវបានឈ្លក់ទឹកស្លាប់ ក្រោយពីជាប់មងអ្នកនេសាទ។

ពុំមានព័ត៌មានទេ ស្តីពីមណ្ឌុកសត្វនៅក្នុង និងជុំវិញតំបន់រ៉ាមសារ។ ដោយសារតំបន់ដីសើម និងជំរកលើដីច្រើនបែប គេសង្ឃឹមថាមានសត្វប្រភេទនេះច្រើនរស់នៅតំបន់នេះ។ កង្កែប ត្រូវបានគេចាប់ពីវាលស្រែ និងតាមដងស្ទឹង ព្រែក/អូរ សំរាប់ធ្វើម្ហូប និងលក់គ្រប់កន្លែងនៅក្នុងតំបន់រ៉ាមសារ។

## ពពួកមច្ឆាជាតិ

មានត្រីជាង៨៥០ប្រភេទ នៅតាមទន្លេមេគង្គក្រោម និងទន្លេសាប ហើយអាចចែកចេញជា២ក្រុម គឺត្រីស និងត្រីខ្មៅ។ ត្រីស ត្រូវការអុកស៊ីសែនច្រើននៅក្នុងទឹក និងទឹកដែលមានកំរិតអាស៊ីតទាបជាងត្រីខ្មៅ។ ពួកវា ធ្វើបំលាស់ទីជា ទៀងទាត់ រវាងទន្លេសាប និងផ្នែកខាងលើទន្លេមេគង្គ និងដៃទន្លេដែលចូលតំបន់រ៉ាមសារ នៅពេលដែលទឹកទន្លេឡើងនៅរដូវវស្សា។ ដូចនេះ ពួកវាបង្កើតជាមូលគ្រឹះសំខាន់មួយសំរាប់ផលផលរបស់តំបន់រ៉ាមសារ។ រីឯត្រីខ្មៅរស់នៅជាប្រចាំនៅតំបន់ទន្លេសាប (Ashwell, 1997)។

បច្ចុប្បន្ន ការសិក្សាពីត្រីនៅតំបន់រ៉ាមសារបានបង្ហាញថា មាន១៦៧ប្រភេទ Vong (2004)។ តាមពិតប្រភេទ ត្រី មានច្រើនជាងនេះទៅទៀត។ ត្រី២១ប្រភេទ ដែលមានសារៈសំខាន់សំរាប់អ្នកនេសាទនៅតំបន់រ៉ាមសារ គឺបង្ហាញនៅតារាង ៤.១០ និង ប្រភេទមួយចំនួនទៀត ដែលកត់ត្រាដោយ Smith (2001) ដែលគេចាត់ទុកថាសំខាន់សំរាប់ ការអភិរក្សសំរាប់ ប្រទេសកម្ពុជា ។

ការផ្លាស់ទីតាមរដូវរបស់ត្រីរវាងទន្លេសាប និងទន្លេមេគង្គខាងលើ ព្រមទាំងដៃរបស់វានៅរដូវវស្សាបានផ្តល់ផលត្រីយ៉ាងសំខាន់សំរាប់ប្រជាជននៅតំបន់រ៉ាមសារ។ វាមានតំលៃណាស់សំរាប់ជីវភាព និងការរស់នៅរបស់ប្រជាជន ដោយសារតែមានការបំលាស់ទីដ៏សំបើមរបស់ត្រីគ្រប់ប្រភេទជារៀងរាល់ឆ្នាំ។ វិធី និងឧបករណ៍នេសាទជាច្រើន ត្រូវគេប្រើដើម្បីចាប់ត្រី។ ការនេសាទ គឺធ្វើឡើងសំរាប់តែបរិភោគ និងលក់តាមមូលដ្ឋាន។

**តារាង ៤.៩ ប្រភេទល្មូនដែលនៅក្នុង និងជិតតំបន់រ៉ាមសារ**

| ឈ្មោះល្មូន | ឈ្មោះវិទ្យាសាស្ត្រ | ពិពណ៌នា |
|---|---|---|
| ក្រពើ | *Crocodylus siamanesis* | មាននៅកោះកេ និងអូរតាឡាស់។ រងការគំរាមកំហែងធ្ងន់ធ្ងរ CITES I ដោយការប្រមាញ់ |
| កន្ធាយចិន | *Pelodiscus sinensis* | មានលក់នៅភូមិរុនសៀន តំបន់រ៉ាមសារ |
| កន្ធាយក្បាលកង្កែប | *Pelochelys cantorii* | កំពុងរងគ្រោះ និងរងការគំរាមកំហែងដោយការប្រមាញ់ |
| អណ្តើកសោមឈ្មោល | *Cyclemis spp* | ជិតរងការគំរាមកំហែងដោយការប្រមាញ់ |
| កន្ធាយអាស៊ី | *Amyda cartilaginea* | រងការគំរាមកំហែង និងងាយរងគ្រោះដោយការប្រមាញ់ |

| | | |
|---|---|---|
| អណ្តើកក្របីក្បាលលឿង | *Hieremys annandalii* | កំពុងរងគ្រោះ និងរងការគំរាមកំហែងដោយការប្រមាញ់ |
| អណ្តើកសោមញី | *Heosemys grandis* | រងការគំរាមកំហែង និងងាយរងគ្រោះដោយការប្រមាញ់ |
| អណ្តើកបិទមុខស្លូកខ្មៅ | *Cuora amboinensis* | រងការគំរាមកំហែងដោយការប្រមាញ់ |
| អណ្តើកសកល | *Malayemys subtrijuga* | រងការគំរាមកំហែង និងងាយរងគ្រោះដោយការប្រមាញ់ |
| អណ្តើកភ្នំ | *Indotestudo elongata* | កំពុងរងគ្រោះ និងរងការគំរាមកំហែងដោយការប្រមាញ់ |
| ត្រកួត | *Varanus bengalensis* | CITES I ថយចុះដោយការប្រមាញ់ |
| អន្សង | *Varanus salvator* | មានច្រើន CITES II ថយចុះដោយការប្រមាញ់ |
| កន្ត្រង | *Physignathus cocincinus* | មាននៅកោះតំបន់រ៉ាមសារ ថយចុះដោយការប្រមាញ់ |
| ក្តួនប្រភេទ Garden fence lizard | *Calotes versicolor* | មានច្រើននៅតំបន់រ៉ាមសារ |
| ក្តួនប្រភេទ Spotted gliding lizard | *Draco maculatus* | មាននៅពាសពេញតំបន់រ៉ាមសារ |
| ក្តួនប្រភេទ Common gliding lizard | *Draco volans* | មាននៅពាសពេញតំបន់រ៉ាមសារ |
| ក្តួនប្រភេទ Common butterfly lizard | *Leiolepis belliana* | ថយចុះដោយការប្រមាញ់ |
| ក្តួនប្រភេទ Eastern butterfly lizard | *Leiolepis reevesii* | ថយចុះដោយការប្រមាញ់ |
| ក្តួនប្រភេទ Northern forest crested lizard | *Calotes emma* | មាននៅតាមភូមិតំបន់រ៉ាមសារ |
| ក្តួនប្រភេទ Long-tailed lizard | *Takydromus sexlineatus* | មាននៅតាមភូមិតំបន់រ៉ាមសារ |
| ពស់ថ្លាន់ធំ | *Python reticulatus* | មានច្រើន CITES II |
| ពស់ថ្លាន់តូច | *Python molurus* | CITES II |
| ពស់វែករនាម | *Opiophagus hannah* | CITES II ថយចុះដោយការប្រមាញ់ |
| ពស់វែកក្របី | *Naja kaouthia* | CITES II ថយចុះដោយការប្រមាញ់ |
| ពស់វែកដំបូក | *Naja siamensis* | CITES II ថយចុះដោយការប្រមាញ់ |
| ពស់ក្រៃ | *Bungarus fasciatus* | នៅតំបន់រ៉ាមសារ |

**តារាង ៤.៩ ប្រភេទល្មូនដែលនៅក្នុង និងជិតតំបន់រ៉ាមសារ(ត)**

| ឈ្មោះល្មូន | ឈ្មោះវិទ្យាសាស្ត្រ | ពិពណ៌នា |
|---|---|---|
| ពស់វែក | *Trimeresurus sp* | នៅតំបន់រ៉ាមសារ |
| Common mock | *Psammodynastes pulverulentus* | មាននៅព្រៃស្ងួតជិតតំបន់រ៉ាមសារ |
| ពស់ប្រភេទ Rainbow watersnake | *Enhydris enhydris* | មាននៅទន្លេមេគង្គ រងគ្រោះដោយការប្រមាញ់ |
| ពស់ត្រីរស់ ពស់កាចាន់ | *Enhydris bocourti* | មាននៅទន្លេមេគង្គ និងដៃទន្លេរងគ្រោះដោយការប្រមាញ់ |
| ពស់ត្រី | *Homolopis buccata* | មាននៅដៃទន្លេមេគង្គ |
| Chequered keel-back | *Xenochrophis piscator* | មាននៅលើកោះតំបន់រ៉ាមសារ |
| ពស់ប្រភេទ Cave dwelling snake | *Elaphe taeniura ridleyi* | មាននៅតំបន់រ៉ាមសារ |
| ពស់ព្រៃ Radiated rat snake | *Elaphe radiata* | មាននៅព្រៃឈើទាលស្ងួត |
| កន្ធ្លង | *Physignathus cocincinus* | មាននៅលើកោះតំបន់រ៉ាមសារ ដៃទន្លេរងគ្រោះដោយការប្រមាញ់ |
| ពស់ព្រៃ | *Ptyas korros* | មាននៅតាមអូរតាឡាស់ រងគ្រោះដោយការប្រមាញ់ |
| ពស់ប្រភេទ Striped kukri snake | *Oligodon taeniatus* | មាននៅតំបន់រ៉ាមសារ |
| ពស់ប្រភេទ Golden tree snake | *Chrysopelea ornata* | មាននៅលើកោះតំបន់រ៉ាមសារ |
| តុកកែ | *Gecko* gecko | មានគ្រប់ទីកន្លែង បរបាញ់ធ្វើថ្នាំ |
| តុកកែ Spiny-tailed gecko | *Hemidactylus frenatus* | មាននៅតាមផ្ទះក្នុងភូមិ |
| tukEk Flat-tailed gecko | *Cosymbotus platyurus* | មាននៅតំបន់រ៉ាមសារ |
| Many-lined sun skink | *Mabuya multifasciata* | មាននៅតាមកោះតំបន់រ៉ាមសារ |
| Speckled forest skink | *Mabuya maculata* | មាននៅតាមកោះតំបន់រ៉ាមសារ និងមាត់ទន្លេ |

**ប្រភព:** ដកស្រង់ពី Smith (2001) and Vong (2004)

**តារាង ៤.១០ ប្រភេទត្រីសំខាន់ៗនៅតំបន់រ៉ាមសារ**

| ឈ្មោះត្រី | ឈ្មោះវិទ្យាសាស្ត្រ | ពិពណ៌នា និងឈ្មោះភាសាអង់គ្លេស |
|---|---|---|
| ត្រីរាជ * | *Pangasianodon gigas* | Giant catfish ថយចុះ |
| ត្រីប្រាធំ | *Pangasianodon hypophthalmus* | Iridescent shark catfish ថយចុះ |
| ត្រីគល់រាំង | *Catlocarpio siamensis* | Giant barb ថយចុះ |
| ត្រីត្រសក់ * | *Probarbus jullieni* | Seven-line barb ថយចុះ |
| ត្រីត្រសក់ | *Probarbus labeamajor* | ថយចុះ |
| ត្រីចាស៊ីអ៊ី | *Mekongina erythrospila* | ប្រភេទពិសេសសំរាប់ទន្លេមេគង្គ មានតិច |
| ត្រីកេស | *Micronema apogon* | ត្រីគោលដៅ ថ្លៃ |
| ត្រីកេសប្រាក់ | *Micronema bleekeri* | ត្រីគោលដៅ ថ្លៃ |
| ត្រីខ្យា | *Hemibagrus wyckioides* | ត្រីគោលដៅ ថ្លៃ |
| ត្រីឆ្លាំងខ្មៅ | *Hemibagrus wycki* | ថយចុះ |
| ត្រីស្តូក | *Wallago leerii* | ថយចុះ |
| ត្រីខ្លា | *Coius undecemradiatus* | |
| ត្រីពោព្រុយ | *Pangasius sanitwongsei* | |
| ត្រីខ្សាក់ * | *Tenualosa thibaudeaui* | Laotian shad ថយចុះ |
| ត្រីសេះ ឬចាសានាក់ | *Adaptosyax grypus* | ថយចុះ |
| ត្រីអំបូង | *Channa grandinosa* | ថយចុះ |
| ត្រីប្រម៉ា | *Boesemania microlepis* | Small scale croaker. ថយចុះ |
| ត្រីរមាស | *Osphronemus exodon* | ថយចុះ |
| ត្រីត្រចៀកដំរី | *Osphronemus gouramy* | ថយចុះ |
| ត្រីក្រឡង ឬព្រូល | *Cirrhinus microlepis* | ថយចុះ |
| ត្រីកញ្ចុះ * | *Botia sidthmunki* | Ladderback loach |
| * ប្រភេទសំរាប់អភិរក្ស<br>* ប្រភេទជាប្រភេទដែលអ្នកនេសាទច្រើនតែនេសាទយក | | |

**ប្រភព:** ដកស្រង់ពី Smith (2001) and Vong (2004) ។

អ្នកនេសាទរាយការណ៍ថា ចំនួនត្រីដែលចាប់បានថយចុះ នេះបង្ហាញថាកន្លែងផ្សេងទៀតនៅក្នុងប្រទេសក៏មានការថយចុះដែរ។ មិនមានការសិក្សាលំអិតទេ ទៅលើចំនួនត្រីដែលចាប់នៅក្នុង និងជុំវិញតំបន់រ៉ាមសារ។ កំណើនប្រជាជន និងអ្នកនេសាទ ក៏អាចនាំឱ្យមានការថយចុះចំនួនត្រី។ ត្រីរាជ (giant catfish) និងត្រីប្រា (Pangasianodon gigas) កំពុងតែថយចុះទូទាំងប្រទេស ហើយឥឡូវនេះគេកម្រចាប់វាបានណាស់នៅផ្នែកខាង

លើនៃទន្លេមេគង្គរបស់កម្ពុជា។

ត្រីដែលផ្លាស់ទី និងត្រីដែលរស់នៅតំបន់រ៉ាមសារបន្តពូជនៅតាមប្រព័ន្ធទន្លេនៅតំបន់នោះ។ សំខាន់បំផុតគឺអន្លង់ និងដៃទន្លេដែលហូរចូលតំបន់ឋបនីយមណ្ឌល ជាពិសេសអូរតាឡាស់។ អ្នកនេសាទនៅតំបន់រ៉ាមសាររាយការណ៍ថា មានអន្លង់សំខាន់ៗចំនួន២៥នៅក្នុងតំបន់រ៉ាមសារ ដែលភាគច្រើននៅស្រុកថាឡាបរិវ៉ាត (Vong, 2004) មានបង្ហាញនៅតារាង ៤.១១។

**តារាង ៤.១១ អន្លង់នៅតំបន់រ៉ាមសារ**

| ឈ្មោះអន្លង់ | ទីតាំង និង ពិពណ៌នា |
| --- | --- |
| ឈើទាល | ភូមិកោះល្វ អន្លង់សត្វផ្សោត |
| អូរតាឡាស់ | ភូមិក្រឡាពាស ឃុំព្រះរំកិល |
| វ៉ុនខាវ តាហេង | ភូមិឃុំអូរស្វាយ |
| វ៉ុនស្វក្រសេនឡាយ គីខេ | ភូមិអូររុន ឃុំអូរស្វាយ |
| ក្រឡាពាស ឡុងឡុក អូរតាព្រៃ | ភូមិវ៉ុនសៀន ជាអន្លង់៤ដំបូងដែលមានភក់ |
| អូរផ្លុង ប៉ុងក្រាក់ វ៉ុនសៀន, វ៉ុនផ្លុង | |
| អន្លង់កណ្តុរ និង ថ្មធំ | ភូមិកោះស្នែង និងឃុំកោះស្នែង |
| តាព្រហ្ម តាថាវ វ៉ុនខាំ កំបោរ និងកន្ធាយ | ភូមិដាំធំ ឃុំកោះស្នែង |
| វ៉ុនឌុក និង វ៉ុនសាន វ៉ុនតាលុន កន្ទុយកោះតាង | ភូមិថ្មី ឃុំសាមគ្គី |

**ប្រភព:** ដកស្រង់ពី Vong (2004)

អន្លង់ទាំងនេះ ផ្តល់ជាទីជំរកនៅរដូវប្រាំងសំរាប់ត្រីនៅតំបន់នោះ ក៏ដូចជាកន្លែងត្រីពង-កូន និង រីកធំធាត់ត្រីនៅតំបន់ និងពួកត្រីដែលផ្លាស់ទីសំរាប់ពង។ វាមានសារៈសំខាន់ណាស់ សំរាប់ការអភិរក្សត្រី ដែលអន្លង់ទាំងនេះត្រូវតែការពារពី ការនេសាទហួសហេតុ និងត្រូវថែរក្សាគុណភាពទឹកឱ្យបានល្អ ។ អាទិភាពទីមួយអាចត្រូវបានគេទទួលស្គាល់តាមរយៈការ រើសយក និងអនុវត្តរបស់អ្នកស្រុកនូវវិធានការអភិរក្ស និងដំណើរការគ្រប់គ្រង។ ដំណើរការគ្រប់គ្រង អាស្រ័យលើការ ធានាថា ការអភិវឌ្ឍន៍នៅតាមដងទន្លេទាំងនៅផ្នែកខាងលើ និងនៅក្នុងផ្ទៃរងទឹកភ្លៀងនៅតំបន់រ៉ាមសារ (ដូចជា ការសង់ទំនប់ទឹក ប្រព័ន្ធស្រោចស្រព ការបំបែកប្រព័ន្ធទន្លេ ។ល។) ដែលមិនបង្កការប្រែប្រួល ចំពោះលំហូររបស់ទន្លេ និងគុណភាពទឹកទេ។

ការគំរាមកំហែងធំ ចំពោះពូជត្រីនៅក្នុងតំបន់រ៉ាមសារបានកត់ត្រាដោយ Vong (2004) រួមមាន:

- ការនេសាទខុសច្បាប់ និងបំផ្លាញនៅក្នុងអន្លង់ដូចជា ការប្រើគ្រឿងផ្ទុះ និងថ្នាំពុល ព្រមទាំងការប្រើអគ្គិសនី
- ការប្រើប្រាស់សំណាញ់ មងដើម្បីព័ទ្ធចាប់ត្រីដែលប្រមូលផ្តុំក្នុងអន្លង់នៅរដូវប្រាំង
- ការប្រើអួនមានក្រឡាតូច (ញឹក)ត្រឹម២០សម។ ត្រីធំៗដូចជាត្រីគល់រាំង (giant barb, *Catlocarpio*

(small scale croaker, *Boesimania microlepis* ) គឺត្រូវបានគំរាមកំហែងដោយសារប្រើវិធីនេះ។

- ការនេសាទដោយដាក់អួន ស្ទាក់ត្រីតាមមាត់ទន្លេ ស្ទឹង អូរ ដែលចាប់យកត្រីគ្រប់ប្រភេទទាំងតូច ទាំងធំ។

មានត្រីច្រើនប្រភេទនៅតំបន់រាមសារ និងនៅតាមដៃ អូរ ស្ទឹង។ ពួកវាមានសារៈសំខាន់ណាស់ផ្នែកជីវសាស្ត្រ។ ពួក វាក៏ជាមូលដ្ឋានសំខាន់សំរាប់ការនេសាទ និងការបង្កើនចំណូលរបស់ប្រជាជននៅតំបន់រាមសារ ដែលមានប្រមាណ១៣០០០នាក់។ មានភ័ស្តុតាងមួយបង្ហាញថា ប្រភេទត្រីជាច្រើនកំពុងថយចុះដោយសារហេតុផលដែលគេបានកត់ត្រាទុក តែទំហំនៃ ការថយចុះមិនទាន់ដឹងច្បាស់ទេ។ អ្នកនេសាទនៅតំបន់រាមសារ មានភាពឆ្លាតវៃក្នុងការចាត់ចែងការពារពូជត្រី សំរាប់ពេលអនាគត ប៉ុន្តែសព្វថ្ងៃនេះគេជឿថាសកម្មភាពសហគមន៍នេសាទមិនមានប្រសិទ្ធិភាព គ្រប់គ្រាន់ក្នុងការការពារត្រីទេ។ ការថែរក្សាពូជត្រីឱ្យបានល្អ គឺជារឿងសំខាន់បំផុតសំរាប់ប្រជាជននៅតំបន់រាមសារ។

## ពពួកសត្វឥតឆ្អឹងកង

ព័ត៌មាន ស្តីពីសត្វឥតឆ្អឹងកងនៅតំបន់រាមសារ និងតំបន់នៅជាប់នោះ គឺពុំសូវសំបូរទេ។ ប្រភេទខ្យង លៀស បង្កង ក្តាម អាចរកបានច្រើននៅគ្រប់កន្លែង សំរាប់យកហូប និងលក់នៅផ្សារក្នុងស្រុក។ ប្រភេទទាំងនេះ គួរតែកំណត់អត្តសញ្ញាណ និងសិក្សា ដើម្បីកំណត់អេកូឡូស៊ី និងផលប្រយោជន៍ចំពោះសុខភាព និងជីវភាពរស់នៅរបស់ប្រជាជន។

នៅក្នុងតំបន់ដីសើម ស៊ីផានដនរបស់ប្រទេសឡាវ មានប្រភេទខ្យង *Tricula aperta* ដែលដើរតួនាទីជាទីជំរក របស់បារ៉ាសិតមនុស្ស *Schistosoma mekongi* ដែលនាំឱ្យកើតជំងឺស៊ីស្តូ schistosomiasis ។ ជំងឺនេះ មាននៅតំបន់ទន្លេមេគង្គ និងតំបន់ពាមរបស់ប្រទេសកម្ពុជា ។

## សង្ខេប

មានព័ត៌មានច្រើន អំពីបរិស្ថានសំខាន់ៗរបស់តំបន់រាមសារ។ តែទោះជាយ៉ាងណាក៏ដោយ ព័ត៌មានមានកំណត់ និងមិនសូវពិស្តារទេ។

អាកាសធាតុនៅតំបន់រាមសារនេះ គ្របដណ្តប់ដោយឥទ្ធិពលខ្យល់មូសុងដែលបក់ទៅមករវាងទិសឦសាន និងនិរតី។ ជាពិសេស មានទឹកភ្លៀងខ្ពស់តាមរដូវ ដែលជាង៨០ភាគរយ ភ្លៀងធ្លាក់ចន្លោះខែឧសភា និងតុលា ។ បញ្ហានេះ កំណត់ដល់ការដាំស្រូវ និងការនេសាទត្រី ដែលជាមុខរបរបន្ថែមសំខាន់ និងជាសកម្មភាពរកចំណូលរបស់អ្នកស្រុកជាច្រើននៅតំបន់រាមសារ។ របបទឹកភ្លៀងនៅទន្លេផ្នែកខាងលើរបស់តំបន់រាមសារ បានកំណត់លំហូរតាមរដូវរបស់ទន្លេមេគង្គ។ ការខ្វះទិន្នន័យ ជលធាររួមជាមួយចំណេះដឹងមិនគ្រប់គ្រាន់ពីអេកូឡូស៊ីត្រីសត្វទឹក និងព្រៃលិចទឹក បានក្លាយជាឧបសគ្គ ក្នុងការយល់ដឹងពីលំហូររបស់ទន្លេ ដែលមានសារៈសំខាន់ក្នុងការថែរក្សាធនធានជីវៈចម្រុះ។ បញ្ហានេះសំខាន់ណាស់ នៅពេលដែលមានការកើនឡើងនូវសំពាធទៅលើធនធាន

ទាំងនេះដោយសារតែចំនួនប្រជាជនកើនឡើង តំរូវការទឹកខ្ពស់ពីទន្លេមេគង្គ សំរាប់ការស្រោចស្រព ការសង់វារីអគ្គិសនី ការកាប់ព្រៃ និងការប្រែប្រួលអាកាសធាតុ។ មិនមានពត៌មាន ស្តីពីគុណភាពទឹកសំរាប់តំបន់រ៉ាមសារទេ។ តែគេជឿថា ទឹកមានគុណភាពល្អ ហើយនៅពេលអនាគត គុណភាពទឹកអាចថយចុះនៅពេលដែលមានការអភិវឌ្ឍន៍តាមទន្លេ និងការកើនឡើង ផ្នែកឧស្សាហ៍កម្មនៅលើគោក។ គុណភាពទឹកដែលនាំឱ្យត្រីមានសុខភាពល្អ មិនទាន់ដឹងច្បាស់នៅឡើយទេ។

មានព័ត៌មានតិចតួច ស្តីពីភូមិសាស្ត្រតំបន់រ៉ាមសារ និងធនធានរ៉ែ។ នៅពេលដែលការអភិវឌ្ឍន៍សេដ្ឋកិច្ចកើនឡើងនៅពេលអនាគត គួរតែមានការចាប់អារម្មណ៍ការស្រាវជ្រាវរុករករ៉ែសំរាប់ពាណិជ្ជកម្ម។ ការអភិវឌ្ឍន៍ទាំងនេះ នឹងបំផ្លាញគុណភាពទឹករបស់ទន្លេមេគង្គ និងតំបន់នៅក្នុង ឬនៅក្រោមតំបន់រ៉ាមសារ។ ជាការចាំបាច់ណាស់ ដែលគុណភាពទឹកត្រូវតែថែរក្សាឱ្យបានល្អទូទាំងទន្លេមេគង្គកម្ពុជា ដើម្បីឱ្យមានល័ក្ខខ័ណ្ឌល្អសំរាប់ត្រីដែលផ្លាស់ទី ដែលអ្នកស្រុកតំបន់រ៉ាមសារជាច្រើន ពឹងផ្អែកលើវា។

រុក្ខជាតិនៅតំបន់រ៉ាមសារ ត្រូវបានសិក្សាតិចតួចណាស់។ ព្រៃសំខាន់ គឺព្រៃលិចទឹក ដែលស្ទើរតែពុំមានសោះនៅលើពិភពលោក។ សព្វថ្ងៃនេះមានការបំផ្លាញតិចតួច ហើយគួរមានការអភិរក្សជាបឋម។ ដូចគ្នានេះដែរ ព្រៃមាត់ច្រាំងមានសារៈ សំខាន់សំរាប់រក្សាជីវៈចម្រុះ ការពារការសឹកមាត់ច្រាំង និងមានទេសភាពគួរទាក់ទាញ ដែលនេះគួរតែមានការអភិរក្សដែរ។

សត្វទឹកតំបន់រ៉ាមសារ និងតំបន់នៅជាប់នេះ គឺពិតជាមានសារៈខាន់សំរាប់ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះ។ តំបន់ ថបនីយ ដែលមានដី៥០០មពីច្រាំងទន្លេសងខាងនេះ គឺតូចណាស់ សំរាប់ប្រភេទសត្វលើគោក។ វាមានសារៈសំខាន់ សំរាប់សត្វ ដែលរស់ នៅក្នុងទឹកនិងលើគោក ដូច ជាសត្វភេ ដែលពឹងផ្អែកលើតំបន់នេះដែរ ប៉ុន្តែមិនមានព័ត៌មានទេ ។

តំបន់រ៉ាមសារ និងតំបន់ដែលនៅជាប់នោះ មានសត្វលើគោកដែលកំពុងរងគ្រោះថ្នាក់ជាច្រើនដែលគេបានស្គាល់ ។ ដូចនេះ ថនិកសត្វ១៨ប្រភេទ ក្នុងចំណោម២៦ប្រភេទក៏ទទួលរងការគំរាមកំហែង។ ក្រៅពីនេះមានបក្សី១៧ប្រភេទ និងសត្វ ល្មូន២៣ ក្នុងចំណោម៤៣ប្រភេទ ដែលរងការគំរាមកំហែង។ សត្វឆ្អឹងកងទាំងនេះភាគច្រើនត្រូវបរបាញ់សំរាប់ហូប និងលក់ជាអន្តរជាតិ។ អ្នកស្រុករាយការណ៍ថា ប្រភេទសត្វជាច្រើនកំពុងថយ-ចុះ និងបាត់បង់នាពេលថ្មីៗនេះ។ ការបរបាញ់ជាការគំរាម កំហែងធំចំពោះសត្វទាំងនេះនៅតំបន់រ៉ាមសារ និងនៅប្រទេសទាំងមូល។ ប្រសិនបើពុំមានការកាត់ បន្ថយការបរបាញ់ តាមរយៈការពង្រឹងច្បាប់ និងមិនផ្លាស់ប្តូរឥរិយាបថ ចំពោះការបរបាញ់ទេ ពេលនោះវានឹងធ្វើឱ្យបាត់បង់ពូជសត្វជាច្រើន។

តំបន់រ៉ាមសារមានប្រភេទត្រីជាច្រើន យ៉ាងហោចណាស់ប្រមាណ១៦៧ប្រភេទ ហើយចំនួនពិត គឺច្រើនជាងនេះ។ អ្នកនេសាទ ចាប់ត្រីបានជាច្រើនសំរាប់ធ្វើអាហារប្រចាំថ្ងៃ និងលក់រកប្រាក់ចំណូល។ ប្រភេទត្រីទាំងនេះ ជាប្រភេទផ្លាស់ទី ដែលឡើងពីទន្លេសាបនៅរដូវសម្រក ដើម្បីបន្តពូជនៅទន្លេមេគង្គ និងស្ទឹង បឹង បួរ។ មានដៃទន្លេចំនួន៤០ បានហូរចូលតំបន់រ៉ាមសារ ដែលដៃសំខាន់ គឺអូរតាឡាស់។ អូរនេះ មានសារៈសំខាន់សំរាប់ត្រីពង-កូន និងរីកធំធាត់នៅតាមអន្លង់ និងនៅតាមព្រៃលិចទឹក។ ការការពារ និងការ

គ្រប់គ្រងតំបន់ទាំងនេះ មានសារៈសំខាន់សំរាប់រក្សាពូជត្រីទាំងនេះរយៈពេលយូរ។ កូនត្រីធំធាត់ នៅតំបន់រ៉ាមសារ បានផ្លាស់ទីត្រឡប់ទៅកាន់ទន្លេសាបវិញដោយបង្កើត ជាតំបន់នេសាទសំខាន់ៗនៅទីនោះ។ តំបន់ថបនីយ គឺជាទីតាំងសម្បត្តិធម្មជាតិរបស់ជាតិសំរាប់ថែរក្សាពូជត្រី ។

សារៈសំខាន់របស់តំបន់រ៉ាមសារចំពោះកម្មវិធី MWBP គឺតំបន់នេះ និងតំបន់នៅជាប់នោះ គឺជាទីជំរករបស់ប្រភេទសត្វសំខាន់ៗ ដូចជាត្រីគល់រាំង សត្វផ្សោត សត្វក្រៀល និងក្រពើភ្នំ។ ដោយយល់ថា ត្រីរាជ (មិនសូវសំបូរ) នៅតំបន់រ៉ាមសារ ព្រោះតំបន់នេះ មិនអាចជួយថែរក្សាប្រភេទនេះទេនាពេលនេះ។ តំបន់រ៉ាមសារគួរតែត្រូវចាត់ទុកថាជា តំបន់ស្នូលសំរាប់ជាផលប្រយោជន៍ដល់តំបន់ដ៏ធំមួយ។ ផ្ទុយទៅវិញ តំបន់រ៉ាមសារពឹងផ្អែកលើលក្ខខ័ណ្ឌបរិស្ថានល្អនៅក្នុងតំបន់ដ៏ធំ។ តំបន់ដ៏ធំទាំងនេះ រួមមានដៃទន្លេ ស្ទឹង បឹងបួរដែលហូរចូលតំបន់រ៉ាមសារ ជាមួយនឹងតំបន់រងទឹកភ្លៀងដែរ ។

ការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាសំខាន់សំរាប់ការព្យាករណ៍ថាតើតំបន់រ៉ាមសារ នឹងប្រែប្រួលយ៉ាងណានៅខាងមុខ។ សីតុណ្ហភាព ទឹកភ្លៀង និងលំហូរទន្លេ អាចនឹងផ្លាស់ប្តូរនៅទសវត្សរ៍នេះ។ ឥទ្ធិពលទៅលើជីវៈចម្រុះពិបាកនឹងព្យាករណ៍ ព្រោះវាទាក់ទងនឹងកំណើនប្រជាជន និងកំណើនតំរូវការទឹកសំរាប់វារីអគ្គិសនី ការធ្វើកសិកម្ម និងឧស្សាហកម្ម នៅសតវត្សរ៍ទី២១នេះ។ ទោះជាយ៉ាងណាក៏ដោយ កត្តាផ្សំខាងលើនេះ នឹងបន្ថែមសំពាធលើរុក្ខជាតិ សត្វ រួមទាំងជលផល ក្នុងតំបន់រ៉ាមសារនាពេលបច្ចុប្បន្ន និងអនាគត។

# ជំពូក៥: និន្នាការអភិវឌ្ឍន៍

## សេចក្តីផ្តើម

និន្នាការអភិវឌ្ឍន៍បច្ចុប្បន្ន ដោយរួមទាំងកិច្ចសហការថ្នាក់តំបន់ គឺកំពុងតែផ្លាស់ប្តូរនូវវិធីសម្រេចចិត្តលើការអភិវឌ្ឍន៍។ កំណើនប្រជាពលរដ្ឋ និងការធ្វើបំលាស់ទីរបស់ពួកគេ បានដាក់សំពាធទៅលើធនធានមូលដ្ឋាន ដោយរួមទាំងតំបន់ដីសើម នឹងជីវៈចម្រុះ។ ក្រុមហ៊ុនឯកជននានា កំពុងបង្កើនការចាប់អារម្មណ៍របស់ពួកជាមួយឱកាសថ្មីៗក្នុងការដកហូតធនធានទាំងនេះ។ ការសាងសង់ទំនប់វារីអគ្គិសនី និងប្រព័ន្ធធារាសាស្រ្ត បានក្លាយជាអាទិភាពមួយខ្ពស់បំផុតរបស់ប្រទេសនៅក្នុងតំបន់។ ទីផ្សារថ្មីៗ ក៏ត្រូវបានបង្កើតឡើងនៅក្នុងតំបន់ និងសកលលោក សំរាប់ផលិតផលដែលមានធនធានទាំងនេះ។ ផែនការអភិវឌ្ឍន៍សំខាន់ៗ ត្រូវបានគ្រោងសំរាប់បណ្តាខេត្តភាគឦសាន្តប្រទេសកម្ពុជា ដែលមានខេត្តស្ទឹងត្រែង និងរតនគីរីជាដើម។ គ្រប់អ្នកធ្វើការសំរេចចិត្តនៅថ្នាក់តំបន់នៅកម្ពុជា និងខេត្តនានាបានព្យាយាមត្រួសត្រាយការអភិវឌ្ឍន៍នៅក្នុងកម្រិតខ្ពស់ និងសាំញ៉ាំនៃកំលាំងផ្លាស់ប្តូរលំនាំអភិវឌ្ឍន៍តាមវិស័យ ដោយរួមទាំងជម្លោះ និងការប្រកួតប្រជែងផ្នែកផលប្រយោជន៍ ពីភាគីពាក់ព័ន្ធទាំងអស់។

ផ្ទុយនឹងការបកស្រាយខាងលើ ការអភិវឌ្ឍន៍នៅក្នុងតំបន់រ៉ាមសារ នឹងត្រូវចាប់ផ្តើម ហើយវានឹងត្រូវទទួលរងនូវផលប៉ះពាល់ ពីគំរោងអភិវឌ្ឍន៍ទាំងឡាយណា ដែលបានកើតឡើងនៅក្រៅព្រំដែនតំបន់រ៉ាមសារថែមទៀត។

## យុទ្ធសាស្រ្តអភិវឌ្ឍន៍ចម្បងៗ

### គណៈកម្មការទន្លេមេគង្គ

នៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០ គណៈកម្មកាទន្លេមេគង្គត្រូវបានបង្កើតឡើង ដើម្បីធ្វើការប៉ាន់ប្រមាណទៅលើសក្តានុពលសេដ្ឋកិច្ច ទាក់ទងនឹងគំរោងសាងសង់ទំនប់វារីអគ្គីសនី គំរោងបង្វៃផ្លូវទឹក និងប្រព័ន្ធធារាសាស្រ្ត គំរោងកាប់ព្រៃឈើ គំរោងធ្វើនាវាចរ ជលផល និងវិស័យទេសចរណ៍។ ករណីនេះ បណ្តាលឱ្យមានការបង្កើតផែនការគ្រប់គ្រងធនធានទឹកដ៏មានមហិច្ឆតា ក្នុងឆ្នាំ១៩៧០ ដែលផ្នែកសំខាន់ៗរបស់វារួមមាន ការកសាងទំនប់ល្បាក់ទឹក ដើម្បីបង្កើតថាមពល ២៣.៣ ជីហ្គាវ៉ាត់ និងដើម្បីស្តុកទឹកចំនួន១៣៦កោដម$^{៣}$។ ក្រោយមកផែនការនេះត្រូវបាន កែប្រែនៅឆ្នាំ១៩៨៧ (កែប្រែសន្ទស្សន៍ផែនការ) សំរាប់ការអភិវឌ្ឍន៍ធនធានធម្មជាតិ ធនធានដី និងទឹករបស់ទន្លេមេគង្គ។ ដំណាក់កាលទាំងនេះ បានបរាជ័យដោយសារមហិច្ឆតាហួសកម្រិតមានតំលៃលើសលប់ និងភាពមិនយកចិត្តទុកដាក់ពីបណ្តាប្រទេសដែលមានដងទន្លេមេគង្គរួម (Öjendal 2000) ។

នៅក្នុងឆ្នាំ១៩៩៥ កិច្ចព្រមព្រៀងស្តីពីការអភិវឌ្ឍន៍និរន្តរភាព នៃអាងទន្លេមេគង្គ ត្រូវបានចុះហត្ថលេខាដោយប្រទេសទាំង៦នៃទន្លេមេគង្គ ហើយកិច្ចព្រមព្រៀងនេះ ត្រូវបានប្រើជាមូលដ្ឋានសំរាប់ប្រត្តិបត្តិការគណៈកម្មការទន្លេមេគង្គ (MRC )។ មកទល់ឥឡូវនេះ មានតែប្រទេសចំនួនបួន (កម្ពុជា ថៃ ឡាវ និងវៀតណាម)

ដែលស្ថិតនៅក្រោមកិច្ចសម្របសម្រួលពីគណៈកម្មការទន្លេមេគង្គ និងមានការគោរពទៅនឹងសកម្មភាព និងការសម្រេចចិត្តរបស់ខ្លួន។

លោក Ahmed និង Hirsh ក្នុងឆ្នាំ២០០០បានធ្វើការកត់សំគាល់ថា រាល់តម្លៃបង់ខាតរបស់ការអភិវឌ្ឍន៍ទន្លេមេគង្គ បានក្លាយជាបន្ទុកអ្នករស់នៅតាមមូលដ្ឋាន ដោយសារការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធខ្នាតធំទាំងនេះប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគេ និងបរិស្ថាន។ ការប្រឈមបច្ចុប្បន្ន សំរាប់ការអភិវឌ្ឍន៍និរន្តរភាពនៃអាងទន្លេ គឺការសម្រុះសម្រួលរវាងផលប្រយោជន៍ប្រជាជនមូលដ្ឋាន ដែលជាលក្ខណៈរួមរបស់អ្នកនេសាទ និងកសិករភាគច្រើនរស់នៅតាមអាងទន្លេជាមួយនឹងទស្សនវិស័យអភិវឌ្ឍន៍ដ៏ទូលំទូលាយ។ អនាគតគំរោងអភិវឌ្ឍន៍ខ្នាតធំ ត្រូវបានព្យាករណ៍តាមរយៈការដកហូតធនធាននៃអាងទន្លេដែលជាធនធានរួម។

ក្នុងករណីនេះ ការផ្លាស់ប្តូរទស្សនះទៅលើការអភិវឌ្ឍន៍ ក៏មានឥទ្ធពលទៅលើគោលនយោបាយដែលប៉ះពាល់ទៅដល់ធនធានធម្មជាតិនៃអាងទន្លេនេះផងដែរ។ ការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច ដោយរួមទាំងកំណើនប្រជាជន និងចំនួនអ្នកស្ថិតក្នុងបន្ទុកគ្រួសារខ្ពស់ បានបណ្តាលឱ្យមានតម្រូវការច្រើនទៅលើធនធានទឹក ព្រៃឈើ ដីធ្លី និងជលផល របស់អាងទន្លេ។

ទ្រព្យសម្បត្តិរួមតាមមូលដ្ឋាននឹងរងផលប៉ះពាល់ដោយផ្ទាល់ និងប្រយោលដោយគំរោងអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធ កំណើនផលិតកម្មពាណិជ្ជកម្ម ទំនាក់ទំនងទ្រព្យសម្បត្តិបែបថ្មី និងការផ្លាស់ប្តូរផ្សេងៗទៀតនឹងប៉ះពាល់ ដល់តំបន់។ ការពិត ដែលថាធនធានទឹក ត្រី ដី ព្រៃឈើ គឺជាធនធានរួម បានបណ្តាលឱ្យមានការដកហូត និងប្រើប្រាស់មិនសមស្រប ដោយពុំមានការយកចិត្តទុកដាក់លើតំលៃ ក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជនមូលដ្ឋាន។ តួនាទីរបស់ធនធានរួម គេមិនសូវយកចិត្តទុកដាក់នៅក្នុងក្របខ័ណ្ឌវាយតំលៃទាក់ទងផលចំណេញ និងខាតនៃគំរោងអភិវឌ្ឍន៍ ហើយតំលៃធនធានរបស់វាត្រូវបានគេមើលស្រាលដោយស្វ័យប្រវត្តិ (Hirsh, 2000)។

កិច្ចព្រព្រៀងគណៈកម្មការទន្លេមេគង្គ គឺផ្អែកទៅលើផលប្រយោជន៍របស់ប្រទេសដែលចូលរួម ផ្ទុយទៅ-វិញ មានកសិករ និងអ្នកនេសាទចំនួន៦៥លាននាក់កំពុងរស់នៅតាមអាងទន្លេមេគង្គ គឺមានផលប្រយោជន៍រួមផ្សេងពីរដ្ឋ។ ជីវភាពរបស់ពួកគេ គឺពឹងផ្អែកលើធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ី ដែលបង្កើតដោយទន្លេមេ-គង្គ។ ទំនាក់ទំនង និងការពឹងអាស្រ័យគ្នាទៅវិញទៅមករវាងធនធានរួម និងធនធានឯកជន ត្រូវបានទទួលស្គាល់ជាផ្នែកមួយយ៉ាងសំខាន់ដល់ជីវភាព រស់នៅរបស់ពួកគេ។

ជាឧទាហរណ៍ ស្របពេលដែលកសិករកម្ពុជាភាគច្រើន ពុំមានកម្មសិទ្ធិដីធ្លីដែលពួកគេធ្វើកសិកម្ម ប៉ុន្តែសិទ្ធិដើម្បីរស់នៅ និងប្រើប្រាស់ដីធ្លីនោះ ត្រូវបានទទួលស្គាល់ជាទូទៅ។ ស្របពេលនោះដែរ កសិករអាចធ្វើការនេសាទ បរបាញ់ ប្រមូលអនុផលព្រៃឈើ ទំនិញ និងសេវាកម្ម ដែលទទួលបានពីធនធានរួម ដូចជា ដី ទឹក និងព្រៃឈើជាដើម។

មកដល់ពេលនេះ ពុំទាន់មានសញ្ញានៃការអភិវឌ្ឍន៍ណាមួយគួរឱ្យកត់សំគាល់នៅតាមដងទន្លេមេគង្គ ក្នុង-បរិវេណ នៃតំបន់រ៉ាមសារក្នុងខេត្តស្ទឹងត្រែង ឬក៏តំបន់រងទឹកភ្លៀងរបស់វានៅឡើយទេ។

## ផែនការប្លង់មេ សំរាប់អភិវឌ្ឍន៍តំបន់ត្រីកោណ

នៅក្នុងឆ្នាំ២០០៤ ប្លង់មេក្នុងការអភិវឌ្ឍន៍តំបន់ត្រីកោណត្រូវបានបង្កើតឡើងដោយប្រទេសវៀតណាម ដោយបង្ហាញថា តំបន់ព្រំដែននៃប្រទេសទាំងបី (កម្ពុជា វៀតណាម ឡាវ) បានក្លាយជាអាទិភាព សំរាប់កិច្ចសហប្រតិបត្តការអភិវឌ្ឍន៍រវាងប្រទេសទាំងបី។ ផែនការនេះ បានក្លាយជាការពិតក្នុងអំឡុងពេលកិច្ចប្រជុំលើកទីពីរ[៨] របស់នាយករដ្ឋមន្ត្រី ប្រទេសទាំងបី នៅទីក្រុងហូរជីមិញ ប្រទេសវៀតណាម ចាប់ពីថ្ងៃទី២៥ និង ២៦ខែមករា ២០០២។ ការអភិវឌ្ឍន៍ តំបន់ ត្រីកោណ បានគ្របដណ្តប់លើផ្ទៃដីនៃខេត្តចំនួនប្រាំពីរ មានខេត្ត គន្ទុំ យ៉ាឡៃ ដាក់ឡាក់ នៃប្រទេសវៀតណាម ខេត្តអាតាពឺ និងសេកុង នៃប្រទេសឡាវ និងខេត្តរតនៈគីរី និងស្ទឹងត្រែង នៃប្រទេសកម្ពុជា។ ការអភិវឌ្ឍន៍ តំបន់ត្រីកោណ មានផ្ទៃដី សរុបចំនួន ៨៥ ៦៤៨ គ.ម$^{២}$ និងមានប្រជាជនសរុបជាង ៣.៧ លាននាក់រស់នៅទីនោះ។ ដង់ស៊ីតេប្រជាជនគិតជាមធ្យម គឺស្មើនឹង៤៤នាក់/គ.ម$^{២}$ ប៉ុន្តែរបាយនេះ មិនមែនលក្ខណៈស្មើគ្នាទេ។ នៅខេត្តស្ទឹងត្រែង ដង់ស៊ីតេប្រជាជន គឺមានចំនួន ៨នាក់/គ.ម$^{២}$ ដែលចំនួននេះ តិចជាងគេបំផុត ក្នុងចំនោមខេត្តទាំង៧។

ខេត្តទាំងអស់របស់ប្រទេសទាំងបី គឺជាខេត្តតំបន់ខ្ពង់រាប ស្ថិតនៅតាមបណ្តោយព្រំដែនប្រទេសនីមួយៗ។ ខេត្តទាំងនេះ មានលក្ខណៈស្រដៀងគ្នាជាច្រើន ទាក់ទងលក្ខខ័ណ្ឌធម្មជាតិ សេដ្ឋកិច្ច និងសង្គម។ កម្រិតអភិវឌ្ឍន៍របស់ខេត្តទាំងនេះ ជាទូទៅនៅទាប បើប្រៀបធៀបទៅនឹងកម្រិតមធ្យមរបស់ប្រទេសនីមួយៗ។ ខុសពីការអភិវឌ្ឍន៍តំបន់ត្រីកោណរបស់ ប្រទេសផ្សេងៗនៅក្នុងតំបន់ ការអភិវឌ្ឍន៍តំបន់ត្រីកោណនៅប្រទេសអតីតឥណ្ឌូចិន គ្មានការផ្តោតលើការអភិវឌ្ឍន៍ (ដូច ប្រទេសសិង្ហបុរី) ហេតុដូច្នេះប្រទេសទាំងនេះ ត្រូវតែស្វែងរកនូវវិធីរបស់ខ្លួនដើម្បីធ្វើការអភិវឌ្ឍន៍។

យោងតាមគំរោងប្លង់មេ ការអភិវឌ្ឍន៍តំបន់ត្រីកោណ បានគ្រប់គ្រងតំបន់យុទ្ធសាស្រ្តនៅក្នុងប្រទេសនីមួយៗ ទាក់ទងនឹងស្ថានភាពនយោបាយ សេដ្ឋកិច្ច សង្គម សន្តិសុខ ការពារជាតិ និងបរិស្ថានធម្មជាតិ។ តំបន់អភិវឌ្ឍន៍ទាំងមូល ត្រូវបានតភ្ជាប់ទៅនឹងកំពង់ផែសមុទ្រវៀតណាម តាមច្រកសេដ្ឋកិច្ចនៃផ្លូវជាតិលេខ៧៨ ប្រទេសកម្ពុជា ផ្លូវជាតិលេខ១៨ និង១៦ នៃប្រទេសឡាវ និងផ្លូវជាតិលេខ១៤ លេខ១៩ លេខ២៤ និង៤៩ នៃប្រទេសវៀតណាម។ ស្របពេលនោះ តំបន់នេះត្រូវបានតភ្ជាប់ទៅនឹងទីក្រុងភ្នំពេញ និងវៀងច័ន្ទ តាមរយៈផ្លូវជាតិលេខ៧ នៃប្រទេសកម្ពុជា និងផ្លូវជាតិលេខ១៣ប្រទេសឡាវ និងឆ្ពោះទៅកាន់ទីក្រុងហូរជីមិញ និងហាណូយ តាមបណ្តោយផ្លូវជាតិលេខ ១A និងផ្លូវជាតិហូជីមីញ។ កត្តាទាំងនេះ បានបង្កើតបង្កនូវលក្ខណៈអនុគ្រោះបំផុតសំរាប់ប្រទេសទាំងបី ដើម្បីពង្រីកការដោះដូរ និងការពង្រឹងសម្ព័ន្ធភាពរបស់ពួកគេ សំរាប់ប្រយោជន៍អភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។

## ផលប្រយោជន៍ជាអាទិភាពរបស់ប្រទេសកម្ពុជា

យោងតាមគំរោងប្លង់មេនៃការអភិវឌ្ឍន៍តំបន់ត្រីកោណ ប្រទេសកម្ពុជាបានស្នើនូវគំរោងអភិវឌ្ឍន៍ជា

[៨] កិច្ចប្រជុំលើកទី១ បានប្រារព្ធលើនៅទីក្រុងវៀងច័ន្ទ ក្នុងឆ្នាំ១៩៩៩ ដែលភាគីទាំងអស់ព្រមព្រៀងនូវកិច្ចសហប្រតិបត្តិការ សាមគ្គីភាព និងការជួយគ្នាទៅវិញទៅមក នៅក្នុងស្មារតីមិត្តភាព និងភាតរភាព ដែលជាកត្តាសំខាន់ក្នុងការរក្សាស្ថេរភាព និងអភិវឌ្ឍន៍ របស់ប្រទេសនីមួយៗ ក្រោមស្ថានភាពបច្ចុប្បន្ន។

ច្រើនសំរាប់ ខេត្តស្ទឹងត្រែង និងរតនគិរី។ ទោះបីគំរោងទាំងនេះ មិនស្ថិតនៅក្នុងតំបន់រ៉ាមសារក៏ដោយ ក៏វាមានសក្តានុពលប៉ះពាល់ដល់តំបន់នេះផងដែរ។ ផលប៉ះពាល់ទាំងនេះ អាចកើតឡើងដោយសារគំរោងអភិវឌ្ឍន៍កំពុងតែកើតឡើងនៅតាមតំបន់រងទឹកភ្លៀងរបស់ទន្លេ ដែលហូរចូលទៅក្នុងតំបន់រ៉ាមសារ ឧទាហរណ៍ អូរតាឡាស់ និងទន្លេ សេកុង សេសាន និងស្រែពក ដែលហូរចូលទន្លេមេគង្គ។ ប្រសិនបើមានការប្រែប្រួលអាក្រក់ណាមួយដល់គុណភាពទឹក នៅក្នុងទន្លេមេគង្គខាងក្រោមតំបន់រ៉ាមសារ វានឹងនាំឱ្យមានផលប៉ះពាល់ដល់តំបន់នេះតែម្តង និងជាពិសេសការធ្វើបំលាស់ទីរបស់ត្រីតាមដងទន្លេ។

ផែនការអភិវឌ្ឍន៍ដែលបានស្នើដ៏មានសារៈសំខាន់បំផុត គឺការសាងសង់ទំនប់វារីអគ្គិសនី (ចំនួន៥) នៅតាមដងទន្លេសេសាន ស្រែពក និងសេកុង។ ទាំងនេះ នឹងបណ្តាលឱ្យមានការប្រែប្រួលលំហូររបស់ទន្លេ ដោយរួមទាំងផលប៉ះពាល់ទៅ លើធនធានជលផល សត្វព្រៃ កសិកម្ម ហើយអាចពាក់ព័ន្ធនឹងការតាំងលំនៅថ្មីរបស់អ្នកភូមិ ដែលរស់នៅក្នុងតំបន់គោលដៅគំរោង។ លើសពីនេះទៅទៀតគេក៏បានគ្រោងសង់ទំនប់វារីអគ្គិសនីខ្នាតតូច និងមធ្យមនៅតាមដៃ ឬអូរនានារបស់ទន្លេសំខាន់ៗ ដែលទំនងជានឹងប៉ះពាល់ដល់ជីវភាពប្រជាជន រស់នៅតាមនោះដែរ។

នៅក្នុងផែនការមេ ក៏បានទោះទាយផងដែរថា ប្រទេសកម្ពុជានឹងក្លាយជាអ្នកលក់ចេញថាមពលទៅឱ្យប្រទេសវៀតណាម។ ដោយភ្ជាប់ទៅនឹងគំរោងសង់វារីអគ្គសនី ផែនការមេក៏បានស្នើនូវគំរោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្រ្តជាច្រើន ដែលអាចប៉ះពាល់ដល់លំហូរទន្លេ និងគុណភាពទឹក នៅតាមប្រព័ន្ធទន្លេទាំងមូល។ យោងតាម ផែនការទាំងនេះ ផែនការ អភិវឌ្ឍន៍ តំបន់ត្រីកោណ បានទោះទាយនូវសកម្មភាពអភិវឌ្ឍន៍ កសិកម្មខ្នាតធំជាច្រើន (ដូចជាស្រូវ ដំណាំឧស្សាហកម្ម និងការ ចិញ្ចឹមសត្វ) នៅទូទាំងខេត្តទាំងពីរ ដែលនឹងក្លាយទៅជាកន្លែងនាំចេញនូវ គ្រឿងបរិភោគដល់ទូទាំងប្រទេសកម្ពុជា និងប្រទេសវៀតណាម។ ស្របពេលនោះវិស័យជលផល នឹងត្រូវបង្កើត ឡើងតាមរយៈវារីវប្បកម្ម នៅតាមស្រះ បឹង ធម្មជាតិ និងតាមបែរជាច្រើន។

ផែនការមេអភិវឌ្ឍន៍តំបន់ត្រីកោណ ក៏បានស្នើនូវការបង្កើនដាំព្រៃឈើឡើងវិញ។ ផែនការនេះ បានផ្តល់អនុសាសន៍ ឱ្យពង្រីកការដាំដើមឈើឡើងវិញឱ្យបានចំនួន ១.៦លានហិកតា នៅដំណាច់ឆ្នាំ២០១០។ ទង្វើនេះនឹងគាំទ្រដល់ឧស្សាហកម្ម ក្រដាស និងឈើ ដោយរួមទាំងឈើហ៊ុប ដើម្បីលក់ចេញថែមទៀត។ សំណើអភិវឌ្ឍន៍ ផ្សេងៗទៀតរួមមាន អាជីវកម្មជីករ៉ែ រោងចក្រផលិតជីគីមី រោងចក្រកែច្នៃអាហារ និងរោងចក្រផលិតចំណីសត្វ។

ប្រសិនបើផែនការអភិវឌ្ឍន៍តំបន់ត្រីកោណត្រូវបានអនុវត្ត វានឹងបណ្តាលឱ្យមានការប្រែប្រួលខ្លាំងចំពោះខេត្តស្ទឹងត្រែង និងតំបន់រ៉ាមសារ។ ប្រសិនបើគ្មានការយកចិត្តទុកដាក់ក្នុងការអនុវត្ត ពេលនោះការផ្លាស់ប្តូរអាក្រក់នឹងកើតឡើងដល់លំហូរទន្លេ និងគុណភាពទឹករបស់វា។ របៀបរស់នៅបែបបុរាណនឹងត្រូវប្តូរដោយសារមានឱកាសការងារច្រើនបានកើតឡើង។ ស្របពេលនោះនឹងមានមនុស្សជាច្រើន នាំមកកាន់ខេត្តស្ទឹងត្រែងដើម្បីកសាង និងបង្កើតគំរោង ហើយក្រោយមកក៏ធ្វើការនៅលើគំរោងនោះតែម្តង។ ស្ថានភាពសេដ្ឋកិច្ច សង្គមរបស់ខេត្តទាំងមូល ត្រូវបានបង្កើតឡើងដើម្បីធ្វើការ ផ្លាស់ប្តូរតាមវិធីជាច្រើន។

មានគំរោងអភិវឌ្ឍន៍ស្រដៀងគ្នាជាច្រើន ត្រូវបានស្នើឡើងដោយប្រទេសឡាវ និងវៀតណាមផងដែរ។ ជាការពិតណាស់ តំបន់ត្រីកោណនេះ គឺកំពុងតែធ្វើដំណើរឆ្លងកាត់ដំណាក់កាលអន្តរកាល ហើយតំបន់រ៉ាមសារនឹងត្រូវរងផលប៉ះពាល់។ ស្របពេលដែលឱកាសសំរាប់បង្កើនប្រាក់ចំណូល បណ្តុះបណ្តាល និងការងារត្រូវបានស្វាគមន៍ វាត្រូវការកិច្ចប្រឹងប្រែងច្រើន ដើម្បីធានាថាផលប៉ះពាល់បរិស្ថានធម្មជាតិ នឹងអាចទទួលយកបានក្នុងកម្រិតមួយខ្ពស់។

ក្រៅពីនេះ នៅមានផែនការអភិវឌ្ឍន៍សំរាប់ខេត្តស្ទឹងត្រែងជាច្រើន បានស្នើឡើងដោយគណៈកម្មការទន្លេមេគង្គ (MRC) ជាផ្នែកមួយនៃផែនការអភិវឌ្ឍន៍អាងទន្លេរបស់ខ្លួន (CNMC, 2005a និង 2005b) ។ ផែនការនេះ បានត្រួតស៊ីគ្នាទៅនឹងផែនការអភិវឌ្ឍន៍តំបន់ត្រីកោណជាច្រើនផ្នែក។ ផែនការរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ត្រូវបានផ្តុំនៅក្នុងគោលបំណងជាច្រើនដោយរួមមាន បង្កើនសន្តិសុខស្បៀងជាមូលដ្ឋាន បង្កើនផលិតផលកសិកម្ម ការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិដោយត្រឹមត្រូវ បង្កើនការអភិវឌ្ឍន៍វិស័យទេសចរណ៍ និងធនធានមនុស្ស។ យុទ្ធសាស្ត្រ និងគំរាង ដែលឆ្លើយតបទៅនឹងគោលបំណងទាំងនេះរួមមាន :

- ការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រកសិកម្មដើម្បីសំរេចនូវសន្តិសុខស្បៀង និងផ្គត់ផ្គង់ដល់តម្រូវការទីផ្សារមូលដ្ឋាន ជាតិ អន្តរជាតិ និងតំបន់។
- អភិរក្សសត្វផ្សោត និងអន្លង់ជ្រៅៗនៃទន្លេមេគង្គ តាមរយៈការការពារដែនជម្រកធម្មជាតិ ពង្រឹងការអនុវត្តន៍ច្បាប់ និងការនេសាទ។
- អនុវត្តការគ្រប់គ្រងចម្រុះតំបន់រងទឹកភ្លៀង ដើម្បីបង្កើនជីជាតិដី និងរក្សាធនធានទឹក និងធនធានជីវៈចម្រុះ និងផែនការប្រើប្រាស់ទឹក។
- ពង្រីកវិស័យវប្បធម៌ និងទេសចរណ៍ សំរាប់ផលប្រយោជន៍ប្រជាជនមូលដ្ឋាន។
- ធ្វើឱ្យប្រសើរឡើង នូវប្រព័ន្ធផ្គត់ផ្គង់ទឹក ការគ្រប់គ្រងកាកសំណល់ និងអនាម័យ។
- អភិវឌ្ឍន៍ ផែនការទំនប់វារីអគ្គីសនីខ្នាតតូច
- ការគ្រប់គ្រងគ្រោះទឹកជំនន់ និងរាំងស្ងួត
- លើកទឹកចិត្តផ្នែកឯកជន ឱ្យពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ជនបទ
- ការអភិវឌ្ឍន៍ធនធានមនុស្ស និងសមត្ថភាព នៅក្នុងស្ថាប័នរដ្ឋ និងវិស័យឯកជន។
- បង្កើនការចូលរួមពីប្រជាជនមូលដ្ឋាន តាមរយៈការគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍។

ផែនការដែលស្នើឡើងដោយគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា CNMC (2005a, 2005b) គឺមានមហិច្ឆតា ទាបជាងផែនការអភិវឌ្ឍន៍តំបន់ត្រីកោណ ដែលស្នើឡើងដោយសាធារណៈរដ្ឋសង្គមនិយមវៀតណាម (២០០៤)។ តែទោះជាយ៉ាងណា ផែនការនេះនៅតែស្នើឱ្យមានការអភិវឌ្ឍន៍ទំនប់វារីអគ្គីសនីខ្នាតធំ នៅតាមដងទន្លេដដែល។ ប៉ុន្តែផែនការនេះ បានផ្តោតការយកចិត្តទុកដាក់ទៅលើបញ្ហាបរិស្ថានច្រើនជាង។

## គោលនយោបាយរដ្ឋ សំរាប់កំណើនសេដ្ឋកិច្ច

បន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីសថ្ងៃទី២៣តុលា១៩៩១មក ប្រទេសកម្ពុជាបានបោះជំហ៊ានឆ្ពោះទៅមុខដោយផ្លាស់ប្តូរប្រព័ន្ធសង្គមនិយម មកកាន់របបទីផ្សារសេរី និងពីប្រព័ន្ធនយោបាយឯកបក្ស មកកាន់ពហុបក្សវិញ (Peou, 2000)។ នៅក្នុងមហិច្ឆតា នៃកិច្ចប្រឹងប្រែងអភិវឌ្ឍន៍សេដ្ឋកិច្ច ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចលើកទី១ (SEDP I) ឆ្នាំ១៩៩៦-២០០០ ត្រូវបានយកមកអនុវត្ត ដើម្បីឆ្លើយតបនឹងគោលដៅសេដ្ឋកិច្ចនេះ។ ផែនការនេះ បានផ្តោតទៅលើការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធអប់រំ និងសុខាភិបាលរដ្ឋ ដោយរួមទាំងការបង្កើតកម្មវិធីអនាម័យ និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅ តាមជនបទ (RGC, 1997) ។

យុទ្ធសាស្ត្រត្រីកោណរបស់រដ្ឋាភិបាល ដែលបានអនុម័តនៅខែកក្កដាឆ្នាំ១៩៩៨ ត្រូវបានរៀបចំដើម្បីសំរេចនូវទស្សនវិស័យអភិវឌ្ឍន៍នេះ។ ជ្រុងទីមួយរបស់យុទ្ធសាស្ត្រត្រីកោណ គឺមានគោលបំណងស្តារសន្តិភាព ស្ថេរភាព រក្សាសន្តិសុខ សំរាប់ប្រទេសជាតិ និងប្រជាជន។ ជ្រុងទីពីរ គឺការធ្វើសមាហរណកម្មប្រទេសចូលក្នុងតំបន់ និងរក្សាទំនាក់ទំនងល្អជាមួយ សហគមន៍អន្តរជាតិ។ ជាលទ្ធផល ប្រទេសកម្ពុជាបានទទួលកៅអីរបស់ខ្លួននៅអង្គការសហប្រជាជាតិវិញ ហើយបានក្លាយជាសមាជិកទី១០ នៃសមាគមប្រជាជាតិអាស៊ី-អាគ្នេយ៍ និងដំណើរការចូលរួមសមាជិកអង្គការពាណិជ្ជកម្មពិភពលោក។ ផ្នែកទីបី នៃយុទ្ធសាស្ត្រត្រីកោណ គឺការលើកកំពស់ការអភិវឌ្ឍន៍ សេដ្ឋកិច្ច និងសង្គម តាមរយៈការអនុវត្តនូវកម្មវិធីកំណែទម្រង់ជាច្រើន។ ការរីកចំរើនសំខាន់ៗ ត្រូវបានធ្វើឡើងតាមរយៈការអនុវត្តនូវកំណែទម្រង់ទាំងនេះ ហើយកំណើនសេដ្ឋកិច្ច ក៏បានកើនឡើងខ្លាំងកាលពីពីរឆ្នាំកន្លងមក ទោះបីមានផលប៉ះពាល់ពីទឹកជំនន់ឆ្នាំ២០០០ ក៏ដោយ។

យុទ្ធសាស្ត្រជាក់លាក់ជាច្រើនទៀត ត្រូវបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហាភាពក្រីក្រ និងសង្គមដែលប្រឈម មុខដោយសហគមន៍មូលដ្ឋានរស់នៅភាគឥសាន្តប្រទេស។ កិច្ចប្រឹងប្រែង ត្រូវបានធ្វើឡើងដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងលើកកំពស់វិស័យការងារកសិកម្មនៅតំបន់ខ្ពង់រាប។ លើសពីនេះទៀត គំរោងអភិវឌ្ឍន៍ មានគោលបំណងលើកទឹកចិត្តប្រជាជនឱ្យចូលរួម និងទទួលផលពីការដកហូតធនធានធម្មជាតិ ដូចជា ដីធ្លី និងព្រៃឈើ ដោយរួមទាំងសេវាកម្មអប់រំ និងសុខភាព បច្ចេកវិទ្យាសមស្រប និងឥណទានជាដើម។

ក្នុងអំឡុងពេលនោះដែរ ការលើកស្ទួយពាណិជ្ជកម្មអន្តរជាតិ សំរាប់អភិវឌ្ឍសេដ្ឋកិច្ចជាតិ បានបង្ហាញថាតំបន់ភូមិភាគឥសាន្តប្រទេសកម្ពុជា គឺត្រូវបានចាត់ទុកជាតំបន់សេដ្ឋកិច្ច និងប្រភពប្រាក់ចំណូលរបស់រដ្ឋ។ កត្តានេះបានជំរុញឱ្យមានកំណើនតម្រូវការធនធាននៅក្នុងតំបន់ ដូចជាព្រៃឈើ ត្រី ដីធ្លី និងរ៉ែជាដើម។ ដោយសារអវត្តមាននៃប្រសិទ្ធិភាពច្បាប់ ពេលនោះធនធានព្រៃឈើ ស្ថិតនៅក្នុងស្ថានភាពបើកចំហ សំរាប់ប្រើប្រាស់ជាច្រើន ដូចជា យោធា សហគ្រិនមូលដ្ឋាន ប្រជាកសិករ ជនចំណូលស្រុកមកពីស្រុកក្រោម និងអ្នកវិនិយោគ-បរទេស ដែលទង្វើនេះបង្កើតឱ្យមានការដកហូតឈើខ្នាតធំទៅលើធនធានទាំងនេះ។

ស្របពេលដែលតំបន់ដីព្រៃជាច្រើន បានប្រែក្លាយទៅជាតំបន់ដំណាំកសិឧស្សាហកម្ម ភ្នាក់ងារអភិវឌ្ឍន៍របស់រដ្ឋបានក្លាយជាគោលដៅនៃការរិះគន់អំពីគំរោងអភិវឌ្ឍន៍ទាំងនេះ។ ផ្ទុយទៅវិញ រដ្ឋាភិបាលបានដាក់សំពាធជាច្រើនយ៉ាងទៅលើសហគមន៍មូលដ្ឋាន ដែលបានរងគ្រោះដោយសារភាពវិចវិលបរិស្ថាន និងធនធានធម្មជាតិ និងជាអ្នកទន់ខ្សោយទាក់ទងនឹងសិទ្ធិកាន់កាប់ដីធ្លី និងការភាន់ច្រឡំរវាងសហគមន៍មូលដ្ឋានជាមួយនឹងភ្នាក់ងារ

អភិវឌ្ឍន៍របស់រដ្ឋទៅលើបញ្ហាដូចជា សិទ្ធិសហគមន៍ និងការអនុវត្តតាមមូលដ្ឋាន។ ជាលទ្ធផល សហគមន៍មូលដ្ឋាន បានបាត់បង់នូវឱកាស មិនត្រឹមទៅលើការកាន់កាប់ដីធ្លីទេ គឺថែមទាំងសិទ្ធិដកហូតធនធានរួមថែមទៀត។

កត្តាទាំងនេះ គឺជាលទ្ធផលរបស់រដ្ឋាភិបាល ដែលបានផ្តល់ដី និងព្រៃសម្បទាន ទៅឱ្យសហគ្រិនជាតិ និងអន្តរជាតិ និងដោយរួមទាំងកំណើននៃការតាំងលំនៅថ្មីរបស់អ្នកចំណូលស្រុក នៅក្នុងខេត្តភាគឥសាន្តប្រទេស។ នៅក្នុងស្ថានភាពនេះ ជនចំណូលស្រុក និងសហគ្រិនឯកជនបានឆ្លៀតឱកាសទៅលើសហគមន៍មូលដ្ឋាន តាម-រយៈ ធ្វើប្លង់កម្មសិទ្ធិពីអាជ្ញាធរមូលដ្ឋាន និងខេត្ត។

នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ ផែនការអភិវឌ្ឍរដ្ឋ បានចាប់ផ្តើមជំរុញកសិក-ឧស្សាហកម្ម ដោយពង្រីកដីកសិកម្ម សំរាប់ដាំកាហ្វេ កៅស៊ូ ដូងប្រេង ហើយនឹងដំណាំផ្សេងៗទៀត ជាពិសេសនៅក្នុងខេត្តរតនគិរី ហើយបន្ទាប់មកនៅក្នុងខេត្តស្ទឹងត្រែង។ ប្រព័ន្ធប្រពលវប្បកម្ម ត្រូវបានអនុវត្តដើម្បីកំណើនផលិតផលកសិកម្ម ដោយសារដីភាគច្រើនបានខ្សោះជីជាតិ។ ប្រការនេះ អាចដាក់សំពាធបន្ថែមទៅលើដីព្រៃនៅឆ្ងាយៗ និងបណ្តាលឱ្យមានវាលហោរស្ថាន។ តម្រូវការសំរាប់ដីកសិកម្ម គឺមានន័យថាអ្នកវិយោគអន្តរជាតិ ជាតិ និងអ្នកស្រុកក្រោម បានបង្កើតនូវការបំពានទៅលើតំបន់របស់សហគមន៍កាន់កាប់ និងបង្កើតឱ្យមានជម្លោះជាមួយសហគមន៍ជនជាតិ។

នៅឆ្នាំ២០០២ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមលើកទី២ ២០០១-២០០៥បានអនុម័តដោយរាជរដ្ឋាភិបាល ដើម្បីដឹកនាំយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ។ ដើម្បីអនុវត្តយុទ្ធសាស្ត្រនេះ រដ្ឋាភិបាល មានតួនាទីជាអ្នក សម្របសម្រួល និងកាប្រើនូវអំណាច និងធនធានរបស់ខ្លួន ដើម្បីគ្រប់គ្រងដំណើរការអភិវឌ្ឍន៍ឱ្យសំរេចបាននូវលទ្ធផល សេដ្ឋកិច្ចសង្គម (RGC, 2002)។
ទស្សនៈវិស័យរបស់ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមលើកទី២នេះ គឺចង់បានទំនាក់ទំនងសង្គមល្អ ភាពរីក ចំរើនវិស័យអប់រំ និងការរក្សានូវវប្បធម៌ជាតិ ដោយពុំមានភាពក្រីក្រ អវិជ្ជា និងជំងឺ។ ដោយទទួលស្គាល់ថាទស្សនវិស័យនេះតម្រូវ ឱ្យប្រកាន់ខ្ជាប់ទៅនឹងតម្លៃ នៃយុត្តិធម៌សង្គម សុខមាលភាពសង្គម ការផ្តល់អំណាចការអនុវត្ត និងការបង្កើតនូវគោលនយោបាយនានា ដើម្បីកាត់បន្ថយភាពក្រីក្រតាមរយៈការលើកកំពស់កំណើនសេដ្ឋកិច្ច និងអភិបាលកិច្ចល្អ។

យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្របណ្តោះអាសន្ន ក៏ត្រូវបានបង្កើតឡើងដោយយោងតាមផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមលើកទីពីរដើម្បីលើកស្ទួយគោលនយោបាយ គោលបំណង និងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រដ្ឋាភិបាល។ យុទ្ធសាស្ត្រទាំងនេះ រួមមាន : ទី១ លើកស្ទួយកំណើនសេដ្ឋកិច្ច ប្រកបដោយនិរន្តរភាព និងសមភាពដែលមានវិស័យឯកជន ជាអ្នកដើរតួសំខាន់។ ទី២ លើកកំពស់ការអភិវឌ្ឍន៍សង្គម និងវប្បធម៌ តាមរយៈបង្កើននូវឱកាសដល់អ្នកក្រ នូវវិស័យអប់រំ ទឹកស្អាត និងអនាម័យ សុខាភិបាល ថាមពលឥណទានទីផ្សារព័ត៌មាន និងបច្ចេកវិទ្យាសមស្រប។ ទី៣ លើកស្ទួយការគ្រប់គ្រង និងការប្រើប្រាស់ធនធានធម្មជាតិ និងបរិស្ថានប្រកបដោយនិរន្តរភាព។ ទី៤ លើកស្ទួយអភិបាលកិច្ច តាមរយៈការអនុវត្តឱ្យមានប្រសិទ្ធិភាព នៃផែនការសកម្មភាពអភិបាលកិច្ច។

នៅឆ្នាំ ២០០៤ ដើម្បីសំរេចនូវអាទិភាពគោលនយោបាយសេដ្ឋកិច្ច រាជរដ្ឋាភិបាលបានបង្កើតយុទ្ធសាស្ត្រអភិវឌ្ឍន៍មួយទៀត គឺ "យុទ្ធសាស្ត្រចតុកោណ"។ ស្របពេលនោះ អភិបាលកិច្ចល្អត្រូវបានចាត់ទុកជាទស្សទានស្នូលដែលរួមមានៈ ការប្រឆាំងអំពើពុករលួយ កំណែទំរង់ប្រព័ន្ធច្បាប់ និងតុលាការ កំណែទំរង់រដ្ឋបាលសាធារណៈ កំណែទំរង់កងកំលាំងប្រដាប់អាវុធ និងការរំសាយទ័ព។

មុំទី១ នៃយុទ្ធសាស្ត្រចតុកោណ គឺលើកកំពស់វិស័យកសិកម្ម ដោយរួមមានការបង្កើន និងបង្វៃផលិតភាពបោសសំអាតមីន និងកែទំរង់ដីធ្លី កែទំរង់វិស័យជលផល និងព្រៃឈើ។ មុំទី២ គឺការស្តារ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដោយរួមមានផ្លូវគមនាគមន៍ ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ ការអភិវឌ្ឍន៍វិស័យថាមពល និងបណ្តាញអគ្គិសនី និងការអភិវឌ្ឍន៍បច្ចេកវិទ្យាទំនាក់ទំនង និងព័ត៌មាន។ មុំទី៣ គឺការអភិវឌ្ឍន៍វិស័យឯកជន និងបង្កើតការងារ ដែលរួមមាន : ពង្រឹងវិស័យឯកជន ទាក់ទាញវិនិយោគទុន បង្កើតការងារធានាគារពង្រឹងល័ក្ខខ័ណ្ឌការងារ លើកកំពស់អាជីវកម្មខ្នាតតូច និងមធ្យម និងធានាឱ្យបាននូវសុវត្ថិភាពសង្គម។ មុំទី៤ នៃយុទ្ធសាស្ត្រចតុកោណ គឺការកសាងសមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្ស ដែលរួមមានៈ ជំរុញនូវគុណភាពអប់រំ បង្កើនសេវាកម្មសុខភាព លើកស្ទួយគុណភាពយេនឌ័រ និងអនុវត្តគោលនយោបាយកំណើនប្រជាជន (RGC, 2004)។

ដោយយោងតាមផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមលើកទី១ និងទី២ កម្មវិធីអភិវឌ្ឍន៍របស់រដ្ឋជាច្រើនចូលមក ដល់ខេត្តស្ទឹងត្រែង។ ការធ្វើវិមជ្ឈការអំណាចរបស់រដ្ឋ ត្រូវបានបង្កើតឡើង ដើម្បីបង្កើតឱកាសថ្មីសំរាប់តំណាងឱ្យផ្នែកនយោបាយ និងសម្រួលឱ្យមានការចូលរួមដោយផ្ទាល់ពីអ្នកក្រ នៅក្នុងដំណើរការសំរេចចិត្ត។ នេះជាជំនួយមួយ ដល់យុទ្ធសាស្ត្រប្រឈមរបស់អ្នកក្រ និងជាខ្សែបណ្តោយរបស់រដ្ឋក្នុងការជួយគាំទ្រ និងបង្វៃមុខរបរចិញ្ចឹមជីវិត។ ក្នុងករណីនេះ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំលើកទី១ ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០២។

ចាប់តាំងពីពេលនោះមក មានគំរោងជាច្រើនត្រូវបានអនុវត្តដោយស្ថាប័នរដ្ឋនៅថ្នាក់ខេត្ត។ គំរោងអភិវឌ្ឍន៍ភូមិ ភូមិភាគឥសាន្ត (NVDP) គឺស្ថិតនៅក្រោមក្រសួងអភិវឌ្ឍន៍ជនបទ ដែលផ្តល់ហិរញ្ញវត្ថុដោយ ធានាគារពិភពលោក។ គំរោងនេះមានទឹកប្រាក់ចំនួន៥,៦លានដុល្លារសហរដ្ឋអាមេរិក ដោយផ្តោតលើខេត្តចំនួន៤ : កំពង់ធំ កំពង់ចាម ក្រចេះ និងស្ទឹងត្រែង។ នៅខេត្តស្ទឹងត្រែង គំរោងនេះបានអនុវត្តចាប់ពីឆ្នាំ២០០១ដល់២០០៣។ គោលបំណងរបស់គំរោង គឺដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទក្នុងខេត្ត ជាពិសេសនៅក្នុងស្រុកសៀមបូក និងសេសាន។ បច្ចុប្បន្ន គំរោងនេះលែងមាន សកម្មភាព ហើយរងចាំការឧបត្ថម្ភហិរញ្ញវត្ថុបន្ថែមពីធនាគារពិភពលោក។

នៅឆ្នាំ២០០៣ គំរោងសីលា បានអនុវត្តនៅក្នុងខេត្តស្ទឹងត្រែង។ គោលបំណងសំខាន់របស់គំរោងនេះគឺដើម្បីកែទំរង់រចនាសម្ព័ន្ធថ្នាក់ឃុំ និងការអនុវត្តគោលការណែនាំរបស់ក្រសួងមហាផ្ទៃនៅតាមមូលដ្ឋាន។ រចនាសម្ព័ន្ធថ្នាក់ឃុំ ត្រូវបានចាត់ទុកជាអង្គភាពរដ្ឋបាលមូលដ្ឋាន ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យសហគមន៍មូលដ្ឋាន។ ហេតុដូច្នេះ វាបានផ្ទេរ អំណាច ពីស្ថាប័នអភិវឌ្ឍន៍ខេត្ត មកមូលដ្ឋានវិញ។ ក្រុមប្រឹក្សាឃុំ បានលើកទឹកចិត្តអ្នកភូមិ ឱ្យចូលរួមសកម្មភាពអភិវឌ្ឍន៍ ដូចជាកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ និងសន្តិសុខសៀង។

ក្រុមប្រឹក្សានេះ បានចូលរួមរៀបចំឡើងវិញនូវរចនាសម្ព័ន្ធសង្គមមូលដ្ឋាន ដើម្បីងាយស្រួលគ្រប់គ្រងប្រជាជន និងធនធានទៅតាមវិធីដែលរដ្ឋដាក់ឱ្យអនុវត្ត។

យោងតាមរបាយការណ៍រីកចំរើនរបស់កម្មវិធីសីលា ខេត្តស្ទឹងត្រែងបានទទួលប្រាក់ចំនួន២០៤.៨៤៤ដុល្លាអាមេរិក និងប្រាក់បដិភាគសហគមន៍ របស់គណៈកម្មាធិការអភិវឌ្ឍន៍ខេត្តចំនួន ៨៩០.២៣១.០០០រៀល។ ចំពោះថវិកាវិនិយោគ ចំនួន៦៣.០០០ដុល្លា គណៈកម្មាធិការបានចុះកិច្ចសន្យាជាមួយមន្ទីរពាក់ព័ន្ធរបស់ខេត្ត ដើម្បីអនុវត្តការងារ (Seila Taske Force, 2004)។

## សកម្មភាពអភិវឌ្ឍន៍ របស់អង្គការសង្គមស៊ីវិល

ថ្មីៗនេះអង្គការមិនមែនរដ្ឋាភិបាល បានដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សហគមន៍តាមដងទន្លេមេគង្គ ទោះបី នៅទសវត្សរ៍ទី៩០ មានអង្គការតិចតួចក៏ដោយ។ ទោះជាយ៉ាងណា មានអង្គការមួយចំនួន បានធ្វើការនៅតំបន់រ៉ាមសារ។ អង្គការទាំងនេះ មានការងារផ្សេងៗគ្នា រួមមានគំរោងអប់រំ និងអភិវឌ្ឍន៍សហគមន៍។

អង្គការដៃគូសំរាប់អភិវឌ្ឍន៍ (PFD) បានអនុវត្តគំរោងតាំងពីឆ្នាំ១៩៩៤។ អង្គការនេះ បានគាំទ្រនូវគំរោងជាច្រើនដោយរួមមានការកសាងអណ្តូងទឹកស្អាត និងអនាម័យស្ពាន និងផ្លូវលំតាមភូមិ ធនាគារអភិវឌ្ឍន៍ភូមិ គណៈកម្មការអភិវឌ្ឍន៍ភូមិ និងសិប្បកម្ម។ អង្គការនេះ បានសហការជាមួយមន្ទីរអប់រំ កសិកម្ម សុខាភិបាល និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ហើយកម្មវិធីត្រូវបានបញ្ចប់នៅឆ្នាំ២០០២។ ប៉ុន្តែគំរោងនេះ មិនអាចផ្គត់ផ្គង់នូវតម្រូវការគ្រប់យ៉ាងដល់សហគមនមូលដ្ឋាន ទោះជាមានការរីកចំរើននៅភូមិជាច្រើនក្នុងតំបន់រ៉ាមសារ ទាក់ទងការចូលរួមរបស់ប្រជាជន សួនដំណាំគំរូជាលក្ខណៈគ្រួសារ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងសហគមន៍ ជាដើម។ ចាប់តាំងពីឆ្នាំ២០០២ អង្គការដៃគូរសំរាប់អភិវឌ្ឍន៍ នៅតែមានសកម្មភាពក្នុងខេត្ត ភាគច្រើនផ្តោតទៅលើសុខភាពបឋម និងការអប់រំបឋមសិក្សា ដោយសហការជាមួយមន្ទីរអប់រំ និងសុខាភិបាលខេត្ត។

កម្មវិធីសិទ្ធិកុមារ (កម្មវិធីនេះផ្តល់ហិរញ្ញវត្ថុពីអង្គការយូនីសេហ្វ) បានចូលមកជំនួសសកម្មភាពអង្គការដៃគូរសំរាប់អភិវឌ្ឍន៍ ក្នុងតំបន់រ៉ាមសារ។ នេះ គឺជាកម្មវិធីមួយនៃកម្មវិធីទាំង៣ ដោយផ្តោតលើសួនដំណាំ ឥណទាន និងការកសាងអណ្តូងទឹក។ កម្មវិធីនេះ មានការិយាល័យនៅក្នុងមន្ទីរអភិវឌ្ឍន៍ខេត្ត។ អ្នកភូមិភាច្រើនបានរាយការណ៍ថាពួកគេភាគច្រើនមិនបានទទួលឥណទានពីកម្មវិធីនេះ ប៉ុន្តែបានទទួលពូជបន្លែ និងសំភារៈធ្វើសួនដំណាំ។ គំរោងចំនួនពីរទៀតរបស់អង្គការ យូនីសេហ្វ រួមមានកម្មវិធីសុខភាព ធ្វើការជាមួយមន្ទីរសុខាភិបាលខេត្ត និងកម្មវិធីអប់រំ ធ្វើការជាមួយមន្ទីរអប់រំខេត្ត ដោយរួមទាំងកម្មវិធីអប់រំក្រៅប្រព័ន្ធតាមសាលាបឋមសិក្សាផងដែរ ។

ទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ គឺមានអង្គការចំនួនពីរ ដែលកំពុងតែធ្វើការនៅតំបន់រ៉ាមសារ ដើម្បីឆ្លើយ តបនឹងវិបត្តិនៃឱកាស និងភាពអនាធិបតេយ្យ ការគ្រប់គ្រងធនធានធម្មជាតិ តាំងពីទសវត្សរ៍ទី៩០។ ការគ្រប់គ្រងធនធានធម្មជាតិ ដោយផ្អែកលើសហគមន៍ ត្រូវបានជំរុញ និងគស្ស៊ូមតិ ដោយអង្គការទាំងពីរនេះ។ នៅដើមទសវត្សរ៍ទី៩០ ឱកាសក្នុងការដកហូតធនធានរួមដូចជា ត្រី ព្រៃឈើ និងដីធ្លី បានក្លាយជាប្រភពនៃភាពតានតឹង។ នៅក្នុងវិស័យជលផល ភាពតានតឹងបានកើតឡើងតាមរយៈការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់



និងឧបករណ៍បំផ្លាញមួយចំនួនទៀត ការតស៊ូដើម្បីសិទ្ធិគ្រប់គ្រងធនធាន និងអវត្តមាននៃការអនុវត្តច្បាប់ដោយរួមទាំងការជំរុញនូវវិស័យឯកជននិងការរំលោភ បំពាន។

នៅឆ្នាំ១៩៩៨ ដើម្បីជួយដោះស្រាយនូវវិបត្តិ ទាំងនេះ អង្គការផ្តល់ជំនួយសហគមន៍បរទេស អុកស្វាម អូស្ត្រាលី (ស៊ី អេ អេ )ដោយមានកិច្ចសហប្រតិបត្តិការជាមួយការិយាល័យជលផលខេត្ត បានបង្កើតសហគមន៍នេសាទលើកដំបូង នៅក្នុងខេត្ត។ បច្ចុប្បន្ន អង្គការនេះ និងការិយាល័យជលផលខេត្ត បានបង្កើតសហគមន៍នេសាទចំនួន៣៤ ដែលក្នុងនោះមាន ចំនួន៤ ស្ថិតនៅក្នុងតំបន់រ៉ាមសារ។ សហគមនេសាទភាគច្រើន បានបង្កើតនៅស្រុកសៀមបូក ភាគខាងក្រោមតំបន់រ៉ាមសារ នៃទន្លេមេគង្គ និងមួយចំនួនតូចនៅស្រុកសេសាន តាមដងទន្លេសេសាន។

នៅឆ្នាំ២០០០ សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ (សេចា) បានបង្កើតការិយាល័យរបស់ខ្លួននៅខេត្តស្ទឹងត្រែង។ អង្គការនេះ បានបង្កើតសហគមន៍នេសាទដំបូងនៅឃុំកោះស្នែង បន្ទាប់មកនៅឃុំអូរស្វាយ។ បច្ចុប្បន្ន អង្គការសេចា បានពង្រីកសកម្មភាពរបស់ខ្លួនទៅឃុំចំនួនពីរទៀតក្នុងតំបន់រ៉ាមសារ គឺឃុំសាមគ្គី និងព្រះរំកិល ដោយបានបង្កើតសហគមចំនួន១៧ ក្នុងចំណោមភូមិទាំង២១។ បច្ចុប្បន្ន សហគមន៍នេសាទរបស់អង្គការសេចា និងស៊ីអេអេ មិនទាន់មានប្រសិទ្ធភាពពេញលេញ ទាក់ទងនិងការទប់ស្កាត់បទល្មើសនេសាទ និងការការពារធនធានជលផល។ ហេតុដូច្នេះ ជំនួយបន្ថែមពិតជាត្រូវការដើម្បីឆ្លើយតបនឹងបញ្ហានេះ។

សហគមន៍នេសាទ បានគ្រប់គ្រងដោយគណៈកម្មការជ្រើសរើសចំនួន៥នាក់។ គណៈកម្មការនេះ ជ្រើសរើសដោយប្រជាជន គឺជាអ្នកមិនបំរើឱ្យគណៈបក្សនយោបាយ និងស្ថាប័នណាដែលប្រឆាំងនឹងប្រយោជន៍សហគមន៍។ តួនាទីរួមរបស់ ពួកគេមានការរៀបចំ និងផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងជលផល អនុវត្តសកម្មភាពប្រឆាំងនឹងអ្នកប្រព្រឹត្តបទល្មើសនេសាទ ទាក់ទងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន សំរាប់ជំនួយបច្ចេកទេស និងរាយការណ៍ប្រចាំខែឱ្យការិយាល័យជលផល តាមរយៈក្រុមប្រឹក្សាឃុំ។ បទប្បញ្ញាត្តិសហគមន៍នេសាទ ដែលបង្កើតឡើងដោយប្រជានេសាទ និងអង្គកាមិនមែនរដ្ឋាភិបាល អាចសង្ខេបដូចខាងក្រោម :

- ហាមប្រើគ្រឿងផ្ទុះចាប់ត្រី
- ហាមប្រើឧបរណ៍ឆក់ និងបំពុល
- ហាមដាក់អួន ឬមងក្រឡាញឹក កាត់មុខអូរ និងព្រែក
- មិនអោយកាប់ព្រៃលិចទឹក
- ហាមចាប់កូនត្រី និងប្រភេទត្រីជិតផុតពូជ ដូចជាត្រីរាជ ត្រីត្រសក់ និងត្រីគល់រាំង
- ហាមប្រើមងក្រឡាធំ (១៨ស.ម ឡើងទៅ) ចាប់ប្រភេទត្រីជិតផុតពូជនៅតាមអន្លង់ជ្រៅៗ
- ហាមបូមព្រែក និងអូរដើម្បីចាប់ត្រី។

ចាប់តាំងពីការបង្កើតសហគមន៍នេសាទ ការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់ លែងមានអនុវត្ត ឬមានអនុវត្តតិចតួចពីប្រជាជនក្នុងដែននេសាទរបស់ពួកគេ។ ប៉ុន្តែប្រជានេសាទ នៅតែអាចប្រើឧបករណ៍នេសាទល្មើសច្បាប់នៅក្នុង ដែនសហគមន៍ជិតខាង។ តែទោះជាយ៉ាងណា សហគមន៍នេសាទម្នាក់ឯងមិនអាចបញ្ឈប់បទល្មើសនេសាទដោយងាយស្រួលនោះទេ។ បទល្មើសនេសាទភាគច្រើនត្រូវបានរាយការណ៍នៅតំបន់ដាច់ស្រយ៉ាល ឬនៅអូរតាឡាស់ ក្នុងព្រៃជ្រៅដែលមានមនុស្សតិចតួចទៅដល់ទីនោះ (Try និង Vannara, 2004) ។

មានសកម្មភាពមួយចំនួនទៀត ដើម្បីជួយពង្រឹងការអភិរក្សធនធាន និងការប្រើប្រាស់ដោយឈ្លាសវៃ។ នៅខែមិថុនា ឆ្នាំ២០០១ មានទិវាបរិស្ថានពិភពលោកបានប្រារព្ធឡើងជាលើកទីពីរ នៅឃុំកោះស្នែង ដើម្បីបំផុសការយល់ដឹងស្តីពីបញ្ហាបរិស្ថាន។ ទិវាលើកទី១ ត្រូវបានប្រារព្ធឡើងនៅឆ្នាំ១៩៩៨ នៅពេលដែលមានកូនឈើបេង ចំនួន១០០ដើម បានដាំជានិមិត្តរូបនៃការយល់ដឹងពីបរិស្ថាន។ ស្របពេលនោះ អ្នកភូមិកោះស្នែងបានសារភាពថា នេះជាលើកទីមួយដែលពួកគេបានឃើញអភិបាលខេត្ត អញ្ជើញទៅដល់ភូមិរបស់ពួកគេ។ ទិវាបរិស្ថាន បច្ចុប្បន្ន មានអ្នកចូលរួមដូចជាអភិបាលខេត្ត តំណាងមកពីមន្ទីរពាក់ព័ន្ធនៅក្នុងខេត្តទាំងអស់។

នៅពេលនោះ ផ្លាកសញ្ញាត្រូវបានលើកឡើងនៅមាត់កំពង់ក្នុងភូមិកោះស្នែង ជានិមិត្តរូបនៃការអភិរក្សប្រភេទត្រីជិតផុតពូជចំនួនបីៈ ត្រីរាជ ត្រីត្រសក់ និងត្រីគល់រាំង។ ផ្លាកសញ្ញាបានសរសេរថា សូមជួយថែរក្សា និងការពារប្រភេទ ត្រីជិតផុតពូជដែលរស់នៅក្នុងអន្លង់ជ្រៅៗតាមដងទន្លេ។ ការបំផុសការយល់ដឹង ស្តីពីការអភិរក្ស និងបរិស្ថានក្នុងចំណោម ប្រជាជនតំបន់រ៉ាមសារ អាជ្ញាធរដែនដី និងអង្គការមិនមែនរដ្ឋាភិបាល គឺកំពុងតែមានការកើនឡើង។

ដោយសារលទ្ធផលជោគជ័យមួយចំនួន នៅក្នុងការគ្រប់គ្រងជលផលផ្អែកលើសហគមន៍ ប្រជាជននៅឃុំអូរស្វាយ បានផ្តួចផ្តើមទាមទារឱ្យបង្កើតសហគមន៍ព្រៃឈើបន្ថែមទៀត។ ជាពិសេស ពួកគេចង់ទាមទារមកវិញនូវព្រៃឈើ និងវាលស្រែចំនួន៧.៤០០ហិកតា ដែលគ្រប់គ្រងដោយក្រុមហ៊ុនសម្បទាន ដោយរួមទាំងសិទ្ធិរបស់ពួកគេចូលក្នុងព្រៃសម្បទាន ដើម្បីប្រមូលអនុផលព្រៃឈើ។ សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ កំពុងជួយសហគមន៍ ធ្វើការតស៊ូមតិដើម្បីបង្កើតសហគមន៍ព្រៃឈើនៅក្នុងឃុំចំនួនពីរក្នុងតំបន់រ៉ាមសារៈ អូរស្វាយ (ប្រហែល ៥.០០០ហិកតា)និងកោះស្នែង (ប្រហែល ៧.៤០០ហិកតា)។ ការបង្កើតលក្ខន្តិកៈសំរាប់គ្រប់គ្រងសហគមន៍ព្រៃឈើ ដែលបានស្នើឡើងដោយអង្គការសេចា គឺពុំមានភាពខុសគ្នាទេពីសហគមន៍នេសាទ។ គោលបំណងខ្ញី គឺដើម្បីទប់ស្កាត់បទល្មើសព្រៃឈើ លើកកំពស់ការប្រើប្រាស់និរន្តរភាព ការចែករំលែកធនធានធម្មជាតិដោយសមភាពនៅក្នុងសហគមន៍ និងដើម្បីទាមទារសិទ្ធិក្នុងការគ្រប់គ្រងដោយសហគមន៍ផ្ទាល់។

យោងតាមការសិក្សាបានបង្ហាញថា ការគ្រប់គ្រងសហគមន៍នេសាទបានទទួលនូវជោគជ័យមួយចំនួន តែវាក៏ជួបនឹងបញ្ហា និងឧបសគ្គផងដែរ។ បញ្ហាទាំងនេះរួមមាន ប្រជាជនមូលដ្ឋានមានចំណេះដឹងទាបជាឧបសគ្គដល់សមត្ថភាពអនុវត្តតាមបទប្បញ្ញត្តិសហគមន៍ និងការចូលរួមបង្កើតបញ្ញត្តិទាំងនេះ។ បទល្មើសនេសាទ នៅមានកម្រិតខ្ពស់ ដោយសារនៅមានការអនុវត្តវិធីសាស្ត្របំផ្លាញ ដូចជាឆក់ត្រីជាដើម។ ឧបសគ្គមួយទៀត គឺកង្វះខាតអនុក្រឹត្យ ឬច្បាប់ដែលអនុញ្ញាតឱ្យប្រជាជនបង្កើតសហគមន៍នេសាទ និងកម្មវិធីគ្រប់គ្រងធនធានធម្មជាតិផ្អែកលើសហគមន៍ផ្សេងៗទៀត។ ការទទួលស្គាល់ផ្លូវការ ជាលាយលក្ខណ៍អក្សរនៃគោលនយោបាយ ស្តីពី

សហគមន៍នេសាទ គឺពុំទាន់មានគ្រាន់តែមានការគាំទ្រតាមរយៈសន្ទរកថារបស់អ្នកដឹកនាំ ដូចជា នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន (Try និង Vannara, 2004)។ ការអនុម័តយល់ព្រមនូវអនុក្រឹត្យ ស្តីពីការបង្កើតសហគមន៍នេសាទ នឹងជួយសម្រួលដល់ការលំបាកនេះ។

ដោយសារដែនសហគមន៍នេសាទមានទំហំធំ ហើយពុំមានព្រំដែនច្បាស់លាស់ សមាជិកសហគមន៍នេសាទ ពិតជាមានការលំបាកក្នុងការគ្រប់គ្រងបទល្មើសនេសាទ ដែលអនុវត្តដោយអ្នកខាងក្រៅ។ លើសពីនេះទៅទៀត ពួកគេពុំមានថវិកាគ្រប់គ្រាន់សំរាប់ទិញប្រេងម៉ាស៊ីនកាណូត ដើម្បីយាមល្បាត។ ហើយកិច្ចសហការរវាងស្ថាប័នបច្ចេកទេស និងសហគមន៍នៅមានកំរិតនៅឡើយ។

ក្រៅពីការលំបាកនៃការអនុវត្តន៍ទៅតាមស្តង់ដាសហគមន៍នេសាទក្នុងរង្វង់ព្រំដែនរបស់ខ្លួន គឺនៅមានសកម្មភាព ខាងក្រៅបន្ថែមទៀត បានឆ្លងកាត់ព្រំដែនសហគមន៍ និងរំខានដល់បរិស្ថាន។ សកម្មភាពនេះ រួមមានការ ធ្វើដំណើរទៅ-មក ដោយទូកល្បឿន ដឹកអ្នកដំណើរ អ្នកទេសចរណ៍ អ្នកជំនួញ និងទំនិញតាមមូលដ្ឋាន ពីផ្សារវ៉ឺនខាំនៃប្រទេសឡាវ ទៅកាន់ទីរួមខេត្តស្ទឹងត្រែង ហើយដែលសកម្មភាពនេះ កាន់តែកើនឡើងៗ។ ទូកល្បឿនទាំងនេះ មានសំលេងឮខ្លាំងខ្លាំង រំខានដល់ត្រីរស់នៅជំរកធម្មជាតិ ឱ្យទៅរស់នៅកន្លែងផ្សេងវិញ។ ការបំពុលដោយសំលេង ទូកល្បឿននេះមានរយៈចំងាយប្រមាណ១៥គ.ម ដែលជាការរំខានផងដែរដល់ភាពស្ងប់ស្ងាត់របស់ប្រជាជនមូលដ្ឋាន និងសត្វព្រៃដែលរស់នៅក្បែរៗនោះ។

សរុបមកវិញ ការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិនៅក្នុងតំបន់រ៉ាមសារ គឺមានការអភិវឌ្ឍន៍ល្អ បើប្រៀបធៀបទៅនឹងតំបន់ដទៃទៀតនៅក្នុងខេត្ត។ រាល់គំរោងអន្តរាគមន៍ផ្នែកអភិវឌ្ឍន៍ ដែលអនុវត្តដោយរដ្ឋាភិបាល វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានទទួលស្គាល់ដោយប្រជាជនដែលរស់នៅក្នុងតំបន់រ៉ាមសារ។ មានការរីកចំរើនមួយចំនួន បានធ្វើឡើងក្នុងការលើកតំកើងស្ថានភាពរស់នៅរបស់ប្រជាជន និងការបំផុសនូវការយល់ដឹងជាមូលដ្ឋាន ស្តីពីច្បាប់ជាតិ និងសិទ្ធិជាមូលដ្ឋានក្នុងការអភិរក្សធនធានធម្មជាតិ។

អង្គការអភិវឌ្ឍន៍សហគមន៍ បានទទួលនូវការកោតសរសើរពីសហគមន៍មូលដ្ឋានជាច្រើន។ មានប្រជាជនមួយចំនួន មិនសប្បាយចិត្ត ហើយមួយចំនួនទៀតបានបញ្ចេញនូវគំនិតរបស់ពួកគេ ដែលអាចសង្ខេបដូចខាងក្រោមៈ(១) គំរោងអភិវឌ្ឍន៍ មិនបានឆ្លើយតបទៅនឹងតំរូវការពេញលេញរបស់ពួកគេ។ (២) អង្គការទាំងនេះបានបន្សល់ទុកនូវបញ្ហា មិនបានដោះស្រាយមួយចំនួន ជុំវិញជំលោះរវាងប្រជាជនមូលដ្ឋាន អ្នកមានអំណាច និងក្រុមហ៊ុនឯកជន។ (៣) សិទ្ធិរបស់សហគមន៍មូលដ្ឋានទៅលើការគ្រប់គ្រងដីធ្លី ព្រៃឈើ ត្រី និងធនធានធម្មជាតិផ្សេងៗទៀត មិនត្រូវបានទទួលស្គាល់ពេញលេញទេ។ (៤) សិទ្ធិរបស់សហគមន៍មូលដ្ឋាន (ដោយរួមទាំងជនជាតិភាគតិច) ក្នុងការទទួលសេវាកសង្គម ដូចជាការថែទាំសុខភាព និងអប់រំនៅមានកំរិតថែមទៀត។

## គោលនយោបាយតំបន់ដីសើម និងធនធានទឹក

ការគ្រប់គ្រងតំបន់ដីសើមក្នុងប្រទេសកម្ពុជា គឺជាការទទួលខុសត្រូវរួមរបស់ស្ថាប័នរដ្ឋមួយចំនួន (World Bank, 2003)។ គ្មានស្ថាប័នណាមួយ អាចទទួលខុសត្រូវទាំងស្រុងនោះទេ។ ទាក់ទងនឹងការគ្រប់គ្រង និងអភិរក្សជីវៈចម្រុះ តំបន់ដីសើម មានក្រសួងចំនួនពីរគឺក្រសួងបរិស្ថាន និងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ជាអ្នកពាក់ព័ន្ធ។ ក្រសួងបរិស្ថាន ទទួលខុសត្រូវគ្រប់គ្រងតំបន់ការពារ និងដើម្បីស្វែងរកធនធានរបស់ប្រទេសកម្ពុជា ដោយផ្អែកទៅលើអនុសញ្ញាតំបន់រ៉ាមសារ និងអនុសញ្ញាស្តីពីជីវៈចម្រុះ។ ក្រសួងកសិកម្ម ទទួលខុសត្រូវលើអនុសញ្ញាស្តីពីពាណិជ្ជកម្មប្រភេទសត្វជិតផុតពូជ (CITES)។ នាយកដ្ឋានជលផល មានតួនាទីបង្កើតច្បាប់ជលផល និងអនុវត្ត ដោយរួមទាំងការផ្តល់សម្បទានឡូត៍នេសាទ តំបន់ការពារដែនជម្រកត្រី ព្រៃលិចទឹកវាលភក់ និងកន្លែងនេសាទផ្សេងៗទៀត ដូចជាបឹង និងត្រពាំងជាដើម (Torrel et al, 2004)។

ការទទួលខុសត្រូវដាច់ដោយឡែកបែបនេះ បណ្តាលឱ្យមានការគ្រប់គ្រងពុំសូវមានប្រសិទ្ធិភាពតំបន់ដីសើម។ បច្ចុប្បន្នគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា កំពុងតែរៀបចំផែនការសកម្មភាពតំបន់ដីសើមជាតិ។ សង្ឃឹមថាផែនការនេះ នឹងជួយឱ្យមានការគ្រប់គ្រង និងអភិវឌ្ឍន៍សមស្របទៅលើតំបន់ដីសើមប្រទេសកម្ពុជា និងផ្តល់លទ្ធផលល្អដល់កិច្ចប្រឹងប្រែងទាំងនេះ។

បច្ចុប្បន្នបើយោងតាមច្បាប់ និងកាតព្វកិច្ចជាតិជាច្រើន ប្រទេសកម្ពុជា គឺមានច្បាប់ និងគោល-នយោបាយច្រើនទាក់ទងនឹងតំបន់ដីសើម។ ច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (១៩៩៦) បានស្វែងរកការការពារ គ្រប់គ្រង និងអនុវត្តបរិស្ថាន និងលើកកំពស់ការអភិវឌ្ឍន៍និរន្តរភាព។ ក្រសួងបរិស្ថាន ទទួលខុសត្រូវនូវការអនុវត្ត ដែលតម្រូវឱ្យមានផែនការបរិស្ថាន ការចូលរួមពីសាធារណៈ និងការគ្រប់គ្រងការបំពុល។ តម្រូវការសំរាប់ការវាយតំលៃ ហេតុប៉ះពាល់បរិស្ថាន (EIA) ត្រូវបានបកស្រាយលំអិតបន្ថែមនៅក្នុងអនុក្រឹត្យស្តីពី ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន (១៩៩៩)។ ព្រះរាជក្រម ស្តីពីការបង្កើត និងតែងតាំងតំបន់ការពារ គឺជាមូលដ្ឋានគ្រឹះមួយសំរាប់កម្មវិធីតំបន់ការពារប្រទេសកម្ពុជាដែលមានក្រសួងបរិស្ថានជាអ្នកទទួលខុសត្រូវអនុវត្ត។

ច្បាប់ព្រៃឈើ (២០០២) គឺទាក់ទងនឹងការធ្វើនិយតកម្ម ចេញច្បាប់អនុញ្ញាត និងការអនុវត្តព្រៃសម្បទាន។ យោងតាមតម្រូវការ ក្រុមហ៊ុនសម្បទានព្រៃឈើ គឺតម្រូវឱ្យគោរពសិទ្ធិប្រើប្រាស់របស់សហគមន៍មូលដ្ឋាន។ ទាំងនេះរួម មានការប្រើប្រាស់ព្រៃឈើសំរាប់ជីវភាពរស់នៅ មិនអនុញ្ញាតឱ្យលក់ធ្វើពាណិជ្ជកម្ម និងការលក់អនុផលព្រៃឈើ ដោយរួមមានសត្វព្រៃសាមញ្ញមួយចំនួន។ ចំណុចសំខាន់ពិសេសរបស់ច្បាប់ព្រៃឈើ គឺអនុក្រឹត្យស្តីពីការបង្កើតសហគមន៍ព្រៃឈើ។ ចំណុចនេះ បានបង្កើតនូវរចនាសម្ព័ន្ធ និងដំណើរការមួយ ដែលសហគមន៍មូលដ្ឋានអាចគ្រប់គ្រង ប្រើប្រាស់ និងទទួលផលពីធនធានព្រៃឈើ នៅតាមមូលដ្ឋានរបស់ពួកគេ។ ការដកហូតខ្នាតតូចបែបនេះ អាចអនុវត្តបាននៅក្នុងតំបន់ការពារប្រសិនបើមានការអនុញ្ញាតពីក្រសួងបរិស្ថាន។

ច្បាប់ជលផល និងការអនុវត្ត គឺជាបញ្ហាសំខាន់នៅក្នុងប្រទេសកម្ពុជា។ ក្រៅពីសារៈសំខាន់តំបន់រ៉ាមសារខេត្តស្ទឹងត្រែង គឺនៅមានអនុក្រឹត្យស្តីពីសហគមន៍នេសាទផងដែរ។ បន្ទាប់ពីការអនុម័តនៅខែមិថុនា ឆ្នាំ២០០៥ អនុក្រឹត្យនេះ បានផ្តល់នូវមូលដ្ឋានច្បាប់ និងគោលការណ៍ណែនាំ ដែលសហគមន៍មូលដ្ឋានអាចគ្រប់គ្រងធនធានជលផលដោយខ្លួនឯង។ បច្ចុប្បន្ន សហគមន៍នេសាទនៅតំបន់រ៉ាមសារទាំងនោះ ពុំទាន់មានប្រសិទ្ធិភាពនៅឡើយ លើដំណើរការនេះ។ ហេតុដូច្នេះ វាត្រូវការជំនួយបន្ថែមពីរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីពង្រឹងនូវប្រសិទ្ធិភាពគ្រប់គ្រងរបស់ពួកគេ។

ការទទួលខុសត្រូវភាគច្រើន ស្តីពីការគ្រប់គ្រងធនធានទឹកដ៏មហាសាលនៅកម្ពុជា គឺស្ថិតនៅលើការទទួលខុសត្រូវ របស់ក្រសួងធនធានទឹក និងឧតុនិយម ដែលទើបតែបង្កើតឡើងនៅឆ្នាំ១៩៩៩។ ក្រសួងនេះ មានច្បាប់ជាច្រើនទាក់ទងនឹងការគ្រប់គ្រង និងអភិវឌ្ឍធនធានទឹក ក្នុងនោះរួមមាន ប្រព័ន្ធធារាសាស្ត្រ ការគ្រប់គ្រងទឹកជំនន់ និងវារីអគ្គិសនី។ ទាំងនេះ គឺជាបញ្ហាចម្បងដែលគំរោងអភិវឌ្ឍន៍ នឹងត្រូវស្នើឡើងនៅក្នុងតំបន់ ឬក្បែរតំបន់រ៉ាមសារ។ សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក គឺកំពុងពិចារណាដោយរដ្ឋសភា និងសេចក្តីព្រាងគោលនយោបាយធនធានទឹកថ្នាក់ជាតិ គឺត្រូវបានអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រី។

## អនុសញ្ញាអន្តរជាតិនានា

កម្ពុជា ជាប្រទេសហត្ថលេខីលើអនុសញ្ញាអន្តរជាតិជាច្រើន ទាក់ទងនឹងបញ្ហាបរិស្ថាន និងជីវៈចម្រុះ។ ហេតុដូច្នេះ នៅខែតុលាឆ្នាំ១៩៩៩ ប្រទេសកម្ពុជាបានអនុម័តលើអនុសញ្ញា ស្តីពីតំបន់ដីសើមនៃសារៈសំខាន់អន្តរជាតិ (អនុសញ្ញារ៉ាមសារ)។ តំបន់រ៉ាមសារខេត្តស្ទឹងត្រែង គឺជាតំបន់រ៉ាមសារទី៩៩៩ ដែលបានប្រកាសជាសកល។ អនុសញ្ញានេះ តម្រូវឱ្យប្រទេសកម្ពុជាអនុវត្តនូវជំហ៊ានសមស្របទាំងអស់ដើម្បីអភិរក្ស និងគ្រប់គ្រងតំបន់ដីសើមរបស់ខ្លួន ប្រកបដោយនិរន្តរភាព។ កម្មវិធី MWBP គឺជាផ្នែកមួយដ៏មានសារៈសំខាន់នៃការបំពេញនូវកាតព្វកិច្ចនេះ។

នៅឆ្នាំ១៩៩៥ ប្រទេសកម្ពុជាក៏បានចុះហត្ថលេខាលើអនុសញ្ញា ស្តីពីជីវៈចម្រុះ។ អនុសញ្ញានេះ តម្រូវឱ្យប្រទេសកម្ពុជា អភិរក្សនូវជីវសាស្ត្រចម្រុះរបស់ខ្លួន និងជំរុញឱ្យមានការប្រើប្រាស់ដោយនិរន្តរភាព។ ដោយសារកាតព្វកិច្ច ប្រទេសកម្ពុជា បានរៀបចំផែនការសកម្មភាពជីវៈចម្រុះរបស់ខ្លួន (MoE,2002)។ គោលនយោបាយគន្លឹះនៅក្នុងផែនការសកម្មភាព រួមមាន :

- ថែរក្សាជីវសាស្ត្រចម្រុះ និងផលិតភាពប្រព័ន្ធអេកូឡូស៊ី ដោយការការពារនូវប្រភេទសរីរាង្គមានជីវិតផ្សេងៗ នៅក្នុងបរិស្ថានធម្មជាតិ និងកែច្នៃ ជាពិសេសព្រៃឈើ ទឹកសាប ប្រព័ន្ធអេកូឡូស៊ីទឹកប្រៃ តំបន់ដីសើម និងដីកសិកម្ម។
- គ្រប់គ្រងសកម្មភាពមនុស្ស និងប្រើប្រាស់ធនធានជីវសាស្ត្រ តាមវិធីដែលអាចរក្សាបាននូវធនធានធម្មជាតិ ដ៏យូរអង្វែង ដែលមានសារៈសំខាន់សំរាប់ជីវភាពរស់នៅរបស់មនុស្ស និងការអភិវឌ្ឍន៍។
- ត្រូវធានាថា ផលប្រយោជន៍ដែលបានមកពីការប្រើប្រាស់ដោយនិរន្តរភាពនៃធនធានជីវសាស្ត្រ ផ្តល់នូវការកាត់បន្ថយភាពក្រីក្រ និងលើកកំពស់គុណភាពជីវិតដល់ជនកម្ពុជាគ្រប់រូប។

គោលនយោបាយទាំងនេះ គឺមានលក្ខណៈដូចគ្នាជាច្រើនទៅនឹងគោលបំណងរបស់កម្មវិធី MWBP សំរាប់តំបន់រ៉ាមសារ ខេត្តស្ទឹងត្រែង។

ប្រទេសកម្ពុជា ក៏ជាហត្ថលេខីលើអនុសញ្ញា ស្តីពីពាណិជ្ជកម្មអន្តរជាតិ លើប្រភេទសត្វជិតផុតពូជ។ ទោះបីការចុះហត្ថលេខាបានចាប់ផ្តើមឆ្នាំ១៩៧៥ ក៏អនុសញ្ញានេះត្រូវបានចាប់ផ្តើមអនុវត្តនៅឆ្នាំ១៩៩៩។ អនុសញ្ញានេះតម្រូវឱ្យប្រទេសកម្ពុជា ធ្វើការគ្រប់គ្រងពាណិជ្ជកម្មទៅលើប្រភេទសត្វដែលជិតផុតពូជ ឬផុតពូជពីទឹកដីកម្ពុជា និងពិភពលោក។ ការធ្វើពាណិជ្ជកម្មទៅលើប្រភេទសត្វទាំងនេះ ត្រូវហាមឃាត់ ឬអនុញ្ញាតដែលស្ថិតនៅ

ក្រោមការត្រួតត្រាយ៉ាងតឹងរឹង។ មាន ថនិកសត្វ បក្សី និងពពួកល្មូនជាច្រើនប្រភេទ ដែលមាននៅតំបន់រ៉ាមសារ គឺស្ថិតក្នុងបញ្ជីហាមឃាត់របស់អនុសញ្ញានេះ។ ប្រទេសកម្ពុជាពុំមានធនធានគ្រប់គ្រាន់ ដើម្បីអនុវត្តអនុសញ្ញា ឱ្យបានពេញលេញនូវការតព្វកិច្ចរបស់ខ្លួន ហើយការធ្វើពាណិជ្ជកម្មខុសច្បាប់បានកើតឡើង ដោយរួមទាំងប្រភេទ សត្វហាមឃាត់តំបន់រ៉ាមសារ ខេត្តស្ទឹងត្រែងថែមទៀត។

ម្យ៉ាងទៀតប្រទេសកម្ពុជា មានស្ថាប័នសំខាន់ៗទទួលខុសត្រូវនូវគោលនយោបាយជាតិ ដែលមានស្រាប់ ឬបានគ្រោង និងការតព្វកិច្ចសន្ធិសញ្ញាអន្តរជាតិមួយចំនួនដើម្បីដឹកនាំកិច្ចប្រឹងប្រែងរបស់ខ្លួនក្នុងការអភិរក្ស និង គ្រប់គ្រងរបស់តំបន់ការពារតំបន់ដីសើម និងជីវៈចម្រុះ។ ទោះជាយ៉ាងណា នៅបច្ចុប្បន្ននេះសមត្ថភាពក្នុងការ ជំរុញ និងអនុវត្តបទប្បញ្ញត្តិទាំងនេះគឺនៅខ្សោយ។ ទង្វើនេះ សំដៅទៅលើការអនុវត្តថ្នាក់ជាតិ(ក្រសួង) និង មន្ទីរពាក់ព័ន្ធក្នុងខេត្ត។ ការអនុវត្តថ្នាក់ខេត្ត ជារឿយៗត្រូវបានមើលរំលង និងមិនបានប្រឹក្សាយោបល់ក្នុងការ គ្រប់គ្រងបញ្ហាបរិស្ថាន ដែលពាក់ព័ន្ធនៅក្នុងខេត្ត។ ប្រសិនបើសមត្ថភាពទាំងថ្នាក់ខេត្ត និងជាតិមិនត្រូវបាន ពង្រឹង ពេលនោះប្រសិទ្ធភាពនៃការគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ដីសើមនឹងត្រូវពន្យាពេល។ នេះពិតជាមាន សារៈសំខាន់ ដែលការពង្រឹងសមត្ថភាពនេះត្រូវតែអនុវត្តជាអាទិភាព។

## សង្ខេប

ការអភិវឌ្ឍន៍នៅខេត្តស្ទឹងត្រែង គឺកំពុងចាប់ផ្តើមក្នុងការឆ្លើយតបនឹងផែនការ និងសំណើថ្នាក់ជាតិ និង អន្តរជាតិ។ គណៈកម្មការទន្លេមេគង្គ (MRC) គឺជាអង្គការដំបូង ដើម្បីធ្វើផែនការអភិវឌ្ឍន៍នៃធនធាន ទន្លេ មេគង្គ។ សមាជិកប្រទេសទាំងបួន (កម្ពុជា ឡាវ ថៃ និងវៀតណាម) បានអនុវត្តនូវការសិក្សាស្រាវជ្រាវផ្នែក សង្គម និងវិទ្យាសាស្ត្រជាច្រើន ដើម្បីដឹកនាំការអភិវឌ្ឍន៍ទាំងនេះ។ បច្ចុប្បន្ន គណៈកម្មការទន្លេមេគង្គ កំពុងរៀបចំផែនការអភិវឌ្ឍអាងទន្លេមេគង្គ និងដៃនានារបស់វា។

ប្រទេសវៀតណាម ដោយសហការជាមួយប្រទេសកម្ពុជា និងឡាវ បានរៀបចំផែនការដ៏មានមហិច្ឆតា មួយសំរាប់ខេត្តស្ទឹងត្រែង និងខេត្តរតនគីរី។ ផែនការនេះ បានប្រមើលមើលនូវការអភិវឌ្ឍន៍ឡើងវិញដ៏មហា សាលនៅតាមជ្រលងទន្លេ សេកុង សេសាន និងស្រែពក។ នៅមានគំរោងជាច្រើនទៀត រួមមានវារីអគ្គិសនី ប្រព័ន្ធធារាសាស្ត្រ កាប់ឈើ កសិកម្ម ទេសចរណ៍ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្លូវទឹក និងផ្លូវគោក និង- កសិឧស្សាហកម្ម។

ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមដំណាក់កាលទីមួយ និងទីពីរ ក៏បានប្រមើលឃើញនូវការអភិវឌ្ឍន៍បែប នេះរួមមាន ការបង្កើនវិស័យអប់រំ យុត្តិធម៌សង្គម ប្រាក់ចំណូល សមត្ថភាពរដ្ឋាភិបាល និងអភិបាលកិច្ចល្អ និង កំណែទម្រង់វិស័យ គ្រប់គ្រងជលផល និងព្រៃឈើ តាមរយៈវិស័យឯកជន និងអង្គការមូលដ្ឋាន តាមរយៈ ដំណើរការគ្រប់គ្រងបែបសហគមន៍។ ម្យ៉ាងទៀត យើងឃើញមានចលនានៃការផ្តល់អំណាចវិមជ្ឈការ និង ការគ្រប់គ្រងធនធានធម្មជាតិ។ ប៉ុន្តែ សមត្ថភាពរបស់រដ្ឋាភិបាល និងប្រជាជនមូលដ្ឋាន នៅមានកម្រិតក្នុង- ការគ្រប់គ្រងធនធាន បច្ចុប្បន្នឱ្យមានប្រសិទ្ធភាព និងត្រូវការជំនួយពីខាងក្រៅបន្ថែម។

អង្គការមិនមែនរដ្ឋាភិបាល បានដើរតួជាផ្នែកមួយដ៏មានសារៈសំខាន់នៅក្នុងតំបន់រ៉ាមសារ។ កន្លងមក ការគ្រប់ គ្រងធនធានធម្មជាតិ ដែលដឹកនាំដោយសមាគមថែរក្សាបរិស្ថាន និងវប្បធម៌ និងអង្គការស៊ីអេអេ គឺមានភាពសកម្មច្រើន ក្នុងការបង្កើតគំរោងគ្រប់គ្រងសហគមន៍ព្រៃឈើ និងនេសាទនៅទីនោះ។

# ជំពូក៦: នយោបាយ និង ស្ថាប័ន

## សេចក្តីផ្តើម

ជំពូកនេះ នឹងពិភាក្សានូវចំណុចជាបន្តបន្ទាប់ ដូចជា: អភិបាលកិច្ច តួនាទី និងសមត្ថភាពរបស់ស្ថាប័នរដ្ឋ និងប្រព័ន្ធរដ្ឋបាល ឥទ្ធិពលរបស់ស្ថាប័នក្នុងការគ្រប់គ្រងធនធាន ការចូលរួមរបស់សាធារណៈជន និងអ្នកពាក់ព័ន្ធសំខាន់ៗដូចជា វិស័យ រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជន ។

## អភិបាលកិច្ច និង វិមជ្ឈការ

បញ្ហាអភិបាលកិច្ច បានក្លាយជាវិធីសាស្រ្តពិពណ៌នានូវគ្រប់សកម្មភាពត្រួតស៊ីគ្នាទាំងឡាយ របស់ស្ថាប័នពាក់ព័ន្ធ រួមមានស្ថប័នរដ្ឋ អង្គកាមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ ។ អភិបាលកិច្ច បានពិពណ៌នា នូវការរៀបចំសាញ៉ាំមួយ នៃអំណាចទាមទារ បែបប្រកួតប្រជែង (Dore, ២០០៣)។

ពេលមានដំណើរការសន្តិភាពក្នុងប្រទេសកម្ពុជាតាំងពីដើមឆ្នាំ១៩៩០ រដ្ឋាភិបាលបានផ្តួចផ្តើមគម្រោងអភិវឌ្ឍសំខាន់ៗ ដោយមានបំណងធ្វើឱ្យប្រសើរដល់ការរស់នៅរបស់ប្រជាជន។ ដើម្បីសម្របសម្រួលគម្រោងទាំងនោះ តម្រូវការ បង្កើនសមត្ថភាព ស្ថាប័នថ្នាក់ខេត្ត និងថ្នាក់ទាបជាងនេះ គឺត្រូវតែមានជាចាំបាច់។ ក្រសួងអភិវឌ្ឍន៍ជនបទ មានការទទួលខុសត្រូវបង្កើតគណៈកម្មកា អភិវឌ្ឍន៍ជនបទខេត្ត គណៈកម្មការអភិវឌ្ឍន៍ជនបទឃុំ គណៈកម្មការអភិវឌ្ឍន៍ជនបទភូមិ។ គណៈកម្មកាទាំងនេះ ត្រូវបានបង្កើតឡើងទូទាំងប្រទេស ដោយមានគោលបំណងបង្កើតផែនការវិមជ្ឈការ ការគ្រប់គ្រង ការអនុវត្តន៍ និងត្រួតពិនិត្យគម្រោងកម្មវិធី ទៅលើការអភិវឌ្ឍន៍ជនបទ (Sam Ang, ២០០២)។ ក្នុងអំឡុងពេល ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម៥ឆ្នាំលើកទី២ របបវិមជ្ឈការនៃអំណាចរដ្ឋ ត្រូវបានបង្កើតដើម្បីផ្តល់ឱកាសថ្មីដល់តំណាង និងសម្រួលនូវការចូលរួមផ្ទាល់ពីអ្នកក្រនៅក្នុងដំណើការសម្រេចចិត្តតាមមូលដ្ឋាន ហេតុដូច្នេះ យុទ្ធសាស្រ្តនេះអាចជំរុញ ឱ្យពួកគេមានយុទ្ធសាស្រ្តដោះស្រាយប្រសើរជាង និងអាចឱ្យពួកគេមានឱកាសទទួលធនធានពីរដ្ឋាភិបាលដោយផ្ទាល់តាម សកម្មភាពផ្សេងៗទៀត (RGC, ២០០២)។

នៅឆ្នាំ២០០២ ដើម្បីឆ្លើយតបនឹងកម្មវិធីវិមជ្ឈការ ការបោះឆ្នោតឃុំលើកទី១បានធ្វើឡើងដោយមានការចូលរួមពីគណបក្សប្រជាជន គណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្សសមរង្ស៊ី។ គណបក្សប្រជាជន បានទទួលសន្លឹកឆ្នោតច្រើនជាងគេ ហើយបានកាន់តំណែងជាប្រធាន អនុប្រធានទី១ និងជាលេខារួមក្នុងជួរគណៈកម្មការអភិវឌ្ឍន៍ ចំណែកគណបក្សហ្វ៊ុនស៊ិនប៉ិច បានទទួលតំណែងភាគច្រើនជាអនុប្រធានទី២ និងអនុប្រធានទី៣សំរាប់គណបក្សសមរង្ស៊ី។ តាមការអនុវត្តជាក់ស្តែង គណបក្សប្រជាជន និងគណបក្សហ្វ៊ុនស៊ិនប៉ិច បានចងសម្ព័ន្ធភាព រីឯគណបក្សសមរង្ស៊ីជាបក្សប្រឆាំង ។

យោងតាមទំនាក់ទំនងអំណាចមានស្រាប់ រាល់ការសម្រេចចិត្តដែលទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិដូចជា លក់ដែនេសាទ ដីធ្លី និងព្រៃឈើទៅឱ្យឯកជន គឺត្រូវបានអនុវត្តដោយគណបក្សប្រជាជន និង

ហ៊្វុនស៊ីនប៉ិច។ ឯគណបក្សសមរង្ស៊ី មិនយល់ព្រមដោយទាមទារថា ធនធានទាំងនេះត្រូវតែគ្រប់គ្រង និងចាត់ចែងដោយប្រជាជនមូលដ្ឋាន។ ជាលទ្ធផល គណបក្សសមរង្ស៊ី ត្រូវបានគេគិតថាជាអ្នកបង្ករឿងនៅក្នុងឃុំ ។

វេទិកាសម្ព័ន្ធឃុំ ត្រូវបានចាត់ទុកថា អង្គភាពរដ្ឋបាលមូលដ្ឋាន ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យសហគមន៍មូលដ្ឋាននេះ គឺមានន័យថា បានផ្លាស់ប្តូរអំណាចស្ថាប័នអភិវឌ្ឍន៍ (ថ្នាក់ជាតិ និងខេត្ត)។ ថ្នាក់ខេត្ត បានព្យាយាមបញ្ចុះបញ្ចូលអ្នកភូមិឱ្យចូលរួមក្នុង ដំណើរការអភិវឌ្ឍន៍ តាមរយៈការសាងសង់ហេដ្ឋារចនាសម្ព័ន្ធជនបទ និងបង្កើនសន្តិសុខស្បៀង។ យោងតាម ការណែនាំរបស់រដ្ឋ គណៈកម្មាការសហគមន៍ បានចូលរួមរៀបចំឡើងវិញនូវរចនាសម្ព័ន្ធសង្គមតាមភូមិ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងប្រជាជន (សូមមើលជំពូក៥)។

កម្មវិធីនេះ បានចាប់ផ្តើមនៅឆ្នាំ២០០៣ នៅខេត្តស្ទឹងត្រែង ហើយឥឡូវបានគ្របដណ្តប់គ្រប់ស្រុក។ គណៈកម្មការក្រុមការងារសីលា មានអ្នកតំណាងមកពីមន្ទីរពាក់ព័ន្ធចំនួន៧: មន្ទីរកិច្ចការនារី មន្ទីរធនធានទឹក និងឧតុនិយម មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មហាផ្ទៃ(សាលាខេត្ត) មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរផែនការ និងមន្ទីរអភិវឌ្ឍន៍ជនបទ ។ គោលបំណងសំខាន់ គឺជំរុញសមាហរណកម្មអភិបាលកិច្ចតាមមូលដ្ឋានក្នុងការអភិវឌ្ឍន៍។ កម្មវិធីសីលា បានប្រតិបត្តិកម្មវិធីអភិបាលមូលដ្ឋាន តាមរយៈថានានុក្រមគណៈកម្មការអភិវឌ្ឍន៍ខេត្ត ស្រុក ឃុំ និងភូមិ។ គណៈកម្មការអភិវឌ្ឍន៍ឃុំ និងភូមិ បានបង្កើតឡើង តាមរយៈការបោះឆ្នោតមូលដ្ឋានក្រោមកិច្ចសម្របសម្រួល ពីគណៈកម្មការអភិវឌ្ឍន៍ជនបទខេត្ត ។

គោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ តែងតែដាក់សំពាធលើប្រជាជនមូលដ្ឋាន ឱ្យឃ្លាតចេញពីរបៀបរស់នៅតាមបែបប្រពៃណី (ADB, ២០០០)។ គឺមានឱកាសតិចតួច សំរាប់អ្នកទន់ខ្សោយ ឬអ្នកក្រ ក្នុងការបច្ចេញសេរីភាព និងសិទ្ធិដកហូតធនធាន ដែលពួកគេត្រូវការ។ ការបែងចែកធនធានធម្មជាតិ ភាគច្រើនគ្រប់គ្រងដោយអ្នកមានអំណាច មកពីជួរកងទ័ព និងពួកអភិជនតាមមូលដ្ឋាន ដោយធានាថាបក្សពួក និងញាតិសន្តានពួកគេជាគោលដៅទទួលផលប្រយោជន៍មុនគេ។

## តួនាទី និងសមត្ថភាពរបស់ស្ថាប័នរដ្ឋ និងប្រព័ន្ធរដ្ឋបាលរដ្ឋ

សមត្ថភាពរបស់ស្ថាប័ន នៅទូទាំងប្រទេសកម្ពុជា ជាពិសេសនៅថ្នាក់ខេត្ត ស្រុក និងឃុំ គឺមានដែនកំណត់ច្រើន។ កត្តានេះ បណ្តាលមកពីហេតុផលជាច្រើនរួមមាន ការបាត់បង់ធនធានមនុស្សក្នុងទសវត្សរ៍ទី៧០ បុគ្គលិករដ្ឋមានប្រាក់ខែតិច និងវិស័យសាធារណៈគុណភាពទាប ហេដ្ឋារចនាសម្ព័ន្ធទ្រុឌទ្រោម និងកង្វះខាតធនធានហិរញ្ញវត្ថុ។ ផ្ទុយទៅនឹងបញ្ហាខាងលើ ប្រព័ន្ធរដ្ឋបាលរដ្ឋអាច បកស្រាយដូចខាងក្រោម:

រចនាសម្ព័ន្ធគ្រប់គ្រងប្រទេសកម្ពុជា ត្រូវបានបង្កើតឡើងតាមប្រព័ន្ធធ្វើការបែបវៀតណាម នៅទសវត្សរ៍ទី៨០។ ប្រព័ន្ធនេះ ត្រូវបានរៀបចំឡើងដើម្បីរក្សា និងត្រួតត្រាស្ថេរភាពនយោបាយ។ ប្រព័ន្ធនេះបង្កើតនូវលក្ខណៈពិសេសក្នុងការបន្តការអភិវឌ្ឍន៍ និងការស្វែងយល់ពីការងារអភិវឌ្ឍន៍របស់កម្ពុជា។ ប្រព័ន្ធរដ្ឋបាលរដ្ឋផ្លូវការ ត្រូវបានអនុវត្តតាម ថានានុក្រម ដូចជា ថ្នាក់ជាតិ ខេត្ត ស្រុក ឃុំ ភូមិ និងក្រុម។ យោងតាមខ្សែបណ្តោយការងារនេះ គណបក្សប្រជាជន គឺជាអ្នកមានឥទ្ធិពលជាងគេ (Ojendal, ២០០០)។

ប្រជាជនភាគច្រើនយល់ថា ថ្នាក់ខេត្ត គឺជាមជ្ឈមណ្ឌលអំណាចរដ្ឋបាល។ ថ្នាក់ស្រុក គឺជាមជ្ឈមណ្ឌលសំរាប់គ្រប់គ្រងជនបទ ហើយថ្នាក់ឃុំ មានឋានានុក្រមទាបបំផុត នៅក្នុងប្រព័ន្ធការិយាល័យធិបតេយ្យ។ ចំណែកមេភូមិ និងអនុប្រធានគាត់ គឺជាអ្នកដែលត្រូវទាក់ទងញឹកញាប់ រវាងរចនាសម្ព័ន្ធរដ្ឋ និងប្រជាជនសាមញ្ញ។ ប្រព័ន្ធរដ្ឋបាលទាំងនេះបានប្រកាន់ខ្ជាប់នឹងការិយាល័យធិបតេយ្យ និយមខ្លាំងណាស់។ ទោះជាយ៉ាងណាមានការងាររអាជីវកម្មជាច្រើន បានកើតឡើងផ្ទុយពីប្រព័ន្ធរដ្ឋបាលនេះ ដែលបង្ហាញថា អំណាចផ្តាច់ការពុំសូវមានអនុវត្ត ដូចមុនទេ។ ថ្មីៗនេះ មានកម្មវិធីផ្តួចផ្តើមអភិវឌ្ឍ មួយចំនួនបានកើតឡើង ដោយមិនបានឆ្លងកាត់ រចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធនយោបាយនេះទេ។

**ថ្នាក់ខេត្ត**

ប្រព័ន្ធរដ្ឋបាលថ្នាក់ខេត្ត មានទំហំធំធេង ជាកន្លែងកាត់ក្តី មានមន្ទីរពាក់ព័ន្ធទាំងអស់ស្ថិតនៅក្រោមឱវាទរបស់ខ្លួន និងស្ថាប័នផ្សេងៗទៀត។ ឋានានុក្រមនេះ ត្រូវបានដឹកនាំដោយអភិបាលខេត្ត ដែលតែងតាំងដោយរដ្ឋាភិបាលមជ្ឈឹម។ អំណាច របស់អភិបាលខេត្ត មិនដូចគ្នាទេ គឺអាស្រ័យទៅលើបុគ្គល និងអំណាចដែលគាត់មានជាមូលដ្ឋាន។ ជាទូទៅ អភិបាលខេត្ត ជាអ្នកគ្រប់គ្រងកងកំលាំងប្រដាប់អាវុធ ឬជាអ្នកមានទំនាក់ទំនងជិតស្និទជាមួយកងទ័ពតែម្តង។ បុគ្គលិកស៊ីវិលមកពីសាលាខេត្ត កម្រចុះទៅទស្សកិច្ចតាមភូមិណាស់។

**ថ្នាក់ស្រុក**

ថ្នាក់ស្រុក គឺជាថ្នាក់សំខាន់សំរាប់គ្រប់គ្រងរដ្ឋបាលមូលដ្ឋាន។ សាលាស្រុកពុំមានធនធានសំរាប់គ្រប់គ្រងស្ថាប័ន ក្រោមឱវាទដូចថ្នាក់ខេត្តទេ។ ផ្ទុយទៅវិញ ការទទួលខុសត្រូវ ត្រូវបានបែងចែកតាមបុគ្គល។ ជាការពិត-ណាស់ អាទិភាពខ្ពស់នៅកម្រិតនេះ គឺផ្តោតលើសន្តិសុខតាមតំបន់ជនបទតាំងពីទសវត្សរ៍ទី៨០ ហើយកិច្ចប្រឹងប្រែងផ្នែកអភិវឌ្ឍន៍បានក្លាយជាអាទិភាពបន្ទាប់វិញ។

**ថ្នាក់ឃុំ**

សាលាឃុំ ជាការិយាល័យបន្ទាប់នៅក្នុងឋានានុក្រមនៃការិយាល័យធិបតេយ្យ។ ថ្នាក់នេះ ជាទូទៅ-ពាក់ព័ន្ធការងារ ថ្នាក់ ភូមិប្រចាំថ្ងៃច្រើន។ ថ្នាក់ឃុំ ទទួលខុសត្រូវគម្រោងអភិវឌ្ឍន៍ខ្នាតតូចជាច្រើន ដូចជាធ្វើផ្លូវតាមភូមិ និងសង់ស្ពាន ជាដើម។ មេឃុំមានតួនាទី ដោះស្រាយជម្លោះតាមភូមិ ឬនៅក្នុងភូមិ។ សាលាឃុំទទួលខុសត្រូវប្រមូលស្ថិតិភូមិ រក្សាសន្តិសុខ តាមរយៈកងជីវពលឃុំ និងរៀបចំផែនការអភិវឌ្ឍន៍ឃុំ និងកំណត់អាទិភាព។

**ថ្នាក់ភូមិ**

នៅក្នុងភូមិ មេភូមិជាមនុស្សម្នាក់ ដែលជួលដោយរដ្ឋ។ ប្រភពធនធានហិរញ្ញវត្ថុ និងសមត្ថភាព-បច្ចេកទេស សំរាប់វិនិយោគ និងពង្រីកសេវាកម្ម គឺមានការកំណត់ណាស់។ ក្នុងឋានានុក្រមនេះ គឺមានលំបាកបំផុត សំរាប់អាជ្ញាធរក្នុងតំបន់ ធ្វើការផ្ទាល់ជាមួយអ្នកភូមិ ទោះជាយ៉ាងណាក៏ដោយ ប្រធានភូមិមានការ-ទាក់ទងប្រចាំថ្ងៃជាមួយអ្នកភូមិ ។

ទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិចាប់តាំងពីមានប្រព័ន្ធវិមជ្ឈការអំណាចមក គឺមានអំណាចមួយចំនួនបានផ្ដល់ឱ្យក្រុមប្រឹក្សាឃុំ។ ដូចនេះធនធានធម្មជាតិមួយចំនួន និងសំភារៈក្នុងស្រុក ពេលនេះត្រូវបានហូតពន្ធនៅថ្នាក់ភូមិ។ ទាំងនោះរួមមាន ការកាប់ឈើហុប ការលក់ក្របី ការផលិតស្រា ម៉ាស៊ីនកិនស្រូវ និងម៉ាស៊ីនកាណូត។ នៅក្នុងតំបន់វ៉ាមសារ ការបង់ពន្ធនេះតម្រូវឱ្យមាន។ មានឃុំមួយចំនួនដូចជា កោះស្នែង និងអូរស្វាយ អ្នកភូមិបង់ពន្ធ ៣០,០០០រៀល ឱ្យទៅក្រុមប្រឹក្សាឃុំសំរាប់ឈើហុបមួយម៉ែត្រគីប កាប់ពីព្រៃតាមការអនុញ្ញាត។ ទាក់ទងនឹងការកាប់ឈើ ក្រុមប្រឹក្សាឃុំ ចង់ផ្ដល់សិទ្ធិផ្ដាច់មុខឱ្យមនុស្សមួយក្រុម ឬគ្រួសារមួយដើម្បីកាប់ឈើលក់ឱ្យអ្នកភូមិ ឬដែលគេហៅថា ធ្វើឯកជនតូបនីយកម្មធនធានធម្មជាតិក្នុងមូលដ្ឋាន (Try, ២០០៤) ។



នៅកោះស្នែង ដែននេសាទមួយចំនួន ធ្លាប់បានលក់ឱ្យឯកជនអូសអួន ពីអាជ្ញាធរខេត្ត។ តែក្រោយពីការបង្កើតក្រុមប្រឹក្សាឃុំ ការសុំអនុញ្ញាតិពីថ្នាក់ឃុំក៏ត្រូវការផងដែរ។ នេះមានន័យថា ម្ចាស់អួនត្រូវបង់លុយបន្ថែមឱ្យក្រុមប្រឹក្សាឃុំ ដើម្បីសុំសិទ្ធិ។ ដូច្នេះម្ចាស់អួនយល់ថា ពួកគេមានសិទ្ធិនេសាទផ្ដាច់មុខក្នុងតំបន់ដែននេសាទទទួលបានពីឃុំ និងថ្នាក់ខេត្ត។ ហេតុនេះ ពួកគេ មិនអនុញ្ញាត ឱ្យអ្នកនេសាទមកពីតំបន់ផ្សេងៗ នេសាទនៅក្នុងតំបន់របស់គេទេ ហើយការចែកផលនេសាទឱ្យអ្នកភូមិ ក៏លែងមានដែរ។

ដំណើរការនេះ បានបង្កើននូវជម្លោះ រវាងអ្នកនេសាទមូលដ្ឋានដែលគ្មានសិទ្ធិ ជាមួយអ្នកអូសអួន និងម្ចាស់ដីសម្បទានដែលទទួលសិទ្ធិផ្ដាច់មុខ ទៅលើធនធានទាំងនោះ។ បទពិសោធន៍នេះបង្ហាញថា របបវិមជ្ឈការនៃអំណាច គឺមិនបានអមដោយមូលនិធិ ការបណ្ដុះបណ្ដាល ឬកសាងសមត្ថភាពឱ្យគ្រប់គ្រាន់ទេ ក្នុងចំណោមមន្ត្រីដែលទទួលខុសត្រូវការអនុវត្តន៍ គោលនយោបាយទាំងនេះ។ គោលនយោបាយ អាចខកខានក្នុងការអនុវត្តតាម ឬអនុវត្តផ្ទុយពីអ្វីដែលបានចែង ដែលអ្នកបង្កើតគោលនយោបាយចង់បាននោះ។

## ការចូលរួមរបស់សាធារណៈជន

ពាក្យថា **ការចូលរួម** ត្រូវបានកំណត់អត្ថន័យ និងប្រើតាមរបៀបផ្សេងគ្នាដោយអ្នកស្រាវជ្រាវអ្នកធ្វើផែនការ និងរដ្ឋបាល ។ ធម្មជាតិនៃការចូលរួម ក្នុងដំណើរការអភិវឌ្ឍន៍ បង្កើតឱ្យមានរឿងចំរុងចំរាសច្រើនទាក់ទងនិងនិយមន័យ ព្រោះពុំទាន់មានការទទួលស្គាល់ជាសកលនៅឡើយ។ ការចូលរួមរបស់អ្នកក្រ តាមរយៈអង្គការក្នុងស្រុករបស់ខ្លួន បានផ្ដល់ប្រយោជន៍មិនត្រឹមតែពួកគេទេ គឺថែមទាំងផ្ដល់ដល់រដ្ឋបាលរបស់រដ្ឋាភិបាលផងដែរ។ ផលប្រយោជន៍ទ្វេរនេះ បានជួយសម្រួលការអភិវឌ្ឍន៍ជនបទ សំរាប់ហេតុផលជាច្រើន (Vannaren, 2002) ដូចមានពន្យល់ដូចតទៅ:

Vannaren, 2002 បានស្នើលក្ខណៈ៣យ៉ាងរបស់ការចូលរួមដែលទាក់ទងជាមួយការអភិវឌ្ឍន៍ជនបទ: អ្វី? អ្នកណា ? និង ដោយរបៀបណា ?

- អ្វី និយាយដល់ប្រភេទនៃការចូលរួម ឧទាហរណ៍ ការស្ទាបស្ទង់ ការបោះឆ្នោត និងគណៈកម្មការ។
- អ្នកណា ជាពិសេសពិពណ៌នាពីអ្នកចូលរួមដូចជា អ្នកស្រុក អ្នកដឹកនាំ បុគ្គលិករដ្ឋាភិបាល និងបុគ្គលិកអន្តរជាតិ
- ដោយរបៀបណា ទាក់ទងនឹងរបៀបដែលការចូលរួមអនុវត្តឡើង ។

នៅតំបន់រ៉ាមសារ បញ្ហានៃការចូលរួមពីសាធារណៈក្នុងការអភិរក្ស (ត្រីព្រៃឈើ និងអនុផលព្រៃឈើ ។ល។) មានភាពសាំញ៉ាំច្រើន។ ទោះជាយ៉ាងណា គឺមានវិធីជាច្រើនសំរាប់សាលារៀនតាមមូលដ្ឋាន អ្នកជំនួញ (រួមមាន ម្ចាស់ផ្ទះ សំណាក់ និងអ្នកនាំភ្ញៀវទេសចរណ៍) ព្រះសង្ឃ ចាស់ទុំភូមិ និងប្រជាជនផ្សេងៗទៀតដែលបារម្ភណ៍ពីអនាគតធនធានធម្មជាតិ អាចចូលរួមបានតាមរយៈកិច្ចប្រឹងប្រែងរួមគ្នា។ មានភូមិជាច្រើនបានអនុវត្តវិធានការគ្រប់គ្រងធនធានធម្មជាតិរបស់គេយ៉ាងសកម្ម ដូចជាតាមរយៈការបង្កើតសហគមន៍នេសាទដែលមានកិច្ចជំនួយពីអង្គការសេចា៉ និងអង្គការ ស៊ីអេអេ។

យោងតាមកាសិក្សាស្តីពីសហគមន៍នេសាទ លោកវ៉ាណ្ណារ៉េន (២០០២) បានវែកញែកថាកត្តាជាច្រើនដែលមានឥទ្ធិពល លើការចូលរួមសាធារណៈជន រួមមានកត្តាសង្គម សេដ្ឋកិច្ច និងស្ថាប័ន។ ទី១ កត្តាសង្គមរួមមាន២ចំណែកសំខាន់ៗៈ ការអប់រំ និងទំហំគ្រួសារ។ ប្រជាជនដែលមានការសិក្សាតិច ពាក់ព័ន្ធនឹងសកម្មភាពគម្រោងតិចជាងអ្នកដែលមានការសិក្សាខ្ពស់។ ការសិក្សារកឃើញថា គ្រួសារកាន់តែធំ មានការចូលរួមការប្រជុំកាន់តែច្រើន ហើយមានការផ្តល់យោបល់កាន់តែច្រើននៅក្នុងការប្រជុំផ្តល់កំលាំងពលកម្មកាន់តែច្រើនព្រមទាំងពាក់ព័ន្ធការវាយតំលៃគម្រោងកាន់តែច្រើន។ ទី២ កត្តាសេដ្ឋកិច្ច ដោយរួមមានទំហំដី ប្រាក់ចំណូលគ្រួសារប្រចាំឆ្នាំ និងការរកត្រីបាន ឬផលប្រយោជន៍ពីធនធាននៅតំបន់ដីសើម។ ទី៣ កត្តាស្ថាប័ន គឺជាកត្តាបង្កើតការលើកទឹកចិត្ត ឬឧបសគ្គសំរាប់ការចូលរួមរបស់ប្រជាជន ដូចជាគោលនយោបាយ និងការគាំទ្របច្ចេកទេស សេវាបណ្តុះបណ្តាលជលផល ការផ្សព្វផ្សាយ និងការលើកទឹកចិត្ត ។

សង្ខេបមកវិញ ការចូលរួមសាធារណៈនៅក្នុងខេត្តស្ទឹងត្រែង មានលក្ខណៈសកម្មណាស់។ មនុស្សជាច្រើនដែលពាក់ព័ន្ធការធ្វើអាជីវកម្មធនធាន និងការគ្រប់គ្រង បានចូលរួមការប្រជុំ សិក្ខាសាលា និងការពិភាក្សា ។ ប៉ុន្តែ ការសំរេចចិត្ត គឺនៅស្ថិតក្នុងដៃក្រុមអ្នកមានអំណាច។ ក្នុងន័យនេះ ការរៀបចំការគ្រប់គ្រងធនធានធម្មជាតិដែលពឹងផ្អែកលើសហគមន៍ ត្រូវគេជឿថា តំណាងឱ្យគំរូល្អបំផុតសំរាប់ការចូលរួមសាធារណៈ។ គោលគំនិតនៃការបង្កើតគណៈកម្មការសហគមន៍នេសាទ ឬព្រៃឈើ គឺដើម្បីបញ្ចូលសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធផ្សេងទៀត នៅក្នុងការគ្រប់គ្រងធនធានក្នុងមូលដ្ឋាន ដែលទង្វើនេះ នឹងធានានូវនិរន្តរភាព។ តែទោះជាយ៉ាងណា អ្នកភូមិនៅតែត្រូវការជំនួយពីខាងក្រៅ ដើម្បីគាំទ្រនូវជោគជ័យទាំងនេះ។

## អ្នកពាក់ព័ន្ធសំខាន់ៗ

អ្នកពាក់ព័ន្ធ គឺជាក្រុមមនុស្ស (ដូចជា អ្នកមូលដ្ឋាន អ្នកទេសចរណ៍ ) ឬទីភ្នាក់ងារ (ដូចជារដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ឬផ្នែកឯកជន) ដែលពាក់ព័ន្ធ ឬមានការចាប់អារម្មណ៍នឹងអ្វីដែលកំពុងកើតឡើង ឬនឹងកើតឡើងនៅ ក្នុងតំបន់រ៉ាមសារ នៅអនាគត។ អ្នកដែលមានការពាក់ព័ន្ធ និងរងគ្រោះជាងគេ គឺប្រជាជន

មូលដ្ឋានរស់នៅទីនោះ ចំណែកភ្នាក់ងារដទៃទៀតគឺចាប់អារម្មណ៍ក្នុងការលើកស្ទួយ និងអភិវឌ្ឍន៍ តែប្រយោជន៍ពួកគេតែប៉ុណ្ណោះ។ ជាការពិតណាស់ គេអាចធ្វើទៅបានក្នុងការឆ្លើតតបនឹងបំណងប្រាថ្នារបស់អ្នកពាក់ព័ន្ធទាំងអស់ ប៉ុន្តែជម្លោះនឹងកើតឡើង ប្រសិនបើគោលបំណង របស់ពួកគេមិនសមរម្យ។ ក្នុងករណីនេះ ការពិគ្រោះយោបល់ និងសម្របសម្រួល ពិតជាត្រូវការដើម្បីស្វែងរកការឯកភាពគ្នា។

ប្រជាជនចំនួន១៣,០០០នាក់ នៃតំបន់រ៉ាមសារ គឺជាអ្នកពាក់ព័ន្ធសំខាន់បំផុត។ ពួកគាត់ភាគច្រើនទទួល បានម្ហូបអាហារដោយផ្ទាល់ពីតំបន់នេះ ហើយតម្រូវការជាច្រើនទៀតពីធនធានធម្មជាតិ ដែលអាចរកបានដូចជាការលក់ធនធានទាំងនេះ ដើម្បីរកចំណូលសំរាប់ទិញសម្ភារៈ។ ប៉ុន្តែចំណូលរបស់ពួកគេ នៅទាបនៅឡើយ ហើយធនធានទាំងនេះអាស្រ័យលើការប្រែប្រួលធនធានធម្មជាតិ និងការថយចុះដោយសារអាជីវកម្មហួសកម្រិតដូចជា ការប្រមាញ់សត្វជាដើម។ វាជាការត្រឹមត្រូវដែលថា អ្នកភូមិតំបន់រ៉ាមសារពាក់ព័ន្ធពេញលេញនឹងរបៀបដែលតំបន់នេះត្រូវគ្រប់គ្រង និងអភិវឌ្ឍន៍។ ពួកអ្នកស្រុក អាចជាអ្នកដែលប្រឈមមុខការបាត់បង់ច្រើន បើសិនធនធានទាំងនោះត្រូវបានបំផ្លាញដោយការអភិវឌ្ឍន៍ មិនត្រឹមត្រូវដូចជា ការសង់វារីអគ្គិសនី ប្រព័ន្ធស្រោចស្រពទ្រង់ទ្រាយធំ និងកសិកម្មប្រពលវប្បកម្ម។

អ្នកភូមិតំបន់រ៉ាមសារ មានវិធីផ្សេងៗសំរាប់បង្ហាញចំណូលចិត្តរបស់ខ្លួនក្នុងការអភិវឌ្ឍន៍។ ក្នុងនោះមានដូចជា មានផែនការអភិវឌ្ឍន៍ភូមិ សហគមន៍នេសាទ គណៈកម្មការសហគមន៍ព្រៃឈើ និងការពិភាក្សាជាមួយភ្នាក់ងាររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការនៅតំបន់នោះ។ ការពិភាក្សាបែបនេះ គួរតែធ្វើឡើងឱ្យបានពេញលេញ និងស្មោះត្រង់ ។ គោលគំនិតនោះ គឺថារាល់គំរោងអភិវឌ្ឍន៍ ដែលប្រឆាំងនឹងបំណងប្រាថ្នាមនុស្សភាគច្រើននឹងមិនត្រូវអនុញាតនោះទេ។ ការយល់ព្រមជាឯកច្ឆ័ន្ទពីអ្នកភូមិតំបន់រ៉ាមសារ ទំនងជាមានភាពខុសគ្នាមួយចំនួនទាក់ទងនិងគំនិតយោបល់។

ទាំងថ្នាក់ជាតិ និងថ្នាក់ខេត្តរបស់ស្ថាប័នរដ្ឋ គឺមានផលប្រយោជន៍ស្របច្បាប់នៅតំបន់រ៉ាមសារ។ ថ្នាក់ទាំងពីរប្រាថ្នាជំរុញគោលបំណងរបស់ខ្លួន និងអនុវត្តគោលនយោបាយជាតិ។ មន្ទីរដែលពាក់ព័ន្ធភាគច្រើន គឺមន្ទីរបរិស្ថាន (ទទួលខុសត្រូវចំពោះតំបន់ការពារ) នាយកដ្ឋានជលផល (ការគ្រប់គ្រងធនធានត្រី) រដ្ឋបាលព្រៃឈើ (សំរាប់ការអភិរក្សសត្វរុក្ខជាតិ និងការគ្រប់គ្រងព្រៃឈើ)។ មន្ទីរនៅខេត្តស្ទឹងត្រែង ភាគច្រើនមានទំនាក់ទំនងស្និទ្ធ នឹងតំបន់រ៉ាមសារ។ សមត្ថភាពរបស់មន្ទីរទាំងនេះ នៅទាបនៅឡើយ និងមិនមានធនធានមនុស្សគ្រប់គ្រាន់ទេ។ ចំណែកធនធានបច្ចេកទេស និងហិរញ្ញវត្ថុសំរាប់អនុវត្តគោលបំណងដែលបានដាក់ចេញតាមរយៈថ្នាក់ជាតិ ក៏នៅខ្សោយផងដែរ។ ចំណុចខ្សោយទាំងនេះ ជាឧបសគ្គធំចំពោះការអភិវឌ្ឍន៍ និងគ្រប់គ្រងតំបន់រ៉ាមសារ។ មន្ទីរផ្សេងៗទៀតដែលមានការចាប់អារម្មណ៍តិចតួចនៅពេលនេះ (ឧទាហរណ៍ មន្ទីរធនធានទឹក និងឧត្តុនិយម, ឧស្សាហកម្មរ៉ែ និងថាមពល និងមន្ទីរទេសចរណ៍) នៅពេលខាងមុខ នឹងមានសារៈសំខាន់ក្នុងគម្រោងវារីអគ្គិសនី ជីករ៉ែ ប្រព័ន្ធស្រោចស្រព និងទេសចរណ៍ ។

មានអង្គការមិនមែនរដ្ឋាភិបាលចំនួនពីរ ដែលពាក់ព័ន្ធខ្លាំងនៅតំបន់រ៉ាមសារ គឺអង្គការសេប៉ា និង-ស៊ីអេអេ។ អង្គការទាំងពីរនេះ បានបង្កើតគម្រោងសហគមន៍នេសាទ និងគម្រោងសហគមន៍ព្រៃឈើ ហើយថែមទាំងធ្វើការបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងធនធានធម្មជាតិ។ គម្រោងទាំងនេះមានសារៈសំខាន់ណាស់

និងត្រូវតែបន្តនៅពេលអនាគត។ អង្គការទាំងពីរ មានការទាក់ទងនឹងជីវភាពរស់នៅដែរដូចជាកសិកម្ម។ អង្គការមិនមែនរដ្ឋាភិបាលផ្សេងៗទៀត ដូចជា អង្គការដៃគូសំរាប់អភិវឌ្ឍន៍ បានបំពេញតួនាទីសំខាន់ផ្នែកសុខភាពអនាម័យ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធភូមិ។ បើមិនមានជំនួយពីអង្គការមិនមែនរដ្ឋាភិបាលទេ ក្តីសង្ឃឹមរបស់អ្នកភូមិតំបន់វ៉ាមសារ នឹងត្រូវរលាយសាបសូន្យ ។

បច្ចុប្បន្ននេះ ផ្នែកឯកជនមានការពាក់ព័ន្ធតិចជាមួយតំបន់វ៉ាមសារ។ ផលប្រយោជន៍សំខាន់របស់ផ្នែកនេះគឺការអភិវឌ្ឍន៍ទេសចរណ៍ ជាពិសេសការអភិវឌ្ឍន៍សណ្ឋាគារ និងសកម្មភាពផ្សេងៗដែលពាក់ព័ន្ធ។ ផ្នែកឯកជនគួរតែត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងការអភិវឌ្ឍន៍នៅតំបន់នោះ ប៉ុន្តែត្រូវមានការពិភាក្សាជាមួយអ្នកស្រុកនៅទីនោះ ជាមួយរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល។

អ្នកពាក់ព័ន្ធសំខាន់ផ្សេងៗទៀត គឺជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ (ដូចជា IUCN, WCS, WWF) ដែលមានផលប្រយោជន៍ជំរុញការប្រើប្រាស់ប្រកបដោយនិរន្តរភាពរបស់តំបន់វ៉ាមសារ និងការថែរក្សា ឬធ្វើឱ្យប្រសើរសំរាប់ជីវៈចម្រុះ។ ភ្នាក់ងារទាំងនោះ ផ្តល់មូលនិធិដល់គម្រោងផ្សេងៗតាមតម្រូវការរបស់គេ ប៉ុន្តែអង្គការ IUCN មានការពាក់ព័ន្ធផ្ទាល់តិចតួច ជាមួយតំបន់វ៉ាមសារ។ តួនាទីរបស់អង្គការ IUCN ត្រូវបានបកស្រាយលំអិតនៅជំពូកទី១។ អង្គការនេះសង្ឃឹមថា ក្នុងពេល៥ឆ្នាំទៀត ខ្លួនគេនឹងមានឥទ្ធិពលខ្លាំង ចំពោះអ្វីដែលនឹងកើតមាននៅតំបន់វ៉ាមសារ។ ដើម្បីឱ្យមានប្រសិទ្ធិភាពសំរាប់រយៈពេលវែង អង្គការ IUCN ត្រូវបង្កើនតួនាទី និងធ្វើការជាមួយអង្គការដែលមានសមត្ថភាពក្នុងចំណោមអ្នកភូមិ និងធ្វើការជាមួយភ្នាក់ងាររដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ខេត្ត ។

ជាទូទៅ មន្ត្រីរដ្ឋាភិបាលមូលដ្ឋាន និងអភិបាលខេត្ត អាចគាំទ្រការគ្រប់គ្រងសហគមន៍ធនធានធម្មជាតិ។ បើពុំមានអំណាច ឬគោលនយោបាយគាំទ្រជាក់លាក់ទេ ពួកគេនឹងមានការស្ទាក់ស្ទើរក្នុងការអនុវត្ត ទោះបីបញ្ហាទាំងនេះ បានបើកចំហក្នុងការពិភាក្សាថ្នាក់ខេត្ត ស្រុក ឃុំ ឬភូមិក៏ដោយ។ ចំពោះហេតុផលនេះ វាពិតជាមានសារៈសំខាន់ ក្នុងការទាក់ទាញការគាំទ្រមិនផ្លូវការបែបបុគ្គល ទៅលើប្រព័ន្ធគ្រប់គ្រងធនធានដោយសហគមន៍ ឬបង្កើតការគាំទ្រដោយអ្នកតាក់តែងច្បាប់។ នេះហើយជាមូលហេតុ ដែលអង្គការសេដា និងអង្គការស៊ីអេអេ មានសារៈសំខាន់ក្នុងតំបន់វ៉ាមសារ។

ជាថ្មីម្តងទៀតលោក Bryant និង Bailey (1997) បានបង្ហាញថា ការប្រើប្រាស់ធនធាន ទ្រព្យសម្បត្តិសារធារណៈ ដូចជាត្រី ព្រៃឈើ គឺទាក់ទងនឹងបញ្ហាចំនួនពីរៈ សិទ្ធិដកហូតធនធានដោយបើកចំហ នឹងមិនត្រូវអនុញ្ញាត ដោយមានប្រព័ន្ធត្រួតពិនិត្យតឹងរឹង បង្កើតឡើងដោយសហគមន៍ ហើយអ្នកខាងក្រៅសហគមន៍ នឹងមិនត្រូវអនុញ្ញាតទេ។ យោងតាមទ្រឹស្តីរបស់ Bromley (1991) បានវែកញែកថា ទ្រព្យសម្បត្តិសារធាណៈ តំណាងឱ្យទ្រព្យសម្បត្តិឯកជន សំរាប់ក្រុមអ្នកជាម្ចាស់ (ព្រោះថា អ្នកមកពីខាងក្រៅតំបន់ ត្រូវបានផាត់ចេញ ពីការប្រើប្រាស់ និងការសម្រេចចិត្ត)។ ទី២ ការប្រើប្រាស់ធនធាន និងការសម្រេចចិត្តអាស្រ័យលើការត្រួត ពិនិត្យពីអ្នកមូលដ្ឋាន ដែល-អាចសម្រួលឱ្យមានការកែប្រែការអនុវត្តន៍ ទៅតាមលក្ខខ័ណ្ឌសង្គម និងបរិស្ថានប្រែប្រួល។ ទី៣ ធនធានទាំងនេះមិនមែនជាវត្ថុនឹងថ្កល់នៅតាមទីកន្លែង ឬពេលវេលានោះទេ គឺវាអាស្រ័យនឹងលក្ខខ័ណ្ឌបរិស្ថាន និងជំលោះសង្គមរវាងអ្នកពាក់ព័ន្ធ។ ទី៤ ធនធានដែលមានលក្ខណៈចែករំលែក បានផ្តល់នូវមធ្យោបាយ ស្ថាប័នបត់បែនមួយ -

ដែលអ្នកមូលដ្ឋានអាចផ្តុំគ្នានូវការប្រើប្រាស់ធនធាន និងការអភិរក្ស។

ដរាបណាការអភិរក្សបរិស្ថាននៅតែជាអាទិភាពខ្ពស់សំរាប់អ្នកពាក់ព័ន្ធទាំងអស់ ដោយចាប់តាំងពីថ្នាក់ភូមិរហូត ដល់ថ្នាក់ជាតិ ដរាបនោះអនាគតរបស់តំបន់រ៉ាមសារ នឹងក្លាយជាសុទ្ធិនិយមមួយ។ ប្រសិនបើ មាន-ផ្នែកណាមួយខកខាន ឬធ្វើឱ្យធនធានធម្មជាតិវិចវិល ពេលនោះអនាគតប្រជាជនតំបន់រ៉ាមសារ នឹងមិនភ្លឺស្វាងទេ។ ទោះបីប្រជាជនតំបន់រ៉ាមសារ ជាអ្នកពាក់ព័ន្ធសំខាន់បំផុត ក៏ពួកគេមិនជាអ្នកមានអំណាចបំផុតដែរ ហើយផលប្រយោជន៍របស់ពួកគេ នឹងមិនត្រូវអើពើ ក្នុងការសម្រេចនូវគោលដៅរបស់ខ្លួន។

## សង្ខេប

ធនធានធម្មជាតិដូចជា ត្រី ព្រៃឈើ ទឹក ដីវាលស្មៅ និងតំបន់ផ្សេងៗទៀត គឺងាយរងគ្រោះនៅពេលដែលពួកវាស្ថិតនៅស្ថានភាពបើកចំហ ព្រោះមនុស្សតែងតែបង្កើនការដកហូតធនធានឱ្យបានច្រើន ដែលអាចធ្វើបាន។ ផ្ទុយទៅវិញ ប្រសិនបើ រដ្ឋគ្រប់គ្រងធនធានធម្មជាតិទាំងនោះផ្តាច់មុខ វានឹងបណ្តាលឱ្យមានការដកហូតធនធានហួសកម្រិត និងបដិសេធ សិទ្ធិប្រជាជន ដែលធ្លាប់មាន តាំងពីបុរាណមក។ ដើម្បីដោះស្រាយបញ្ហានេះ គឺតម្រូវឱ្យមានស្ថាប័នមួយដែលខ្លាំងសំរាប់ត្រួតពិនិត្យ ការប្រើប្រាស់អភិរក្ស និងដកហូតធនធានដោយនិរន្តរភាព។

នៅប្រទេសកម្ពុជា ក្របខ័ណ្ឌស្ថាប័នរដ្ឋ និតិវិធីការងារ និងប្រព័ន្ធរដ្ឋបាលត្រូវបានបង្កើតឡើងបែបប្រព័ន្ធគ្រប់គ្រងវៀតណាម ដែលណែនាំនៅទសវត្សរ៍ទី៨០។ រចនាសម្ព័ន្ធផ្លូវការរបស់ប្រព័ន្ធគ្រប់គ្រងរដ្ឋ អនុវត្តតាមឋានានុក្រម ពីថ្នាក់ជាតិ ខេត្ត ស្រុក ឃុំ ភូមិ និងក្រុម ។ គណបក្សប្រជាជន ជាបក្សដែលមានឥទ្ធិពលលើសគេក្នុងខ្សែបណ្តាញឋានានុក្រមទាំងអស់ ។

ដោយសារបញ្ហានេះ ការណែនាំប្រព័ន្ធអភិបាលកិច្ច និងការធ្វើវិមជ្ឈការអំណាចតាមមូលដ្ឋាន បានក្លាយជារឿងភាន់ច្រឡំ ហើយជួនកាលបណ្តាលឱ្យមានជម្លោះរវាងអ្នកប្រើប្រាស់ធនធានធម្មជាតិទៀតផង។ កត្តាទាំងនេះបណ្តាលមកពីភាពមិនស្មើគ្នា នៃ ទំនាក់ទំនងអំណាចរបស់អ្នកពាក់ព័ន្ធ ប្រព័ន្ធច្បាប់ដែលហួសសម័យ ហើយមានច្បាប់ និងអនុក្រិត្យជាច្រើនទៀត ស្ថិតនៅក្នុងស្ថានភាពជាសេចក្តីព្រាងនៅឡើយ។ ការទទួលខុសត្រូវរបស់ស្ថាប័ននីមួយៗ គឺមិនបានចែងច្បាស់លាស់ ហើយស្ថាប័នទាំងនេះពុំមានថវិកាការបណ្តុះបណ្តាលគ្រប់គ្រាន់ និងកង្វះខាតមន្ត្រីជំនាញ ដែលអនុវត្តគោលនយោបាយទាំងនេះ។ នៅខេត្តស្ទឹងត្រែង គំរោងកម្មវិធី ដូចជាសហគមន៍នេសាទ សហគមន៍ព្រៃឈើ និងគំរោងអភិរក្ស តំបន់ដីសើមដោយផ្អែកលើសហគមន៍ គឺកំពុងតែមានដំណើរការ។ គំរោងទាំងនេះ បានទទួលស្វាគមន៍ពីអ្នកពាក់ព័ន្ធទាំងអស់ ប៉ុន្តែដោយសារពុំមានច្បាប់ទទួលស្គាល់ច្បាស់លាស់ អាជ្ញាធរមូលដ្ឋានមានការស្ទាក់ស្ទើរក្នុងការគាំទ្រឱ្យបានពេញលេញ ។

# ជំពូក៧:     ការវិភាគ

## សេចក្តីផ្តើម

នៅក្នុងជំពូកនេះ នឹងបកស្រាយការវិភាគទៅលើភាពងាយរងគ្រោះ ហានិភ័យ និងការគំរាមកំហែងដល់ការចិញ្ចឹមជីវិត និងធនធានធម្មជាតិ នៅក្នុងតំបន់រ៉ាមសារ។ ជាទូទៅ ទង្វើទាំងនេះមានទំនាក់ទំនងគ្នាទៅវិញទៅមក ដោយសារការចិញ្ចឹមជីវិតពឹងផ្អែកយ៉ាងខ្លាំងទៅលើតំបន់ ដែលអាចដកហូតបាននូវធនធានរូប និងធនធានជីវៈចម្រុះធម្មជាតិ។ ម្យ៉ាងទៀត ធនធានទាំងនេះក៏ត្រូវបានពិចារណារ ជាឱកាសសំរាប់ការគ្រប់គ្រង និងការអភិវឌ្ឍន៍ទៅអនាគតនៃតំបន់ ដោយរួមទាំងតម្រូវការនៃការស្រាវជ្រាវបន្ថែម និងឱកាសសំរាប់អន្តរាគមន៍បន្ថែមទៀតរបស់កម្មវិធី MWBP។

### ភាពងាយរងគ្រោះ

តំបន់រ៉ាមសារ បានផ្តល់វត្ថុស្ទើរតែគ្រប់យ៉ាង ដែលប្រជាជនមូលដ្ឋានត្រូវការ ដូចជា ថាមពលអុសសំរាប់ដាំស្ល និងកំដៅរុក្ខជាតិ និងសត្វព្រៃសំរាប់ឱសថបុរាណ ឈើសំរាប់ធ្វើផ្ទះ គ្រឿងសង្ហារឹម និងសាងសង់គ្រឿងបរិភោគដូចជា ស្រូវ អង្ករ សាច់ ផ្លែឈើ និងបន្លែ ទឹកសំរាប់បោកគក់ និងច្បារដំណាំ ខ្សាច់ និងគ្រួសសំរាប់កសាងអាគារ ផ្លូវទឹកសំរាប់មធ្យោបាយ ធ្វើដំណើរផ្នែកពាណិជកម្ម និងផ្ទាល់ខ្លួន និងការកំសាន្តជាដើម។ ធនធានទាំងនេះ បានផ្តល់នូវតម្រូវការប្រចាំថ្ងៃភ្លាមៗ ហើយប្រជាជនជាច្រើនបានលក់ ដើម្បីយកថវិកាមកទិញសំលៀកបំពាក់ វត្ថុសំរាប់ដាក់ផ្ទះសម្បែង សំភារៈនេសាទ ថ្លៃទូកដរ សំរាប់សាលារៀន និង ។ល។ ចំពោះអ្នកភូមិភាគច្រើនយល់ថា តំបន់រ៉ាមសារជាព្រភពតែមួយនៃការចិញ្ចឹមជីវិតដែលមាន។

តែទោះជាយ៉ាងណា ប្រាក់ចំណូល និងកម្រិតជីវភាពរស់នៅ គឺនៅទាប។ ប្រជាជនភាពច្រើននៃតំបន់រ៉ាមសារ ស្ថិតក្នុងស្ថានភាពក្រីក្រ និងងាយរងគ្រោះទៅនឹងការស្រុតចុះ នូវធនធានធម្មជាតិដែលមានស្រាប់។ បច្ចុប្បន្ន មានបញ្ហាមួយចំនួន ដែល អាចធ្វើឱ្យប្រជាជនមូលដ្ឋានងាយរងគ្រោះ ទៅនឹងបញ្ហាប្រែប្រួលអវិជ្ជមាន។

តម្រូវការសំខាន់បំផុត គឺស្រូវ។ រាល់ផលិតផលស្រូវ គឺអាស្រ័យលើទឹកភ្លៀង ហើយទិន្នផលមានកម្រិតទាបជាងគេបំផុតនៅទ្វីបអាស៊ី។ បច្ចុប្បន្ន គឺពុំទាន់មានភាពខ្វះខាតដីស្រែ ដែលកំពុងដាំតាមវាលស្រែក្នុងភូមិឬក្បែរភូមិ ឬតាមវាលស្រែ បណ្តោះអាសន្ន ដែលបានមកពីការរានដីព្រៃថ្មី។ ទិន្នផលស្រូវ ងាយរងគ្រោះដោយសារអាកាសធាតុប្រែប្រួល ដោយរួមទាំង ទឹកជំនន់ និងការរាំងស្ងួត ដែលបណ្តាលឱ្យមានការបាត់បង់ទិន្នផលទាំងស្រុង ឬមួយផ្នែកធំ។  ដោយសារគ្រួសារភាគច្រើន បានធ្វើកសិកម្ម ទៅលើផ្ទៃដីដែលអាចផ្តល់នូវតម្រូវការគ្រប់គ្រាន់ប្រចាំឆ្នាំ ហេតុដូច្នេះប្រសិនបើមានការខូចខាត ឬបាត់បង់ ទិន្នផល វាពិតជាមានគ្រោះថ្នាក់ខ្លាំង។

ហេតុដូច្នេះ ផលិតផលស្រូវ គឺងាយរងគ្រោះចំពោះបម្រែបម្រួលអាកាសធាតុប្រចាំឆ្នាំ និងបម្រែបម្រួលអាកាសធាតុ ដែលអាចកើតមាននាពេលអនាគត។ បម្រែបម្រួលនេះ ត្រូវបានព្យាករណ៍ បណ្តាលឱ្យមានកំណើនសីតុណ្ហភាព និងបម្រែបម្រួលលំនាំទឹកភ្លៀងនៅក្នុងតំបន់រ៉ាមសារ។

ផលិតផលស្រូវ ក៏ងាយរងគ្រោះផងដែរទៅនឹងការបាត់បង់ផ្ទៃដី ដែលបានកើតឡើងតាមរយៈតម្រូវការរបស់ក្រុមហ៊ុនឯកជន (ឃុំអូរស្វាយ) ឬការសង់ផ្លូវ ឬការទិញ/លក់ដីនៅឃុំសាមគ្គី។ ការបាត់បង់ផលិតផលស្រូវបណ្តាលឱ្យមានផលវិបាកជាច្រើនដល់គ្រួសាររងគ្រោះ ដូចជាការថយចុះនូវការផ្គត់ផ្គង់ស្បៀងអាហារ ថវិកាដែលមានសំរាប់ចំណាយលើអង្ករ ដោយរួមទាំងតម្រូវការផ្សេងៗ គឺមិនអាចរ៉ាប់រងបាន ( ឧ. បង់ថ្លៃសាលារៀន ថ្នាំពេទ្យជាដើម) សំពាធបន្ថែមទៅលើធនធានផ្សេងៗ ដូចជាមច្ឆាជាតិ សត្វព្រៃ និងអនុផលព្រៃឈើ។

ជីវភាពរស់នៅ ងាយរងគ្រោះចំពោះការថយចុះផលិតផលត្រី។ យោងតាមភស្តុតាងចងក្រងនៅតំបន់រ៉ាមសារ ជាច្រើនបានឱ្យដឹងថាធនធានមច្ឆាថយចុះ ដែលជាធម្មតាបណ្តាលមកពីការនេសាទខុសច្បាប់ ដូចជាការប្រើគ្រឿងផ្ទុះ បំពុល និងការឆក់ ដោយរួមទាំងវិធីសាស្ត្រនេសាទបែបបំផ្លាញជាច្រើនប្រភេទទៀត ដូចជាទំលាយ ទឹកពីព្រែក អូរ ត្រពាំង ដើម្បីចាប់ ត្រី និងការដាក់មងកាត់ទទឹងព្រែក។ ការថយចុះធនធាននេះ អាចបណ្តាលមកពីកំណើនប្រជាជន ដូចជាកំណើនចំនួនអ្នកនេសាទផលចាប់ត្រីជាមធ្យមក្នុងគ្រួសារថយចុះ។ ការថយចុះផលចាប់ត្រីដែលជាប្រភពប្រូតេអ៊ីនសំខាន់បំផុតបាន ធ្វើឱ្យប្រជាជនងាយរងគ្រោះដល់សុខភាព បញ្ហាកង្វះអាហាររូបត្ថម្ភ និងការថយចុះចំនួនលក់នៅទីផ្សារ និងការបាត់បង់ថវិកា សំរាប់សេវាកម្ម និងទំនិញសំខាន់ៗជាដើម។ ដោយមានការថយចុះនូវផលិតផលស្រូវ ការថយចុះផលនេសាទ ក៏អាចបង្កើននូវសំពាធទៅលើ ធនធានធម្មជាតិផ្សេងៗផងដែរ។

ប្រជាជនរស់នៅតំបន់រ៉ាមសារ ជាទូទៅមានកម្រិតវប្បធម៌ទាប ដែលជាប្រភពងាយរងគ្រោះផងដែរ។ ដោយសារ ការប្រែប្រួលផ្នែកបច្ចេកវិទ្យា និងឱកាសការងារថ្មីៗកើតឡើង បានធ្វើឱ្យប្រជាជនជាច្រើនមានស្ថានភាពលំបាកក្នុងការឆក់យកឱកាសការងារទាំងនេះ។ ពួកគេ ប្រឈមនឹងការច្រានចោលពីការអភិវឌ្ឍន៍ ហើយការងារថ្មីៗ នឹងត្រូវឆក់យកពីអ្នកមកពីខេត្តផ្សេងៗនៃប្រទេស។ ប្រសិនបើប្រជាជនទាំងនេះ ចាកចេញពីភូមិកំណើត ដើម្បីឆក់យកការងារថ្មី (ជាទូទៅការងារ គ្មានជំនាញ និងមានប្រាក់ឈ្នួលតិច) ពេលនោះការបាត់បង់កំលាំងពលកម្ម នឹងក្លាយជាផលវិបាកធ្ងន់ធ្ងរ ចំពោះគ្រួសារអ្នកធ្វើស្រែ-ចំការ និងនេសាទ។ ហេតុដូច្នេះ របរចិញ្ចឹមជីវិតបែបបុរាណ និងទំនាក់ទំនងក្នុងភូមិ នឹងងាយរងគ្រោះចំពោះបម្រែបម្រួលអភិវឌ្ឍ ដែលបានស្នើឡើងនៅខេត្តស្ទឹងត្រែង។

សត្វព្រៃ និងធនធានផ្សេងៗទៀត ក៏មានភាពងាយរងគ្រោះផងដែរ។ ការបរបាញ់ពពួកថនិកសត្វ សត្វស្លាប និង ពពួកល្មូន គឺបានរីកសាយ និងពេញនិយមនៅក្នុងតំបន់រ៉ាមសារ។ ភស្តុតាងមានស្រាប់បានស្នើថាមានប្រភេទសត្វក្នុង មូលដ្ឋានមួយចំនួនបានផុតពូជ ហើយប្រភេទសត្វជាច្រើនទៀត បានថយចុះតាមរយៈ ការបរបាញ់។ ប្រជាជន ធ្វើការបរបាញ់ ដើម្បីធ្វើជាចំណី និងលក់នៅតាមមូលដ្ឋាន ឬលក់ឱ្យឈ្មួញកណ្តាលយកថវិកា។ មកដល់ពេលនេះ គឺគ្មានហេតុផលដែលបង្ហាញថា ការបរបាញ់សត្វព្រៃ នឹងមានការថយចុះនៅអនាគត។ តែផ្ទុយទៅវិញ វាទំនងជាមានការកើនឡើង ដោយសារកំណើនប្រជាជន និងធនធានមច្ឆាថយចុះ។

អនុផលព្រៃឈើ និងធនធានវារីតំបន់ដីសើម (ឧ. រុក្ខជាតិ ប្រភេទគ្រាំផ្សេងៗ) អាចទទួលនូវភាពងាយរងគ្រោះ ដោយសារសំពាធបន្ថែម និងការដកហូតធនធានហួសកម្រិត បណ្តាលមកពីកំណើនប្រជាជន និងធនធានធម្មជាតិផ្សេងៗទៀតថយចុះ ហើយឱកាសក្នុងការប្រើប្រាស់ដីព្រៃមួយចំនួនត្រូវបានហាមឃាត់ពីក្រុមហ៊ុនឯកជន

។ ការថយចុះធនធានទាំង នេះនឹងមានឥទ្ធិពលអាក្រក់ដល់ប្រជាជនតំបន់រ៉ាមសារ តាមរយៈការកាត់បន្ថយចំនួនបរិភោគផ្ទាល់ខ្លួន ដូចជា ផ្លែឈើ បន្លែ ថ្នាំពេទ្យ ។ល។ និង ការលក់ដូរ ដូចជា ជ័រទឹក និងទឹកឃ្មុំជាដើម។

មច្ឆាជាតិ និងធនធានវារីផ្សេងៗទៀត គឺមានភាពងាយរងគ្រោះខ្លាំង ចំពោះការផ្លាស់ប្តូរបរិមាណ និងគុណភាពទឹកទន្លេមេគង្គ។ ការផ្លាស់ប្តូរទាំងនេះ អាចកើតឡើងជាបណ្តើរៗ តាមរយៈបម្រែបម្រួលអាកាសធាតុ ហើយនឹងប្រែប្រួលខ្លាំងតាមរយៈការកសាងវារីអគ្គិសនី ប្រព័ន្ធធារាសាស្ត្រ និងការកាប់ឈើ។

ការអភិវឌ្ឍន៍បែបនេះ ត្រូវបានស្នើឡើងនៅតាមដងទន្លេមេគង្គទាំងមូល និងដៃនានារបស់វា។ ការថយចុះបរិមាណ និងគុណភាពទឹក អាចជាផលវិបាកយ៉ាងខ្លាំងដល់ប្រព័ន្ធអេកូឡូស៊ី ការធ្វើបំលាស់ទី និងពងកូនរបស់មច្ឆាជាតិព្រមទាំងបរិមាណរបស់វា។ ការផ្លាស់ប្តូរទាំងនេះ អាចជាគ្រោះថ្នាក់ដល់ប្រជាជនរស់នៅតំបន់រ៉ាមសារ ព្រោះវាមិនអាចគ្រប់គ្រងបាន។

ព្រៃលិចទឹកទន្លេមេគង្គ ក៏អាចរងគ្រោះផងដែរចំពោះការផ្លាស់ប្តូរលំហូរទឹកបណ្តាលមកពីគំរោងអភិវឌ្ឍន៍ ឬ បម្រែបម្រួលអាកាសធាតុ។ បច្ចុប្បន្ន ចំនួន និងទំហំព្រៃឈើដែលមាន គឺនៅមានលំនឹងជាមួយនឹងលក្ខណៈលំហូរទឹក។ ប្រសិនបើលំហូរទឹកមានការប្រែប្រួលខ្លាំង ចំនួនព្រៃឈើក៏មានការប្រែប្រួលដែរ។ ប្រសិនបើកម្រិតទឹកហូរទាប មានរយៈពេលយូរជាងធម្មតា ពេលនេះព្រៃលិចទឹកទាំងនោះនឹងមានលក្ខណៈស្ងួត ហើយសារៈសំខាន់របស់វាសំរាប់ប្រព័ន្ធអេកូឡូស៊ី និងការពងកូនរបស់មច្ឆាថយចុះ។ លើសពីនេះទៅទៀត តម្លៃទាក់ទាញទេសភាពរបស់ព្រៃលិចទឹកទាំងនេះ នឹងត្រូវបាត់បង់សំរាប់ការអភិវឌ្ឍន៍ វិស័យទេសចរណ៍នៅពេលអនាគត។

## ហានិភ័យ និងការគំរាមកំហែង

ហានិភ័យ និងការគំរាមកំហែង ដល់តំបន់រ៉ាមសារ គឺបណ្តាលមកពីការបន្ត នៃនិន្នាការបច្ចុប្បន្ន គំរោងអភិវឌ្ឍន៍អនាគត សមត្ថភាពទាបរបស់ប្រជាជន ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធភូមិលំបាក និងសមត្ថភាពរបស់មន្ទីររដ្ឋាភិបាលទាប។ និន្នាការបច្ចុប្បន្នរួមមានធនធានធម្មជាតិ (ជាពិសេសសត្វព្រៃ) និងផលនេសាទថយចុះ។ ការបន្តថយចុះ នៃចំនួនសត្វព្រៃទំនងជាមិនអាចជៀសផុត ព្រោះវាមានសារៈសំខាន់សំរាប់ការបរិភោគ និងការបង្កើតចរិកាតាមមូលដ្ឋាន។ ដោយសារ សត្វព្រៃថយចុះ ដូច្នេះ តំលៃសំរាប់អ្នកភូមិក៏ថយចុះផងដែរ ទាក់ទងនឹងអាហារ និងបាត់បង់ចរិកា។ លើសពីនេះទៅទៀត តំលៃថ្នាក់ជាតិនៃតំបន់រ៉ាមសារ ចំពោះការថយចុះជីវៈចម្រុះ និងសមត្ថភាពប្រទេសកម្ពុជា ទៅនឹងកាតព្វកិច្ចអន្តរជាតិរបស់ខ្លួន សំរាប់ការការពារសត្វព្រៃ គឺត្រូវថយចុះ។ សក្តានុពលវិស័យទេសចរណ៍ របស់តំបន់នឹងត្រូវធ្លាក់ចុះផងដែរ។

ការធ្លាក់ចុះជាសំខាន់នូវបរិមាណត្រី អាចជាគ្រោះថ្នាក់សំរាប់តំបន់រ៉ាមសារផងដែរ។ នេះគឺជាហានិភ័យប្រាកដមួយ ដែលបណ្តាលមកពីការដកហូតធនធានធម្មជាតិហួសកម្រិត តាមរយៈកំណើនប្រជាជន វិធីសាស្ត្រនេសាទខុសច្បាប់ និងការផ្លាស់ប្តូរប្រព័ន្ធជលសាស្ត្រទន្លេមេគង្គ និងដៃនានារបស់វាតាមរយៈទំនប់វារីអគ្គិសនី ប្រព័ន្ធធារាសាស្ត្រ ការកាប់ព្រៃឈើ និងការបំពុលផ្សេងៗពីសំណើគំរោងឧស្សាហកម្ម។ ការថយចុះនូវធនធានណាមួយ គឺមិនត្រឹមតែមានឥទ្ធិពលទៅលើតំបន់រ៉ាមសារ គឺសំរាប់ប្រទេសកម្ពុជាទាំងមូល ព្រោះទន្លេមេគង្គជុំវិញ

ខេត្តស្ទឹងត្រែង គឺជាសំបុកត្រីពងកូន សំរាប់ត្រីបឹងទន្លេសាប។

ប្រភេទរុក្ខជាតិ នៃទន្លេមេគង្គ ជាពិសេសព្រៃលិចទឹក ក៏ស្ថិតនៅក្នុងស្ថានភាពហានិភ័យ និង-ការគំរាមកំហែង នៃការផ្លាស់ប្តូរ របបជលសាស្ត្រនៅក្នុងទន្លេ។ បញ្ហានេះ អាចបណ្តាលមកពីការស្នើនូវគំរោងអភិវឌ្ឍន៍វារីអគ្គិសនី តាមដងទន្លេមេគង្គ ភាគខាងលើ។ ទង្វើនេះ អាចផ្លាស់ប្តូរលំហូរទឹកបច្ចុប្បន្ន ដែលអាចឱ្យព្រៃលិចទឹករស់បាន ហើយដែលមិនអាចគេចផុតពីការប្រែប្រួលផងដែរ។ តំលៃបច្ចុប្បន្នរបស់ព្រៃលិចទឹក ជាកន្លែងពង-កូនរបស់មច្ឆា នឹងត្រូវថយចុះ និងផលប៉ះពាល់អវិជ្ជមាន ដល់ប្រជាជនមូលដ្ឋាន និងផលិត-ផលថ្នាក់ជាតិ។

បច្ចុប្បន្ន ដោយសារកម្រិតវប្បធម៌ទាប និងអត្រាអនក្ខរជនខ្ពស់ របស់ប្រជាជនរស់នៅតំបន់រ៉ាមសារ វាជាការគំរាមកំហែងផងដែរ ដល់សមត្ថភាពរបស់ពួកគេក្នុងការស្រូបយកបច្ចេកវិទ្យា និងឱកាសការងារថ្មីៗ។ ចំពោះឱកាសការងារអាចធ្លាក់ទៅលើអ្នកដែលមកពីខាងក្រៅទៅវិញ។ សេណារីយ៉ូដែលអាក្រក់បំផុត គឺថានៅពេលដែលធនធានមច្ឆា និងធនធានផ្សេងៗថយចុះ ពេលនោះវានឹងបណ្តាលឱ្យប្រជាជនតំបន់រ៉ាមសារកាន់តែក្រ ចំពោះអ្នកដែលមិនអាចសម្របខ្លួនទៅនឹងឱកាសថ្មីៗ ដែលបានកើតឡើងនៅទីនោះ។

ផ្ទុយទៅវិញ ទង្វើនេះអាចជាសំពាធទៅលើធនធានធម្មជាតិ និងការធ្វើចំណាកស្រុកទៅកាន់ទីក្រុង ដើម្បីស្វែងរកការងារ។ ហេតុដូច្នេះ ការបាត់បង់ចំនួនមនុស្សនៅក្នុងភូមិណាមួយ អាចជាភាពគ្រោះថ្នាក់ដល់គុណភាពនៃជីវិតក្នុងភូមិ និងជាការគំរាមកំហែងដល់អត្តសញ្ញាណក្នុងភូមិផងដែរ។

ចំពោះហេដ្ឋារចនាសម្ព័ន្ធ និងកម្រិតអភិវឌ្ឍន៍ទាបក្នុងភូមិ អាចជាការគំរាមកំហែងផងដែរទៅអនាគត របស់ប្រជាជនមូលដ្ឋាន។ ជាពិសេស ប្រព័ន្ធផ្លូវថ្នល់មានការលំបាក ដែលប្រជាជនភាគច្រើនពឹងផ្អែកលើប្រព័ន្ធដឹកជញ្ជូនផ្លូវទឹក។ បញ្ហានេះ មានការយឺតយ៉ាវដល់ការដឹកទំនិញ និងមនុស្សដែលមានតម្លៃខ្ពស់ថែមទៀត។ នៅពេលដែលរបបទឹកទន្លេមានកម្រិតទាប ការធ្វើចរាចរតាមផ្លូវទឹកមានការលំបាកនៅតាមផ្នែកមួយចំនួននៃតំបន់រ៉ាមសារ។

ចំពោះភូមិដែលស្ថិតនៅតាមបណ្តោយច្រាំងទន្លេមេគង្គភាគខាងលិច និងតាមកោះនានា មានការលំបាកខ្លាំង ដោយសារប្រព័ន្ធគមនាគមន៍ដែលពឹងផ្អែកទាំងស្រុងទៅនឹងទន្លេ។ ផ្ទុយទៅវិញ នៅតាមច្រាំងទន្លេភាគខាងកើត ដែលផ្លូវថ្នល់ថ្មីកំពុងតែកសាងឡើងវិញ ស្ថានភាពធ្វើដំណើរ គឺមានភាពប្រសើរជាង។ តែទោះជាយ៉ាងណាគ្រប់ភូមិទាំងអស់ពុំមានភ្លើងអគ្គិសនី បុស្តិ៍ប្រៃណីយ៍ និងប្រព័ន្ធទូរស័ព្ទទេ។ បញ្ហាទាំងនេះ បានរាំងស្ទះដល់ការធ្វើពាណិជ្ជកម្មខ្នាតតូចនៅក្នុងតំបន់។ ដោយយោងទៅតាមភាពដាច់ស្រយ៉ាល នៃភូមិមួយចំនួនក្នុងតំបន់រ៉ាមសារ បញ្ហាហេដ្ឋារចនាសម្ព័ន្ធទាំងនេះ ទំនងជានឹងត្រូវកែលំអរនាពេលអនាគត។

ដោយសារប្រជាជនតំបន់រ៉ាមសារ ប្រកបរបរចិញ្ចឹមជីវិតមួយគ្រប់ៗ ហេតុដូច្នេះពួកគេមិនសូវមានធនធានហិរញ្ញវត្ថុ ច្រើនទេ។ នៅតាមភូមិ ពុំទាន់មានសេវាកម្មធនាគារ ហើយការខ្ចីឥណទានបានអនុវត្តឡើងតាមរយៈបុគ្គលដែលមានការប្រាក់ខ្ពស់។ សមត្ថភាពក្នុងការខ្ចីប្រាក់ ដើម្បីពង្រឹងជីវភាពរស់នៅ គឺនៅមានកម្រិតខ្លាំង។ បញ្ហានេះ គឺជាការគំរាមកំហែងមួយដែរដល់សមត្ថភាពសំរាប់ឆក់ឱកាសដែលមាននៅក្នុងតំបន់។

បច្ចុប្បន្ន សមត្ថភាពភ្នាក់ងាររដ្ឋាភិបាលដើម្បីជួយដល់អ្នកភូមិ គឺមានកម្រិតទាប ដែលជាការគំរាមកំហែង និងហានិភ័យផងដែរ ដល់ការអភិវឌ្ឍន៍ភូមិ។ ចំពោះធនធានហិរញ្ញវត្ថុ និងបច្ចេកទេសរបស់មន្ទីររដ្ឋាភិបាល ដូចជា បរិស្ថាន ជលផល រុក្ខាប្រមាញ់ និងកសិកម្មនៅមានកម្រិតទាប ក្នុងការជួយអ្នកភូមិផ្នែកបណ្តុះបណ្តាល ជំនាញ ថវិកាសំរាប់ធ្វើទុន ទំនិញ និងសំភារៈផ្សេងៗ។ ស្ថានភាពនេះ នឹងពុំមានការផ្លាស់ប្តូរនាពេលអនាគត ទោះបីជាគោលនយោបាយជាតិសំរាប់ឧបត្ថម្ភបញ្ហាទាំងនេះ ត្រូវបានផ្តល់ក៏ដោយ។ សកម្មភាពអភិវឌ្ឍន៍កម្រិតភូមិ ស្ទើរទាំងអស់ ត្រូវបានអនុវត្តដោយអង្គការមិន មែនរដ្ឋាភិបាល ដែលស្ថានភាពនេះ បានកាត់បន្ថយសំពាធទទួលខុសត្រូវរបស់រដ្ឋាភិបាលមួយចំនួនផងដែរ។

## ឱកាសផ្សេងៗ

ការកំណត់នៃភាពងាយរងគ្រោះហានិភ័យ និងការគំរាមកំហែងដល់តំបន់រ៉ាមសារ និងប្រជាជនរស់នៅក្នុងតំបន់បានផ្តល់នូវវិធីនៃការស្វែងរកនូវឱកាសលុបបំបាត់ ឬកាត់បន្ថយបញ្ហាទាំងនេះ។



តម្រូវការចាំបាច់ គឺការបង្កើននូវទិន្នផលស្រូវ និងបង្កើនប្រសិទ្ធភាព សហគមជលផល និងព្រៃឈើ។ ជម្រើសទីមួយ គឺជាការទទួលខុសត្រូវរបស់មន្ទីរកសិកម្ម ហើយជម្រើសបន្ទាប់អាចជាការប្រឹងប្រែងរួមគ្នារវាងអង្គការមិនមែនរដ្ឋាភិបាល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការពង្រឹងនូវវិស័យទាំងនេះ ជាជំនួយដ៏ធំមួយដែលអាចផ្តល់ដល់ប្រជាជន។ តម្រូវការទាំងនេះ ទាមទារនូវពេលវេលា (ជាច្រើនឆ្នាំ) ឯកទេស និងធនធានហិរញ្ញវត្ថុ និងបច្ចេកទេស។

ដោយសារធនធានធម្មជាតិ ទំនងជាថយចុះ អ្នកភូមិទាំងនេះ នឹងត្រូវបង្កើតនូវរបរចិញ្ចឹមជីវិតបែបថ្មី។ ពួកគេត្រូវការជំនួយដើម្បីអនុវត្ត ដូចជាការកំណត់នៃមុខរបរ/ការងារអាជីវកម្មថ្មី ការបណ្តុះបណ្តាល និងការផ្តល់នូវធនធានហិរញ្ញវត្ថុ និងបច្ចេកទេសជាដើម។ ឱកាសចុងក្រោយអាចជាការផ្តល់នូវកម្ចី ឬឥណទានពីអង្គការមិនមែនរដ្ឋាភិបាល ដោយរួមទាំងការផ្តល់នូវឱកាសទទួលប្រាក់កម្ចីពីស្ថាប័នហិរញ្ញវត្ថុថែមទៀត។ ដើម្បីជួយអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធតាមភូមិ គឺត្រូវកែលំអរមធ្យោបាយធ្វើដំណើរ ការផ្គត់ផ្គង់ថាមពល និងផ្លូវគមនាគមន៍ជាដើម។ ការស្វែងរកឱកាសថ្មីគួររួមបញ្ចូលផលិតផលតំបន់ដីសើម និងតំលៃបន្ថែមទៅនឹងផលិតផលមានស្រាប់ ដូចជាផ្លែឈើ និងបន្លែដោយការកែច្នៃដាក់ដប និងការរក្សាទុកជាដើម។

ចំពោះការអភិវឌ្ឍនូវឱកាសចិញ្ចឹមជីវិតបែបថ្មី ជាពិសេសទាក់ទងនឹងកសិឧស្សាហកម្ម គួរមានលក្ខណៈសមស្រប ទៅនឹងសមត្ថភាពប្រើប្រាស់ដីធ្លីរបស់ភូមិ/ឃុំ។ បញ្ហានេះ ពុំសូវមានការចាប់អារម្មណ៍នាពេលបច្ចុប្បន្ន ប៉ុន្តែវាអាចវាយតំលៃតាមរយៈការប្រើប្រាស់ដីធ្លី និងការសិក្សាពីសមត្ថភាពដី។ វាអាចជាឱកាសមួយសំរាប់ផ្តល់នូវគ្រឿងបរិក្ខាបូមទឹកសំរាប់វិស័យកសិកម្ម ដែលអាចយកទឹកពីក្រោមដី ឬពីទន្លេ។ បច្ចុប្បន្ន ភូមិដែលនៅក្នុងតំបន់រ៉ាមសារ សំបូរទៅដោយប្រភពទឹក ដែលកម្រទាញយកមកប្រើសំរាប់ហេតុផលពាណិជកម្ម។

ដោយសារផលស្តុកត្រី និងផលនេសាទមានការថយចុះ ហេតុដូច្នេះឱកាស និងតម្រូវការសំរាប់វារីវប្បកម្មនឹងកើតឡើង។ ទង្វើនេះ គួរគិតពិចារណារទៅលើឯកទេសនៅក្នុងប្រទេសកម្ពុជា ដែលអង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នរដ្ឋអាចរួមគ្នាធ្វើការ។ ការអភិវឌ្ឍន៍បែបនេះ អាចត្រូវការនូវម៉ាស៊ីនបូមទឹក។

ឱកាសមួយទៀតក្នុងការអភិវឌ្ឍន៍ជីវភាពរបស់នៅ គឺតាមរយៈវិស័យទេសចរណ៍។ តំបន់រ៉ាមសារ មានសក្តានុពលច្រើនទាក់ទងនឹងវិស័យនេះ ដែលបច្ចុប្បន្នពុំសូវមានការយល់ដឹងច្រើន។ បច្ចុប្បន្ន អាចធ្វើការពិចារណារទៅលើសត្វផ្សោតរស់នៅតាមព្រំដែនកម្ពុជា-ឡាវ ទាំងតំលៃអភិរក្ស និងទេសចរណ៍។ នៅពេលខ្លះជម្រើសចុងក្រោយ ត្រូវបានផ្តល់តំលៃហួស ជាការកំសាន្តមើលទេសភាព ដែលជាទូទៅមិនសូវញឹកញាប់ និងពីចំងាយ។ ភាពទាក់ទាញផ្សេងទៀតរបស់ទន្លេ ដែលគេមិនសូវយកចិត្តទុកដាក់ គឺមានតំបន់ទឹកជូរព្រៃលិចទឹក បក្សី ភូមិដ៏ចាប់អារម្មណ៍ ទេសភាព និងឆ្នេរទន្លេជាដើម។ ដោយសារធនធានទាំងនេះ ទើបធ្វើឱ្យតំបន់រ៉ាមសារមានការទាក់ទាញពិត។ ហើយដែលត្រូវការអភិវឌ្ឍន៍រួមគ្នារវាងអង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នរដ្ឋ វិស័យឯកជន និងអ្នកភូមិដោយផ្ទាល់។

ប្រការនេះតម្រូវឱ្យមាន និងជាឱកាសដើម្បីធ្វើការបណ្តុះបណ្តាលគ្រប់កម្រិត។ ជាពិសេស អ្នកភូមិត្រូវការជំនួយ (រដ្ឋបាល និងបច្ចេកទេស) ជាមួយនិងការបង្កើតនូវជីវភាពថ្មី និងការគ្រប់គ្រងគំរោងសហគមន៍ជលផល និងព្រៃឈើ។ បើពុំមានជំនួយ បែបនេះទេ វានឹងក្លាយជាភាពមិនប្រាកដនិយមសំរាប់ពួកគេទទួលយក និងទទួលបានជោគជ័យ។ ចំពោះស្ថាប័នរដ្ឋ ក៏ត្រូវការបង្កើននូវសមត្ថភាពរបស់ខ្លួន។ ប្រសិនបើបញ្ហានេះមិនត្រូវបានដោះស្រាយទាំងប្រជាជនតាមមូលដ្ឋាន និងមន្ត្រីថ្នាក់ខ្ពស់ដោយរួមទាំងជំនួយស្តួចស្តើងពីរដ្ឋាភិបាល ដែលមានបច្ចុប្បន្ននឹងត្រូវបន្ត ហើយការអភិវឌ្ឍន៍ភូមិនឹងក្លាយជាឧបសគ្គ។

មន្ត្រីរដ្ឋាភិបាល ក៏ត្រូវការបណ្តុះបណ្តាលធនធាន និងការលើកទឹកចិត្តបន្ថែមផងដែរ ដើម្បីអនុវត្តនូវច្បាប់សត្វព្រៃដែលមានស្រាប់។ មន្ត្រីទាំងនោះ រួមមាន ប៉ូលីស គយ កងកំលាំងប្រដាប់អាវុធតាមព្រំដែន។ ការបណ្តុះបណ្តាល ក៏ជាបញ្ហាមួយផងដែរ។ មានមន្ត្រីជាច្រើន ប្រហែលជាយល់ដឹងច្បាស់ពីច្បាប់ ប៉ុន្តែមិនបានត្រៀមអនុវត្តទេ។

មានឱកាសជាច្រើនសំរាប់អភិរក្សសត្វព្រៃ តែការយល់ដឹងគឺជាការលំបាក។ ការបរបាញ់សត្វជាកត្តាបណ្តាឱ្យថយចុះចំនួនសត្វព្រៃ ដែលទង្វើនេះបានកើតមានរាលដាលក្នុងតំបន់រ៉ាមសារ។ បុព្វហេតុ អាចបណ្តាលមកពីភាពក្រីក្រ និងអាកប្បកិរិយា មិនថែរក្សាសត្វព្រៃជាទូទៅ។ បញ្ហានេះ មានការលំបាកក្នុងការលុបបំបាត់។ ប៉ុន្តែជម្រើសអាចធ្វើទៅបាន តាមរយៈការអភិវឌ្ឍន៍វិស័យទេសចរណ៍ដែលជាវិធីល្អបំផុតក្នុងការការពារសត្វព្រៃក្នុងតំបន់រ៉ាមសារ និងការយល់ដឹងពីតំលៃពាណិជ្ជកម្មសត្វព្រៃក្រៅពីលក់នៅទីផ្សារមូលដ្ឋាន និងបរទេស។

## ភាពចន្លោះប្រហោងនៃការស្រាវជ្រាវ

ព័ត៌មានស្តីពីជលសាស្ត្រ ដោយរួមទាំងគុណភាពទឹក របស់ទន្លេមេគង្គតំបន់រ៉ាមសារ និងដៃទន្លេសំខាន់ៗរបស់វា គឺជាចន្លោះដ៏សំខាន់ នៅក្នុងចំណេះដឹងបែបវិទ្យាសាស្ត្រ។ ដោយមានការអនុវត្ត នៃសំណើគំរោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី ប្រព័ន្ធធារាសាស្ត្រ ការកាប់ព្រៃឈើ និងគំរោងឧស្សាហកម្មនៅអនាគត ជាហេតុធ្វើឱ្យ

មានការផ្លាស់ប្តូរលំហូរទន្លេដែលមិនអាចជៀសវាងបាន។ នេះទំនងជាការពិត ដែលការផ្លាស់ប្តូរទាំងនេះនឹងកើតមានដោយពុំមានចំណេះដឹងគ្រប់គ្រាន់ ទាក់ទងនឹងផលប៉ះពាល់ទៅលើធនធានជលផលសត្វព្រៃ និងប្រជាជន។ មានការសិក្សាតិចតួច ស្តីពីប្រព័ន្ធអេកូឡូស៊ីរបស់ត្រី ប្រភេទរុក្ខជាតិ និងសត្វដែលពិបាកនឹងព្យាករណ៍នូវផលប៉ះពាល់ណាស់។ តែទោះជាយ៉ាងណា ជាទូទៅប្រភេទជីវៈចម្រុះទាំងនេះ មានការបន្សាំបានទៅនៅកម្រិតលំហូរ និងគុណភាពទឹកនាពេលបច្ចុប្បន្ន។ ការប្រែប្រួលចម្បងមួយចំនួននឹងបណ្តាលឱ្យមានការផ្លាស់ប្តូរផងដែរ ចំពោះអ្នកដែលពឹងអាស្រ័យទៅលើការនេសាទ និងបរបាញ់សត្វព្រៃ។

ម្យ៉ាងទៀត មានព័ត៌មានតិចតួចផងដែរ ទាក់ទងនឹងដីជាតិដី និងសមត្ថភាពប្រើប្រាស់ដីនៅតំបន់វ៉ាមសារ។ ប្រសិនបើមានព័ត៌មានទាំងនោះ វានឹងអាចប្រើដើម្បីជួយកំណត់ឱកាសជីវភាពថ្មីនៅក្នុងភូមិ ដោយធ្វើការថ្លឹងថ្លែងនូវគំរោងសមស្របទៅនឹងសមត្ថភាពធនធានធម្មជាតិនៅទីនោះ។ ប្រសិនបើមាននូវព័ត៌មានទាំងនេះ យើងអាចប្រើជាជំនួយក្នុងការកំណត់នូវឱកាសថ្មីៗនៃរបរចិញ្ចឹមជីវិតនៅក្នុងភូមិ និងវិភាគទៅលើការប្រកួតប្រជែងរបស់គំរោងដែលមានជាមួយនឹងលទ្ធភាព នៃធនធានធម្មជាតិទាំងនេះ។

ការកើតឡើងនូវប្រភេទសត្វមួយចំនួន ពុំសូវមានគេស្គាល់ ទាក់ទងធនធានវារី ប្រភេទសត្វឥតឆ្អឹងកង និងប្រភេទ សត្វមានឆ្អឹងកងដែលរស់នៅលើគោក។ សូម្បីតែពពួកអំបូរប្រភេទ ដែលគេស្គាល់ច្រើន (ឧរង្គសត្វ បក្សី ពពួកល្មូន និងបច្ឆា) ក៏ព័ត៌មានដែលអាចទទួលបាន មានតិចតួចមិនលើសពីតារាងឈ្មោះ នៃប្រភេទទាំងនេះ។ ម្យ៉ាងទៀតព័ត៌មានលំអិតនៃតម្រូវការប្រព័ន្ធអេកូឡូស៊ីប្រភេទទាំងអស់ គឺស្ទើរតែពុំមានគេដឹងឮ។

បញ្ហាស្រដៀងគ្នានេះដែរ គឺមានព័ត៌មានតិចតួច ស្តីពីការកើតឡើង និងរបាយអំបូររុក្ខជាតិក្នុងតំបន់វ៉ាមសារ។ ជាថ្មីម្តងទៀត គឺមានព័ត៌មានតិចតួច មិនលើសពីតារាងស្តីពីប្រភេទនេះ។ វាជាការប្រសើរផងដែរ ដើម្បីស្គាល់ឱ្យបានច្រើន នូវប្រភេទរុក្ខជាតិ ដូច្នេះតំបន់ដែលមានសារៈសំខាន់ ងាយស្រួលក្នុងការការពារ និងគ្រប់គ្រងប្រសិនបើត្រូវការ។

ម្យ៉ាងទៀតក៏មានព័ត៌មានតិចតួច ស្តីពីប្រភេទ និងសារៈសំខាន់នៃការប្រមូលអនុផលព្រៃឈើ និងធនធានវារី តំបន់ដីសើមនៅក្នុងតំបន់វ៉ាមសារ។ ធនធានទាំងនេះ ជាប្រភពអាហារ ថ្នាំពេទ្យយ៉ាងសំខាន់ និងសំភារៈសំរាប់ការបរិភោគ និងលក់យកថវិកា។ វាជាការប្រសើរដើម្បីស្គាល់ពីប្រភេទ និងតំលៃរបស់ផលិតផលទាំងនេះ និងទីកន្លែងប្រភពដែលត្រូវប្រមូល។ ប្រសិនជាចាំបាច់ ការការពារ និងគ្រប់គ្រងនឹងត្រូវផ្តល់ជូនចំពោះតំបន់ដែលមានសារៈសំខាន់ក្នុងការប្រមូលអនុផលទាំងនេះ។

## អន្តរាគមន៍របស់កម្មវិធី MWBP

ដោយផ្អែកលើការពិភាក្សាលើកមុន មានតំបន់មួយចំនួនដែល MWBP អាចចូលរួម។ តំបន់ខ្លះត្រូវបានគេស្នើសុំរួចហើយ នៅក្នុងគំរោងការងាររយៈពេល៥ឆ្នាំ និងមានការពិភាក្សាបន្ថែមច្រើនទៀត។

បញ្ហាមួយ គឺទេសចរណ៍ធម្មជាតិ។ តំបន់វ៉ាមសារ មានសក្តានុពលយ៉ាងច្រើនចំពោះវិស័យនេះ ដែលនៅក្នុងពេលបច្ចុប្បន្នស្ទើរតែមិនត្រូវបានគេយកមកប្រើទាល់តែសោះ។ តំបន់នេះមានចំណុចទាក់ទាញចម្រុះ ជា

គោលការណ៍មួយនោះ គឺជាផ្ទាំងទស្សនីយភាព ព្រៃលិចទឹក កោះនានា កន្លែងឆ្នេរខ្សាច់ ពពួកហ្វូងបក្សី និងមច្ឆាជាច្រើនប្រភេទ និងវិធីសាស្ត្រនេសាទតាមបែបប្រពៃណី ដងទន្លេផ្ទាល់ ដោយមានទឹកគួច តំបន់ទឹកជួរ អន្លង់ជ្រៅ និងឆ្នេរទន្លេ សត្វផ្សោតចម្រុះ រុក្ខជាតិគ្រប់ប្រភេទ ទឹកន្លែងដ៏មានតម្លៃ នៃទន្លេមេគង្គ និងរបបទឹកហូរចាក់ ដូចជាអូរតាឡាស់ និងអន្លង់សត្វផ្សោតទន្លេ ដែលស្ថិតនៅក្រៅការថែរក្សា។ សរុបមក ទាំងនេះបានផ្តល់នូវធនធានដ៏អស្ចារ្យ សំរាប់សកម្មភាព ដូចជាការជិះទូកកំសាន្ត ការថតរូប ការមើលសត្វ បក្សី ការបោះជំរុំកំសាន្ត ការហែលទឹក ការដើរកំសាន្ត និងការដើរព្រៃ។ លើសពីនេះទៀត មានភូមិប្រពៃណី ដែល-អាចធ្វើជាទីស្នាក់នៅពេលយប់ និងទស្សនាការសម្តែង សកម្មភាពជាប្រពៃណីផ្សេងៗទៀត។

ដើម្បីអភិវឌ្ឍន៍ធនធានទាំងនេះ តំរូវអោយមានធនធានដ៏មានជំនាញពីអ្នកឯកទេស។ តំរូវការដ៏សំខាន់មួយ គឺជាព័ត៌មាន ការផលិតខិត្តប័ណ្ណ ដ៏មានគុណភាពខ្ពស់ ប័ណ្ណផ្សព្វផ្សាយ,សៀវភៅព័ត៌មានស្តើងៗ...។ល។ សំរាប់ការទាក់ទាញទាំងនេះ។ បច្ចុប្បន្ន អ្នកទេសចរណ៍ ដែលមកដល់តំបន់នេះ ពុំមានព័ត៌ច្រើនស្តីពីភាពទាក់ទាញ និងសារៈប្រយោជន៍របស់វា នៅពេលដែលគេធ្វើដំណើរឆ្លងកាត់ទៅកាន់ប្រទេស ឬមកទីក្រុងភ្នំពេញ។

ការចិញ្ចឹមជីវិតរបស់ប្រជាជនតំបន់រ៉ាមសារ គឺងាយរងគ្រោះទៅនឹងការផ្លាស់ប្តូរជាច្រើន។ ការផ្លាស់ប្តូរធំជាងគេ នឹងបណ្តាលមកពីតំបន់ការពារ ដូចជាគំរោងអភិវឌ្ឍន៍វារីអគ្គិសនីខ្នាតធំតាមដងទន្លេនៅប្រទេសឡាវ និងចិន ដោយរួមទាំងសំណើផែនការអភិវឌ្ឍន៍មិនច្បាស់លាស់ជាច្រើន នៅខេត្តស្ទឹងត្រែង និងរតនគីរី។ មានការបារម្ភណ៍បង្ហាញថា ការអភិវឌ្ឍន៍ទាំងនេះនឹងត្រូវចាប់ផ្តើម ដោយពុំមានការធ្វើសមាហរណកម្មផែនការ ហើយពុំសូវពេញនិយមថែមទៀត។ ផលប៉ះពាល់បរិស្ថាន ទំនងជាមិនត្រូវបានគេយកចិត្តទុកដាក់សមស្របទេ។ ដើម្បីជួយទប់ស្កាត់គំរោងដែលបំផ្លាញបរិស្ថាន កម្មវិធី MWBP គួរបង្កើតនូវយន្តការមួយដើម្បីធានាថា ផលប៉ះពាល់បរិស្ថានត្រូវបានវាយតំលៃ មុននឹងចាប់ផ្តើមអនុវត្តគំរោងទាំងនោះ។ ដំណើរការនេះ គួរតម្រូវឱ្យសំណើគំរោងអភិវឌ្ឍន៍ទាំងអស់ដាក់ជូនស្ថាប័ននេះ ដើម្បីធ្វើការត្រួតពិនិត្យ និងផ្តល់យោបល់។ ប្រសិនបើគំរោងអភិវឌ្ឍន៍ទាំងនោះ ពុំទាន់បានទទួលការត្រួតពិនិត្យ និងវាយតំលៃទេការអនុវត្តនឹងមិនត្រូវអនុញ្ញាតបានឡើយ។ នៅក្នុងករណីជាច្រើន ការអនុម័តទាំងនេះ តម្រូវឱ្យមានការរៀបចំវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលមានគុណភាពខ្ពស់។ បច្ចុប្បន្ន ស្តង់ដារនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជា គឺពុំមានភាពច្បាស់លាស់ទេ។

ភាពគ្រោះថ្នាក់ នៃការអភិវឌ្ឍន៍ទាំងនេះ នឹងផលប៉ះពាល់អាក្រក់ដល់ធនធានធម្មជាតិដែលមាន (ដូចជាព្រៃឈើ និងមច្ឆាជាតិ) ចំពោះប្រជាជនតំបន់រ៉ាមសារ និងផលប៉ះពាល់គុណភាពទឹកថែមទៀត។ ការបាត់បង់ធនធានធម្មជាតិ នឹងបង្កើនភាពងាយរងគ្រោះរបស់អ្នកភូមិនូវភាពក្រីក្រ និងការបាត់បង់របរចិញ្ចឹមជីវិត ចំណែកការចុះថយគុណភាពទឹក នឹងប៉ះពាល់ដល់ការធ្វើបំលាស់ទីទៅ-មករបស់មច្ឆាពីខេត្តស្ទឹងត្រែងទៅកាន់កន្លែងផ្សេងៗ។

សហគមន៍នេសាទ និងព្រៃឈើ គឺជាបញ្ហាចម្បងពីរ សំរាប់អ្នករស់នៅតំបន់រ៉ាមសារ។ យុទ្ធសាស្ត្រទាំងពីរព្យាយាមរក្សាធនធានជាមូលដ្ឋាន សំរាប់សុខភាព និងប្រាក់ចំណូលរបស់អ្នកភូមិ។ ផ្នែកទាំងពីរ កំពុងតែស្ថិតនៅក្រោមសំពាធនៃការអភិវឌ្ឍន៍តាមដងទន្លេ និងនៅលើគោក ដោយរួមទាំងកំណើនប្រជាជនផងដែរ។ ការធានា

នូវសិទ្ធិប្រើប្រាស់ធនធានទាំងនេះ និងកិច្ចប្រឹងប្រែងដើម្បីរក្សានិរន្តរភាពរបស់វា គឺជាអាទិភាពចម្បង។ កម្មវិធីអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាពនូវជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ (MWBP) ត្រូវតែធ្វើអ្វីៗគ្រប់យ៉ាងដែលអាចធ្វើបានដើម្បីធានាសុវត្ថិភាពធនធានទាំងនេះ។ គំរោងសហគមន៍នេសាទ និងព្រៃឈើ គឺជាផ្នែកនៃកម្មវិធីការងាររយៈពេល៥ឆ្នាំ។ ដើម្បីធានានូវប្រសិទ្ធិភាពការងារ គឺតម្រូវឱ្យមានឆន្ទៈខ្ពស់ជាមួយអង្គការដៃគូដើម្បីលើកកំពស់ការងារសហគមន៍ទាំងនេះ។ ប្រសិនបើគំរោងសហគមន៍ព្រៃឈើ និងនេសាទ ត្រូវបរាជ័យ នៅពេលនោះអ្វីៗទាំងអស់ដែលកម្មវិធី MWBP ព្យាយាមអនុវត្តនៅតំបន់បង្ហាញសាកល្បង នឹងត្រូវបរាជ័យផងដែរ។

បញ្ហាសំខាន់មួយទៀត គឺការកំណត់ព្រំដែនតំបន់រ៉ាមសារ។ បច្ចុប្បន្ន តំបន់រ៉ាមសាររួមបញ្ចូលទាំងផ្លូវទន្លេ និងកោះរបស់វា ដោយរួមទាំងផ្ទៃដីអមសងខាងទន្លេប្រមាណ៥០០ម៉ែត្រ។ នេះមិនមែនជារង្វាស់បែបធម្មជាតិទេ ព្រោះវាមិនបានរាប់បញ្ចូលដៃទន្លេប្រមាណ៤០ ដែលហូរចូលតំបន់ការពារ ឬជាផ្នែកមួយដ៏សំខាន់របស់តំបន់រ៉ាមសារ។ ស្ទឹង ព្រែក ឬអូរទាំងនេះ មានសារៈសំខាន់សំរាប់ត្រីពងកូន និងរីកធំធាត់ ហើយមានប្រភេទបក្សី ថនិកសត្វជាច្រើនពាក់ព័ន្ធនឹងតំបន់ការពារ ឬតំបន់ដែលមានព្រៃល្អទាំងនេះ។ បច្ចុប្បន្ន តំបន់រ៉ាមសារ មានតំលៃកំណត់ក្នុងការការពារ និងថែរក្សាជីវៈចម្រុះដែលរស់នៅលើគោក។

ការធ្វើអង្កេតស្រាវជ្រាវអំពីជីវៈចម្រុះដែលបានគ្រោង គួរផ្តល់ឱកាសដើម្បីពិនិត្យនូវការពង្រីកព្រំប្រទល់តំបន់រ៉ាមសារ។ នេះមិនមែនជាការគិតបែបប្រាកដនិយម ដែលថាតំបន់រងទឹកភ្លៀងទាំងអស់ អាចដាក់បញ្ចូល (ផ្ទៃដីជាច្រើនរាប់ពាន់ គីឡូម៉ែត្រក្រឡា) ដូចជាតំបន់ធំៗដែលមិនអាចគ្រប់គ្រងបាន។ ហេតុដូចនេះចំពោះសំណើពង្រីកផ្ទៃដីមិនថាជាតំបន់ស្នូល ឬជាតំបន់ទ្រនាប់ វាត្រូវតែពាក់ព័ន្ធទៅនឹងការថែរក្សាជីវៈចម្រុះ និងប្រព័ន្ធចិញ្ចឹមជីវិតទាំងអស់។

បច្ចុប្បន្ន មានកង្វះខាតព័ត៌មានត្រឹមត្រូវ ទាក់ទងនឹងគំរោងសាងសង់ប្រព័ន្ធធារាសាស្ត្រ និងវារីអគ្គិសនីដែលបានស្នើឡើងនៅតាមដងទន្លេមេគង្គ និងដៃនានារបស់វា។ គ្រប់គំរោងអភិវឌ្ឍន៍ទាំងនេះ តែងតែមានសក្តានុពល ក្នុងការបង្កើតនូវផលប៉ះពាល់អាក្រក់ទៅលើគុណភាពទឹកទន្លេ ប្រភេទរុក្ខជាតិ សត្វ មច្ឆាជាតិ និងរបរចិញ្ចឹមជីវិត។ របាយការណ៍ដែលគ្រោងបង្កើតគំរោងទាំងនេះ គួរតែមានការត្រួតពិនិត្យឡើងវិញយ៉ាងល្អិត ជាពិសេសសំរាប់ការសិក្សាប្រព័ន្ធធារទឹក និងការធ្វើសេចក្តីសំរេចចិត្ត។ នេះមានន័យថា គំរោងទាំងនេះគួរត្រូវបានត្រួតពិនិត្យឡើងវិញដោយអ្នកឯកទេសដែលមានកេរ្តិ៍ឈ្មោះល្បីជាអន្តរជាតិ។ ប្រសិនបើចាំបាច់ខ្លួនឯង គួរធានានូវការត្រួតពិនិត្យឡើងវិញគំរោងទាំងនេះ។ ប្រការនេះ អាចអនុវត្តបានជាផ្នែកមួយនៃការត្រួតពិនិត្យឡើងវិញដ៏ទំលូទំលាយ នៃការវាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់គំរោងអភិវឌ្ឍន៍ ដែលស្នើឡើង។

បច្ចុប្បន្នមានព័ត៌មានតិចតួចដែលអាចយកជាការបាន ស្តីពីការប្រមូល និងការប្រើប្រាស់អនុផលព្រៃឈើ និងផលិតផលវារី ក្រៅពីត្រីនៅក្នុងតំបន់រ៉ាមសារ និងតំបន់ដែលនៅក្បែរៗនោះ។ ផលិតផលទាំងនេះ គឺមានសារៈសំខាន់ វាជាផ្នែកមួយនៃការរកប្រាក់ចំណូល និងចិញ្ចឹមជីវិតរបស់ប្រជាជនមូលដ្ឋាន។ ហេតុដូច្នេះ កម្មវិធី MWBP គួរអនុវត្តការចុះអង្កេតស្រាវជ្រាវវាយតម្លៃ និងកំណត់នូវតំលៃទាំងនេះ ដោយរួមទាំងទីកន្លែងដែលជាប្រភពរបស់ធនធាន និងឱកាសការងារ និងពាណិជ្ជកម្មដែលធនធានទាំងនេះ ផ្តល់អោយសំរាប់បង្វៃជីវភាពរស់

នៅ។

ចំពោះអនាគត ដែលមានរយៈពេលមធ្យម និងយូរអង្វែង ប្រជាជននៅតំបន់រ៉ាមសារ ត្រូវកាត់បន្ថយនូវការពឹងពាក់ទៅលើធនធានធម្មជាតិសំរាប់ការចិញ្ចឹមជីវិត។ ភស្តុតាងដែលមានស្រាប់បានបង្ហាញថា ធនធានធម្មជាតិមានការថយចុះ ដោយរួមទាំងកំណើនប្រជាជនទៅអនាគតផងនោះ ហើយនិន្នាការនេះទំនងនឹងបន្ត។ នៅក្នុងបរិបទនេះ គំរោងចិញ្ចឹមជីវិតដែលជាជំរើសរបស់ MWBP គឺជាកត្តាចំបង។ ហេតុដូច្នេះ អនុសាសន៍ដែលទទួលបានពីការសិក្សាទាំងនេះ គួរបានអនុវត្តន៍ដោយមានការរៀបចំ និងការផ្តល់ធនធានហិរញ្ញវត្ថុ និង-បច្ចេកទេសទាំងអស់ ពីគំរោង MWBP ។

មានភស្តុតាងដែលបានកត់ត្រាមួយចំនួន បានបង្ហាញថាប្រជាជនរស់នៅតំបន់រ៉ាមសារ គឺចាប់ផ្តើមទទួលរងការលំបាក ពីភាពចុះខ្សោយរបស់អង្គការមិនមែនរដ្ឋាភិបាល។ មានការងាររបស់អង្គការមិនមែនរដ្ឋាភិបាលជាច្រើននៅក្នុងខេត្ត និងលទ្ធភាពនៃកិច្ចប្រឹងប្រែងរបស់ពួកគេ គឺមិនសូវធ្លាក់ទៅដល់ដៃប្រជាជនទេ។ ដើម្បីទប់ស្កាត់នូវភាពមន្ទិលសង្ស័យ ដែលអាចកើតឡើង គំរោង MWBP គួរតែផ្តោតទៅលើលទ្ធផលដែលអាចមើលឃើញជាក់ស្តែងភ្លាមៗ ជាជាងការចុះអង្កេតស្រាវជ្រាវបោះពុម្ពរបាយការណ៍ និងរៀបចំសិក្ខាសាលាជាដើម។ នៅក្នុងបរិបទនេះ កិច្ចផ្តួចផ្តើមអភិវឌ្ឍសហគមន៍ ដែលបានលើកឡើងដោយកម្មវិធី MWBP គួរតែមានអាទិ-ភាពខ្ពស់ ហើយមិនគួររឹតត្បិត ចំពោះគំរោងដែលពាក់ព័ន្ធផ្ទាល់ ទៅនឹងការប្រើប្រាស់តំបន់ដីសើម។ រាល់គំរោងដើម្បីបញ្ឈប់ការលំបាកដល់ការចិញ្ចឹមជីវិតនៅតាមភូមិ គួរតែជំរុញ និងលើកទឹកចិត្ត ។

## ការគ្រប់គ្រងតំបន់រ៉ាមសារ

ចំណុចរួម នៃបញ្ហាប្រឈមមុខតំបន់រ៉ាមសារ គឺតម្រូវការនូវប្រសិទ្ធភាពគ្រប់គ្រងរបស់ខ្លួន។ ករណីនេះទាមទារឱ្យមានកិច្ចសហការ និងការធ្វើសមាហរណកម្ម នៃកិច្ចប្រឹងប្រែងរវាងភ្នាក់ងាររដ្ឋាភិបាល ឯកជនអង្គការមិនមែន រដ្ឋាភិបាល និងអ្នកភូមិផ្ទាល់ខ្លួន ក្នុងការអនុវត្តផែនការអភិវឌ្ឍន៍ដែលបានបង្កើតឡើងយ៉ាងល្អ។ ការអភិវឌ្ឍន៍ទាំងនេះ តម្រូវឱ្យស្ថិតនៅក្នុងក្របខ័ណ្ឌទូទៅមួយ នៃផែនការគ្រប់គ្រង និងអភិវឌ្ឍន៍ ដែលអាចយល់ព្រមសំរាប់តំបន់រ៉ាមសារ។ ហេតុដូច្នេះ អាទិភាពទៅអនាគត គឺការបង្កើតនូវផែនការគ្រប់គ្រង ដែលមានការឯកភាពរួមមួយ។

# ឯកសារយោង


ADB. 2002.
Indigenous People/Ethnic Minority Issues and Poverty Reduction, Cambodia. Asian Development Bank. Manila, Philippines.

Ahmed, H. and Hirsh, P. 2001.
Conflict, Competition and Cooperation in the Mekong Commons: Feeding People and Protecting Natural Resources, in Ahmed, M. and Hirsh, P. (eds.) Common Property in the Mekong: Issues of Sustainability and Subsistence (pp.3-7). ICLARM, the World Fish Center. Penang.

Ashwell, D.A. 1997.
Cambodia-A National Biodiversity Prospectus: A Contribution Towards the Implementation of the Convention on Biodiversity with Particular Emphasis upon Cambodia's Terrestrial Ecosystems. Department of Nature Conservation and Protection, Ministry of Environment and IUCN. Phnom Penh.

Baird, I.G. 2001.
Aquatic Biodiversity in the Siphandone Wetlands, in Daconto, G. (ed.) Siphandone Wetlands (pp. 61-74). Environmental Protection and Community Development in Siphandone Wetlands Project. CESVI. Pakse, Lao PDR.

Baird, I. G. et al. 2002.
A Community-Based Study of the Downstream Impacts of the Yali Falls Dam Along the Se San, Sre Pok and Sekong Rivers in Stung Treng Province, Northeast Cambodia. Stung Treng, Cambodia.

BirdLife International. 2003.
Directory of Important Bird Areas in Cambodia: Key Sites for Conservation. Department of Forestry and Wildlife, Department of Nature Conservation and Protection, BirdLife International in Indochina and the Wildlife Conservation Society Cambodia Program. Phnom Penh.

Bromley, D.W. 1991.
Environment and Economy: Property Rights and Public Policy. Blackwell. Oxford.

Bryant, R. and Bailey, S. 1997.
The Third World Political Ecology. Rutledge. London.

CNMC. 2005a.
Sub-Area Analysis and Development: The Northern Cambodia-Southern Lao and Kratie Sub-Area SA-6C&8C. Cambodian National Mekong Committee. Phnom Penh.

CNMC. 2005b.
Sub-Area Analysis and Development: The Se San/Sre Pok/ Se Kong Sub-Area SA-7C. Cambodian National Mekong Committee. Phnom Penh.

Chandlers, D.1995.
Facing the Cambodian Past. OS Printing House. Bangkok.

Chong, J. 2005.
Veun Sean Village, Stung Treng Ramsar Site Cambodia: Rapid, Participatory Assessment for Wetland Valuation. IUCN, The World Conservation Union. Colombo.

Chu, T.H., Guttman, H., Droogers, P. and Aerts, J. 2003.
Water, Climate, Food and Environment Under Climate Change: The Mekong Basin in Southeast Asia. Final Report. The International Water Management Institute, Mekong River Commission secretariat and the Institute of Environmental Studies. Phnom Penh

Claasen, A. 2004.
A Tern for the Worse: Impacts of the Yali Falls Dam on Se San River Bird Populations in Cambodia. Watershed 9, 19-24.

Colm, S. 1999.
Land Rights: The Challenge for Ratanakiri's Indigenous Communities. Watershed 3 (1): 29-37

CTIA. 2002.
Consolidated ESIA Report as Integral Part of the Strategic Forestry Management Plan for Kratie/Stung Treng Forest Concession of the Everbridge CIG Wood Company Limited. Cambodia Timber Industry Association. Phnom Penh.

Cunningham, P.D. 2001.
Avian Fauna of Done Khone, in Daconto, G. (ed.) Siphandone Wetlands (pp.117-124). Environmental Protection and Community Development in Siphandone Wetlands Project. CESVI. Pakse, Lao PDR.

Cupet, P. 1898.
The Pavie Mission Indochina Papers 1879-1895-Volume 6: Travels in Lao and Among the Tribes of Southeast Indochina. Translated by Walter E.J. Tip in 2000. White Lotus, Bangkok.

Docelmascolo, G. 2004.
Vulnerability Assessment and Adaptation Framework for Stung Treng Province, Cambodia. Asian Disaster Preparedness Center. Rajabhat Institute. India.

Daconto, G. 2001a.
Siphandone Wetlands: an Overview, in Daconto, G. (ed.) Siphandone Wetlands (pp.7-23). Environmental Protection and Community Development in Siphandone Wetlands Project. CESVI. Pakse, Lao PDR.

Daconto, G. 2001b.
Siphandone Wetlands: Values and Future Challenges, in Daconto, G. (ed.) Siphandone Wetlands (pp.125-149). Environmental Protection and Community Development in Siphandone Wetlands Project. CESVI. Pakse, Lao PDR.

Danida. 2000.
Wetland Inventory in Stung Treng Province. A Collaborative Project of the Ministry of Environment with the Ministry of Agriculture Forestry and Fisheries, Ministry of Rural Development and Ministry of Water Resources and Meteorology. Phnom Penh.

de Carné, L. 1872.
Travels on the Mekong, Cambodia, Laos and Yunnan: The Political and Trade Report of the Mekong Exploration Commission (June 1866-June 1868). White Lotus Press. Bangkok. Reprinted in 2000.

Department of Fisheries. 2003a.
Strategic Plan For the Community Fisheries Development Office (CFDO). Department of Fisheries, Ministry of Agriculture, Forestry and Fisheries. Phnom Penh.

Department of Fisheries. 2003b.
Draft Sub-decree on Community Fisheries. Department of Fisheries, Ministry of Agriculture, Forestry and Fisheries. Phnom Penh.

Department of Public Work and Transportation. 2004.
Ground Breaking Ceremony on Rehabilitation Project of the National Road.7 from Kratie-Stung Treng to Cambodia-Lao Border. Phnom Penh.

Dore, J. 2003.
The Governance of Increasing Mekong Regionalism, in Kaosa-ard, M. and John Dore (eds.) Social Challenges for the Mekong Region (pp.405-440). Social Research Institute, Chiang Mai University. Thailand.

Friend, R. 2001.
A People-Centered Fisheries: Socio-economic Perspectives on the Siphandone Wetland, in Daconto, G. (ed.) Siphandone Wetlands (pp.75-88). CESVI. Pakse, Lao PDR.

Government of Vietnam. 2003.
Water Sector Program Support Sub-component 3.1: Integrated Water Resources Management for the Sre Pok River Basin. Hanoi, Vietnam.

Guérin, M. 2001.
Complementary Interrelation of Agricultural Eco-system in Stung Treng at the Beginning of the 20th Century. Aseanie 8: 35-56. ( Translated from France to English by Hubert Bahler).

Hardin, G. 1968.
The Tragedy of the Common. Science. 162:243-248.

Hirsh, P. 2000.
Managing the Mekong Commons: Local, National and Regional Issues, in Ahmed, H. and Hirsch, P. (eds.) Common Property in the Mekong: Issues of Sustainability and Subsistence (pp.19-25). ICLARM, The World Fisher Center. Penang.

Hirsh, P. and Andrew, W. 2004.
Negotiating Local Livelihoods: Scales of Conflict in the Se San River Basin. Asia Pacific Viewpoint 45(1): 51-68.

Ironside, J. and Baird, I.G. 2003.
Wilderness and Cultural Landscape: Settlement, Agriculture, and Land and Resource Tenure in and Adjacent to Virachey National Park, Northeast Cambodia. Biodiversity and Protected Area Management Project (BPAMP), Ministry of Environment, Phnom Penh.

IUCN and Action Aid. 2003.
Participatory Poverty Assessments (PPA): Livelihoods and Wetlands Stung Province, Cambodia. Books for Change, Bangalore.

Kiernan, B. et al. 1982.
Pol Pot and the Kampuchean Communist Movement, in Kiernan, B. and Chanthou, B. (eds.), Peasant and Politics in Kampuchea 1942-1981. Zed Press. London.

Koh Sneng Commune Council. 2003.
A Five-year Commune Development Plan from 2003-2007 and a Three-year Investment Plan 2003-2005. Stung Treng Province, Cambodia. ( in Khmer).

Learner, M. A. 2003.
Dangerous Waters: Violations of International Law and Hydropower Development along the Sesan River. An Oxfam Report (working draft). Oxfam America. Phnom Penh.

Lebillion, P. 2000.
The Political Ecology of Transition in Cambodia 1989-1999: War, Peace, and Forest Exploitation. Development and Change 31:785-805

Mabbett, I. and Chandlers, D. 1995.
The Khmer. Blackwell. Oxford.

McKenney, B. 2001.
Economic Valuation of Livelihood Income Losses and other Tangible Downstream Impacts from the Yali Falls Dam to the Se San River Basin in Ratanakiri Province, Cambodia. Oxfam America Southeast Asian Regional Office. Phnom Penh.

MDCP. 2004a.
Mekong Dolphin Conservation Project. Summary Reports for January, February, March and April 2004. Department of Fisheries, Wildlife Conservation Society and James Cook University. Phnom Penh.

MDCP. 2004b.
Mekong River Irrawaddy Dolphin Conservation and Management Plan 2004-2008. Draft Report. Mekong Dolphin Conservation Project and Cambodian Department of Fisheries. Phnom Penh.

Ministry of Environment. 2002.
National Biodiversity Strategy and Action Plan. Project Number CMB/98/933. Ministry of Environment/FAO/UNDP/GEF. Phnom Penh.

MRC. 2002.
Fisheries in the Lower Mekong Basin: Status and Perspectives. MRC Technical Paper. No.6, May 2002. Mekong River Commission. Phnom Penh.

MRC. 2003.
Status of the Basin Report 2003. Mekong River Commission. Phnom Penh.

Nga, P. 2004.
Briefing Note of the Program: Demonstration Site in Stung Treng, Cambodia. Stung Treng: IUCN-World Conservation Union.

NIS. 1999.
General Population Census of Cambodia 1998. National Institute of Statistics, Ministry of Planning. Phnom Penh.

Öjendal, J. and Torell. E. 2000.
Some Implications of the Mekong River Commission Agreement, in Ahmed, H. and Hirsch, P. (eds.) Common Property in the Mekong: Issues of Sustainability and Subsistence (pp.11-18). ICLARM, The World Fish Center. Penang.

Öjendal, J. 2000.
Sharing the Good: Modes of Managing Water Resources in the Lower Mekong River Basin. Ph.D. Dissertation. Gőteborge University, Sweden.

Osborne, M. 2001.
The Mekong: Turbulent Past, Uncertain Future. Allen and Unwin. Canberra.

O’Svay Commune Council. 2003.
A Five-year Commune Development Plan from 2003-2007 and a Three-year Investment for 2003-2005. Stung Treng. Cambodia. ( in Khmer)

Oxfam America. 2004.
Small-Scale Gold Mining in Cambodia: A Situation Assessment. Oxfam America, Phnom Penh.

PDRD. 2003.
The Third Phase Report on Children and Women Weighing from September to October, 2003 in 58 villages, 17 Communes, 3 Districts, Stung Treng Province. Provincial Department of Rural Development. Stung Treng. ( in Khmer).

Peou, S. 2000.
Intervention and Change in Cambodia: Towards Democracy?. Institute of Southeast Asian Studies. Silkworm Book. Singapore.

Phallavan, S. and Peng B. N. 2000.
The Dry Season Migration Pattern of Five Mekong Fish Species: *Henicorhynchus spp*., *Cyclocheilichthys enoplos*, *Cirrhinus microlepis*, *Pangasianodon hypophthalmus* and *Probabus jullieni*, a paper presented at the annual meeting of the Department of Fisheries. Ministry of Agriculture, Forestry and Fisheries, 27-28 January 2000. Phnom Penh.

Poulsen, P. and Jorgensen, J.V. (eds.). 2000.
Fish Migrations and Spawning Habits in the Mekong Mainstream: A Survey Using Local Knowledge (Basin-wide). AMFP Technical Report, Mekong River Commission. Phnom Penh.

Preah Rumkel Commune Council. 2003.
A five-year Commune Development Plan from 2003-2007 and a Three-year Investment for 2003-2005. Stung Treng, Cambodia. (in Khmer).

Proleung, S. 2005.
*Schistosomiasis* Program in Stung Treng, A paper presented in the 5th Provincial Annual Meeting on Medical Diagnosis from January 30 to February 01, 2005. Provincial Department of Health, Stung Treng. ( in Khmer).

Provincial Department of Environment. 2002.
Action Plan on Natural Resource and Biodiversity Conservation and Sustainable Use in Stung Treng Ramsar Site. Stung Treng Province. Cambodia. (in Khmer).

Provincial Department of Health. 2004.
Annual Report of the Malaria Program in 2004. The Provincial Department of Stung Treng. Stung Treng. (in Khmer).

Provincial Department of Planning. 2003a.
The Report of the Working Group on Sub-Area Analysis and Development on Se Kong, Se San and Srepok Sub-Area SA-7C. Stung Treng. Cambodia. ( in Khmer).

Provincial Department of Planning. 2003b.
Second Five Year Socio-Economic Development Plan in Stung Treng 2001-2005. Stung Treng Province. Cambodia.

Provincial Department of Water Resources and Meteorology. 2005a.
The Baseline Data on Mekong River Level in Stung Treng Province in 2004. Annual Report. Stung Treng Provincial. Cambodia. (in Khmer).

Provincial Department of Water Resources and Meteorology. 2005b.
The Annual Report of the Department of Water Resources and Meteorology in 2003 and Action Plan for 2004. Annual Report. Stung Treng Province. Cambodia. (in Khmer).

Provincial Rural Development Committee. 1997.
A Number of Projects to Develop the Ethnic Minority Community in Stung Treng Province. Stung Treng. (in Khmer).

Rainboth, J. W. 1996.
Fishes of the Cambodian Mekong. Food and Agriculture Organization of the United Nations. Rome.

Ratner, B.D. 2003.
The Politics of Regional Governance in the Mekong River Basin. Global and Change 15(1): 59-76

Reddy, V.M. 1970.
A History of The Cambodian Independence Movement (1863-1955). Sri Venkateswara University. New Delhi.

RGC. 1997.
The First Five-Year Socioeconomic Development Plan 1996-2000: National Economic Growth and Poverty Reduction Strategies. Phnom Penh.

RGC. 2002.
The Second Five-Year Socioeconomic Development Plan 2001-2005: National Economic Growth and Poverty Reduction Strategy. Phnom Penh.

RGC. 2004.
Address by Samdech Hun Sen, Prime Minister of the Royal Government of Cambodia on Rectangular Strategy for Growth, Employment, Equity and Efficiency. The Office of the Council of Ministers. Phnom Penh.

Rundell, P. W. 1999.
Forest Habitats and Flora in Lao PDR, Cambodia and Vietnam. World Wide Fund for Nature, Indochina Program Office. Hanoi.

Samaki Commune Council. 2004.
A Three-year Investment Plan from 2004-2006. Stung Treng Province. Cambodia. (in Khmer).

Sam Ang, P. 2002.
Rural and Community Development and Protected Areas: Toward the Sustainable Management of Natural Resources. Ministry of Rural Development. Phnom Penh.

Seila Task Force. 2000.
Seila Program Document 2001-2005. Seila Task Force, Phnom Penh.

Seila Task Force. 2003.
Village Baseline Data in Stung Treng Province. Provincial Development Committee. Stung Treng. (in Khmer).

Seila Task Force. 2004.
The Third Quarterly Report, September 2004. Provincial Development Committee. Stung Treng. (in Khmer).

Sithik, R. 2000.
Fisheries Degradation and its Impact on Livelihoods: Cambodia's Upper Stream of the Mekong, Stung Treng. Culture and Environment Preservation Association (CEPA). Phnom Penh.

Smith, J.D. (ed.). 2001.
Biodiversity, the Life of Cambodia-Cambodian Biodiversity Status Report 2001. UNDP/GEF/FAO. Phnom Penh.

Sovathana, S. 2004.
The Transformation of Northeastern Cambodia: The Politics of Development in an Ethnic Minority Community of Yak Kal, O'Chum District, Ratanakiri Province. M.A Thesis in Sustainable Development. Chiang Mai University.

Stuart, B.L., van Dijk, P.P. and Hendrie, D. B. 2001.
Photographic Guide to the Turtles of Thailand, Laos, Vietnam, and Cambodia. ISBN 0-9632064-8-6-5.00. Wildlife Conservation Society. Phnom Penh.

The Socialist Republic of Vietnam. 2004.
Socio-economic Development Master Plan of Cambodia-Laos-Vietnam Development Triangle (Executive Summary). The Ministry of Planning and Investment. Hanoi.

Thouk, N. and Van Zalinge, N. 2000.
Challenges in Meeting Cambodia's Inland Fisheries: How Can We Meet Them?, A paper presented in the Management Aspects of Cambodian's Freshwater Capture Fisheries, the Annual Meeting of the Department of Fisheries. Ministry of Agriculture, Forestry and Fisheries, 27-28 January 2000. Phnom Penh.

Timmins, R. and Men. S. 1998.
A Wildlife Survey of Tonle San and the Srepok River Basins in Northeast Cambodia. Fauna and Floral International, Indochina Program and the Wildlife Protection Office, Department of Forestry, Cambodia. Hanoi and Phnom Penh.

Torell, M. 2000.
Institutional and Legal Perspectives on the Management of Aquatic Resources in the Mekong River Basin, in Ahmed. H and Hirsch. P (eds.) Common Property in the Mekong: Issues of Sustainability and Subsistence (pp.27-36). ICLARM, the World Fish Center. Penang.

Torrel, M., Salamanca, A. M. and Ratner, D. (eds.). 2004.
Wetlands Management in Cambodia: Socioeconomic, Ecological and Policy Perspectives. ISBN 983 2346 266. World Fish Center. Penang.

Try, T. 2004.
Making Space and Access to Fishery Resources: Prospects for local Management in Stung Treng Province, Cambodia. M.A Thesis in Sustainable Development. Graduate School, Chiang Mai University.

Try, T. and Vannara, T. 2004.
Making Space for Fisheries Access and Community Management in Stung Treng, Cambodia, in Cuasay, P. and Chayan, V. (eds.) Common Places and Comparison: Dynamism in Regional Eco-politics of Asia. RCSD Politics of the Commons Monograph Series. Chiang Mai University.

UNDP and GEF. 2000.
Proposal Project For Biodiversity Conservation and Wetland Management in Lower Mekong River Basin. UNDP and GEF. Phnom Penh.

Vannaren, C. 2002.
Community Participation in Natural Resource Management for Rural Poverty Alleviation in Stung Treng Province, Cambodia. MSc Thesis in Environment, Resource and Development. Asian Institute of Technology. Bangkok.

Van Song, N. 2003.
Vietnam's Illegal Trade in Wildlife: Why it still Flourishes. ISBN 1 55250 038 1. Economy and Environment Programme for Southeast Asia. Singapore.

Vong, S. 2004.
Biodiversity Assessment of the Stoeng Treng Ramsar Site. Final Report. Ministry of Environment-The ASEAN Regional Center for Biodiversity Conservation. Phnom Penh.

Zweers, J. et al. 2003.
The Spirits are Leaving: Changing Beliefs and Attitudes among the Krueng, Jarai and Tampuon Regarding their Natural Resources. International Development Research Center. Phnom Penh.

World Bank. 2003.
Cambodia Environment Monitor, 2003. World Bank. Phnom Penh.

# កម្មវិធីអភិរក្ស និងប្រើប្រាស់
# ដោយនិរន្តរភាព នូវជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ

កម្មវិធីអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាព នូវជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គ (MWBP) គឺជាគំរោងរួមគ្នារបស់រដ្ឋាភិបាលទាំងបួននៃអាងទន្លេមេគង្គភាគខាងក្រោម រួមមាន ប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ កម្មវិធីនេះ ត្រូវបានគ្រប់គ្រងដោយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) អង្គការសហភាពអភិរក្សពិភពលោក (IUCN) និងគណៈកម្មការទន្លេមេគង្គ (MRC) ដោយរួមសហការជាមួយអ្នកពាក់ព័ន្ធផ្សេងៗទៀត។ ដោយមានការឧបត្ថម្ភថវិកាពីមូលនិធិ បរិស្ថានពិភពលោក (GEF) កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ រាជរដ្ឋាភិបាលហូឡង់ អង្គការសហភាពអភិរក្សពិភពលោក គណៈកម្មការទន្លេមេគង្គ កម្មវិធីផ្តួចផ្តើមទឹក និងធម្មជាតិ (WANI) និងអ្នកផ្តល់ជំនួយផ្សេងៗទៀត កម្មវិធីនេះព្យាយាមដោះស្រាយបញ្ហាចម្បងៗ ដើម្បីធ្វើការអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាព នូវធនធានធម្មជាតិតំបន់ដីសើមទន្លេមេគង្គ។ កម្មវិធី MWBP មានគោលបំណង ដើម្បីពង្រឹងសមត្ថភាពប្រជាពលរដ្ឋ និងស្ថាប័ន ដើម្បីធ្វើឱ្យជីវភាពប្រកប ដោយនិរន្តរភាព និងការគ្រប់គ្រងធនធានជីវៈចម្រុះតំបន់ ដីសើមប្រកបដោយគតិបណ្ឌិត។ នេះជាកម្មវិធីអន្តរាគមន៍មានរយៈពេល៥ឆ្នាំ (២០០៤-២០០៩) ដែលមានកម្រិត៣ផ្សេងៗគ្នា គឺថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ដោយរួមមានការអនុវត្ត បង្ហាញតំបន់ដីសើមសាកល្បង របស់ប្រទេសនីមួយៗ តាមដងទន្លេមេគង្គក្រោម។ តំបន់បង្ហាញសាកល្បងរួមមាន អាងទន្លេ សង្គ្រាមប្រទេសថៃ ខេត្តអាតាពី ភាគខាងត្បូងប្រទេសឡាវ ខេត្តស្ទឹងត្រែងប្រទេសកម្ពុជា និងតំបន់ទំនាបវាលត្រែង នៃដីសណ្តទន្លេមេគង្គ ប្រទេសវៀតណាម។ កម្មវិធី មានគោលបំណងដើម្បី :

- លើកកំពស់ការសម្រសម្រួលផែនការតំបន់ដីសើម ដោយចាប់ពីថ្នាក់តំបន់ ដល់មូលដ្ឋាន។
- ពង្រឹងគោលនយោបាយ និងបរិស្ថានសេដ្ឋកិច្ច សំរាប់អភិរក្សតំបន់ដីសើម
- បង្កើត និងចែករំលែកព័ត៌មាន
- បណ្តុះបណ្តាល និងកសាងសមត្ថភាព សំរាប់ការប្រើប្រាស់តំបន់ដីសើមប្រកបដោយគតិបណ្ឌិត។
- បង្កើតនូវជម្រើសសំរាប់ការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព និងលើកកំពស់ជីវភាពរស់នៅ

MWBP គឺជាកម្មវិធីដៃគូរវាងរដ្ឋាភិបាល ទីភ្នាក់ងារផ្តល់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល ដោយផ្តល់នូវក្របខ័ណ្ឌ សំរាប់ការងារបន្ថែម ដើម្បីអភិរក្សតំបន់ដីសើម និងជីវភាពរស់នៅប្រកបដោយនិរន្តរភាព នៅក្នុងអាងទន្លេមេគង្គក្រោម។

**PROGRAMME MANAGEMENT UNIT**
PO BOX 4340,082/02 Fa Ngum Road, Vientiane, Lao PDR
Phone : + 856(0)21 240 904 Fax: + 856(0)21 216 127
Email: info@mekongwetlands.org
Web: www.mekongwetlands.org

កម្មវិធី ដែលចូលរួមផ្តល់ថវិកាដោយ UNDP-IUCN-MRC GEF

CAMBODIA LAO PDR THAILAND VIET NAM